# សៀវភៅមគ្គុទេសសម្រាប់ហ្មដំរី
# និងអ្នកគ្រប់គ្រងមជ្ឈមណ្ឌលដំរី



Food and Agriculture Organization of the United Nations

**FAO Regional Office for Asia and the Pacific (RAP), Thailand RAP Publication: 2005/10**

*Published by arrangement with the Food and Agriculture Organization of the United Nations (FAO) by the Kulen Elephant Forest*

*This work was originally published by the Food and Agriculture Organization of the United Nations (FAO) in English as Elephant Care Manual for Mahouts and camp managers. This Khmer translation was arranged by Kulen Elephant Forest. In the event of discrepancies, the original language will govern.*

*The designations employed and the presentation of material in this information product do not imply the expression of any opinion whatsoever on the part of the Food and Agriculture Organization of the United Nations (FAO) concerning the legal or development status of any country, territory, city or area or of its authorities, or concerning the delimitation of its frontiers or boundaries. The mention of specific companies or products of manufacturers, whether or not these have been patented, does not imply that these have been endorsed or recommended by the FAO in preference to others of a similar nature that are not mentioned. The views expressed in this information product are those of the author(s) and do not necessarily reflect the views or policies of FAO.*

សៀវភៅនេះត្រូវបានចេញផ្សាយជាលើកដំបូងដោយអង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) ជាភាសាអង់គ្លេស គឺជាសេចក្តីណែនាំអំពីការថែរក្សាសត្វដំរីសម្រាប់ហ្មដំរី និងអ្នកគ្រប់គ្រងជំរុំដំរី។ ការបកប្រែជាភាសាខ្មែរនេះត្រូវបានរៀបចំឡើងដោយមូលនិធិដំរីព្រៃគូលែន (Kulen Elephant Forest)។ ក្នុងករណីមានកំហុសឆ្គង សូមយោងទៅច្បាប់ដើមជាភាសាអង់គ្លេស ប្រសិនបើត្រូវការផ្ទៀងផ្ទាត់។

រាល់ការរចនា និងការបង្ហាញឯកសារនៅក្នុងសៀវភៅនេះ មិនមែនជាការបញ្ចេញមតិរបស់អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) ទាក់ទងទៅនឹងស្ថានភាពច្បាប់ ឬការអភិវឌ្ឍ ឬទាក់ទងទៅនឹងការកំណត់ព្រំប្រទល់ ឬព្រំដែនរបស់ប្រទេស ទឹកដី ទីក្រុង ឬតំបន់ ឬអាជ្ញាធរណាមួយឡើយ។ ការលើកឡើងពីឈ្មោះក្រុមហ៊ុនជាក់លាក់ណាមួយ ឬផលិតផលទាំងឡាយនៅក្នុងសៀវភៅនេះ ទោះបីជាមានប៉ាតង់ ឬអត់ នោះមិនមែនជាការគាំទ្រ ឬក៏ជាការផ្តល់អនុសាសន៍របស់អង្គការ FAO ក្នុងការពេញចិត្តជាងចំពោះក្រុមហ៊ុន ឬផលិតផល ដែលមានលក្ខណៈស្រដៀងគ្នាដទៃទៀត តែមិនត្រូវបានលើកឡើងនោះឡើយ។ ទស្សនៈដែលបានបង្ហាញនៅក្នុងសៀវភៅនេះ ជាទស្សនៈរបស់អ្នកនិពន្ធហើយមិនឆ្លុះបញ្ចាំងពីទស្សនៈ ឬគោលនយោបាយរបស់អង្គការ FAO ទេ។

*Copyright notices* រក្សាសិទ្ធិដោយ៖

*© Kulen Elephant Forest, 2020 (Khmer Translation)*
*© FAO and FIO, 2005 (English Edition)*

## To readers of the Khmer Edition,

The conservation of elephants in Cambodia is more important today than ever before. Captive conservation begins with the improvement of welfare as a priority. The need for the Elephant Care Manual to be translated is to help the mahouts of Cambodia by setting a scientifically/professionally-tested, and approved benchmark for elephant welfare.

This book is an excellent resource for, at the very least, the basic to intermediate-level concerns of elephant care and welfare. This text offers a great many explanations to common issues and insight on topics handled daily by mahouts nationwide. It is our hope that it can serve to improve the conditions of elephants in Cambodia, as has done in Thailand, and quite possibly, beyond.

We want mahouts to take pride in their work, and see it as a career to be proud of. They are but a handful left in Cambodia, the few guardians of a way of life dating back centuries. It is our hope that the translation of this material is another crucial step toward the successful conservation of the Asian Elephant in Cambodia and overall improvement of mahoutship.

David-Jaya Piot
Co-Founder
**Kulen Elephant Forest**

This translation has kept the Thai edition's opening passages intact and translated only the book's core content into Khmer.

We would like to thank all those who made this possible; the book's respected authors and contributors to this edition:

**Preecha Phangkum**
**Richard C. Lair**
**Taweepoke Angkawanith**
**Food and Agriculture Organisation of the United Nations - Regional Office for Asia and the Pacific**
**Forestry Industry Organisation - Royal Thai Government**

This translation was funded in full by **Asian Elephant Support**
***AsianElephantSupport.org***

A special acknowledgment and thank you to Asian Elephant Support who funded the translation into Khmer and for their continued support in helping improve the lives of elephants and mahouts worldwide.

This initiative was coordinated by **Kulen Elephant Forest**
***www.KulenForest.asia***

## ជូនចំពោះអ្នកអានសៀវភៅនេះជាភាសាខ្មែរ

សព្វថ្ងៃនេះ ការអភិរក្សសត្វដំរីនៅកម្ពុជាមានសារៈសំខាន់ជាងពេលណាៗទាំងអស់។ អាទិភាពនៃការអភិរក្ស គឺជាការចាប់ផ្តើមធ្វើឲ្យប្រសើរឡើងនូវសុខុមាលភាពរបស់សត្វដំរី។ សេចក្តីត្រូវការជាក់ស្តែង គឺការបកប្រែសៀវភៅណែនាំអំពីការថែរក្សាដំរីនេះ ដើម្បីជួយដល់ហ្មដំរីនៅប្រទេសកម្ពុជា ដោយកំណត់លក្ខណៈវិទ្យាសាស្ត្រ/ពិសោធន៍ និងបានអនុម័តលើគោលការណ៍សម្រាប់សុខុមាលភាពរបស់សត្វដំរី។

យ៉ាងហោចណាស់សៀវភៅនេះ គឺជាមូលដ្ឋានគ្រឹះដ៏ប្រសើរសម្រាប់ការថែទាំ និងសុខុមាលភាពរបស់សត្វដំរីកម្រិតមធ្យម។ អត្ថបទក្នុងសៀវភៅនេះបានពន្យល់យ៉ាងច្រើនចំពោះបញ្ហាទូទៅ និងការយល់ដឹងដ៏ទូលំទូលាយលើសត្វដំរី ដែលហ្មដំរីតែងជួបប្រទះជារៀងរាល់ថ្ងៃនៅទូទាំងប្រទេស។ យើងសង្ឃឹមថាសៀវភៅនេះនឹងអាចជួយធ្វើឲ្យប្រសើរឡើងនូវល័ក្ខខ័ណ្ឌជីវិតរបស់សត្វដំរីនៅកម្ពុជា ដូចដែលគេធ្លាប់បានធ្វើរួចមកហើយនៅប្រទេសថៃ ហើយកម្ពុជាអាចនឹងធ្វើលើសពីនេះទៀតបាន។

យើងចង់អោយហ្មដំរីមានមោទនភាពចំពោះការងាររបស់ពួកគេ ហើយចាត់ទុកវាជាអាជីពមួយដែលគួរឲ្យមានមោទនភាព។ នៅក្នុងប្រទេសកម្ពុជាមានតែពួកគេទេ ដែលបានថែរក្សាចំណេះដឹងតៗគ្នាទាំងនេះ តាំងពីរាប់សតវត្សរ៍មកហើយ។ យើងសង្ឃឹមថាការបកប្រែឯកសារនេះ គឺជាជំហានដ៏សំខាន់មួយទៀត ក្នុងការឆ្ពោះទៅរកការអភិរក្សដំរីអាស៊ីនៅកម្ពុជា ប្រកបដោយជោគជ័យ និងធ្វើឲ្យការងាររបស់ហ្មដំរីកាន់តែមានភាពល្អប្រសើរឡើង។

David-Jaya Piot

សហស្ថាបនិកដំរីព្រៃគូលែន (Kulen Elephant Forest)

ក្នុងការបកប្រែនេះ យើងបានរក្សាទុកអត្ថបទខាងដើមនៃការបោះពុម្ពនៅប្រទេសថៃឲ្យនៅដដែលហើយ យើងបានបកប្រែតែខ្លឹមសារសំខាន់នៃសៀវភៅនេះទៅជាភាសាខ្មែរ។

យើងសូមថ្លែងអំណរគុណចំពោះអស់អ្នកទាំងអស់ ដែលបានជួយជ្រោមជ្រែង ដើម្បីសម្រេចកិច្ចការនេះ។ អ្នកនិពន្ធ និងអ្នកដែលបានចូលរួមវិភាគទានក្នុងតាក់តែងសៀវភៅនេះ៖

Preecha Phangkum
Richard C. Lair
Taweepoke Angkawanith

អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិ - ការិយាល័យប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក
អង្គការឧស្សាហកម្មព្រៃឈើ - រាជរដ្ឋាភិបាលថៃ

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក ហុង មករា ដែលបានបកប្រែសៀវភៅដូចខាងក្រោម។
ការបកប្រែនេះត្រូវបានផ្តល់ថវិកាទាំងស្រុងដោយដំរីអាស៊ី

AsianElephantSupport.org

សូមថ្លែងអំណរគុណចំពោះការគាំទ្ររបស់ដំរីអាស៊ីដែលបានផ្តល់ថវិកាដល់ការបកប្រែជាភាសាខ្មែរ ហើយសម្រាប់ការគាំទ្រជាបន្តទៀត ក្នុងការជួយលើកកម្ពស់ជីវភាពរបស់សត្វដំរី និងហ្មដំរីនៅទូទាំងពិភពលោក។

គំនិតផ្តួចផ្តើមនេះត្រូវបានសម្របសម្រួលដោយដំរីព្រៃគូលែន **(Kulen Elephant Forest)**

www.KulenForest.asia

### កម្រិតនៃការថែទាំជំរីដែលបានបង្ហាញនៅក្នុងសៀវភៅនេះ

សៀវភៅមគ្គុទេសក៍នេះនឹងប្រើប្រាស់សម្រាប់និស្សិតពេទ្យសត្វ និងពេទ្យសត្វដែលមិនទាន់មានបទពិសោធន៍ជាមួយសត្វជំរី។ ប៉ុន្តែមិនមានអ្វីថ្មី និងគួរឲ្យភ្ញាក់ផ្អើលសម្រាប់ពេទ្យសត្វជំរីដែលមានបទពិសោធន៍ហើយនោះទេ។ ដូចជាសម្រាប់ពេទ្យសត្វទូទៅដែរ តែផ្នែកខ្លះនៅក្នុងសៀវភៅនេះ អាចផ្តល់ដល់ពួកគាត់នូវការណែនាំមួយចំនួនសម្រាប់ព្យាបាលសត្វជំរី ដែលអាចមានលក្ខណៈខុសគ្នាពីសត្វដទៃទៀត។

គោលបំណងនៃសៀវភៅនេះ គឺដើម្បីឲ្យហ្មជំរីទាំងអស់អាចជួយគាំទ្រដល់ការងាររបស់ពេទ្យសត្វ ប៉ុន្តែមិនមែនឲ្យពួកគាត់ ធ្វើការងារជំនួសពេទ្យសត្វទាំងអស់នោះទេ។ គោលដៅចំបងទាំងបី គឺជួយឲ្យហ្មជំរីអាចធ្វើពេគវិនិច្ឆ័យបានយ៉ាងលឿន ដើម្បីប្រាប់រោគសញ្ញាឲ្យបានកាន់តែច្បាស់លាស់ទៅកាន់ពេទ្យសត្វតាមទូរស័ព្ទ និងកែលម្អការយកចិត្តទុកដាក់ក្នុងការតាមដានសុខភាពសត្វជំរី។ គោលដៅជាមូលដ្ឋាន គឺដើម្បីលើកទឹកចិត្តដល់ការការពារជម្ងឺ និងស្ថានភាពដែលកើតឡើង តាមរយៈការយកចិត្តទុកដាក់បន្ថែមទៀតទៅលើចំណីអាហារ ការងារថែទាំឲ្យបានត្រឹមត្រូវ និងអនាម័យល្អ។

អ្វីដែលជាការលំបាកសម្រាប់អ្នកជំនាញក្នុងការសរសេរសៀវភៅថ្នាក់បឋម អំពីជំនាញរបស់ពួកគាត់ គឺធ្វើឲ្យពួកគាត់ធុញទ្រាន់នឹងការបង្ហាញអ្វីដែលសាមញ្ញៗ ហើយពួកគាត់ពិបាកនឹងគេចមិនប្រើខ្ទឹមសារស្មុគស្មាញ ប្លែក ដែលអ្នកអានមិនធ្លាប់ស្គាល់។ ក្នុងពេលសរសេរសៀវភៅនេះ ក្រុមអ្នកនិពន្ធមិនបានប្រើពាក្យបច្ចេកទេសហួសកម្រិតទេ ឧទាហរណ៍ពីរបៀបបែងចែកពីភាពខុសគ្នារវាងដុំពក និងគំនូសតាងពេគវិនិច្ឆ័យស្មុគស្មាញលើជម្ងឺឈាម រូបមន្តសម្រាប់កំណត់ទម្ងន់តាមរយៈការវាស់វែងយ៉ាងល្អិតល្អន់លើរាងកាយរបស់ជំរីនោះទេ។ល។

អ្នកអានដែលជាពេទ្យសត្វ សុំផ្អាកធ្វើការវិនិច្ឆ័យលើបច្ចេកទេសថែទាំមួយចំនួនដែលផ្ទុយនឹងបទដ្ឋានវិជ្ជាជីវៈលោកខាងលិចនាសម័យទំនើប។ ឧទាហរណ៍ពេទ្យសត្វនឹងងឿងឆ្ងល់ ថាតើហេតុអ្វីបានជាមិនមានការផ្តល់អនុសាសន៍ឲ្យចាក់វ៉ាក់សាំងតេតាណូស? ហេតុអ្វីបានជាមានការជម្រុញឲ្យប្រើប្រាស់សំឡី? ហេតុអ្វីបានជាសៀវភៅនេះផ្តល់អនុសាសន៍ឲ្យដុតដំបៅក្នុងករណីធ្ងន់ធ្ងរខ្លាំង? ហើយតើហេតុអ្វីបានត្រូវណែនាំឲ្យប្រើអ៊ីជ្រូ

សែនអុកស៊ីត? ល័ក្ខខ័ណ្ឌក្នុងតំបន់ គឺជាហេតុផលល្អណាស់សម្រាប់ពិនិត្យមើលឲ្យឃើញនូវកំហុសឆ្គងទាំងនោះ ឬការអនុវត្តទាំងឡាយណាដែលហួសសម័យ។

## អ្នកគ្រប់គ្រងមជ្ឈមណ្ឌលដំរី

ក្រៅពីហ្មដំរី អ្នកអានដ៏សំខាន់ទីពីរសម្រាប់សៀវភៅមគ្គុទេសក៍នេះ គឺអ្នកគ្រប់គ្រងមជ្ឈមណ្ឌលដំរី រួមទាំងម្ចាស់ដំរីដែលគ្រប់គ្រងមជ្ឈមណ្ឌលដោយខ្លួនឯង។ មានអ្នកគ្រប់គ្រងមជ្ឈមណ្ឌលខ្លះដឹងច្បាស់អំពីសត្វដំរី រីឯខ្លះទៀតជាអ្នកគ្រប់គ្រងធម្មតា ដែលមិនខុសអ្វីពីអ្នកគ្រប់គ្រងរថយន្តដឹកទំនិញដែរ។ ដោយអ្នកគ្រប់គ្រងត្រូវត្រួតពិនិត្យលើចំណីអាហារ ថវិកា ការជ្រើសរើសហ្មដំរី និងបញ្ជប់ការងារហ្មដំរី កំណត់ការងារ និងកាលវិភាគការងារជាដើម។ អ្នកគ្រប់គ្រងមជ្ឈមណ្ឌលតែងមានឥទ្ធិពលលើសុខភាពសត្វដំរី គឺអាចមានស្ថានភាពល្អ ឬអាក្រក់ជាងការងាររបស់ហ្មដំរីទៅទៀត។ ឧទាហរណ៍ផ្នែករបប "អាហារ" ជាបឋមត្រូវសរសេរតាក់តែងជាមួយអ្នកគ្រប់គ្រងមជ្ឈមណ្ឌលទៅតាមការគិតរបស់គាត់។ ចំពោះឧបករណ៍ និងបច្ចេកទេស ដែលត្រូវយកមកប្រើដើម្បីគ្រប់គ្រងដំរីភាគច្រើនគេសរសេរសម្រាប់អ្នកគ្រប់គ្រងមជ្ឈមណ្ឌល ដែលមិនទាន់មានបទពិសោធន៍។ (ហ្មដំរីក្មេងៗ ដែលមិនទាន់មានបទពិសោធន៍នឹងទទួលបានការណែនាំដោយផ្ទាល់មាត់ពីការប្រើប្រាស់ឧបករណ៍ទាំងនោះ ពីហ្មដំរីដើងចាស់ៗ)

យើងសង្ឃឹមថាការរាប់បញ្ចូលអ្នកគ្រប់គ្រងមជ្ឈមណ្ឌល នឹងធ្វើឲ្យសៀវភៅនេះមានប្រយោជន៍ដល់មនុស្សផ្សេងៗទៀត ដែលធ្វើការដើម្បីសុខុមាលភាពដំរី មានដូចជា៖ មន្ត្រីរដ្ឋាភិបាល បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល អ្នកវិទ្យាសាស្ត្រ។ ល។

## ការថ្លែងអំណរគុណ

ក្រុមអ្នកនិពន្ធសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកគ្រូពេទ្យសត្វ ដែលបានចូលរួមចំណែកផ្តល់ព័ត៌មានអំពីជំនាញរបស់ពួកគាត់។ អ្នកត្រួតពិនិត្យបច្ចេកទេសសំខាន់ៗមានលោកបណ្ឌិត Michael Woodford និងលោកបណ្ឌិត Susan Mikota បានផ្តល់ទាំងចំណេះដឹងខាងការងារសិក្សា និងគតិបណ្ឌិតនៃបទពិសោធន៍ជាច្រើន។ លោកវេជ្ជបណ្ឌិត Parntep Ratanakorn ព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រពេទ្យសត្វនៃសាកលវិទ្យាល័យ Mahidol បានអានផ្នែកសេចក្តីព្រាងនៃសៀវភៅនេះ ហើយក៏បានផ្តល់យោបល់

ដ៏មានសារសំខាន់ជាច្រើន។ លោកបណ្ឌិត Bjarne Clausen ដែលជាមិត្តភក្តិរបស់មជ្ឈមណ្ឌលអភិរក្សដំរីថៃបានផ្តល់គំនិតដ៏មានប្រយោជន៍ជាច្រើន។ លោកបណ្ឌិត Vishnu Songkitti ជំនួយការបច្ចេកទេសអង្គភាពកសិកម្ម (RAPG) នៃអង្គការ FAO ក៏បានផ្តល់ដំបូន្មានល្អៗជាច្រើនដល់សេចក្តីព្រាងដំបូងៗនៃសៀវភៅនេះ។

លោកស្រី Sarah Scarth នាយកអង្គការ IFAW ទទួលបន្ទុកសង្គ្រោះបន្ទាន់បានផ្តល់ការគាំទ្រនិងលើកទឹកចិត្តជាប្រចាំ។

នៅក្នុងអង្គការ FAO យើងក៏សូមថ្លែងអំណរគុណដល់លោក Masakazu Kashio មន្ត្រីធនធានព្រៃឈើនៃអង្គភាពរដ្ឋបាលព្រៃឈើ (RAPO) ចំពោះការខិតខំប្រឹងប្រែង និងការលះបង់ពេលវេលាដ៏មានតម្លៃរបស់លោក និងលោក Ronald Van Nijnanten អ្នកសម្របសម្រួលសាខាប្រតិបត្តិការប្រចាំតំបន់ (RAPR) ចំពោះការអត់ធ្មត់ និងចំពោះការយោគយល់របស់លោក។

នៅក្នុងអង្គការរបស់យើងផ្ទាល់ យើងក៏សូមថ្លែងអំណរគុណដល់លោក Chanatt Lauhawatana នាយកគ្រប់គ្រងនៃអង្គការឧស្សាហកម្មព្រៃឈើ ដែលបានលើកទឹកចិត្ត និងជឿជាក់យ៉ាងមុតមាំចំពោះគម្រោងនេះ។ អ្នកកាន់តំណែងមុនរបស់គាត់ គឺលោកវរសេនីយ៍ឯក M.R. Aduldej Chakrabandhu បានជួយជ្រោមជ្រែង និងការគាំទ្រជាច្រើនចាប់តាំងពីថ្ងៃដំបូង ដូចគ្នានេះដែរចំពោះលោក Manoonsak Tuntiwiwat ក្នុងឋានៈជាអនុប្រធានគ្រប់គ្រង។ លោក Suntud Sangkul ប្រធានផ្នែកផលិតផលឈើនៃការិយាល័យឧស្សាហកម្មឈើ និងលោកស្រី Sureeporn Niyomdham ប្រធានផ្នែកបច្ចេកទេសនៃការិយាល័យរដ្ឋបាល ដែលបានផ្តល់ការគាំទ្រផ្នែកភស្តុភារ ដែលមិនអាចកាត់ថ្លៃបាន។ នៅ Lampang លោក Nipakorn Singphutankul ប្រធានរដ្ឋបាលទូទៅ ក៏បានគាំទ្រឥតឈប់ឈរដូចលោក Chalermsak Toomhirun ប្រធានមជ្ឈមណ្ឌលអភិរក្សដំរីថៃដែរ។ លោកវេជ្ជបណ្ឌិត Sittidet Mahasawangkul ប្រធានស្តីទីនៃមន្ទីរពេទ្យដំរីរបស់អង្គការ FIO និងលោកវេជ្ជបណ្ឌិត Saran Chansitthiwet ក៏បានផ្តល់ជាដំបូន្មានផ្នែកពេទ្យសត្វដ៏មានសារសំខាន់ជាច្រើន។ លោក Prasob Thipprasert ប្រធានសាលាបណ្តុះបណ្តាលហ្មដំរី និងដំរីក៏បានផ្តល់យោបល់ដែលមានប្រយោជន៍ជាច្រើន។

កញ្ញា Wikanda Wongsuk ដែលបានបំពេញការងារជាលេខាធិការដ៏គួរឲ្យកោតសរសើរបំផុត។

យើងក៏សូមថ្លែងអំណរគុណដល់លោក Saksith Camluang និងលោក Chalaphan Upakij ដែលបានរចនាទំព័រ និងលោកស្រី Sirikorn Inkom ដែលបានគូររូបដ៏ស្រស់ស្អាតនៅក្នុងសៀវភៅនេះ ដោយប្រើតែខ្មៅដៃ ។

# មាតិកា

**សេចក្តីផ្តើម** ........ 13
**ភាគពូកិច្ចច្បាប់** ........ 15
*ការចុះឈ្មោះនិងច្បាប់* ........ 15
*វិញ្ញាបនប័ត្រចុះបញ្ជី* ........ 16
*ម៉ៃក្រូឈីប* ........ 19
*ការដឹកជញ្ជូនដំរី* ........ 21
*ទ្រុងនៅក្នុងឡានដឹកដំរី* ........ 25
**ជម្រកនិងអាហារ** ........ 27
*ជម្រក* ........ 27
*ទឹក* ........ 30
*អាហារ* ........ 31
*កត្តាសង្គមនិងសេដ្ឋកិច្ចនៃចំណីអាហារ* ........ 32
*ចំណីដាំដុះនៅក្នុងមជ្ឈមណ្ឌលទេសចរណ៍* ........ 34
*អាហារដែលបានមកពីការដាំដុះ ទិដ្ឋភាពជាក់ស្តែង* ........ 37
**ការគ្រប់គ្រងដំរី** ........ 45
*ឧបករណ៍* ........ 46
*កង្វេរ* ........ 46
*កាំបិត* ........ 47
*ខ្សែបង្ហៀរត្រចៀក* ........ 47
*កងជើង* ........ 48
*ច្រវាក់ជើង* ........ 49
*ខ្សែ និងខ្សែពួរ* ........ 54
*ឧបករណ៍ពិសេសសម្រាប់ស្ថានភាពដែលមានបញ្ហា* ........ 58
*គោលការណ៍ណែនាំសម្រាប់ចងសត្វដំរី* ........ 62
*ការហាមឃាត់ដាច់ខាតក្នុងពេលគ្រប់គ្រងដំរី* ........ 63

ឧបករណ៍សម្រាប់អូស.....64
**ព្រឹត្តិការណ៍ក្នុងជីវិត**.....65
ការកំណត់អាយុ.....65
ការកំណត់វដ្ដរបន្តពូជ.....66
ការព្យាករណ៍វដ្ដរបន្តពូជ.....68
ការដាក់បា.....69
ការបង្កាត់ពូជ.....70
ពេលផើម.....71
កំណើត.....72
ការជ្រើសរើសទឹកន្ទៃង.....74
ចំណីអាហារសម្រាប់កូនដំរី.....75
វ័យចុះប្រេង.....82
ការទុកដាក់សាកសពដំរី.....85
វិធីសាស្ត្រទុកដាក់សាកសព.....87
ជម្ងឺដែលទាមទារឲ្យមានការប្រុងប្រយ័ត្ននៅពេលទុកដាក់សាកសពដំរី.....89
**ការថែទាំសុខភាពបឋម**.....91
ថាំពេទ្យដែលត្រូវមាននៅក្នុងដៃ.....92
សម្ភារៈនិងឧបករណ៍.....96
សម្ភារៈនិងឧបករណ៍ដែលត្រូវមាននៅក្នុងមជ្ឈមណ្ឌលដំរី.....96
ឧបករណ៍សម្រាប់មជ្ឈមណ្ឌលតូចៗ និងពេលធ្វើដំណើរ.....98
អនាម័យ.....100
ការប្រមូលគំរូសម្រាប់ការវិភាគ.....103
ការកំណត់សុខភាព.....105
ការប្រើប្រាស់ទែម៉ូម៉ែត្រ.....107
ការបញ្ចូកថ្នាំតាមមាត់.....108
ការប្រើថ្នាំតាមរន្ធគូថ.....109
ហ្មដំរីចាក់ថ្នាំ.....110
មើលថៃដំរីឈើដេកនៅលើដី.....114

ស្ថានភាពសុខភាពជំរឺបណ្តាលមកពីមនុស្ស ....... 114
ការផ្ការលើសកម្លាំង (ការហត់នឿយខ្លាំង) ....... 115
កង្វះអាហារូបត្ថម្ភ ....... 115
សម្ពាធការផ្ការ (ស្ត្រេស) ....... 119
ជម្ងឺចាញ់ក្តៅ ....... 120
ជំរឺដួលដោយសារត្រជាក់ ....... 121
របួសស្នាម ....... 122
ការព្យាបាលរបួសស្នាម ....... 123
ការហូរឈាមតាមសរសៃឈាម ....... 123
សំភារៈសម្អាតមុខរបួស ....... 124
វិធីក្តៅ និងត្រជាក់ ....... 126
ប្រភេទស្នាមរបួស ....... 126
ជម្ងឺបូស (Abscesses) ....... 134
ជាតិពុល ....... 136
**ផ្នែកខាងក្រៅរបស់សត្វជំរឺ** ....... 140
ស្បែក ....... 140
ជម្ងឺឬស Papilloma ....... 140
ជម្ងឺផ្សិតលើស្បែក ....... 142
ជម្ងឺហើមពោះ ....... 143
ប៉ារ៉ាស៊ីតខាងក្រៅ ....... 144
របោម ....... 145
ចៃនិងសត្វល្អិតនៅលើកន្ទុយ ....... 146
ចៃ ....... 146
រុយ ....... 147
ក្បាល ....... 148
ភ្នែក ....... 148
ជម្ងឺត្រចៀក ....... 151
ប្រមោយ ....... 153

ភ្លុក ....................................................................................................................153
ជើងនិងក្រចក..........................................................................................................156
**ផ្នែកខាងក្នុងនៃរាងកាយរបស់ដំរី**..........................................................................160
សាច់ដុំ ....................................................................................................................160
ឆ្អឹង.........................................................................................................................161
ជម្ងឺរលាកសន្លាក់.....................................................................................................162
ប្រព័ន្ធរំលាយអាហារ ..................................................................................................163
ពពួកប៉ារ៉ាស៊ីតក្នុងប្រព័ន្ធរំលាយអាហារ ........................................................................164
ជម្ងឺឆ្អល់ពោះ (Dyspepsia)........................................................................................169
ជម្ងឺទល់លាមក .........................................................................................................170
ជម្ងឺរាក ...................................................................................................................171
ជម្ងឺផ្សេងៗទៀត .......................................................................................................176
**រូបថត**...................................................................................................................196
**ឧបសម្ព័ន្ធ** ..............................................................................................................200
ឧបសម្ព័ន្ធទី ១៖ ការណែនាំដល់ពេទ្យសត្វ ..................................................................200
តារាងទី ១ ៖ ចំណីរបស់ដំរី...........................................................................................205
តារាងទី ២ ៖ រុក្ខជាតិឱសថ ..........................................................................................207
**ឯកសារពិគ្រោះ** .......................................................................................................209

# សេចក្ដីផ្ដើម

*សម្រាប់ប្រជាពលរដ្ឋ ដែលប្រកបរបរចិញ្ចឹមជីវិតដោយសារដំរីនៅប្រទេសថៃ នៅក្នុងឆ្នាំ ២០០៥ ពិភពលោក គឺជាកន្លែងដ៏ចម្លែកមួយ។ ហ្វូងដំរីចាស់ៗអាចចាំបានយ៉ាងច្បាស់ ពេលដែលពួកគាត់នៅក្មេង កាលពីជាង ៣០ ឆ្នាំមុន ការថែរក្សាសត្វដំរី គឺមិនខុសពីសម័យបុរាណទេ។ នៅភាគខាងជើងប្រជាពលរដ្ឋបានចូលព្រៃកាប់ឈើ។ នៅសុរិន្ទ និងភាគឥសានប្រជាពលរដ្ឋជាច្រើនបានចាប់សត្វដំរីព្រៃជាពិសេសនៅប្រទេសកម្ពុជា ប៉ុន្តែដំរីព្រៃចុងក្រោយគេ ត្រូវបានគេចាប់នៅសុរិន្ទនៅចុងឆ្នាំ ១៩៦៣។ ភាគច្រើននៅប្រទេសថៃ ជាពិសេសនៅរដូវវស្សាប្រជាពលរដ្ឋ នៅតែប្រើសត្វដំរីសម្រាប់ធ្វើជាមធ្យោបាយធ្វើដំណើរប្រចាំថ្ងៃ។ ជីវិតរបស់សត្វដំរីពិតជាមានការលំបាកខ្លាំងណាស់ ប៉ុន្តែវាជារឿងសាមញ្ញ ដែលយើងទាំងអស់គ្នាអាចយល់បានដោយងាយ។*

*គ្រាន់តែពាក់កណ្ដាលជីវិតក្រោយមកទៀត ពិភពលោកយើងបានផ្លាស់ប្ដូរគ្រឡាប់ចាក់យ៉ាងខ្លាំង។ ចំនួនសត្វដំរីក្នុងស្រុកបានធ្លាក់ចុះប្រមាណពី ១០០ ០០០ កាលពីមួយសតវត្សរ៍មុន មកនៅត្រឹមតែប្រមាណ ២ ៥០០ ក្បាល មានន័យថាយើងបានបាត់បង់សត្វដំរីរហូតដល់ចំនួន ៩៧ ភាគរយ។ ការចាប់ដំរីព្រៃគឺជារឿងខុសច្បាប់ មិនថានៅក្នុងប្រទេសថៃ ឬចូលមកក្នុងប្រទេសកម្ពុជាទេ។ រដ្ឋាភិបាលថៃបានហាមឃាត់ការកាប់ឈើនៅក្នុងដីសម្បទានព្រៃឈើក្នុងឆ្នាំ ១៩៨៩ ហើយនៅឆ្នាំ ២០០៥ សូម្បីតែការកាប់ឈើខុសច្បាប់ក៏ត្រូវបានកាត់បន្ថយយ៉ាងច្រើនដែរ។ គំនិតប្រើប្រាស់សត្វដំរី ដើម្បីធ្វើជាមធ្យោបាយដឹកជញ្ជូនទំនិញ ឬមនុស្សជាប្រចាំ ក្រៅពីការដឹកភ្ញៀវទេសចរកំសាន្ត គឺជារឿងដ៏គួរឲ្យអស់សំណើច។ កូនដំរីអាយុពីរឆ្នាំដែលស្ទើរតែគ្មានតម្លៃកាលពីជំនាន់មុន ឥឡូវស្រាប់តែមានតម្លៃជាងដំរីធំៗទៅទៀត ព្រោះថាក្រៅពីគ្មានភ្លុកដ៏ស្រស់ស្អាត កូនដំរីតូចៗនេះ តែងចូលចិត្តប្រឡែងលេង មានភាពទន់ភ្លន់ជាមួយមនុស្ស និងពេលនៅជិតមនុស្សពួកវាក៏មានសុវត្ថិភាពទៀតផង។*

*បច្ចុប្បន្នការងារភាគច្រើនសម្រាប់សត្វដំរី ដែលមាននៅសេសសល់ក្នុងប្រទេសថៃ ហើយស្ទើរតែទាំងអស់ ជាការងារដែលមិនប្រឆាំងនឹងច្បាប់ គឺសម្រាប់តែការកែកំសាន្តរបស់ភ្ញៀវទេសចរ ពេលខ្លះភ្ញៀវទេសចរជាជនជាតិថៃ ប៉ុន្តែភាគច្រើនជាជនបរទេស។*

ចាប់តាំងពីឆ្នាំ ២០០១ មកប្រទេសថៃទទួលបានភ្ញៀវទេសចរជាង ១០ លាននាក់ក្នុងមួយឆ្នាំៗ។ បើគ្មានភ្ញៀវទេសចរទាំងនោះ ដែលបានឡើងជិះយន្តហោះនៅទីក្រុងប៉ារីស ឬនៅទីក្រុងឡុងដ៍ ឬនៅទីក្រុងញូវយ៉ក ហើយចំណាយពេលមិនដល់មួយថ្ងៃ ក៏បានមកដល់ប្រទេសថៃនោះទេ ពេលនោះប្រាកដជានឹងមានការងារតិចតួច ឬគ្មានការងារធ្វើនៅក្នុងប្រទេសថៃ គឺប្រាកដជាគ្មានការងារគ្រប់គ្រាន់សម្រាប់សត្វដំរីស្រុកទាំងចំនួន ២ ៥០០ ក្បាលរបស់ប្រទេសថៃនោះទេ។ ប៉ុន្តែសាកលភាវូបនីយកម្មដដែលនេះ ក៏បាននាំមកនូវការងារថ្មីៗ ដើម្បីជំនួសការងារចាស់ៗបែបប្រពៃណី ដែលបានបាត់បង់ទៅហើយ ប៉ុន្តែក៏បាននាំមកនូវបញ្ហាថ្មីៗថែមទៀតផងដែរ។ អ្នកមកពីបស្ចិមប្រទេសទំនើបៗ និងប្រជាពលរដ្ឋថៃក្នុងទីក្រុងជាគន្លឹះមួយសំខាន់ខ្លាំងណាស់ ក្នុងការពារសត្វដំរីនៅប្រទេសថៃ។ នៅឆ្នាំ ២០០៣ ខ្សែវីដេអូមួយស្តីអំពីការផ្សាំងសត្វដំរីតាមបែបបុរាណនៅម៉ាយហុងសុន (Mae Hong Son) ត្រូវបានចាក់ផ្សាយតាមកញ្ចក់ទូរទស្សន៍ទូទាំងពិភពលោកដែលក្លាយជារឿងអាស្រូវអន្តរជាតិមួយ នៅពេលដែលក្រុមការពារសិទ្ធិរបស់សត្វបានទាមទារអោយទេសចរធ្វើពហិការប្រទេសថៃ។ ហេតុការណ៍នេះត្រូវបានអាជ្ញាធរទេសចរណ៍ និងក្រសួងការបរទេសប្រទេសថៃមើលឃើញថាជាបញ្ហាធំនៅក្នុងទំនាក់ទំនងអន្តរជាតិ។

នៅឆ្នាំ ២០០៣ ការផ្ទុះជម្ងឺសារ (SARS) ដែលជាវីរុសបង្កជម្ងឺរបស់សត្វព្រៃនៅភាគខាងត្បូងប្រទេសចិនក៏បានឆ្លងចូលទៅក្នុងរាងកាយរបស់មនុស្ស នៅតាមតំបន់ជាច្រើនជុំវិញពិភពលោករួមទាំងប្រទេសថៃផងដែរ។ លោកអ្នកប្រហែលជាអាចគិតថា បញ្ហានេះគ្មានអ្វីប៉ះពាល់ដល់សត្វដំរីរបស់យើងទេ ប៉ុន្តែតាមការពិត វាបានរីករាលដាល បណ្តាលឲ្យចំនួនភ្ញៀវទេសចរដែលចូលមកទស្សនានៅក្នុងតំបន់អាស៊ីមានការធ្លាក់ចុះ។ ដូច្នេះចំនួនមនុស្សដែលបានចូលមកក្នុងប្រទេសថៃ ក៏បានថយចុះដែរ ហើយមជ្ឈមណ្ឌលដំរីមួយចំនួនក៏បានទទួលរងនូវឥទ្ធិពលនេះលើការធ្វើជំនួញរបស់គេ ហើយសូម្បីតែតម្លៃដំរីក៏ត្រូវបង្ខំចិត្តឲ្យធ្លាក់ចុះទាបជាងពេលមុនៗផងដែរ។

ចំណុចសំខាន់ទាំងអស់នេះគឺថាពេលវេលាបានផ្លាស់ប្តូរ ហើយហ្មដំរី (និងម្ចាស់ដំរី និងអ្នកគ្រប់គ្រង) ត្រូវតែបង្ខំចិត្តផ្លាស់ប្តូរទៅតាមពេលវេលា។ តម្រូវការផ្លាស់ប្តូរនេះ តាម

*ការពិតគឺវាស្ថិតនៅក្នុងវិស័យថែទាំសុខភាពរបស់សត្វ។ ថ្នាំពេទ្យសត្វមានភាពកាន់តែប្រសើរឡើងយ៉ាងខ្លាំង ក្នុងរយៈពេល ១០០ ឆ្នាំចុងក្រោយនេះ ប៉ុន្តែហ្មដំរី និងអ្នកគ្រប់គ្រងមជ្ឈមណ្ឌលដំរីនៅប្រទេសថៃត្រូវតែខិតខំរៀនសូត្របន្ថែមទៀត អំពីវិធីជឿនលឿនខាងវិទ្យាសាស្ត្រ ដែលយើងអាចយកមកប្រើដើម្បីកែលម្អសុខុមាលភាពរបស់សត្វដំរី។*

# ភាគព្វកិច្ចច្បាប់

## ការចុះឈ្មោះនិងច្បាប់

*ច្បាប់ជាច្រើនត្រូវបានយកមកអនុវត្តសម្រាប់អ្នកដែលមានចិញ្ចឹមសត្វដំរី ប៉ុន្តែអ្វីដែលច្បាស់និងសំខាន់ជាងគេបំផុតនោះ គឺសេចក្តីព្រាងច្បាប់ស្តីពីសត្វនៅឆ្នាំ ១៩៣៩* (phrarachbanyat sat pahana, B.E. ២៤៨២) *បានផ្តល់អំណាចដល់មន្ត្រីការិយាល័យចុះឈ្មោះនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (ក្រសួងមហាផ្ទៃ) ដែលមានយុត្តាធិការលើសត្វដំរី។ (លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ បើពុំនោះទេ រាល់កាតព្វកិច្ចទាំងអស់របស់ម្ចាស់ដំរី ដែលយើងបានលើកឡើងនៅខាងក្រោម គឺសុទ្ធតែដកស្រង់យកចេញមកពីច្បាប់នេះ។) បន្ថែមលើសេចក្តីព្រាងច្បាប់ស្តីពីសត្វ បទប្បញ្ញត្តិផ្សេងៗដែលចេញដោយក្រសួង ក៏មានវិសាលភាពលើម្ចាស់ដំរីផងដែរ។*

*សេចក្តីព្រាងច្បាប់ស្តីពីសត្វ គឺជាច្បាប់ហួសសម័យ ដែលត្រូវបានសរសេរតាក់តែងឡើងអស់រយៈពេលជាង ៦០ ឆ្នាំកន្លងមកហើយ ដោយមានកែសម្រួលតែបន្តិចបន្តួចចាប់តាំងពីត្រូវបានប្រកាសដាក់ឲ្យប្រើរួចមក។ គោលបំណងរបស់ច្បាប់នៅពេលនោះ គឺដើម្បីកំណត់អត្តសញ្ញាណសត្វដំរីនីមួយៗ និងម្ចាស់របស់វា ដោយគេបានបង្កើតសិទ្ធិ និងកាតព្វកិច្ចលើម្ចាស់កម្មសិទ្ធិ ដើម្បីគ្រប់គ្រងបញ្ហាចោរកម្ម ព្រោះថាសត្វដំរីត្រូវបានគេបញ្ចូលគ្នាជាមួយសត្វគោ ក្របី សេះ និងលាផងដែរ។ នៅឆ្នាំ ១៩៣៩ មានសត្វដំរីស្រុករាប់ម៉ឺនក្បាលជាកម្មសិទ្ធិឯកជន។ប៉ុន្តែពួកវានៅតែស្ថិតក្នុងច្បាប់របស់ប្រទេសថៃដដែល។ ច្បាប់នេះ ត្រូវបានតាក់តែងឡើងយ៉ាងត្រឹមត្រូវ ចំពោះសង្គមកសិកម្មតាមបែបប្រពៃណី*

ដែលដំរីជាសត្វដ៏មានតម្លៃ។ នៅពេលនោះមានការគិតគូរព្រួយបារម្ភតិចតួចណាស់ចំពោះសុខុមាលភាពរបស់សត្វនីមួយៗ។

អង្គការ ស្ថាប័នជាច្រើន រួមទាំងទីភ្នាក់ងាររដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលផង បាននិងកំពុងស្នើសុំច្បាប់ថ្មី ដែលត្រូវទៅនឹងសម័យទំនើប ក្នុងការធ្វើនិយ័តកម្មលើការប្រើប្រាស់ និងការគ្រប់គ្រងសត្វដំរីនៅក្នុងប្រទេសថៃ។

មធ្យោបាយសំខាន់បំផុតមានពីរ ដើម្បីចៀសវាងបញ្ហាទាក់ទងនឹងច្បាប់គឺ (១) ត្រូវថែរក្សាពល់ឯកសារចុះឈ្មោះ និងលិខិតធ្វើដំណើរឲ្យមានរបៀបរៀបរយ (២) កុំយកដំរីទៅទីប្រជុំជន ដែលយើងដឹងច្បាស់ថាបញ្ហាទំនងជាអាចកើតមានឡើង។

## វិញ្ញាបនប័ត្រចុះបញ្ជី

លោកអ្នកត្រូវមានវិញ្ញាបនប័ត្រចុះបញ្ជី (និងប័ណ្ណកម្មសិទ្ធិ) ដែលមានសុពលភាពសម្រាប់សត្វដំរីទាំងអស់ដែលអ្នកមាន។ ប្រសិនបើអ្នកជាម្ចាស់ ឬអ្នករក្សាដំរី ដែលគ្មានវិញ្ញាបនប័ត្រចុះបញ្ជី (ឬមានវិញ្ញាបនប័ត្រដែរ តែជាឈ្មោះរបស់ដំរីមួយទៀត) សត្វដំរីនោះត្រូវប្រឈមនឹងការរឹបអូសយក លុះត្រាតែអ្នកអាចបញ្ជាក់ថា អ្នកជាម្ចាស់កម្មសិទ្ធិពិតប្រាកដ និងបង្ហាញថាអ្នកទទួលបានសត្វដំរីនោះដោយស្មោះត្រង់។ ឯកសារនេះត្រូវបានតម្រូវដោយច្បាប់ ក្នុងការកាន់កាប់សត្វដំរី នៅពេលអ្នកនៅជាមួយសត្វដំរី ជាពិសេសនៅពេលអ្នកធ្វើដំណើរតាមសត្វដំរីនោះ។

ការទទួលបាន ឬការផ្លាស់ប្តូរវិញ្ញាបនប័ត្រចុះបញ្ជី ត្រូវទៅធ្វើនៅការិយាល័យចុះឈ្មោះក្នុងស្រុកកំណើតរបស់អ្នក។ វិញ្ញាបនប័ត្រចុះបញ្ជីមានសុពលភាពសម្រាប់រយៈពេលពេញមួយជីវិត ហើយមានកាលៈទេសៈតែ ៣ ប៉ុណ្ណោះ ដែលតម្រូវឲ្យមានការផ្លាស់ប្តូរឯកសារគឺៈ (១) នៅពេលកូនដំរីមានអាយុ ៨ ឆ្នាំ (២) ការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិ និង (៣) នៅពេលដំរីស្លាប់។

នៅពេលកូនដំរីឈានចូលដល់អាយុប្រាំបីឆ្នាំ (ឬក្នុងរយៈពេល ៩០ ថ្ងៃក្រោយពេលនេះ) ម្ចាស់សត្វដំរីនោះ ត្រូវតែទៅសុំធ្វើវិញ្ញាបនប័ត្រចុះបញ្ជី។ ម្ចាស់កម្មសិទ្ធិណាដែលមានបំណងបំពេញបែបបទនេះ អាចទទួលបាននូវឯកសារជំនួសមួយ តាំងពីកូនដំរី

នៅវ័យក្មេង ដែលមានឈ្មោះថា " វិញ្ញាបនប័ត្រស្តេរភាពបន្តពូជ" ដែលមានបង្ហាញពីម្ចាស់កម្មសិទ្ធិផងដែរ។ រហូតមកដល់ពេលថ្មីៗនេះ ឯកសារនេះមានសារប្រយោជន៍ច្រើនណាស់ ព្រោះជាធម្មតាមន្រ្តីរដ្ឋាភិបាលមិនត្រួតពិនិត្យប័ណ្ណកម្មសិទ្ធិចំពោះកូនដំរី ដែលមានអាយុតិចជាងប្រាំបីឆ្នាំនោះទេ ជាពិសេសនៅពេលដែលកូនដំរីនៅជាសត្វដំរីញីពេញវ័យ ដែលយើងអាចសន្មត់ថាជាមេរបស់វា។ បញ្ហាមួយទៀតដែលបង្កឡើងដោយ "វិញ្ញាបនប័ត្រស្តេរភាពបន្តពូជ" គឺថាសត្វដំរីដែលមានអាយុតិចជាងប្រាំបីឆ្នាំ វាមានការផ្លាស់ប្តូរ ហើយប្រែប្រួលយ៉ាងឆាប់រហ័ស ដូច្នេះវាមានលក្ខណៈពិសេសសម្រាប់ធ្វើការកត់សម្គាល់តិចតួចណាស់។

នៅពេលមានការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិ (ឬក្នុងរយៈពេល ៩០ ថ្ងៃក្រោយពេលនេះ) ម្ចាស់ថ្មីត្រូវទៅដូរវិញ្ញាបនប័ត្រចុះបញ្ជីជាមួយម្ចាស់មុន។ ការរាយការណ៍ និងការចុះឈ្មោះផ្លាស់ប្តូរគឺចាំបាច់ណាស់សម្រាប់ការលក់ និងទិញ រួមទាំងការទទួលមរតកទាំងអស់នៅក្នុងគ្រួសារ។ មន្រ្តីម្នាក់នឹងកត់ត្រាការផ្លាស់ប្តូរហើយសរសេរព័ត៌មានលំអិតរបស់ម្ចាស់ថ្មីនៅខាងក្រោយឯកសារ។ ទាំងម្ចាស់ចាស់និងថ្មីត្រូវយកអត្តសញ្ញាណប័ណ្ណ និងវិញ្ញាបនប័ត្រចុះបញ្ជីគ្រួសារ។

នៅពេលសត្វដំរីស្លាប់ ម្ចាស់របស់វាត្រូវរាយការណ៍ក្នុងរយៈពេល ១៥ ថ្ងៃ។ ចំណែកវិញ្ញាបនបត្រចុះបញ្ជីត្រូវតែប្រគល់ឲ្យនៅការិយាល័យចុះឈ្មោះវិញ។

មុននឹងដឹកជញ្ជូនសាកសពសត្វដំរីដែលស្លាប់ទៅខេត្តមួយផ្សេងទៀត អ្នកត្រូវតែមានវិញ្ញាបនប័ត្រចុះបញ្ជីរបស់ដំរីនោះ និងវិញ្ញាបនប័ត្រអនុញ្ញាតឲ្យដឹកជញ្ជូន (សូមមើលទំព័រ ២០) និងរាយការណ៍ជាបឋមទៅកាន់ពេទ្យសត្វស្រុកនៅទីតាំងថ្មីដើម្បីស្នើសុំការអនុញ្ញាតធ្វើការដឹកជញ្ជូន ហើយត្រូវបញ្ជាក់ផ្លូវដែលត្រូវធ្វើដំណើរទៀតផង។ អ្នករំលោភបំពានលើករណីទាំងនោះត្រូវទទួលទណ្ឌកម្មមិនត្រូវលើសពី ១ ០០០ បាត ឬត្រូវជាប់ពន្ធនាគារលើសពីពីរខែ ឬត្រូវទទួលទោសទាំងពីរតែម្តង (ច្បាប់ស្តីពីជម្ងឺរាតត្បាតលើសត្វ ឆ្នាំ១៩៥៦ នាយកដ្ឋានបសុសត្វ)។

## ជម្ងឺរាតត្បាត

ក្នុងករណីដំរីបានធ្ងន់ ឬស្លាប់ដោយសារជម្ងឺរាតត្បាត អ្នកត្រូវរាយការណ៍អំពីករណីនេះទៅពេទ្យសត្វស្រុកក្នុងរយៈពេល២៤ម៉ោង។ ប្រសិនបើសត្វដំរីនោះនៅរស់ ហាមដាច់ខាតមិនឲ្យផ្លាស់ទីសត្វដំរីចេញពីកន្លែងនោះទេ។ ច្បាប់តម្រូវឲ្យមានវិធានការផ្សេងៗទៀតជាច្រើន ប៉ុន្តែអ្វីដែលត្រូវធ្វើមុនគេបំផុតនោះ គឺអ្នកត្រូវធ្វើតាមបញ្ជារបស់ពេទ្យសត្វស្រុក (ច្បាប់ស្តីពីជម្ងឺរាតត្បាតលើសត្វឆ្នាំ ១៩៥៦ នាយកដ្ឋានបសុសត្វ)។

## តំបន់ទីក្រុង

នៅពេលណាដែលអ្នកយកសត្វដំរីមួយចូលទៅក្នុងតំបន់ទីក្រុងណាមួយ អ្នកនឹងស្ថិតនៅក្រោមបទប្បញ្ញត្តិរបស់ទីក្រុងនោះ ដូចជាទីក្រុងបាងកក ឈៀងម៉ៃ ប៉ាតាយ៉ាជាដើម អ្នកអាចប្រឈមនឹងបញ្ហាតាមផ្លូវច្បាប់ជាច្រើន។ ប្រសិនបើប៉ូលីស ឬមន្ត្រីក្រុងមានបំណងចង់ធ្វើឲ្យអ្នកមានការលំបាក អ្នកអាចនឹងត្រូវគេចោទប្រកាន់ពីបទរំលោភលើច្បាប់ចរាចរណ៍ ច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈ ច្បាប់ស្តីពីអនាម័យ ច្បាប់ស្តីពីការបំផ្លាញទ្រព្យសម្បត្តិ (ដូចជាបំផ្លាញដើមឈើ)។ល។

## រក្សាច្បាប់ចម្លង

ត្រូវថែរក្សាទុកឯកសារចម្លងវិញ្ញាបនប័ត្រចុះបញ្ជី យ៉ាងហោចណាស់ឲ្យបានចំនួនពីរច្បាប់ ដោយទុកនៅកន្លែងពីរផ្សេងៗគ្នា ក្នុងករណីដែលឯកសារមួយច្បាប់ត្រូវបាត់បង់ ឬក៏ត្រូវបានបំផ្លាញ យើងនឹងនៅមានឯកសារមួយច្បាប់ទៀត។ នៅពេលទៅទទួលវិញ្ញាបនប័ត្រចុះបញ្ជី នៅការិយាល័យចុះឈ្មោះ អ្នកអាចស្នើសុំច្បាប់ចម្លងបន្ថែមទៀតដែលចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន ដើម្បីទុកជាច្បាប់ចម្លងត្រឹមត្រូវ និងមានសុពលភាពស្មើគ្នាដូចឯកសារច្បាប់ដើម។ ច្បាប់ចម្លងបន្ថែមនេះ អ្នកនឹងត្រូវចំណាយត្រឹមតែពីរ ឬបីបាតក្នុងមួយសន្លឹកហើយវាអាចជួយសន្សំសំចៃប្រាក់ និងបញ្ហារបស់អ្នកបានច្រើន ដោយចៀសវាងការចំណាយ និងបញ្ហាដែលបណ្តាលមកពីការបាត់បង់ឯកសារ ឬត្រូវខូចខាត។ វាមិនមែនជារឿងល្អ ដែលត្រូវធ្វើការរើបអូសដំរីស្របច្បាប់ ដោយ

សារតែមានការបាត់បង់ក្រដាសមួយសន្លឹក ឬក៏ត្រូវបានដាក់ខុសទីកន្លែងនោះទេ បើទោះបីជាការរើបអូសនោះមានលក្ខណៈជាបណ្តោះអាសន្នយ៉ាងណាក៏ដោយ។

រក្សាទុកឯកសារដើម (ដោយមានបោះត្រា) នៅកន្លែងមានសុវត្ថិភាពក្នុងផ្ទះ។ នៅពេលធ្វើដំណើរ សូមអ្នកយកតែច្បាប់ចម្លង ដែលបានបញ្ជាក់រួច ទៅជាប់នឹងខ្លួនជាមួយអ្នក។ តាមពិតនៅតាមផ្លូវ ដែលគ្រោះថ្នាក់អាចកើតមានឡើងជាយថាហេតុ អ្នកគួរតែមានច្បាប់ចម្លងពីរ ទុកជាមួយនឹងមនុស្សពីរនាក់ផ្សេងគ្នាដែលនៅក្នុងក្រុមជាមួយគ្នា នោះអ្នកនឹងមានសុវត្ថិភាព និងងាយស្រួលបំផុត។

នៅក្នុងសៀវភៅចម្លង សូមអ្នកមេត្តាសរសេរកាលបរិច្ឆេទ និងលេខស៊េរី ទីកន្លែង (រួមទាំងលេខបង្កាន់ដៃសៀវភៅ) នៃវិញ្ញាបនប័ត្រចុះបញ្ជីសត្វដំរីរបស់អ្នក។ ក្នុងករណីមានការបាត់បង់វិញ្ញាបនប័ត្រ ព័ត៌មានដែលអ្នកបានកត់ត្រាទុកទាំងនេះនឹងជួយបង្កើនល្បឿននិតិវិធីដាក់ពាក្យសុំវិញ្ញាបនប័ត្រថ្មី មកជំនួសវិញ។

វាជាគំនិតល្អក្នុងការទិញស្រោមប្លាស្ទិច ឬស្រោមសំបុត្ររឹងមាំជាប់បានយូរ ដើម្បីថែរក្សាទុកឯកសារ ដែលផុយស្រួយទាំងនោះ។ សូមមេត្តាកុំព្យាយាមបត់ឯកសារទាំងអស់នោះឲ្យសោះ។

## ម៉ៃក្រូឈីប

 

ម៉ៃក្រូឈីបគឺជាឧបករណ៍ ដែលអាចដាក់បញ្ចូលទៅក្នុងខ្លួនរបស់សត្វដំរី ដើម្បីកំណត់អត្តសញ្ញាណរបស់វា។ ប្រព័ន្ធម៉ៃក្រូឈីបមានសមាសធាតុពីរ គឺម៉ៃក្រូឈីបខ្លួនវា និងឧបករណ៍មួយទៀត ដែលអាចកំណត់លេខកូដតែមួយគត់របស់ម៉ៃក្រូឈីប។

ម៉ៃក្រូឈីបគឺជាឧបករណ៍មួយដែលមានទំហំតូច មានអង្កត់ផ្ចិតប្រហែលប៉ុនគ្រាប់ស្រូវ និងមានប្រវែងប្រហែល ១ ស.ម ។ នៅខាងក្នុងកែវគឺជាលេខកូដពិសេសមួយ ដែល

គ្មាននណាអាចចម្លងបាន។ ម៉ៃក្រូឈីបត្រូវបានចាក់ចូលទៅក្រោមស្បែកដំរី។ ជាទូទៅពេទ្យសត្វតែងចាក់បញ្ចូលគ្រាប់ម៉ៃក្រូឈីបនៅផ្នែកខាងក្រោយត្រចៀកឆ្វេង។

ឧបករណ៍សម្រាប់អានម៉ៃក្រូឈីបមានសមត្ថភាពអាចអានលេខ នៅក្នុងនោះតាំងពីចម្ងាយប្រហែល ១០ សង្ទីម៉ែត្រ។ លេខកូដនេះជាធម្មតាមាន ៩ ខ្ទង់ ឬបើមិនដូច្នេះទេមានលេខដូចខាងក្រោម៖

TN ១២៣-៤៥៦-៧៨៩ ឬ ១២៣-៤៥៦-៧៨៩ ឬ ៤D ១២៣-៤៥៦-៧៨៩

## អត្ថប្រយោជន៍របស់ម៉ៃក្រូឈីប

ម៉ៃក្រូឈីបមានប្រយោជន៍ខ្លាំងណាស់ ពីព្រោះបច្ចុប្បន្នមានតែវិញ្ញាបនប័ត្រចុះបញ្ជីនេះទេ ដែលអាចឲ្យយើងកំណត់ថានណាជាម្ចាស់របស់សត្វដំរី ហើយឯកសារនោះមិនទាន់មានព័ត៌មានលំអិតគ្រប់គ្រាន់ទេ។ ដូច្នេះវាអាចមានសត្វដំរី ដែលចាប់បានពីព្រៃដោយខុសច្បាប់ ឬជាសត្វដំរីដែលនាំចូលដោយខុសច្បាប់ ឬជាសត្វដំរីដែលត្រូវបានលួចពីគេ ដើម្បីយកមកសុំចុះបញ្ជីទទួលវិញ្ញាបនប័ត្រ។ ការដាក់បញ្ចូលម៉ៃក្រូឈីបអាចការពារការក្លែងបន្លំចុះឈ្មោះក្នុងបញ្ជី។ ម៉ៃក្រូឈីបក៏ងាយស្រួលផងដែរសម្រាប់ឲ្យមន្ត្រីទទួលបន្ទុកការងារនោះអាចដឹងពីប្រវត្តិនៃការចុះឈ្មោះសត្វ នៅពេលសត្វដំរីត្រូវបានដឹកជញ្ជូនពីកន្លែងមួយទៅកន្លែងមួយទៀត ឬប្រវត្តិវេជ្ជសាស្ត្ររបស់សត្វដំរីនោះ នៅពេលយើងធ្វើការព្យាបាលវាតាមជំនាញរបស់បសុពេទ្យ។

## ស្ថានភាពបច្ចុប្បន្ន

បច្ចុប្បន្ននេះទាំងអង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងាររបស់រដ្ឋាភិបាលយល់ព្រមដាក់បញ្ចូលម៉ៃក្រូឈីបសម្រាប់សត្វដំរីទាំងអស់នៅទូទាំងប្រទេសដោយឥតគិតថ្លៃ។

មនុស្សជាច្រើនមានការភ័យខ្លាចចំពោះម៉ៃក្រូឈីប ប៉ុន្តែចំពោះម្ចាស់ដំរីណាដែលគោរពតាមច្បាប់ ម៉ៃក្រូឈីបគឺគ្រាន់តែដូចជាឯកសារចុះបញ្ជីសម្រាប់យានយន្តដែរ ដែលតែងមានលេខពិសេសរបស់យានយន្តនៅលើម៉ាស៊ីន និងតួរបស់វា គឺជាតួលេខដែលពិបាកផ្លាស់ប្តូរ ឬបំផ្លាញចោល។ ប្រសិនបើអ្នកបានចុះឈ្មោះសត្វដំរីរួចហើយ បន្ទាប់មកមានគេលួចសត្វដំរីនោះទៅបាត់ គឺគេអាចរកវាឃើញ ហើយអ្នកនឹងទទួលបានសត្វដំរី

របស់អ្នកមកវិញ។ ប្រសិនបើអ្នកបានចុះឈ្មោះវារួចហើយ ពេលនោះអ្នកនឹងមិនចាំបាច់ប្រាប់គេថា វាមិនមែនជាសត្វដំរីដែលនាំចូលពីប្រទេសមីយ៉ាន់ម៉ា ដោយខុសច្បាប់នោះទេ។

ក្នុងករណីណាក៏ដោយ បច្ចុប្បន្ននេះ តាមច្បាប់ម៉ៃក្រូឈីបមិនទាន់មានតួនាទីច្រើនទេ ពីព្រោះថាច្បាប់មិនទាន់បានទាមទារឲ្យមានម៉ៃក្រូឈីបនៅឡើយទេ ទោះបីជាមានអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ និងទីភ្នាក់ងាររដ្ឋាភិបាលបានដាក់ម៉ៃក្រូឈីបឲ្យសត្វដំរីជាច្រើនហើយក៏ដោយ។ ប៉ុន្តែនៅមិនទាន់មានមូលដ្ឋានទិន្នន័យកណ្តាល ដែលអាចចងក្រងគ្រប់គ្រងលេខទាំងអស់នៅក្នុងមជ្ឈមណ្ឌលណាមួយនៅឡើយទេ។ លើសពីនេះទៀត

កន្លែង ដែលគេដាក់ម៉ៃក្រូឈីបចូល ក៏នៅមិនទាន់មានលក្ខណៈស្តង់ដារនៅឡើយទេដែរ។ ម៉ៃក្រូឈីបខ្លះត្រូវបានដាក់នៅខាងក្រោយត្រចៀក និងស្មាទាំងសងខាង ទាំងនៅខាងស្តាំ និងនៅខាងឆ្វេង។ លើសពីនេះទៀតឧបករណ៍ដែលគេប្រើសម្រាប់អានទិន្នន័យនៅមានតម្លៃថ្លៃ ហើយមន្ត្រីជាច្រើនក៏នៅមិនទាន់មានលទ្ធភាពដែរ។

## ការដឹកជញ្ជូនដំរី

មុនពេលដឹកជញ្ជូនសត្វដំរីពីកន្លែងមួយទៅកន្លែងមួយទៀត សូមអ្នកធ្វើការរៀបចំការងារមួយចំនួនដូចខាងក្រោម៖

១. រៀបចំផែនការធ្វើដំណើរ

២. រៀបចំដំរី

៣. រៀបចំយានយន្ត និងឧបករណ៍ចាំបាច់មួយចំនួន

៤. រៀបចំឯកសារដែលគេត្រូវការពិនិត្យ

### ១. រៀបចំផែនការធ្វើដំណើរ

មុនពេលធ្វើដំណើរ ហ្មដំរីគួរដឹងព័ត៌មានលម្អិតសំខាន់ៗមួយចំនួន៖ ផ្លូវដែលត្រូវធ្វើដំណើរ ពេលវេលាប្រហាក់ប្រហែលនៃការធ្វើដំណើរ និងចំណុចគោលដៅ។ ព័ត៌មាននេះគឺចាំបាច់ណាស់ ដើម្បីធានាឲ្យសត្វដំរីមានអាហារ និងទឹកគ្រប់គ្រាន់នៅពេលធ្វើ

*ដំណើរតាមផ្លូវ។ អ្វីដែលងាយស្រួលបំផុត គឺត្រូវរៀបចំឲ្យមានដើមចេក និងអាហារផ្សេងទៀត ដែលមានជាតិទឹកខ្ពស់ ព្រោះវាមានការងាយស្រួលនឹងដឹកជញ្ជូនជាងចំណីអាហារធម្មតា និងទឹក។ គួរបញ្ជាក់ផងដែរថាហ្មដំរី ឬអ្នកគ្រប់គ្រងគួរតែជានាថាមានកន្លែងសមរម្យ និងងាយស្រួលសម្រាប់ឲ្យសត្វដំរីឡើង និងចុះពីរថយន្តដឹកទំនិញមកវិញនៅចំណុចគោលដៅជាពិសេសប្រសិនបើដំរីពិបាកដឹក។ ប្រសិនបើសត្វដំរីត្រូវតែធ្វើដំណើរឆ្ងាយ (គឺលើសពីមួយថ្ងៃ) ហ្មដំរីគួរតែដឹងពីកន្លែងដែលខ្លួនអាចទិញ ឬស្វែងរកអាហារ និងទឹកសម្រាប់សត្វដំរីបាន។*

*ប្រយ័ត្ន៖ ចាំបាច់ត្រូវជៀសវាងការធ្វើដំណើរក្រោមកំដៅព្រះអាទិត្យខ្លាំង ព្រោះដំរីអាចរងនូវការប៉ះពាល់ខ្លាំង អាចរហូតដល់ស្លាប់។ ធ្វើដំណើរពេលយប់គឺល្អបំផុត។*

## ២. រៀបចំដំរី

*មុនពេលដឹកជញ្ជូនសត្វដំរីណាមួយ យើងគួរតែទុកពេលឲ្យវា យ៉ាងហោចណាស់ពីរ ឬបីថ្ងៃមុនដែរ ដើម្បីឲ្យវាបានសម្រាក អាចស៊ីចំណី និងផឹកទឹកទៅតាមចិត្តរបស់វា។ សម្រាប់សត្វដំរីមេ និងកូនរបស់វា យកល្អមិនគួរឲ្យវាធ្វើដំណើរបែកពីគ្នាតែម្នាក់ឯងទេ។ អ្វីដែលល្អជាងគេបំផុតនោះគឺ មេ ឬកូនវាអាចរួមដំណើរជាមួយដំរីណាមួយ ដែលពួកគេធ្លាប់ស្គាល់។ (មេរបស់វានឹងមិនសូវមានការជ្រួលច្របល់ ហើយយើងក៏មានការងាយស្រួលក្នុងការគ្រប់គ្រងវា) សំខាន់បំផុតនោះ គឺនៅពេលយើងធ្វើការផ្លាស់ប្តូរសត្វដំរីទៅទីតាំងមួយ ដែលពួកគេមិនធ្លាប់ស្គាល់ វាជាការចាំបាច់ណាស់ ដែលហ្មដំរីត្រូវតែនៅជិតដំរីជានិច្ច គឺមិនត្រូវទុកសត្វដំរីនោះចោលតែឯងឡើយ។*

*នៅពេលធ្វើការដឹកជញ្ជូនតាមយានយន្តណាមួយ ហ្មដំរីគួរតែដឹងថាតើដំរីនេះស៊ាំនឹងការឡើង និងយានយន្តនោះដែរឬទេ។ បើមានការលំបាកក្នុងការនាំសត្វដំរីនោះឡើងលើយានយន្ត ឬសត្វដំរីនោះមានការភ័យខ្លាច ត្រូវតែហៅមនុស្សផ្សេងទៀតមកជួយក្នុងការងារនោះ។ ល្អប្រសើរបំផុតនោះគឺត្រូវបង្ហាត់សត្វដំរីឲ្យចេះឡើង និងចុះពីយានយន្តដោយស្រួលសិន បើពុំនោះទេយើងនឹងមានការលំបាកក្នុងការនាំសត្វដំរីឡើង និងចុះពីយានយន្ត ដែលធ្វើឲ្យយើងខាតបង់ពេលវេលាច្រើនណាស់ ហើយអាចធ្វើឲ្យសត្វមាន*

*ភាពតានតឹង ច្របូកច្របល់ខ្លាំង ជួនកាលអាចធ្វើឲ្យវារងរបួសដោយលំពែង ឬកន្ទ្រៃថែមទៀតផង។*

## ៣. រៀបចំយានយន្តនិងឧបករណ៍ចាំបាច់មួយចំនួន

*ប្រសិនបើជាការដឹកជញ្ជូនតាមយានយន្ត ហ្មដំរី ឬអ្នកគ្រប់គ្រងត្រូវតែពិនិត្យមើលទំហំ និងស្ថានភាពរបស់យានយន្តឲ្យបានត្រឹមត្រូវ ដើម្បីជានាឲ្យការធ្វើដំណើរបានទៅដល់គោលដៅប្រកបដោយសុវត្ថិភាព និងទាន់ពេលវេលា។ ហ្មដំរី ឬអ្នកគ្រប់គ្រងគួរតែពិនិត្យមើលថាតើយានយន្តនោះបានចុះបញ្ជី និងមានធានារ៉ាប់រងត្រឹមត្រូវដែរឬទេ។ អ្នកបើកបរគួរតែមានប័ណ្ណបើកបរ ដែលមានសុពលភាពទាំងថ្នាក់ទី ២ ឬថ្នាក់ទី ៣ (ទាំងរថយន្តទេសចរណ៍ និងរថយន្តដឹកទំនិញ)។ ហ្មដំរីត្រូវតែសង្កេតមើលថា តើអ្នកបើកបរនោះមានអារម្មណ៍ធុញទ្រាន់ ហើយបើអាចត្រូវដឹងថា តើគាត់ធ្លាប់មានបទពិសោធក្នុងការដឹកជញ្ជូនសត្វដំរីពីមុនៗមកដែរឬទេ។*

## ៤. រៀបចំឯកសារដែលគេត្រូវការពិនិត្យ

*អ្នកគ្រប់គ្រង ម្ចាស់ ឬហ្មដំរីត្រូវប្រាកដថា តើខ្លួនមានលិខិតបញ្ជាក់ចុះបញ្ជីច្បាប់ដើមនៅជាប់នឹងខ្លួនដែរឬទេ នៅពេលដែលខ្លួនទៅដាក់ពាក្យសុំលិខិតអនុញ្ញាតធ្វើការដឹកជញ្ជូណសត្វដំរីនោះ។ នៅពេលធ្វើដំណើរលិខិតថតចម្លងពីឯកសារដើមមួយច្បាប់ គឺគ្រប់គ្រាន់ហើយ ហ្មដំរីគួរតែត្រៀមបង្ហាញឯកសារថតចម្លងវិញ្ញាបនប័ត្រចុះបញ្ជីរាល់ពេលជួបមន្ត្រីអធិការកិច្ចណាមួយ។*

*មុនពេលធ្វើដំណើរអ្នកគ្រប់គ្រង ហ្មដំរីត្រូវរៀបចំឯកសារសំខាន់ចំនួន ៤ ប្រភេទដូចខាងក្រោម៖*

*១. ការធានាថាទីទ្វៃងរបស់គោលដៅ ដែលយើងត្រូវដឹកដំរីទៅ មានភាពសមស្របសម្រាប់សត្វដំរី។ ការធានានេះត្រូវចេញដោយនាយកដ្ឋានបសុសត្វ។ មុនពេលធ្វើដំណើរម្ចាស់ ឬអ្នកគ្រប់គ្រងត្រូវតែទាក់ទងមន្ត្រីទទួលខុសត្រូវនៃនាយកដ្ឋានបសុសត្វនៅគោលដៅ។*

*២. វិញ្ញាបនប័ត្រចុះបញ្ជីច្បាប់ដើម និងច្បាប់ចម្លង។*

៣. លិខិតបញ្ជាក់ធានាថាសត្វជំរឺនោះបានចាក់វ៉ាក់សាំងនៅស្រុកកំណើតរបស់វារួចហើយ។ ម្ចាស់ជំរឺ អ្នកគ្រប់គ្រង ឬហ្វូងជំរឺត្រូវសុំវិញ្ញាបនប័ត្រនេះពីនាយកដ្ឋានបសុសត្វស្រុក។

៤. ឯកសារចម្លងអត្តសញ្ញាណប័ណ្ណប្រជាជនរបស់ម្ចាស់ជំរឺ និងលិខិតបញ្ជាក់ចុះបញ្ជីគ្រួសារ។ ប្រសិនបើម្ចាស់ជំរឺមិនមែនជាអ្នកទទួលខុសត្រូវក្នុងពេលដឹកជញ្ជូនជំរឺនោះទេ គាត់ត្រូវរៀបចំលិខិតបញ្ជាក់ផ្ទេរសិទ្ធិទៅឲ្យអ្នក ដែលទទួលខុសត្រូវជំនួសខ្លួន ហើយបុគ្គលនោះត្រូវមានឯកសារថតចម្លងអត្តសញ្ញាណប័ណ្ណប្រជាជន និងវិញ្ញាបនប័ត្រចុះបញ្ជីគ្រួសារ ព្រមទាំងលិខិតផ្ទេរសិទ្ធិ នៅពេលគាត់ដាក់ពាក្យសុំលិខិតធ្វើដំណើរ។

អ្នកដែលដាក់ពាក្យសុំលិខិតធ្វើដំណើរត្រូវតែផ្តល់លេខផ្លូវ ស្រុក និងខេត្តគោលដៅ។ ដូចគ្នានេះផងដែរគាត់ត្រូវតែផ្តល់លេខយានយន្តដែលត្រូវប្រើ។

ជាមួយនឹងឯកសារទាំងអស់នេះអ្នកទទួលខុសត្រូវ ដែលចង់ដឹកសត្វជំរឺ (ឬសាកសពរបស់វា) ត្រូវតែទៅកាន់ទាំងការិយាល័យបសុព្យាបាលស្រុក និងមន្ទីរបសុព្យាបាល ខេត្តរបស់ជំរឺនោះ ដើម្បីស្នើសុំវិញ្ញាបនប័ត្រអនុញ្ញាតការដឹកជញ្ជូន ដែលជាទម្រង់ផ្លូវការលេខ ៤។ នៅពេលត្រូវវិលត្រឡប់មកលំនៅដ្ឋានដើមវិញ ត្រូវតែបំពេញបែបបទតាមនីតិវិធីដូចគ្នានៅនាយកដ្ឋានបសុសត្វស្រុកនៃកន្លែងគោលដៅ។

នៅពេលទទួលបានវិញ្ញាបនប័ត្រអនុញ្ញាត ឲ្យមានការដឹកជញ្ជូនត្រឡប់ទៅកាន់ចំណុចដើមវិញហើយ អ្នកដែលមានឈ្មោះក្នុងវិញ្ញាបនប័ត្រត្រូវតែដឹកជញ្ជូនសត្វជំរឺត្រឡប់ទៅតាមផ្លូវដែលបានកំណត់ទុកជាមុនរួចហើយ។ យានយន្តត្រូវឈប់ និងបង្ហាញឯកសារ ដើម្បីធ្វើការត្រួតពិនិត្យ ទាំងឯកសារ ទាំងសត្វជំរឺដល់មន្ត្រីទទួលខុសត្រូវនៅតាមប៉ុស្តិ៍ត្រួតពិនិត្យទាំងអស់នៃនាយកដ្ឋានបសុសត្វនៅតាមដងផ្លូវ។

បន្ទាប់ពីបានទៅដល់គោលដៅរួចហើយ សត្វជំរឺត្រូវរក្សាទុកនៅកន្លែងដែលបានកំណត់ដោយនាយកដ្ឋានបសុព្យាបាល ក្នុងរយៈពេលមិនតិចជាងដប់ថ្ងៃមុនពេលវាអាចរើទៅកន្លែងផ្សេងទៀតបាន។

ប្រសិនបើសត្វជំរឺត្រូវបានផ្លាស់ប្តូរដោយគ្មានការអនុញ្ញាត ឬផ្លាស់ប្តូរតាមផ្លូវ ឬទៅកាន់ទិសដៅណាមួយ ក្រៅពីទិសដៅដែលបានកំណត់នៅក្នុងវិញ្ញាបនប័ត្រអនុញ្ញាតឲ្យ

ដឹកជញ្ជូន អ្នកទទួលខុសត្រូវនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារមិនលើសពីប្រាំមួយខែ ឬពិន័យជាប្រាក់មិនលើសពី ១០ ០០០ បាត ឬក៏អាចមានទោសទាំងពីរតែម្តង។

បន្ទាប់ពីដំរីបានទៅដល់គោលដៅហើយ វាចាំបាច់ត្រូវទទួលការត្រួតពិនិត្យ ដើម្បីឲ្យដឹងថា តើវាមានដំបៅនៅមាត់ ជើង កន្ទុយ ឬលើរាងកាយ ដែលបណ្តាលមកពីការលោតចុះ ឬឡើងដែរឬទេ។ បើមានស្នាមរបួសត្រង់កន្លែងណាមួយ ត្រូវតែធ្វើការព្យាបាលជាបន្ទាន់។ អ្វីដែលសំខាន់ជាងគេនោះគឺ ត្រូវពិនិត្យភ្នែកចំពោះការរលាក ឬជម្ងឺធ្ងន់ណាមួយមកពីខ្យល់ ឬខ្យល់បក់ខ្លាំង ដែលបណ្តាលឲ្យវត្ថុអ្វីមួយចូលក្នុងភ្នែករបស់សត្វដំរី នៅក្នុងពេលធ្វើដំណើរ។ បើមានករណីបែបនេះ សូមលាងភ្នែកឲ្យវា និងត្រូវបន្តក់ថ្នាំភ្នែកឲ្យវាភ្លាមៗ។ បន្ទាប់មកត្រូវឲ្យពេទ្យសត្វពិនិត្យជម្ងឺនោះ និងត្រូវធ្វើការព្យាបាលបន្ថែមជាបន្ទាន់។

## ទ្រុងនៅក្នុងឡានដឹកដំរី

នៅពេលត្រូវដឹកជញ្ជូនសត្វដំរីតាមយានយន្ត យកល្អគួរធ្វើទ្រុងមួយសម្រាប់វា។ (ទ្រុងនោះអាចរុះរើបានយ៉ាងងាយស្រួល និងអាចតម្លើងវិញជាថ្មីសម្រាប់ប្រភេទឡានដឹកទំនិញ៖ កង់ ១០ ឬកង់ ៦ ។ ល។) ចំពោះហ្មដំរី ដែលមិនធ្លាប់បានឃើញ ឬមិនធ្លាប់បានប្រើប្រាស់ទ្រុងនោះ មើលទៅហាក់ដូចជាចង់មានន័យថា ការពារសត្វដំរីកុំឲ្យរត់បាត់ ឬកុំឲ្យវាជាន់ខូចខាតរបស់នៅជុំវិញវា ឬកុំឲ្យសត្វដំរីនោះអាចធ្វើការវាយប្រហារទៅលើហ្មដំរីបាន។ ទ្រុងនោះ គឺពិតជាអាចបម្រើដល់ផលប្រយោជន៍ទាំងអស់នេះមែន។

គោលបំណងពិតប្រាកដនោះ គឺដើម្បីឲ្យសត្វដំរីមានទម្រជួយទប់ខ្លួនវា ដើម្បីជួយដំរីឲ្យមានលំនឹង។ នៅពេលឡានបើកលឿន ហើយធ្វើដំណើរឡើង ឬចុះពីលើភ្នំ ឬបត់ ឬនៅពេលដែលរថយន្តចាប់ហ្វ្រាំងយ៉ាងគំហុក បើគ្មានទ្រុងជាទម្រទេ សត្វដំរីត្រូវតែប្រឹងប្រើសាច់ដុំរបស់វាដើម្បីទប់លំនឹង។ បើយើងមើលទៅ ហាក់ដូចជាដំរីមិនបានធ្វើអ្វីទាល់តែសោះ ប៉ុន្តែតាមពិត វាពិតជាមានការលំបាកក្នុងការប្រឹងទប់ខ្លួន ទាំងផ្លូវកាយ និងផ្លូវចិត្តព្រោះដំរីត្រូវតែប្រុងប្រយ័ត្នជានិច្ច។ ក្នុងស្ថានភាពបែបនេះ នៅពេលទៅដល់គោលដៅសត្វដំរីនឹងមានការហត់នឿយលើរាងកាយយ៉ាងខ្លាំង។



ស្ថានភាពបែបនេះ វាគ្មានអ្វីខុសគ្នារវាងមនុស្ស និងសត្វដំរីនោះទេ។ សូមអ្នកគិតស្រមៃមើលថា ខ្លួនអ្នកកំពុងឈរនៅកណ្តាលឡានដប់កង់ ដោយគ្មានអ្វីសម្រាប់តោង ឬជាទម្រ នៅក្នុងការធ្វើដំណើរមួយអស់រយៈពេលដប់ពីរម៉ោង។ បន្ទាប់មកសូមអ្នកគិតស្រមៃមើលថា តើវាងាយស្រួលប៉ុណ្ណា ប្រសិនបើអ្នកអាចដាក់ដៃរបស់អ្នកនៅលើបង្កាន់ដៃក្នុងរថយន្ត។ វាជាការពិតណាស់ សត្វដំរីមានជើងបួន ដែលធ្វើឲ្យវាកាន់តែមានការងាយស្រួល ប៉ុន្តែវាក៏ពិបាកដែរ ព្រោះសត្វដំរីមិនអាចមានប្រតិកម្មរហ័សដូចមនុស្សទេ។

បើមានទ្រុងជាទម្រ ដំរីអាចផ្អែកខ្លួនទៅលើទ្រុងដែកនោះខ្លះៗ ដើម្បីអាចជួយកាត់បន្ថយទម្ងន់របស់វា។ នៅពេលឡើងភ្នំ សត្វដំរីនឹងទប់ខ្លួនវាលើជញ្ជាំងទ្រុងដែលនៅផ្នែកខាងក្រោយបានខ្លះៗ។ នៅពេលចុះពីលើភ្នំ (ឬនៅពេលឡានចាប់ហ្វ្រាំង) ដំរីនឹងអាចផ្អៀងទ្រូងរបស់វាបន្តិចទល់នឹងទម្រដែកខាងមុខ។ នៅផ្លូវកោង ដំរីនឹងអាចផ្អែកស្មាឬរាងកាយរបស់វាទៅទម្រដែកចំហៀង។ ទម្រដែកជួយទប់ខ្លួនដំរី កាត់បន្ថយទម្ងន់វា ដើម្បីកុំឲ្យវាប្រឹងសាច់ដុំខ្លាំងពេក ប៉ុន្តែអ្វីដែលសំខាន់ជាងនេះទៀតនោះ គឺទ្រុងអាចជួយសត្វដំរីឲ្យទប់លំនឹងខ្លួនវាបាន។ នៅពេលទៅដល់គោលដៅ រាងកាយរបស់ដំរីនឹងស្ថិតនៅក្នុងស្ថានភាពល្អ ដោយវាមិនបានខ្ជះខ្ជាយកម្លាំង និងថាមពលផ្លូវចិត្តជាច្រើន ដើម្បីទប់ខ្លួននៅក្នុងពេលធ្វើដំណើរ ដោយសារមានទ្រុងជួយទប់ខ្លួនវានេះឯង។

គុណប្រយោជន៍មួយទៀតនៃទ្រុងនោះ គឺអាចជួយដោះស្រាយបញ្ហាបន្ទាប់បន្សំមួយចំនួនតូចទៀត ដូចជាកុំឲ្យដំរីភ័យខ្លាំង ដែលអាចនាំឲ្យវាធ្វើការ "វាយប្រហារ" ដែល

ជារឿយៗ វាអាចកើតឡើងនៅពេលដំរីមានអារម្មណ៍ថាខ្លួនវាមិនមានសុវត្ថិភាព និងមានគ្រោះថ្នាក់។

ទ្រុងបែបនេះគឺជារឿងធម្មតានៅទូទាំងភាគខាងជើង ប៉ុន្តែមិនសូវមានគេប្រើនៅភាគឦសានទេ។ ការផលិត និងប្រើទ្រុង គឺជារឿងដ៏ត្រឹមត្រូវមួយ ជាពិសេសនៅពេលដែលត្រូវផ្លាស់ទីរបស់សត្វដំរី នៅតាមផ្លូវហាយវេ (ផ្លូវសម្រាប់ល្បឿនលឿន) ដែលជាញឹកញាប់ តែងមានចំណោត និងមានផ្លូវកោងជាច្រើន។ ថ្លៃធ្វើទ្រុងនោះថោកណាស់ ដោយប្រើតែបង្គោលបួនប៉ុន្តែត្រូវរឹងមាំ ហើយមានតែប៊ូឡុងពីរប៉ុណ្ណោះ។ ហ្មដំរីក៏ត្រូវតែមានខ្សែពួរដែលត្រូវបានប្រើ នៅជាប់នឹងដៃជាប្រចាំ។



# ជម្រកនិងអាហារ

## ជម្រក

ជម្រកគឺជាផ្នែកមួយសំខាន់ខ្លាំងណាស់ នៅក្នុងកន្លែងទុកដំរី ឬមជ្ឈមណ្ឌលដំរី។ ជម្រកសម្រាប់សត្វដំរីមានពីរប្រភេទធំៗ យោងតាមការប្រើប្រាស់ជាក់ស្តែង៖

នៅតាមកន្លែងទេសចរណ៍ គេតែងទុកដំរីនៅខាងក្រៅ ដាច់ពីកន្លែងដែលគេចិញ្ចឹម និងបំប៉នចំណីធម្មជាតិនៅពេលយប់ ដើម្បីឲ្យសត្វដំរីអាចជ្រកកំដៅថ្ងៃ និងភ្លៀងក្នុងពេលម៉ោងធ្វើការ។

នៅតាមកន្លែងផ្សេងៗទៀត ដែលគេត្រូវរក្សាទុកសត្វដំរី នៅចន្លោះពេលថ្ងៃ និង ពេលយប់ នៅក្នុងកន្លែងដដែល ព្រោះគេមិនមានកន្លែងគ្រប់គ្រាន់សម្រាប់ធ្វើខុសពីនេះ ឬមួយដោយសត្វដំរីនោះឈឺ ដែលគេមិនត្រូវធ្វើការផ្លាស់ទីសត្វដំរីដោយសារហេតុផល សុខភាព ឬគ្រូពេទ្យកំពុងព្យាបាលវាទេ។

ជម្រកល្អគួរតែមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

អាចការពារសត្វដំរីពីកម្តៅព្រះអាទិត្យ និងទឹកភ្លៀង ដែលអាស្រ័យទៅលើសម្ភារៈ ដែលយកមកប្រើប្រាស់សម្រាប់ប្រក់ដំបូល។ វត្ថុធាតុដើមដែលគេតែងប្រើញឹកញាប់បំផុត នោះ គឺស្មៅ ឬស្លឹកចេក។ គុណប្រយោជន៍នៃសម្ភារៈទាំងនោះគឺថាវាមានតម្លៃថោកហើយ វាអាចការពារកម្តៅព្រះអាទិត្យបានយ៉ាងល្អ ប៉ុន្តែគុណវិបត្តិរបស់វា គឺគេត្រូវតែផ្លាស់ប្តូរដំបូលនោះរៀងរាល់ ២ ទៅ ៣ ឆ្នាំម្តង ហើយដំបូលស្មៅងាយនឹងឆេះណាស់។

ចំពោះសម្ភារៈផ្សេងទៀត ដូចជាក្បឿង គេប្រើវាប្រក់ធ្វើដំបូល សម្រាប់ធ្វើទីកន្លែងព្យាបាលសត្វដំរីឈឺជាប្រចាំ ពីព្រោះក្បឿងការពារកម្តៅបានល្អ និងដោយសារតែវាជាប់បានយូរ។ គុណវិបត្តិនៃវត្ថុធាតុដើមផ្សេងៗទៀត គឺថ្លៃណាស់។ នៅតាមកន្លែងមួយចំនួនទៀត ដោយគេត្រូវការពន្លឺព្រះអាទិត្យខ្លះៗ ទើបគេប្រើដំបូលប្លាស្ទិចមួយប្រភេទ ដែលគេតែងប្រើនៅកន្លែងបណ្តុះកូនរុក្ខជាតិ។

ប្រយ័ត្ន៖ ត្រូវចៀសសវាងប្រើប្រាស់សម្ភារៈផលិតពីសំណប៉ាហាំងធ្វើដំបូលព្រោះ៖ ដំបូលធ្វើពីសម្ភារៈប្រភេទនេះ វាស្រូប និងបង្កើនកម្តៅ។

ត្រូវមានប្រព័ន្ធខ្យល់ចេញចូលល្អ។ យកល្អជម្រកនោះគួរតែបើកចំហទាំងបួនជ្រុង ហើយដំបូលគួរតែមានកម្ពស់យ៉ាងហោចណាស់ឲ្យបានប្រាំមួយម៉ែត្រដែរ។ (ដំរីឈ្មោលពេញវ័យមានកម្ពស់ប្រហែលជិត ៣ ម៉ែត្រ និងប្រម៉ោយមានប្រវែងប្រហែលពី ១.៥ ទៅ២ ម៉ែត្រ) ។

ប្រយ័ត្ន៖ នៅពេលយប់ មិនគួរទុកសត្វដំរីចោលឲ្យនៅតែឯងទេ ព្រោះវាអាចនឹងបំផ្លាញជម្រក។

ត្រូវមានកន្លែងគ្រប់គ្រាន់សម្រាប់ដំរីទាំងអស់ ហើយកន្លែងមិនត្រូវចង្អៀតពេកទេ។ ដំរីដែលឈរត្រូវការទំហំប្រហែល ១៦ ម៉ែត្រការ៉េ (ទោះបីជាមានការប្រែប្រួលខ្លះៗ ទៅ

តាមតាមលក្ខណៈរបស់សត្វដំរីនីមួយៗក៏ដោយ)។ ដូច្នេះជម្រកសម្រាប់សត្វដំរីចំនួន ១០ ក្បាល នៅពេលថ្ងៃគួរតែមានទំហំ ៤ X ៤០ ម៉ែត្រ ដោយដំរីទាំងអស់ត្រូវដាក់ជាជួរជាប់ៗគ្នា។ (ដំរីដេកត្រូវការផ្ទៃដីទំហំប្រហែលពី ១៩ ទៅ ២០ ម៉ែត្រការ៉េ។ )

ប្រយ័ត្ន៖ យកល្អគួរតែចៀសវាងដាក់ដំរីដែលមិនធ្លាប់ស្គាល់គ្នា ឲ្យនៅក្នុងជម្រកតែមួយ។

កម្រាលការ៉ូបាតត្រូវតែងាយស្រួលលាងសម្អាត គឺមិនត្រូវសើម និងមិនត្រូវរអិល។ កម្រាលឥដ្ឋបាតមានពីរប្រភេទ គឺអំពីដី និងអំពីបេតុង ហើយប្រភេទនីមួយៗមានគុណសម្បត្តិ និងគុណវិបត្តិតែរៀងៗខ្លួន។ សត្វដំរីអាចនឹងមានបញ្ហាតិចតួចជាងនៅជើង និងក្រចកនៅលើកំរាលបាតពីដី ប៉ុន្តែកម្រាលបាតពីបេតុងងាយនឹងលាងសម្អាតជាង។

ត្រូវមានប្រពន្ធ័មួយ ដែលយើងអាចបង្ហូរកាកសំណល់ចេញដោយងាយ និងអាចធ្វើការសម្អាតបានយ៉ាងងាយស្រួល ហើយក៏ត្រូវមានបណ្តាញបង្ហូរទឹកស្អុយចេញក្រៅ

ផងដែរ។ ប្រព័ន្ធដែលល្អបំផុតសម្រាប់អនាម័យ គឺហ្មដំរីដោយខ្លួនឯងតែម្តងព្រោះគាត់ត្រូវសម្អាតសត្វរបស់គាត់ដោយផ្ទាល់។ គួរតែមានប្រព័ន្ធបង្ហូរទឹកចេញក្រៅ ហើយកំរាលឥដ្ឋគួរតែស្អាតជានិច្ច ដោយគ្មានដក់ទឹក ដែលធ្វើឲ្យទឹកនោម និងលាមករបស់សត្វដំរីអាចដក់នៅទីនោះ។ កម្រាលបាតត្រូវតែមានជម្រាលបន្តិចឆ្ពោះទៅរកប្រព័ន្ធលូបង្ហូរទឹកស្អុយ។

ត្រូវមានកន្លែងសម្រាប់ថ្ពក់ច្រវាក់ឲ្យរឹងមាំ។ កន្លែងសម្រាប់ថ្ពក់ច្រវាក់នោះ គួរតែមានគ្រឹះកប់ទៅក្នុងដីឲ្យបានជម្រៅយ៉ាងហោចពី ១ ទៅ ២ ម៉ែត្រដែរ។ បង្គោលទ្រដំបូលមិនគួរយកមកប្រើជាចំណុចសម្រាប់ភ្ជាប់ច្រវ៉ាក់ដាក់ដំរីនោះទេ។

ត្រូវដាក់នៅទីតាំងឲ្យបានសមរម្យ។ មុននឹងជ្រើសរើសទីតាំង យើងគួរតែដឹងថា៖

កន្លែងនោះមិនគួរស្ថិតនៅជិតប្រភពទឹក ឬក៏ជិតកន្លែងដែលអាចមានការបង្ហូរទឹកស្អុយចេញពីលំនៅដ្ឋានទៅកាន់ប្រភពទឹកឡើយ ជាពិសេសប្រភពទឹកធម្មជាតិ។ ទីតាំងនៃកន្លែងនោះ មិនគួរឲ្យស្ថិតនៅខ្ពស់ជាងបណ្តាញទឹកធម្មជាតិឡើយ។

ទីតាំងនោះគួរតែស្ថិតនៅឆ្ងាយពីផ្លូវ ដែលមានចរាចរណ៍មមាញឹក ពីព្រោះសម្លេងចរាចរណ៍អាចបណ្តាលឲ្យសត្វដំរីមានភាពតានតឹង និងជាពិសេសអាចរំខានដល់ការសម្រាករបស់ពួកវា។

ជម្រកដំរីដែលល្អត្រូវសាងសង់នៅលើអ័ក្សពីទិសខាងកើតទៅខាងខាងលិច ដើម្បីកាត់បន្ថយពន្លឺព្រះអាទិត្យ។

ជម្រកសម្រាប់សត្វដំរីគួរតែសាងសង់នៅលើផ្ទៃដីមួយ ដែលមិនសូវចោតខ្លាំង។

## ទឹក

ដំរីជាសត្វដែលងាយនឹងឡើងកំដៅ ហេតុដូចនេះហើយទើបវាចូលចិត្តងូតទឹក និងយកភក់មកដាក់លើខ្លួនរបស់វា។ ដំរីពេញវ័យផឹកទឹកប្រហែល ១២០ លីត្រក្នុងមួយថ្ងៃ ដោយវាបូមយកទឹកក្នុងប្រម៉ោយរបស់វា (ប្រហែលពី ១០ ទៅ ១៥ លីត្រនៅពេលវាបូម

តាមប្រមោយម្តងៗ) រួចហើយវាបាញ់ទឹកចូលទៅក្នុងមាត់របស់វា។ ដូច្នេះចាំបាច់ណាស់យើងត្រូវតែមានទឹកស្អាត ទាំងសម្រាប់សត្វដំរីផឹក និងងូត។ ជាធម្មតាសត្វដំរីផឹកទឹក ក្នុងពេលងូតទឹក បើសិនហ្មដំរីនាំវាទៅ ជាធម្មតាពីរដងក្នុងមួយថ្ងៃ (ពេលព្រឹក និងពេលរសៀល) ។ ក្រៅពីផឹកទឹកសត្វដំរីក៏ត្រូវការទឹក ដើម្បីបាញ់ទៅលើខ្លួនរបស់វា ដើម្បីជួយកាត់បន្ថយកម្តៅដែរ។

ដោយសារសត្វដំរីនោមញឹក ហើយជាពិសេសវាបន្ទោរបង់នៅក្នុងទឹក ដែលពួកវាចុះងូត ទើបទឹកនោះអាចបង្កបញ្ហាសុខភាពដោយសារជម្ងឺធ្ងន់។ ប្រសិនបើអាចធ្វើទៅបាន ហ្មដំរីគួរតែប្រើប្រភពទឹកផ្សេងៗគ្នា គឺមួយសម្រាប់ផឹក និងមួយទៀតសម្រាប់ងូត។ ហ្មដំរីក៏គួរជម្រុញដំរីឲ្យផឹកទឹក មុនពេលវាចុះងូតទឹកផងដែរ ដើម្បីកាត់បន្ថយឱកាសធ្ងន់ជម្ងឺ។ ប្រសិនបើអាចធ្វើបាន មិនត្រូវអនុញ្ញាតឲ្យសត្វដំរីផឹកទឹកពីស្រះ ឬអាងដែលប្រើប្រាស់ដោយសត្វផ្សេងទៀតដូចជាគោក្របីជាដើម។ ប្រសិនបើទឹកជាប្រភពទឹកធម្មជាតិដែលមានចលនាដូចជាទន្លេ ឬទឹកហូរ តែត្រូវជម្រុញសត្វដំរីឲ្យផឹកទឹកមុនគេ គឺត្រូវផឹកទឹកនៅផ្នែកខាងលើកន្លែងដែលវានឹងចុះងូត។

ប្រភពទឹកធម្មជាតិដែលត្រូវប្រើសម្រាប់សត្វដំរីរួមមាន ស្ទឹង ទន្លេ វាលភក់ និងប្រឡាយ។ ហ្មដំរីត្រូវដឹងពីចំណង់ចំណូលចិត្ត និងពីអ្វីដែលដំរីរបស់ខ្លួនមិនចូលចិត្ត ព្រោះមានសត្វដំរីខ្លះនឹងមិនផឹកទឹកដែលប្រឡាក់ដោយទឹកនោម ឬលាមករបស់សត្វដំរីគ្នាវា ឬដោយសត្វចិញ្ចឹមដទៃទៀតទេ។

ឧទាហរណ៍ប្រភពធនធានទឹក ដែលបង្កើតដោយមនុស្សរួមមាន អណ្តូង ស្រះ ប្រឡាយ និងបំពង់បង្ហូរទឹក ហើយជាធម្មតាប្រភពទឹកទាំងនេះមិនមានបញ្ហាជាមួយនឹងការចម្លងរោគ ឬជម្ងឺឆ្លងនោះទេ។ សូម្បីតែសត្វដំរីដែលមិនមានទម្លាប់ផឹកទឹកពីទុយោកៅស៊ូ ក៏ធាប់ក្លាយទៅជាអ្នកចូលចិត្តផឹកទឹកបែបនេះដែរ។

ប្រយ័ត្ន៖

ការអនុញ្ញាតិឲ្យសត្វដំរីផឹកដោយសេរីភ្លាមៗ បន្ទាប់ពីវាបានបំពេញការងារធ្ងន់ៗរួចហើយ អាចបណ្តាលឲ្យដំរីញាក់ ហើយសត្វខ្លះអាចរហូតដល់ស្លាប់ទៀតផង។

អ្នកគួរតែជ្រើសរើសយកប្រភពទឹកណាដែលស្អាត គឺគ្មានសារជាតុពុលនៅក្នុងប្រភពទឹកនោះ ឧទាហរណ៍ដូចជាមានការផលិតប្រេងនៅក្បែរនោះ ព្រោះសត្វដំរីប្រហែលជានឹងមិនផឹក ឬយកប្រមោយវាបូមទឹកនោះមកបាញ់លើខ្លួនវាទេ។

## អាហារ

ចំណីអាហារអាចមានផលប៉ះពាល់លើសុខភាពរបស់សត្វដំរី ដែលមិនគួរឲ្យជឿ។ អាហារូបត្ថម្ភត្រឹមត្រូវ គឺជាអា រសមស្រប ដែលយើងត្រូវផ្តល់ឲ្យសត្វដំរី និងក្នុងបរិមាណត្រឹមត្រូវ ដើម្បីធ្វើឲ្យដំរីមានសុខភាពល្អ ហើយធន់នឹងជម្ងឺ។ ប្រសិនបើពេទ្យសត្វពិនិត្យមើលឃើញថា សត្វដំរីទាំងអស់នៅក្នុងមជ្ឈមណ្ឌល ជាទូទៅស្ថិតនៅក្នុងស្ថានភាពមិនសូវល្អ ការសង្ស័យដំបូងចំពោះបុព្វហេតុនោះ គឺមិនមែនជាជម្ងឺទេ ប៉ុន្តែគឺវាអាចបណ្តាលមកពី ទីមួយអាហារមិនល្អ ឬទីពីរអាហារមិនគ្រប់គ្រាន់ ឬមួយអាហារមិនល្អ ហើយមិនគ្រប់គ្រាន់ទៀត គឺទាំងពីរតែម្តង។

បញ្ហាខាងចំណីអាហារត្រូវបានបែងចែកជាពីរផ្នែកធំៗ៖ ទី១ គឺទិដ្ឋភាពសេដ្ឋកិច្ច និងសង្គមរបស់ចំណីអាហារសព្វថ្ងៃនៅប្រទេសថៃ និងទី២ ការអនុវត្តជាក់ស្តែងលើចំណី

*អាហារ ដែលយើងអាចផលិតបាន ជាពិសេសចំណីអាហារដែលបានពីការដាំដុះៗ ផ្នែកទី ១ ដែលជាផ្នែកសង្គម និងសេដ្ឋកិច្ច យើងគួរតែយកចិត្តទុកដាក់ជាពិសេសចំពោះម្ចាស់ និងអ្នកគ្រប់គ្រងមជ្ឈមណ្ឌលដំរី និងអ្នកទទួលខុសត្រូវដែលមានការយកចិត្តទុកដាក់និង គួរយកចិត្តទុកដាក់ផងដែរចំពោះអ្នកស្រឡាញ់សត្វ អ្នកអភិរក្ស និងអ្នកវិទ្យាសាស្ត្រ។ ហ្វូងដំរីដែលមានការគិតគូរខ្ពស់អាច និងមជ្ឈមណ្ឌលទេសចរណ៍ប្រាកដជាអាចនឹងមើលដឹង ថាចំណីអាហារប្រភេទណាដែលត្រឹមត្រូវ និងបញ្ហាដែលពួកគេត្រូវប្រឈមៗ*

*ផ្នែកទី២ គឺជាទិដ្ឋភាពជាក់ស្តែងនៃចំណីអាហារ ដែលវាអាចមានផលប្រយោជន៍ ដល់ សត្វដំរីទាំងអស់ រួមទាំងហ្វូងដំរីដែលកំពុងបំពេញការងារនៅទីនោះ និងលើសពីនេះ ទៀតនៅមានអ្នកគ្រប់គ្រងមជ្ឈមណ្ឌលផងដែរ។*

*ផ្នែកទី៣ នឹងបរិយាយអំពីអាហារបំប៉នសម្រាប់ដំរីឈឺ និងក្រៅពីល័ក្ខខ័ណ្ឌរបស់ សត្វដំរីធម្មតា ដែលអាចកើតមាននៅគ្រប់ទីកន្លែង មិនថាជាមជ្ឈមណ្ឌលទេសចរណ៍ ឬជាបរិស្ថានធម្មជាតិទេ។*

## **ភក្តាសង្គមនិងសេដ្ឋកិច្ចនៃចំណីអាហារ**

*តាំងពីបុរាណកាលរហូតមកទល់ប្រហែលជាពី ២០ ទៅ ៣០ ឆ្នាំមុន ការចិញ្ចឹម សត្វដំរីមានលក្ខណៈតាមបែបធម្មជាតិស្ទើរតែទាំងស្រុង គឺប្រើតែចំណីអាហារ ដែលមាន នៅក្នុងព្រៃស្រាប់ៗ។ ចាប់តាំងពីពេលនោះមក ការហាមឃាត់កាប់ទន្ទ្រានព្រៃឈើនៅឆ្នាំ ១៩៨៩ បានបណ្តាលឲ្យបាត់បង់ការងារជាច្រើននៅក្នុងព្រៃ ហើយចំនួនការងារក៏មាន ការកើនឡើងជាលំដាប់នៅតាមមជ្ឈមណ្ឌលទេសចរណ៍ក្បែរទីក្រុង និងនៅឆ្ងាយពីតំបន់ ធម្មជាតិ។ នៅឆ្នាំ ២០០៤ អស់រយៈពេលស្ទើរពេញមួយឆ្នាំៗ សត្វដំរីស្រុកប្រហែលជាង ១០០០ ក្បាល ទទួលបានតែចំណីអាហារ ដែលបានមកពីការដាំដុះទេ។*

*ការបែងចែករវាងចំណីអាហារធម្មជាតិ និងចំណីអាហារដែលបានមកពីការដាំដុះ វាមិនដាច់ស្រឡះពីគ្នាទាំងស្រុងនោះទេ។ សត្វដំរីខ្លះធ្វើការនៅតំបន់ជាយក្រុង វាអាច ទទួលបានចំណីអាហារលាយគ្នា ទាំងចំណីអាហារដែលបានមកពីការដាំដុះ និងស្មៅធម្មជាតិ។ ដំរីខ្លះទៀតរស់នៅតាមតំបន់ជនបទអាចទទួលបានទាំងចំណីធម្មជាតិ និងអាហារ កសិកម្មផងដែរ។ លើសពីនេះទៀត មានសត្វដំរីខ្លះចំណាយពេលស្ទើរតែពេញមួយឆ្នាំៗ*

*នៅក្នុងមជ្ឈមណ្ឌលទេសចរណ៍ និងសល់ពីនេះគឺនៅផ្ទះ។ ប៉ុន្តែដោយសារតែចំណីអាហារធម្មជាតិកម្រ ហើយអាចមានគ្រោះថ្នាក់ ទើបគេត្រូវការចំណីអាហារដែលបានមកពីការដាំដុះច្រើន។ ម៉្យាងទៀត គឺដោយសារតែឧស្សាហកម្មទេសចរណ៍នៅតែមានការរីកចម្រើន ទើបសត្វដំរីជាច្រើនត្រូវស៊ីចំណីអាហារដែលបានមកពីការដាំដុះ។ ការពិភាក្សាអំពីអាហារ និងសុខភាពរបស់សត្វដំរីត្រូវតែរកវិធីដោះស្រាយបញ្ហា ដែលបណ្តាលមកពីការផ្លាស់ប្តូរនាពេលថ្មីៗនេះ។*

**អាហារធម្មជាតិ**

*អាហារធម្មជាតិជាអាហារល្អបំផុតសម្រាប់សត្វដំរី ព្រោះវាជាអ្វីដែលពួកវាបានស៊ីឆ្លងកាត់ការវិវត្តរាប់លានឆ្នាំមកហើយ។ សត្វដំរីព្រៃត្រូវស៊ីរុក្ខជាតិប្រមាណ ២០០ ប្រភេទក្នុងកំឡុងពេលមួយឆ្នាំៗ។ ប៉ុន្តែអាហារដែលពួកវាចូលចិត្តគឺស្មៅ និងឫស្សី (ដែលជាស្មៅមួយប្រភេទដែរ)។ សត្វដំរីក៏ស៊ីវល្លិ៍ ដូងព្រៃ ចេកព្រៃ រុក្ខជាតិផ្សេងៗ មានស្នឹក និងសំបកឈើខ្លះៗ មានទាំងរុក្ខជាតិ ដែលមនុស្សយកមកប្រើធ្វើជាឱសថទៀតផង។*

*អាហារធម្មជាតិមានគុណសម្បត្តិ ៣ យ៉ាង។ ទីមួយវាមានតម្លៃថោក ដែលជាធម្មតាយើងមិនបាច់ចំណាយប្រាក់ទេ ប៉ុន្តែពេលខ្លះក៏ត្រូវចំណាយលុយសម្ងាប់ថ្លៃឈ្នួលបន្តិចបន្តួចដែរ។ ទី២ នៅពេលដំរីស៊ីចំណីអាហារភាគច្រើន ដែលមាននៅក្នុងបរិស្ថានធម្មជាតិ ស្រាប់ ពួកវានឹងទទួលបាននូវសារជាតុចិញ្ចឹមពេញលេញល្អ។ ទីបីអាហារធម្មជាតិគ្មានជាតិគីមីពុលទេ ហើយអ្វីដែលសំខាន់បំផុតនោះ គឺក្នុងចំណីអាហារធម្មជាតិគ្មានជាតិថ្នាំសម្រាប់សម្លាប់សត្វល្អិត និងកាកសំណល់ជីគីមីទេ។*

*ទាំងនៅក្នុងសៀវភៅនេះ ឬនៅក្នុងសៀវភៅណាមួយ មិនមានបង្រៀនហ្មដំរីអំពីចំណីធម្មជាតិនោះទេ។ ហ្មដំរីដែលមានវ័យចាស់ៗ គឺជាអ្នកជំនាញខាងចំណីធម្មជាតិរបស់សត្វដំរី ជាអ្នកជំនាញខាងរុក្ខសាស្ត្រ ដែលអាចកំណត់អត្តសញ្ញាណស្មៅ និងរុក្ខជាតិរាប់រយប្រភេទផ្សេងៗទៀតយ៉ាងងាយស្រួល។ ហ្មដំរីវ័យក្មេងប្រហែលជាដឹងតិចតួចជាង ប៉ុន្តែគ្រូបង្រៀនរបស់ពួកគាត់ពិតប្រាកដនោះ គឺមិនមែនជាសៀវភៅទេ ប៉ុន្តែជាហ្មដំរីរៀមច្បងដែលមានវ័យចាស់ៗ។ គួរឲ្យស្តាយណាស់ ដែលចំណេះដឹងពីបុរាណរបស់ហ្ម*

*ដំរីស្ដីអំពីរុក្ខជាតិក្នុងព្រៃជាចំណីសម្រាប់សត្វដំរីប្រាកដជាត្រូវបាត់បង់ បើសិនជាគ្មានការចងក្រងជាឯកសារទុកក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ខាងមុខនេះទេ។*

## ចំណីដាំដុះនៅក្នុងមជ្ឈមណ្ឌលទេសចរណ៍

*ទោះយ៉ាងណាពេលវេលាបានផ្លាស់ប្ដូរ រួមជាមួយនឹងការមកដល់នៃទេសចរណ៍ទ្រង់ទ្រាយធំ សត្វដំរីកាន់តែត្រូវពឹងផ្អែកលើចំណីដែលដាំដុះដោយមនុស្ស។ អាហារដាំដុះភាគច្រើនតែងតែបង្កបញ្ហាសុខភាព ដែលមានទាក់ទងទៅនឹងការចម្លងរោគ ព្រមទាំងអាហារូបត្ថម្ភ ហើយបញ្ហាទាំងនេះនឹងត្រូវលើកយកមកពិភាក្សានៅទំព័រទី៣៤។*

*ចំណីដែលបានមកពីការដាំដុះ យើងត្រូវតែទិញ ហើយវាមានតម្លៃថ្លៃណាស់។ (សត្វដំរីត្រូវការចំណីច្រើនជារៀងរាល់ថ្ងៃ គិតជាមធ្យមប្រហែល ១០០ គីឡូក្រាមក្នុងមួយថ្ងៃៗ) ការចំណាយខ្ពស់បែបនេះ ច្រើនតែនាំឲ្យមានបញ្ហាផ្សេងៗ។ សត្វដំរីច្រើនតែទទួលបានចំណីមិនគ្រប់គ្រាន់ ឬចំណីដែលមានគុណភាពអន់ ឬមួយទាំងពីរតែម្ដង។ ពេលខ្លះសត្វដំរីទទួលបានចំណីអាហារតែមួយ ឬពីរប្រភេទគត់ ដែលបណ្ដាលឲ្យមានអតុល្យភាពអាហារូបត្ថម្ភ និងទីបំផុតនាំឲ្យមានបញ្ហាកង្វះអាហារូបត្ថម្ភ។ ឧទាហរណ៍ ក្នុងករណីជាច្រើនដើម្បីសន្សំប្រាក់លើចំណីដំរី នៅតំបន់កណ្ដាល ជាពិសេសនៅប៉ាតាយ៉ា សត្វដំរីភាគច្រើនគេឲ្យវាស៊ីតែផ្ទៃម្នាស់ និងចុងម្នាស់ដែលបោះចោល ព្រោះវាមានតម្លៃថោកជាងដើមអំពៅឆ្ងាយណាស់។*

## សេដ្ឋកិច្ចចំណីអាហារ

*ដំណើរការមជ្ឈមណ្ឌលទេសចរណ៍ពាណិជ្ជកម្ម គឺជាការប្រកួតប្រជែងខ្ពស់ សូម្បីតែអាជីវកម្មដែលមានប្រាក់ចំណូលទាប។ ចំណីដំរីគ្រាន់តែជាការចំណាយមួយរបស់ថវិការួមជាមួយប្រាក់ខែ យានយន្ត រត់ការ ជួលកន្លែង។ ល។ បញ្ហាមួយទៀត គឺដោយសារនៅក្នុងមជ្ឈមណ្ឌលដំរីសម្រាប់ទេសចរណ៍ភាគច្រើន មានដំរីយ៉ាងហោចណាស់ជាងដប់ក្បាលដែរ ចំណីរបស់វាជាទូទៅត្រូវបានគេទិញក្នុងបរិមាណច្រើន ហើយវាពិបាកក្នុងការបំពេញតម្រូវការរបស់ដំរីនីមួយៗ។ ជារៀងរាល់ឆ្នាំ ពេលវេលាដែលមានចំណីល្អ និងថោកប្រហែលជាមិនមានទេ។*

## ចំណីដំរី ម្ចាស់មជ្ឈមណ្ឌលដំរី និងអ្នកគ្រប់គ្រងមជ្ឈមណ្ឌលដំរី

ម្ចាស់មជ្ឈមណ្ឌលមួយចំនួនមានភាពសកម្មក្នុងការមើលថែរក្សាដំរី ជាពិសេសប្រសិនបើពួកគេជាម្ចាស់ដំរីផ្ទាល់។ ម្ចាស់មជ្ឈមណ្ឌលផ្សេងទៀតបានប្រគល់ការងារទាំងអស់ឲ្យទៅអ្នកគ្រប់គ្រងម្នាក់។ ប្រសិនបើអ្នកគ្រប់គ្រងនោះមានចំណេះដឹងអំពីអាហារដំរី និងស្មោះត្រង់ (គាត់តែងចំណាយលុយទាំងអស់ ដែលម្ចាស់បានផ្តល់ឲ្យគាត់ ដើម្បីទិញចំណីឲ្យដំរីទាំងអស់) នៅពេលនោះបើម្ចាស់មជ្ឈមណ្ឌលខកខានមិនបានចូលរួមការងារដោយផ្ទាល់ ក៏មិនមានបញ្ហាដែរ។ បើអ្នកគ្រប់គ្រងមិនស្មោះត្រង់ ឬបើគាត់មានចំណេះដឹងតិចតួចអំពីតម្រូវការរបស់សត្វដំរី អាចបណ្តាលឲ្យមានគ្រោះមហន្តរាយ ។

## ចំណីដំរី និងម្ចាស់កម្មសិទ្ធិ

សត្វដំរី នៅក្នុងមជ្ឈមណ្ឌលទេសចរណ៍ទាំងអស់មានបួនប្រភេទ៖

១. ម្ចាស់មជ្ឈមណ្ឌលជាម្ចាស់ដំរីផ្ទាល់។

២. ហ្មដំរី (ឬគ្រួសាររបស់គាត់) ជាម្ចាស់ដំរី។

៣. ម្ចាស់មជ្ឈមណ្ឌលជួលដំរីពីគេ ហើយម្ចាស់ដំរីជាអ្នកផ្តល់ហ្មដំរី។

៤. ម្ចាស់មជ្ឈមណ្ឌលជួលដំរីពីគេ ហើយថែមទាំងជួលហ្មដំរីដោយខ្លួនឯងទៀត។

ជារឿយៗគុណភាពចំណីដែលសត្វដំរីទទួលបាន វាអាស្រ័យទៅលើប្រភេទទំនាក់ទំនងខាងលើនេះ។ ម្ចាស់មជ្ឈមណ្ឌលជាម្ចាស់ដំរី និងហ្មដំរីជាម្ចាស់ដំរី តែងតែផ្តល់ចំណីអាហារល្អៗជានិច្ច ព្រោះវាជាការការពារថែរក្សាទ្រព្យសម្បត្តិដ៏មានតម្លៃរបស់ខ្លួន។ ដំរីដែលគេជួលមកឲ្យធ្វើការឲ្យគេអាចបញ្ចប់ទៅវិញ នៅក្នុងស្ថានភាពអកុសល ព្រោះថាម្ចាស់មជ្ឈមណ្ឌលមិនចង់ចាក់លុយចោល ដើម្បីចិញ្ចឹមបំប៉នដំរីរបស់អ្នកដទៃឡើយ។ ក្នុងករណីខ្លះទៀត ហ្មដំរីដែលម្ចាស់ដំរីជួល គ្រាន់តែជាអ្នកធ្វើការឲ្យគេ ដើម្បីទទួលបានប្រាក់ខែ (និងប្រាក់ធីប) ហើយម្ចាស់មជ្ឈមណ្ឌលគឺជាអ្នកមានកាតព្វកិច្ចផ្គត់ផ្គង់ចំណីដល់សត្វដំរី។ ប្រសិនបើគាត់ផ្តល់ចំណីមិនល្អនោះទេ វាអាចបង្កឲ្យមានភាពតានតឹងខ្លាំងរវាងម្ចាស់មជ្ឈមណ្ឌល និងហ្មដំរី ដែលជាម្ចាស់ដំរី និងហ្មដំរីដែលទទួលខុសត្រូវមើលថែទាំដំរីឲ្យបៅកែរបស់ខ្លួន។

**ចំណីដំរី និងហ្មដំរី**

*នៅក្នុងមជ្ឈមណ្ឌលទេសចរណ៍ស្ទើរតែទាំងអស់ ហ្មដំរីមិនសូវត្រួតពិនិត្យចំណីដំរីរបស់ពួកគេទេ។ ម្ចាស់មជ្ឈមណ្ឌលជាអ្នកជ្រើសរើសចំណីឲ្យដំរី ប៉ុន្តែកាតព្វកិច្ចរបស់ហ្មដំរីគឺត្រូវធានាថាដំរីរបស់ខ្លួនទទួលបានរបបចំណីត្រឹមត្រូវដែរឬទេ ហើយហ្មដំរីក៏ត្រូវនៅទីនោះ ដើម្បីផ្តល់ចំណីនោះឲ្យវា។ ហ្មដំរីដែលមានមនសិការខ្ពស់នឹងមើលថែទាំងដំរីរបស់ខ្លួន ដោយផ្តល់ឲ្យដំរីនូវស្មៅធម្មជាតិឲ្យបានច្រើនតាមតែអាចធ្វើទៅបាន គឺថាគាត់ត្រូវច្រូតស្មៅយកទៅឲ្យដំរី ឬនាំយកដំរីនោះទៅឲ្យស៊ីស្មៅ។ ហ្មដំរីភាគច្រើនតែងខ្ជិលថែរក្សាសត្វដំរីណាដែលមិនមែនជាកម្មសិទ្ធិរបស់ខ្លួន ឬក៏គាត់អាចមានការធ្វេសប្រហែសលើសពីនេះថែមទៀតផង។*

**ការសន្និដ្ឋាន**

*ស្ថានភាពចំណីដំរីនៅក្នុងមជ្ឈមណ្ឌលនីមួយៗ តែងមានភាពស្មុគស្មាញណាស់។ សត្វដំរីក្នុងមជ្ឈមណ្ឌលអាចទទួលបានចំណីត្រឹមត្រូវល្អ គឺវាអាស្រ័យទៅលើមនសិការរបស់ម្ចាស់មជ្ឈមណ្ឌល អ្នកគ្រប់គ្រង និងហ្មដំរី។ បើមានចំណុចខ្សោយត្រង់កន្លែងណាមួយនៅក្នុងខ្សែសង្វាក់នេះ វាប្រាកដជាពុំមានផលល្អសម្រាប់សត្វដំរីឡើយ។ ទោះបីម្ចាស់មជ្ឈមណ្ឌល អ្នកគ្រប់គ្រង និងហ្មដំរីសុទ្ធតែមានចេតនាល្អក៏ដោយ ក៏មជ្ឈមណ្ឌលត្រូវតែរកប្រាក់ចំណេញឲ្យបានគ្រប់គ្រាន់ ទើបម្ចាស់មជ្ឈមណ្ឌលមានថវិកាគ្រប់គ្រាន់ ដើម្បីទិញចំណីល្អៗឲ្យសត្វដំរីទាំងនោះ ។*

*សម្រាប់អ្នកដែលមានការព្រួយបារម្ភអំពីសុខភាពរបស់សត្វដំរី ដោយបញ្ហាមួយចំនួនដូចជាចំណីអាហារមិនល្អ ឬចំណីអាហារមិនគ្រប់គ្រាន់នៅក្នុងមជ្ឈមណ្ឌល នោះគឺជាបញ្ហាដែលគួរឲ្យធុញទ្រាន់ណាស់ ជាពិសេសពីព្រោះវាពិបាកក្នុងការដោះស្រាយ។ គេត្រូវបង្ខំឲ្យពេទ្យសត្វព្យាបាលករណីជម្ងឺ ដែលមិនធ្លាប់មានតាំងពីមុនមក។ ដោយសារតែមជ្ឈមណ្ឌលទេសចរណ៍ គឺជាអាជីវកម្មឯកជន ទើបអង្គការក្រៅរដ្ឋាភិបាល និងមន្ត្រីរាជការមិនសូវមានអំណាចក្នុងការអនុវត្តការកែលម្អ ឬបង្ខំឲ្យធ្វើការផ្លាស់ប្តូរ។ នៅទីបញ្ចប់អ្វីដែលគេអាចនិយាយបាននោះ គឺថាវាជាបញ្ហាពុំរ៉ៃ ហើយយើងត្រូវការយកចិត្តទុកដាក់ឲ្យបានច្រើននាពេលអនាគត។*

## អាហារដែលបានមកពីការដាំដុះ និង្គភាពជាក់ស្តែង

*បើប្រៀបធៀបជាមួយនឹងចំណីអាហារធម្មជាតិ អាហារដែលបានមកពីការដាំដុះ ភាគច្រើនកម្រិតអាហារូបត្ថម្ភខ្ពស់ ប៉ុន្តែចំណីអាហារដែលបានមកពីដាំដុះប្រភេទនេះក៏មានគុណវិបត្តិជាច្រើនផងដែរ។ ទីមួយ ចំពោះចំណីអាហារដែលបានមកពីការដាំដុះ គឺយើងត្រូវតែទិញ ហើយភាគច្រើនវាមានតម្លៃថ្លៃ។ ទីពីរ ចំណីអាហារដែលបានមកពីការដាំដុះច្រើនតែមានផ្ទុកសារជាតុគីមី ដែលផលិតដោយមនុស្ស ភាគច្រើនជាថ្នាំសម្លាប់សត្វល្អិត និងថ្នាំសម្លាប់ស្មៅ ដែលមានជាតិពុលខ្ពស់ដល់សត្វដំរី។ ទីបី នៅក្នុងស្ថានភាពជាច្រើន ជាពិសេសមជ្ឈមណ្ឌលទេសចរណ៍ ដែលមានសត្វដំរីចិញ្ចឹមយ៉ាងច្រើន ជាមួយនឹងចំណីអាហារដែលបានមកពីការដាំដុះ សត្វដំរីទាំងនោះនឹងទទួលបានចំណីអាហារមិនគ្រប់គ្រាន់ អាហារដែលមានគុណភាពអន់ ឬទទួលបានចំណីអាហារតែមួយ ឬពីរប្រភេទតែប៉ុណ្ណោះ។ អាហារគ្មានតុល្យភាពអាចនាំឲ្យប៉ះពាល់ដល់អាហារូបត្ថម្ភយ៉ាងខ្លាំងហើយទីបំផុតសត្វដំរីទាំងនោះមានបញ្ហាខ្វះអាហារូបត្ថម្ភ។ ឧទាហរណ៍ចំពោះសត្វដំរីជាច្រើននៅកូកេត ឬប៉ាតាយ៉ា ដែលគេឲ្យពួកវាស៊ីតែដើមចេក និងម្នាស់ច្រើនពេក។*

## ស្មៅ

*ស្មៅស្រស់ដែលបានមកពីការដាំដុះមានឱជារសត្រូវមាត់សត្វដំរី ហើយមានច្រើនប្រភេទ។ ជាទូទៅស្មៅដែលគេឲ្យសត្វដំរីស៊ី គឺដូចគ្នានឹងស្មៅ ដែលគេឲ្យទៅសត្វផ្សេងៗទៀតដែរ មានដូចជាស្មៅបាណា* (Bana Grass៖ *ស្រដៀងដើមអំពៅ*) *ស្មៅប៉ាងហ្គោឡា* (Pangola grass ៖*ជាដើមស្មៅទាបៗមានដុះនៅតាមតំបន់ដីសើមក្នុងតំបន់ត្រូពិច*) *ស្មៅដំរី* (Napier grass៖ *ដូចដើមត្រែងដែរ តែស្ទឹកធំៗជាង*) *ស្មៅហ្គីណេ* (Guinea grass៖ *ដើមត្រែង*) *និងស្មៅរ៉ូហ្ស៊ី* (Ruzi grass៖*ស្រដៀងស្មៅបារាំង* )។ (*សូមមើលឧបសម្ព័ន្ធ* XXXX AND FFF*សម្រាប់ឈ្មោះស្មៅជាភា ថៃ និងពាក្យវិទ្យាសាស្ត្រ។* ) *ស្មៅប្រភេទទាំងនេះមានច្រើនណាស់។ នៅមានស្មៅជាច្រើនប្រភេទទៀត ដែលមានកម្រិតអាហារូបត្ថម្ភមិនដូចគ្នាទាំងអស់ទេ ប៉ុន្តែយើងនៅតែអាចទទួលយកបាន។ ក្រៅពីនេះនៅមានស្មៅផ្សេងទៀត ដែលហ្មដំរីអាចទៅរកបាននៅក្នុងធម្មជាតិ ឬក៏ហ្មដំរីអាចនាំដំរីយកទៅឲ្យស៊ីស្មៅដោយផ្ទាល់ក៏បាន។ នៅមានស្មៅជាច្រើនទៀតលើសពីប្រភេទស្មៅដែលបានរៀបរាប់*

ខាងលើ ត្រូវបានគេយកមកធ្វើជាចំណីសម្រាប់ចិញ្ចឹមដំរីនៅប្រទេសថៃ។ ហ្មដំរីគួរតែចេះសង្កេតមើលថាតើស្មៅប្រភេទមួយណា ដែលដំរីរបស់ខ្លួនចូលចិត្ត និងស្មៅប្រភេទមួយណាដែលវាមិនចូលចិត្ត។

អ្វីដែលសំខាន់ គឺមិនត្រូវចិញ្ចឹមដំរីដោយប្រើស្មៅជាចំណីតែមួយប្រភេទនោះទេ ព្រោះវាមិនត្រឹមតែធ្វើឲ្យសត្វដំរីស៊ីមិនបានឆ្អែតល្អប៉ុណ្ណោះទេ ប៉ុន្តែការស៊ីស្មៅតែមួយប្រភេទគត់ជាចំណីអាហារ វាអាចបណ្តាលឲ្យសត្វដំរីខ្វះអាហារូបត្ថម្ភ ដោយសារតែខ្វះសមាសធាតុអាហារសំខាន់ៗនៅក្នុងចំណីអាហាររបស់វា។

**អ្នកគ្រប់គ្រងមជ្ឈមណ្ឌលត្រូវតែប្រុងប្រយ័ត្ន៖** អ្នកគួរតែប្រុងប្រយ័ត្នប្រសិនបើអ្នកទិញស្មៅ ដែលមានពីប្រភពមកពីខាងក្រៅ។ ហ្មដំរីដែលមានបទពិសោធន៍ខ្ពស់ត្រូវត្រួតពិនិត្យមើលថា តើចំណីដំរីដែលគេយកមកផ្គត់ផ្គង់ឲ្យ ស្រស់ល្អដែរដែរឬទេ ហើយមានប្រឡាក់ដីដែរឬទេ។ល។ ការត្រួតពិនិត្យរកមើលថ្នាំសម្លាប់ស្មៅ និងថ្នាំសម្លាប់សត្វល្អិតដែលអាចមាននៅលើចំណីដំរី ពិតជាលំបាកខ្លាំងណាស់ ដូចនេះយើងគួរតែសួរដេញដោលទៅអ្នកផ្គត់ផ្គង់ចំណីអាហារទាំងនោះឲ្យយើងដោយផ្ទាល់។ ពេទ្យសត្វជាច្រើនយល់ថា មានដីប្រភេទខ្លះអាចបង្កជម្ងឺដល់សត្វដំរីហូតដល់ស្លាប់។ ដូច្នេះអ្នកត្រូវតែបញ្ជាក់ឲ្យច្បាស់ថាស្មៅជាចំណីអាហារទាំងអស់នោះបានមកពីដីដែលគ្មានជាតិពុល។

## អនុសាសន៍

ចំពោះស្មៅដែលបានមកពីរការដាំដុះ មិនថាអ្នកបានដាំដុះដោយខ្លួនឯង ឬទិញពីអ្នកផ្សេងទេ អ្នកគួរតែត្រួតពិនិត្យស្មៅទាំងអស់យ៉ាងយកចិត្តទុកដាក់ ដើម្បីឲ្យប្រាកដថាស្មៅនោះមិនខ្ចីពេក ឬចាស់ពេកទេ ព្រោះវាអាចនាំឲ្យមានជម្ងឺរាក ឬទល់លាមក។ (សូមមើលទំព័រ ១៦៧)។

មិនគួររក្សាស្មៅទុកយូរឲ្យលើសពីមួយសប្តាហ៍ទេ។

**ស្មៅស្ងួត** ដែលគេយកមកធ្វើជាចំណីរបស់សត្វដំរីចិញ្ចឹម នៅក្នុងប្រទេសថៃច្រើនជាប្រភេទស្មៅប៉ាងហ្គោឡា (Pangola grass៖ ជាដើមស្មៅទាបៗ មានដុះច្រើននៅតាមតំបន់ដីសើមក្នុងតំបន់ត្រូពិច) ឬប្រភេទស្មៅកាវ៉ាល់កាដ (Cavalcade grass)។ ស្មៅស្ងួត គេអាចរក្សាទុកបានយូរ និងងាយស្រួលក្នុងការដឹកជញ្ជូន។ ស្មៅស្ងួតមានលក្ខណៈសម

ស្របសម្រាប់សត្វដំរីកំពុងឡើងកពេញកម្លាំង ពីព្រោះវាមានជាតិសរសៃខ្ពស់ ប៉ុន្តែវាមានកម្រិតអាហារូបត្ថម្ភទាប។ (សត្វដំរីចូលចិត្តស៊ីចំណីប្រភេទនេះណាស់ ដែលធ្វើឲ្យគេជឿថា ចំណីនេះនឹងបណ្តាលអោយសត្វដំរីស្ថិតនៅក្នុងភាពឡើងក ចុះប្រេងអស់រយៈពេលយូរ ប៉ុន្តែតាមកាពិតជាចំណីដែលគ្មានកាឡូរីខ្ពស់ទេ។ មានហ្មដំរីខ្លះបានប្រោះទឹកអំបិលបន្ថែម ដើម្បីធ្វើឲ្យស្មៅស្ងួតនោះកាន់តែមានឱជារស។

ប្រយ័ត្ន៖ ស្មៅស្ងួតដែលនៅរាយប៉ាយច្រើន ងាយស្រួលដល់សត្វដំរីយកប្រមោយវាប្រមូលចំណីទាំងនោះ ប៉ុន្តែពួកវាក៏ចូលចិត្តយកស្មៅទាំងនោះគប់បាចបោះលេងទៅលើខ្លួនវាដែរ។ ដូច្នេះយើងគួរតែដាក់ចំណីជាស្មៅស្ងួតនោះម្តងបន្តិចៗបានហើយ នៅពេលដែលសត្វដំរីស៊ីអស់ ចាំយើងបន្ថែមទៀត ដើម្បីកុំឲ្យខ្ជះខ្ជាយស្មៅ។

**ស្លឹកនិងធាងដូង** គឺជាអាហារដ៏ល្អសម្រាប់សត្វដំរី ដែលធ្វើឲ្យវាមានសុខភាពល្អចាប់តាំងពីនៅតូចរហូតដល់ដំរីពេញវ័យ។ ស្លឹកនិងធាងដូង គេអាចរកបានយ៉ាងងាយស្រួលនៅទូទាំងប្រទេស ហើយមានគុណប្រយោជន៍ដ៏ធំធេង ដោយសារវាគ្មានសារជាតុគីមីនៅក្នុងនោះទេ។

ប្រយ័ត្ន៖ មុនពេលដាក់ស្លឹកនិងធាងដូង យើងត្រូវកាត់វាឲ្យខ្លីៗ ប្រវែងប្រហែលមួយហត្ថ។ បើមិនដូច្នោះទេដំរីនឹងមានបញ្ហាទល់លាមក។

**ដើមចេក** សត្វដំរីចូលចិត្តដើមចេកណាស់ នៅពេលវាឡើងខ្លួនពេញវ័យ និងនៅពេលដែលគេទុកវានៅកន្លែងមិនសូវសម្បូរទឹក ឬកន្លែងដែលមានអាកាសធាតុក្តៅ។ ដើមចេកមានបរិមាណទឹក និងជាតិសរសៃខ្ពស់ ប៉ុន្តែអាហារូបត្ថម្ភមានកម្រិតទាប។ ដើមចេកល្អនៅពេលយើងត្រូវដឹកជញ្ជូនសត្វដំរីពីកន្លែងមួយ ទៅកន្លែងមួយផ្សេងទៀត ពីព្រោះវាអាចផ្គត់ផ្គង់ទឹកដែលដំរីត្រូវការបានច្រើន ហើយដំរីក៏ចូលចិត្តស៊ី និងទំពារដើមចេកណាស់។ យើងអាចដាក់គល់ចេកក្នុងកញ្ចប់ ដែលមានភាពងាយស្រួលសម្អាត និងស្រួលលើកដាក់ជាងធុងទឹកនិងស្មៅ។

ប្រយ័ត្ន៖ បើដំរីស៊ីដើមចេកច្រើនពេកអាចបណ្តាលឲ្យវាហើមពោះ។

ត្រូវកាត់ដើមចេកជាកង់ៗខ្លីៗប្រវែងប្រហែលមួយហត្ថ ពីព្រោះបើវែងពេក វាអាចធ្វើឲ្យស្ទះពោះវៀនដំរី។

## **បន្លែនិងផ្លែឈើ**

*បន្លែនិងផ្លែឈើត្រូវបានផ្តល់ជាអាហារធម្មតាដល់សត្វដំរី ដែលធ្វើការនៅកន្លែងទេសចរណ៍ក្នុង ឬក្បែរតំបន់កសិពាណិជ្ជកម្ម។ ផ្លែឈើនិងបន្លែ គឺជាអាហារបំប៉នដ៏ល្អប្រសើរ ប៉ុន្តែយើងមិនគួរយកវាធ្វើជាចំណីអាហារជាមូលដ្ឋានទេ ពីព្រោះនៅក្នុងបន្លែនិងផ្លែឈើភាគច្រើន មិនសូវមានសារធាតុចិញ្ចឹមដែលដំរីត្រូវការនោះទេ។*

*ជាទូទៅនៅតាមមជ្ឈមណ្ឌលទេសចរណ៍ បញ្ហាដែលជួបប្រទះញឹកញាប់ជាងគេ គឺចំពោះផ្លែឈើ និងបន្លែ (ក្រៅពីអំពៅនិងចេក) ដែលគេដាំដុះសម្រាប់តែតម្រូវការរបស់មនុស្ស ហើយភាគច្រើនគេទិញវានៅពេលវាមានតម្លៃថោក ពីព្រោះគេមិនអាចយកវាទៅដាក់លក់នៅលើទីផ្សារបាន ដូនកាលវាចាស់ពេក ឬទុំពេក ឬខ្ចីពេក។ល។ ដូច្នេះយើងត្រូវយកចិត្តទុកដាក់ឲ្យមែនទែន នៅពេលទិញផ្លែឈើ និងបន្លែយកមកធ្វើជាចំណីឲ្យដំរី។*

*បញ្ហាមួយទៀតគឺផ្លែឈើ និងបន្លែភាគច្រើនសុទ្ធតែមានប្រើថ្នាំពុលគីមីកសិកម្ម (ថ្នាំសម្លាប់ស្មៅ ជីគីមី។ល។*

**អំពៅនិងចេក** *នេះគឺជាប្រភេទចំណីអាហារច្រើនជាងគេ ដែលគេតែងដាក់លក់ឲ្យ ឬក៏ផ្តល់ទៅឲ្យភ្ញៀវទេសចរ ដើម្បីយកទៅឲ្យសត្វដំរីស៊ី។ នេះគឺមកពីភ្ញៀវអ្នកទេសចរភាគច្រើនតែងចង់ឲ្យតែអំពៅ និងចេកទៅសត្វដំរី ពីព្រោះដោយសារតែវាងាយស្រួលរក្សាទុក និងមិនប្រឡាក់ដៃ ហើយងាយស្រួលកាន់ទុកនៅក្នុងដៃទៀតផង។ ប៉ុន្តែទាំងអំពៅ និងចេកសុទ្ធតែជាចំណី ដែលមានកម្រិតអាហារូបត្ថម្ភខ្ពស់ណាស់ គឺអាចចាត់ទុកជាអាហារដែលមានថាមពលខ្ពស់។*

**ម្នាស់** *មានបរិមាណជាតិស្ករខ្ពស់ណាស់។ ដំរីអាចស៊ីរុក្ខជាតិម្នាស់គ្រប់ផ្នែកទាំងអស់បាន។ ម្នាស់ល្អណាស់សម្រាប់សត្វដំរី និងជាពិសេសនៅពេលដំរីមានការហត់នឿយពីការងារ។*

*ប្រយ័ត្នះ*

*ប្រសិនបើអ្នកអោយសត្វដំរីស៊ីម្នាស់ច្រើនពេក ឬអោយវាស៊ីញឹកញាប់ពេក ម្នាស់អាចបណ្តាលសត្វដំរីអោយមានជម្ងឺរាក និងឈឺមាត់។*

ការស៊ីម្នាស់ជាចំណីច្រើនពេកធ្វើឲ្យសត្វដំរីមើលទៅហាក់ដូចជាធាត់ និងរឹងមាំ ប៉ុន្តែតាមការពិតពួកវាមានកម្លាំងតិចតួចដោយសារតែបរិមាណស្ករខ្ពស់។

អ្នកគ្រប់គ្រងមជ្ឈមណ្ឌលគួរបន្ថែមចំណីផ្សេងទៀតពីលើផ្លែម្នាស់។

**ត្រសក់និងឪឡឹក** ពេលខ្លះក៏គេយកវាមកឲ្យសត្វដំរីស៊ីជាចំណីដែរ នៅពេលសត្វដំរីកំពុងពេញកម្លាំង និងជាពិសេសសត្វដំរីនៅតាមទីក្រុង។

ប្រយ័ត្ន៖ ត្រសក់និងឪឡឹកជាអាហារល្អ ប៉ុន្តែវាក៏អាចបង្កឲ្យមានបញ្ហាដែរ គឺនៅពេលវាមានភាពកខ្វក់ ដែលហ្មដំរីទាំងអស់ត្រូវដឹង។ ត្រូវយកផ្លែត្រសក់ និងឪឡឹកទៅត្រាំទឹកស្អាត និងមានជាតិប៉ូតាស្យូមពែម៉ង់ហ្គាណាតរយៈពេល ១៥-២០ នាទីមុនឲ្យស៊ី។

**ផ្លែឈើនិងបន្លែផ្សេងទៀត** ពេលខ្លះក៏គេយមមកធ្វើជាចំណីដំរីដែរ មានដូចជាផ្លែក្រូចការ៉ុត ល្ហុង សាឡាត់ ស្ពៃក្តោបជាដើម។ ទាំងនេះមិនមែនជាអាហារចំបងសម្រាប់សត្វដំរីទេ ព្រោះវាមានតម្លៃថ្លៃណាស់ ហើយអាចមានជាតិគីមីពុលទៀតផង។ ហ្មដំរីត្រូវឲ្យសត្វដំរីស៊ីចំណីប្រភេទនេះតែបន្តិចបន្តួច ហើយបន្ទាប់មកត្រូវរង់ចាំពី៦ ទៅ១២ម៉ោង ទើបឲ្យវាស៊ីម្តងទៀត។ ប្រសិនបើសង្កេតឃើញថាគ្មានផលប៉ះពាល់អ្វីមិនល្អដល់សត្វដំរីនោះទេ យើងអាចឲ្យបន្ថែមកាន់តែច្រើនទៀតបាន។

ប្រយ័ត្ន៖ ផ្លែឈើនិងបន្លែគួរតែយកទៅត្រាំក្នុងទឹកស្អាត និងមានជាតិប៉ូតាស្យូមពែម៉ង់ហ្គាណាតក្នុងរយៈពេលពី១៥ ទៅ២០នាទី មុនពេលយើងយកផ្លែឈើ និងបន្លែទាំងនោះទៅឲ្យសត្វដំរីស៊ី។

**ប៉ូតាស្យូមពែម៉ង់ហ្គាណាត** ( Potassium permanganate )

តាស្យូមពែម៉ង់ហ្គាណាត គឺជាសារធាតុគីមី ដែលមាននៅក្នុងគ្រាប់ធញ្ញជាតិ មានពណ៌ស្វាយងងឹតហើយងាយរលាយក្នុងទឹក។ វាមានប្រសិទ្ធភាពក្នុងការសម្លាប់មេរោគមួយចំនួន។ ដាក់វាបន្តិចឲ្យរលាយក្នុងទឹកស្អាតរហូតទាល់តែទឹកប្រែជាពណ៌ផ្កាឈូក។ ប្រើសម្រាប់លាងបន្លែ និងផ្លែឈើហើយក៏សម្រាប់សម្អាតមុខរបួសផងដែរ។ យើងអាចទិញវានៅក្នុងឱសថស្ថានណាមួយ។ ប៉ូតាស្យូមពែម៉ង់ហ្គាណាតមានតម្លៃថោក និងងាយស្រួលក្នុងទុកដាក់ទៀតផង។

## អាហារបំប៉ន

*អាហារបំប៉នគឺជាអាហារ និងសារធាតុ ដែលជាធម្មតាសម្រាប់ផ្តល់ឲ្យសត្វដំរីណា ដែលមានស្ថានភាពមិនសូវល្អ ដូចជានៅពេលដំរីមានជម្ងឺ និងនៅពេលវាចូលវ័យចាស់ជរា ឬនៅពេលវាធ្វើការងារធ្ងន់ហួសកម្លាំង ខ្វះអាហារូបត្ថម្ភជាដើម។ អាហារបំប៉នទាំងនោះអាចចែកចេញជាពីរក្រុម៖ អាហារថាមពលខ្ពស់ និងអាហារប៉ូវកម្លាំង។*

## អាហារដែលមានថាមពលខ្ពស់

*អាហារដែលមានថាមពលខ្ពស់ គេមិនសូវផ្តល់ឲ្យដំរីណាដែលមានសុខភាពល្អទេ ហើយវាក៏មិនមែនជាអាហារចំបងដែរ ដោយសារតែ ទីមួយវាមានតម្លៃថ្លៃ និងម្យ៉ាងទៀត បើសិនជាសត្វដំរីស៊ីចំណីអារហារប្រភេទនេះច្រើន វានឹងមានការពិបាកក្នុងការរំលាយអាហារណាស់។ វាមានកម្រិតសារជាតុចិញ្ចឹមទាបបំផុត ប៉ុន្តែទោះជាឲ្យសត្វដំរីស៊ីចំណីអាហារប្រភេទនេះបានតិចតួចក៏ដោយ ក៏អាហារទាំងនេះនៅតែល្អសម្រាប់ដំរី ដែលមានជម្ងឺ ដំរីដែលធ្វើការហួសកម្លាំង និងដំរីចាស់ៗជាដើម ហេតុផលគឺថាអាហារទាំងអស់នេះមានជាតិកាបូនអ៊ីដ្រាត និងកាឡូរីខ្ពស់ ហើយចំណីអាហារខ្វះទៀតក៏មានជាតិប្រូតេអ៊ីនល្អៗសម្រាប់សត្វដំរីផងដែរ។*

*ស្រូវមានកម្រិតអាហារូបត្ថម្ភខ្ពស់ណាស់ ហើយវាក៏សមស្របល្អណាស់សម្រាប់សត្វដំរីនៅពេលខំប្រឹងធ្វើការ និងសម្រាប់បំប៉នដំរីដែលមានទម្ងន់មិនគ្រប់គ្រាន់ ដោយសារការខ្វះខាតចំណីអារហារ។*

*មួយលើកៗមិនត្រូវឲ្យសត្វដំរីស៊ីចំណីប្រភេទនេះលើសពីប្រាំគីឡូក្រាមទេ ពីព្រោះវាអាចឲ្យដំរីពិបាកក្នុងការរំលាយអាហារ។*

*ប្រយ័ត្ន៖ កុំផ្តល់ចំណីអាហារជាស្រូវឲ្យសត្វដំរីស៊ីភ្លាមៗ បន្ទាប់ពីបញ្ចប់ការងារ ព្រោះដំរីអាចនឹងស៊ីយ៉ាងលឿន ហើយស្រូវនោះអាចនឹងធ្លាក់ជាប់នៅក្នុងបំពង់ករបស់វា។*

*មិនត្រូវឲ្យដំរីចាស់ៗស៊ីស្រូវទេ។*

**ពោតស្រស់** *គឺជាអាហារដ៏ល្អសម្រាប់ដំរីជាពិសេសសម្រាប់ដំរីឈឺ ដំរីទើបនឹងជាពីជម្ងឺ ដំរីចាស់ៗ និងដំរីញីដែលកំពុងមានកូនបៅដោះជាដើម ព្រោះពោតស្រស់មានកម្រិតអាហារូបត្ថម្ភខ្ពស់ណាស់។*

*ប្រយ័ត្នៈ ពោតគឺជាដំណាំមួយ ដែលជារឿយៗគេបានប្រើសារជាតិគីមីជាថ្នាំពុលកសិកម្មច្រើន ដូចជាផ្លែត្រសក់ និងផ្លែឪឡឹកដែរ។ ដូច្នេះហ្មដំរី និងអ្នកគ្រប់គ្រងត្រូវតែចាត់វិធានការឲ្យបានហ្មត់ចត់ល្អ ដូចជាត្រូវធ្វើការជ្រើសរើសពោតពីប្រភពណា ដែលគួរឲ្យទុកចិត្តបាន និងត្រូវយកពោតនោះទៅត្រាំទឹកស្អាត និងមានជាតិប៉ូតាស្យូមពែម៉ង់ហ្គាណាតមុនពេលឲ្យដំរីស៊ី។*

**អាហារគ្រាប់ៗ** *សម្រាប់សត្វដំរី តែកាលពីសម័យមុន វាគឺជារូបមន្តចំណីអាហារមួយប្រភេទ ដែលគេបានបង្កើតឡើងសម្រាប់សត្វសេះ។ ប៉ុន្តែឥឡូវនេះក្រុមហ៊ុនផលិតចំណីចំណីអាហារសត្វខ្លះ កំពុងលាយថែមបញ្ចូលគ្នាសម្រាប់សត្វដំរី។ ជាធម្មតាចំណីអាហារមានកម្រិតអាហារូបត្ថម្ភខ្ពស់ ដូច្នេះវាសមស្របសម្រាប់សត្វដំរី ដែលមានការហាត់នឿយនិងធ្វើការហួសកម្លាំង។ អាហារគ្រាប់ៗមិនទាន់បានក្លាយជាអាហារ ដែលគេពេញនិយមនៅឡើយទេ ព្រោះវាមានតម្លៃខ្ពស់ បើប្រៀបធៀបជាមួយនឹងចំណីដទៃទៀត។*

**ចេក** *នៅពេលសត្វដំរីស៊ីចេកទុំ ក្រពះរបស់វាមានការងាយស្រួលក្នុងការរំលាយណាស់ ហើយចេកក៏មានកម្រិតអាហារូបត្ថម្ភខ្ពស់ ដូច្នេះវាសមស្របល្អសម្រាប់ដំរីឈឺ កូនដំរី ដំរីផើម ដំរីដែលធ្វើការងារធ្ងន់ៗ និងដំរីចាស់ៗ។*

*ប្រយ័ត្នៈ បើឲ្យដំរីស៊ីចេកច្រើនពេក បណ្តាលឲ្យមានក្លិនស្អុយ និងលាមករាវៗ។*

**អំពៅ** *មានកម្រិតអាហារូបត្ថម្ភខ្ពស់ណាស់ ដូច្នេះវាសមស្របល្អសម្រាប់សត្វដំរីដែលកំពុងធ្វើការលំបាកៗ និងសម្រាប់មេដំរី ដែលកំពុងបំបៅកូន។ មិនគួរឲ្យដំរីចាស់ស៊ីអំពៅទេ ព្រោះវាអាចបណ្តាលឲ្យបែកធ្មេញ ឬរហូតដល់ថ្នាក់ជ្រុះមកក្រៅទៀតក៏មានដែរ។*

*ប្រយ័ត្នៈ ប្រសិនបើដំរីស៊ីអំបៅជាចំណីអាហារច្រើនពេក ឬស៊ីញឹកញាប់ពេក ដើមអំពៅអាចបណ្តាលឲ្យដំរីឈឺមាត់ ឬក៏មានដំបៅក្នុងមាត់ថែមទៀត។*

## អាហារប៉ូវកម្លាំង

*អាហារប៉ូវកម្លាំងមានបរិមាណសារជាតុមួយចំនួនតិចតួច ក្នុងគោលបំណងដើម្បីបង្កើនឲ្យមានប្រសិទ្ធិភាពពិសេសណាមួយ ដូចជានៅពេលគេចង់ប្រើថ្នាំ ដើម្បីធ្វើការព្យាបាលជម្ងឺអ្វីមួយ ដូចជាការសម្អាតពោះវៀន ធ្វើឲ្យសត្វដំរីស្រេកទឹក ឬធ្វើឲ្យវាឃ្លានចង់ស៊ីចំណីអាហារជាដើម។*

បាយដំណើបមិនមែនជាអាហារប៉ូវកំលាំងទេ ប៉ុន្តែគេតែងប្រើវាជាញីកញាប់ដើម្បីបញ្ច្រកថ្នាំដំរី ឬសម្រាប់លាយបញ្ច្រកអាហារបំប៉នផ្សេងៗទៀត។ មួយលើកឲ្យតែពីមួយទៅប្រាំគីឡូក្រាមបានហើយ។

**ប្រយ័ត្ន៖** អ្នកមិនគួរឲ្យសត្វដំរីស៊ីបាយដំណើប ដែលមិនសូវឆ្អិនល្អទេ។ មិនត្រូវឲ្យសត្វដំរីស៊ីអង្ករទេ ព្រោះវាអាចធ្វើឲ្យដំរីមានជម្ងឺទល់លាមក ពេលខ្លះអាចធ្វើឲ្យដំរីស្លាប់ទៀតក៏មានដែរ។

**អំពិលទុំ** គឺអាយជួសម្រួលអារម្មណ៍ និងមានចំណង់អាហារ។ វាធ្វើឲ្យដំរីកាន់តែខ្លាំងហើយសមស្របល្អណាស់សម្រាប់ដំរី ដែលមានការហត់នឿយខ្លាំង បន្ទាប់ពីបានធ្វើការងារធ្ងន់ៗ។ ជាធម្មតាវាត្រូវដាក់អំបិលបន្តិចលាយជាមួយអំពិលទុំ។

**ប្រយ័ត្ន៖** យើងមិនត្រូវឲ្យដំរីស៊ីអំពិលទុំច្រើនពេកទេ ព្រោះវាអាចបណ្តាលឲ្យដំរីរាក។ ដូច្នេះកុំអោយលើសពីមួយគីឡូក្រាម។

**អំបិលគ្រាប់** អាចធ្វើឲ្យសត្វដំរីកើនចំណង់អាហារ ប្រសិនបើយើងប្រោះទឹកអំបិលលើស្មៅ ឬប្រសិនបើយើងយកអំបិលគ្រាប់លាយជាមួយអំពិលទុំ។

**ប្រយ័ត្ន៖** បើយើងឲ្យអំបិលគ្រាប់ដល់សត្វដំរីក្នុងបរិមាណត្រឹមត្រូវ វាជួយបង្កើនចំណង់អាហារ ប៉ុន្តែប្រសិនបើយើងអោយអំបិលច្រើនពេក វានឹងធ្វើអោយដំរីស្រេកទឹកខ្លាំងណាស់ ហើយនឹងធ្វើអោយដំរីស្រវាំងភ្នែក និងមានដំណើរទ្រេតទ្រោត។

**អំបិលរ៉ែ** គឺដូចគ្នាទៅនឹងការផ្តល់ទៅឲ្យសត្វគោ និងក្របីដែរ។ មុនពេលដាក់អំបិលរ៉ែឲ្យដំរី យើងគួរតែបំបែកដុំអំបិលជាបំណែកតូចៗ ឬត្រាំក្នុងទឹកសិន។ ជាមធ្យមក្នុងរយៈពេលមួយខែ ឲ្យវាតែម្តងបានហើយ។

**ថ្នាំផ្សំពីរុក្ខជាតិ** ដូចជាថ្នាំបុរាណ ម៉ុងកូសេង (ម៉ុងកូសេង គឺជាយីហោឱសថបុរាណ) ដែលគេច្រើនប្រើសម្រាប់សត្វដំរីអូសឈើនៅភាគខាងជើងប្រទេសថៃ។ ឱសថបុរាណប្រភេទនេះ គឺជាភ្នាក់ងាររំញោចដ៏ល្អ ដែលធ្វើសត្វដំរីមានចំណង់អាហារ។

**ប្រយ័ត្ន៖** បើឲ្យថ្នាំប្រភេទនេះច្រើនពេក វាអាចបណ្តាលដំរីឲ្យរាក។

# ការគ្រប់គ្រងដំរី

*ការគ្រប់គ្រងសត្វដំរីឲ្យបានពេញលេញល្អ គឺជាផ្នែកមួយដ៏សំខាន់នៃការងាររបស់ហ្មដំរី។ ក្រៅពីការធានាថាការងារគ្រប់គ្រងនោះនឹងត្រូវធ្វើឲ្យបានត្រឹមត្រូវជាទីបំផុត និងមានប្រសិទ្ធិភាពល្អ ការត្រួតពិនិត្យពេញលេញនោះក៏ត្រូវធានាបន្ថែមទៀតនូវសុវត្ថិភាពរបស់ហ្មដំរី និងសុវត្ថិភាពរបស់មនុស្សដទៃទៀតដែលនៅក្បែរនោះ រួមទាំងសុវត្ថិភាពរបស់សត្វដំរីផងដែរ។*

*ការត្រួតពិនិត្យសត្វដំរីចែកចេញជាពីរប្រភេទ គឺនៅក្នុងកាលៈទេសៈធម្មតា និងនៅពេលសត្វដំរីលែងស្តាប់បញ្ជា និងអាចបង្កគ្រោះថ្នាក់ដល់មនុស្ស (មិនមែនគ្រប់ពេលទេ តែអាចកើតឡើងម្តងម្កាល ជាពិសេសនៅពេលវាឡើងកចុះប្រេង) ដំរីអាចរត់គេចខ្លួន ឬជួនកាលវាគ្រាន់តែស្ទន់ស្ទោជ្រួលច្របល់។ ដើម្បីអាចគ្រប់គ្រងដំរីឡើងវិញ យើងក៏មានឧបករណ៍ធម្មតា ដែលអាចយកមកប្រើប្រាស់បាន ប៉ុន្តែជារឿយៗ ត្រូវតែយកឧបករណ៍ពិសេសមកបំពេញបន្ថែមទៀត ដូចដែលមានពិពណ៌នានៅចុងបញ្ចប់នៃផ្នែកនេះ។*

*ការគ្រប់គ្រងសត្វដំរីត្រូវពឹងផ្អែកទៅលើកត្តាទាក់ទងគ្នាចំនួន ៣ គឺៈ (១) កម្រិតនៃការបណ្តុះបណ្តាលហ្មដំរី (២) សម្ភារៈ ឬឧបករណ៍ដែលត្រូវយកមកប្រើប្រាស់ (៣) វិធីប្រើប្រាស់ឧបករណ៍ទាំងនោះឲ្យបានល្អបំផុត។ បើមានភាពទន់ខ្សោយនៅក្នុងផ្នែកណាមួយនោះមានន័យថាវានឹងមានផលប៉ះពាល់ដល់សុវត្ថិភាព និងសុខភាពរបស់សត្វដំរី។*

*ចំពោះគុណភាពនៃការបណ្តុះបណ្តាលហ្មដំរីវិញ មានសញ្ញាដែលគួរឲ្យព្រួយបារម្ភមួយចំនួន ដោយសារតែហ្មដំរីនាសម័យបច្ចុប្បន្នកំពុងបាត់បង់ជំនាញជាច្រើនដែលធ្លាប់មានកាលពីសម័យចាស់។ កង្វះជំនាញនេះ ទំនងជាអាចនឹងលេចចេញជារូបរាងច្បាស់លាស់ក្នុងពេលអនាគតដ៏ខ្លីខាងមុខ ដែលនឹងបង្ហាញឲ្យឃើញថាការគ្រប់គ្រងសត្វដំរីឡើងកចុះប្រេង កាន់តែចុះខ្សោយ ហើយដែលភាគច្រើនអាចធ្វើឲ្យមានគ្រោះថ្នាក់ថែមទៀតផង។ ការបណ្តុះបណ្តាលហ្មដំរី គឺហួសពីវិសាលភាពនៃសៀវភៅនេះ។*

## ឧបករណ៍

*ឧបករណ៍សម្រាប់ប្រើជាមួយសត្វដំរីទាំងអស់មានលក្ខណៈជាប្រពៃណី ដែលមានការវិវត្តជាច្រើនសតវត្សរ៍មកហើយ។ ការផ្លាស់ប្តូរបច្ចេកវិទ្យាចុងក្រោយនេះ គឺគេបានយកខ្សែផ្តៅ និងខ្សែពួរធ្វើពីរុក្ខជាតិ មកប្រើជំនួសច្រវាក់។*

**កង្វេរ**



*កង្វេរ គឺជាឧបករណ៍សំខាន់បំផុតសម្រាប់ហ្មដំរី។ ឧបករណ៍នេះត្រូវតែនៅជាមួយហ្មដំរីគ្រប់ពេលដែលគាត់នៅជាមួយដំរីរបស់គាត់ ហើយគាត់ក៏ត្រូវតែដឹងពីរបៀបប្រើវាដោយមិនបង្កឲ្យដំរីរងរបួស។ តាំងពីដំបូង គេតែងតែរំលឹកហ្មដំរីជាញឹកញាប់ថា គោលបំណងពិតប្រាកដនៃការប្រើកង្វេរ គឺមិនមែនដើម្បីបង្កឲ្យសត្វដំរីមានការឈឺចាប់នោះទេ ផ្ទុយទៅវិញយើងប្រើវា គឺគ្រាន់តែកំញើញដំរី ដើម្បីបញ្ជាវាឲ្យធ្វើតាមនូវអ្វីដែលដំរីបានហាត់រៀនរួចមកហើយ (ឈប់ បត់ឆ្វេង បត់ស្តាំ លុតជង្គង់ ឈរស្ងៀម។ល។) កង្វេរមានដងឈើវែង ដែលមានប្រវែងប្រហែលពីរហត្ថ ដើម្បីឲ្យហ្មដំរីងាយស្រួលកាន់។*

*កង្វេរត្រូវតែមានទំហំសមរម្យល្មម និងរចនាឡើងតម្រូវទៅតាមដៃរបស់ហ្មដំរី និងលក្ខណៈធម្មជាតិរបស់ដំរី។ ក្បាលកង្វេរត្រូវតែណែនតឹងល្អ ហើយដងរបស់ត្រូវតែមាំ មិនងាយបាក់ ឬរអិលទេ។ ចុងកង្វេរមិនគួរឲ្យមុតស្រួចទេ ព្រោះវាងាយមុតចូលទៅក្នុងស្បែករបស់សត្វដំរី។*

*ប្រយ័ត្ន៖ កុំវាយធ្វើបាបដំរី ជាពិសេសនៅលើក្បាលរបស់វា ដោយចុងកង្វេរ។ លើកលែងតែករណីបន្ទាន់បំផុត បើពុំនោះទេ មិនត្រូវដងកង្វេរវាយលើបរិវេណជុំវិញភ្នែក ឬចិញ្ចើមរបស់សត្វដំរីទេ ព្រោះទង្វើនេះអាចបង្កឲ្យមានរបួស និងពេលខ្លះអាចធ្វើឲ្យដំរីពិការភ្នែកទៀតផង។ មិនត្រូវប្រើចុងកង្វេរចាក់ចូលក្នុងរន្ធត្រចៀករបស់ដំរីទេ។*

## កាំបិត

*ដូចជាកន្សែងដែរ ហ្មដំរីត្រូវតែមានកាំបិតនេះ នៅជាប់នឹងខ្លួនរបស់គាត់គ្រប់ពេល លើកលែងតែនៅពេលជិះដំរី ដែលមានសុវត្ថិភាពបំផុត នៅក្នុងដំរុំទេសចរណ៍ (កាំបិតនោះអាចធ្វើឲ្យភ្ញៀវទេសចរមានការភ័យខ្លាច)។ នៅពេលចូលព្រៃកាំបិតនេះពិតជាចាំបាច់ណាស់ក្នុងគ្រាមានអាសន្ន (ដូចជាក្នុងករណីដំរីរអិលចុះពីលើភ្នំ ឬដីទួល) ហ្មដំរីនឹងត្រូវការប្រើកាំបិតនេះ ដើម្បីកាត់ខ្សែពួរដែលចងរបស់ផ្សេងៗលើខ្នងដំរី។*

*មិនត្រូវប្រើកាំបិតនោះ ដើម្បីបញ្ជាគ្រប់គ្រងលើសត្វដំរីទេ លើកលែងតែនៅពេលដែលហ្មដំរីបានរបូតធ្លាក់កន្សែងពីដៃ ឬបាត់កន្សែង ឬក៏នៅពេលមានអាសន្ន ដែលអាចមានគ្រោះថ្នាក់ដល់ជីវិតមនុស្ស។ គោលបំណងចំបងនៃការប្រើប្រាស់កាំបិតនោះ គឺដើម្បីទុកកាត់ចំណីអាហារឲ្យដំរី ត្រួសត្រាយផ្លូវដើរ សម្រាប់ឲ្យហ្មដំរីកាប់អុស។ល។*

*កាំបិតត្រូវតែទុកនៅក្នុងស្រោមមាំល្អ ប្រកបដោយសុវត្ថិភាព ប៉ុន្តែអាចដកយកមកប្រើបានដោយងាយស្រួល។ កាំបិតគួរតែមានទំហំសមល្មម និងមានដង ដែលអាចឲ្យយើងចាប់កាន់វាបានយ៉ាងរឹងមាំជាប់នៅក្នុងដៃ។*

*ប្រយ័ត្ន៖ មិនត្រូវយកកាំបិតមកប្រើជំនួសកន្សែងទេ។ មិនត្រូវយកកាំបិតមកប្រើដើម្បីចាក់ ឬកាប់ទៅលើសត្វដំរីឡើយ។*

## ខ្សែបង្ហៀរត្រចៀក



*ខ្សែបង្ហៀរត្រចៀក គឺធ្វើអំពីដែក ដែលមានរាងដូចផ្ទៃសន្ទូច គេដាក់នៅព័ទ្ធជុំវិញត្រចៀកសត្វដំរី ដោយមានខ្សែពួរតូចមួយ។ គេប្រើវាដើម្បីដឹកនាំសត្វដំរី ហើយសម្រាប់តែក្នុងរយៈពេលខ្លីទេ។ ខ្សែពួរសម្រាប់ដឹកមានប្រវែងពី ១ ទៅ ៣ ម៉ែត្រ ភ្ជាប់ទៅនឹងបង្ហៀរត្រចៀកនៅពេលយើងទាញខ្សែថ្នមៗ ចុងដែកនោះចុចត្រចៀកស្រាលៗពីខាងក្រោយ ជាសញ្ញាប្រាប់សត្វដំរីឲ្យដើរទៅមុខ (ឬដើម្បីបញ្ឈប់សត្វដំរីឲ្យនៅស្ងៀមមួយកន្លែងនៅពេលដែលយើងយកខ្សែនោះទៅចងជាប់នឹងបង្គោលណាមួយ។*

*ខ្សែបង្ហៀរត្រចៀកមានប្រយោជន៍ណាស់ ជាពិសេស ក្នុងការបង្ហឹកកូនដំរីតូចៗឲ្យវាចេះស្តាប់បញ្ជាដើរតាមហ្មដំរី។ នៅពេលកូនដំរីចេះស្តាប់បញ្ជាហើយ យើងអាចដកបង្ហៀរត្រចៀកនោះចេញ នៅពេលដែលមិនត្រូវការ។ បង្ហៀរត្រចៀកមានសុវត្ថិភាពល្អឥតខ្ចោះនិងមិនបង្កគ្រោះថ្នាក់ដល់សត្វដំរីទៀតផង បើយើងប្រើវាឲ្យបានត្រឹមត្រូវ។ ប៉ុន្តែវាក៏អាច បណ្តាលឲ្យមានរបួសដែរ ប្រសិនបើយើងប្រើដោយធ្វេសប្រហែស។ អ្នកគ្រប់គ្រងដំរីត្រូវត្រួតពិនិត្យការប្រើប្រាស់បង្ហៀរត្រចៀកនេះយ៉ាងប្រុងប្រយ័ត្ន។*

*ប្រយ័ត្ន៖ មិនត្រូវកញ្ចក់ខ្សែបង្ហៀរត្រចៀកខ្លាំងៗទេ។ មិនត្រូវប្រើខ្សែបង្ហៀរត្រចៀកលើសត្វដំរីណាមួយ ក្នុងរយៈពេលយូរពេក ឬក៏យកសត្វដំរីទៅចងទុកចោលទេ។ ប្រសិនបើសត្វដំរីមានការភ័យស្ងន់ស្ងោ វាអាចនឹងធ្វើឲ្យដំរីឈឺខ្លាំង ឬអាចរងរបួសត្រចៀក។*

**កងជើង**



*កងជើង គឺដូចជាខ្នោះដៃដែរ ដោយមានខ្សែកងពីរ ភ្ជាប់គ្នាដោយសារកងធំមួយ។ កងជើង គេប្រើសម្រាប់ដាក់នៅលើជើងមុខរបស់សត្វដំរី ដើម្បីឲ្យវានៅស្ងៀមមួយកន្លែង សម្រាប់បន្ថយល្បឿន ឬដើម្បីកុំឲ្យវាដើរកន្ទងឆ្វងកាត់វត្ថុ ឬឧបសគ្គធំៗ។ ពេលខ្លះគេប្រើកងជើងដើម្បីកុំឲ្យសត្វដំរីដោយញីដោយឈ្មោលបាន។ គេអាចប្រើកងជើងដាច់តែឯង ឬក៏អាចចងភ្ជាប់ទៅនឹងខ្សែច្រវាក់បាន។*

*យើងត្រូវត្រួតពិនិត្យជើងដំរីយ៉ាងយកចិត្តទុកដាក់ជារៀងរាល់ថ្ងៃ ដើម្បីធានាថា កងជើងដែលបានប្រើនោះ ប្រាកដជាមិនបានបង្ករឲ្យសត្វដំរីមានរបួស។*

*ប្រយ័ត្ន៖ កងជើងត្រូវតែគ្មានគែម ឬចុងមុតស្រួចទេ ព្រោះវាអាចធ្វើឲ្យរបួសជើងដំរី។ កងជើងដំរីមិនត្រូវដាក់តឹងពេក (ព្រោះវាអាចធ្វើឲ្យជើងដំរីមានរបួស) ហើយក៏មិនមិនត្រូវឲ្យវារលុងពេកដែរ (ព្រោះវាអាចរបូត ឬក៏ដំរីមិនស្តាប់បញ្ជា)។*

## ច្រវាក់ជើង

*គេប្រើច្រវាក់ជើងសម្រាប់ដាក់ជាប់ទៅនឹងជើងម្ខាងរបស់សត្វដំរីមួយ (ជាធម្មតាគេដាក់វានៅជើងខាងស្តាំ) ហើយចុងច្រវាក់ម្ខាងទៀតទុកសម្រាប់ចងភ្ជាប់ទៅនឹងដើមឈើ ឬបង្គោលណាមួយ។ នៅតាមជនបទ គេតែងប្តូរកន្លែងចងសត្វដំរីជារៀងរាល់យប់ គឺដើម្បីឲ្យដំរីអាចស៊ីចំណីជារុក្ខជាតិដែលនៅជិតៗវា បែបនេះដំរីអាចទទួលបាននូវចំណី ដូចជាសត្វដំរីព្រៃដែរ។*

*ច្រវាក់ជើងត្រូវតែជាប់នឹងជើងដំរី ឬនៅក្បែរវាគ្រប់ពេល។ ច្រវាក់ជើងគឺជាគ្រឿងបរិក្ខារតែមួយគត់ ដែលអាចឲ្យហ្មដំរីទុកដំរីចោលបានមួយរយៈ ដោយគាត់អាចទុកចិត្តបានថា ដំរីគាត់នឹងមិនរត់បាត់ ឬអាចបង្កឲ្យមានបញ្ហាឡើយ។*

*នៅពេលត្រូវទិញច្រវាក់ជើងដំរី យើងត្រូវគិតគូរពីគុណសម្បត្តិនៃបច្ចេកទេសចំនួនបីយ៉ាង៖ (១) ប្រវែងច្រវាក់ (២) ទម្ងន់ / ទំហំច្រវាក់ និង (៣) គុណភាពច្រវាក់។*

*ប្រវែងច្រវ៉ាក់ដែលយើងយកមកប្រើសម្រាប់ដំរីពេញវ័យ នៅក្នុងបរិស្ថានធម្មជាតិ ឬទីធ្លាទូលាយ ត្រូវមានប្រវែងចន្លោះពី ២០ ទៅ ៣០ ម៉ែត្រ។ ចំពោះកូនដំរី គេច្រើនតែប្រើប្រវែងប្រហែលពី ១២ ទៅ ១៥ ម៉ែត្រ។ នៅពេលយើងត្រូវការបង្ខាំងសត្វដំរី នៅក្នុងទីណាមួយ ខ្សែច្រវ៉ាក់នឹងអាចខ្លីជាងនោះ។ ជាការពិតណាស់ ខ្សែច្រវ៉ាក់វែងក៏យើងអាចប្រើ*

បង្រួញឲ្យខ្លីក៏បានដែរ គឺយើងយកចុងវាទៅចងភ្ជាប់នឹងបង្គោល ហើយទុកប្រវែងដែលនៅសល់ពីបង្គោលទៅសត្វដំរីតាមតម្រូវការរបស់យើង។

ទម្ងន់ ឬទំហំរបស់ប្រវាក់ជើង យើងអាចពិពណ៌នាតាមរយៈអង្កត់ផ្ចិតរបស់ប្រវាក់មួយកង់ៗ។ ឯកតារង្វាស់គិតជាហ៊ុនឬ ១/៨ អ៊ីញ [៣.៥ ម.ម]។ ទំហំធម្មតា ដែលយើងយកមកប្រើសម្រាប់ដំរីពេញវ័យគឺ ៤ ហ៊ុន ឬ ១/២ អ៊ីញ [០,៤ ស.ម]។ ពេលខ្លះយើងអាចប្រើប្រវាក់ធ្ងន់ៗជាងនេះ ជាមួយសត្វដំរីណា ដែលចង់តស៊ូផ្ដាច់ប្រវាក់របស់វា។ យើងយកប្រវាក់ស្រាលមកប្រើជាមួយសត្វដំរីស្លូតៗ ដែលមិនផ្ដាប់ប្រវាក់របស់វា។ ចំពោះកូនដំរីវិញតាមម្មតា គឺប្រវាក់ ២ ហុន ឬ ១/៤ អ៊ីញ [៧ មម]។ ខ្សែប្រវាក់ស្រាលជាងនេះ គឺកាន់តែល្អសម្រាប់ដំរី ព្រោះសត្វដំរីនឹងមិនត្រូវការប្រើកម្លាំងច្រើនក្នុងការអូសខ្សែប្រវាក់នោះ ហើយក៏មិនធ្វើឲ្យសត្វដំរីងាយរងរបួសជើង និងកជើងបានដែរ។

ភាគច្រើន គុណភាពប្រវាក់ វាអាស្រ័យលើតម្លៃ។ ប្រវាក់ល្អបំផុត ផលិតនៅបណ្ដាប្រទេសលោកខាងលិច ដែលធ្វើពីលោហៈដ៏ល្អ ហើយការផ្សារដែកភ្ជាប់តំណនីមួយៗ ក៏មានស្តង់ដារខ្ពស់បំផុតដែរ។ ខ្សែប្រវាក់ដែលមានគុណភាពល្អមានតម្លៃថ្លៃណាស់។ ខ្សែប្រវាក់ផលិតក្នុងស្រុក និងនៅតាមតំបន់មានតម្លៃថោកជាង ប៉ុន្តែដែក និងការផ្សារភ្ជាប់តំណនីមួយៗមានគុណភាពអន់។ វានាំឲ្យមានភាពស្មុគស្មាញខ្លាំងណាស់ នៅពេលយើងទិញវាយកមកប្រើប្រាស់។ ខ្សែប្រវាក់ដែលមានគុណភាពទាប មានតម្លៃថោកជាង តែប្រើបានតែក្នុងរយៈពេលខ្លី ឆាប់ខូចជាងប្រវាក់ដែលមានគុណភាពល្អ ដែលយើងអាចប្រើបានអស់មួយជីវិត។ ខ្សែប្រវាក់ដែលមានគុណភាពខ្ពស់ ជាប់ល្អ យើងមិនបាច់ទិញយកទំហំធំពេកទេ ហើយស្រាលជាង ងាយស្រួលយកមកពាក់លើខ្លួនដំរី។ ប្រវាក់ដែលមានគុណភាពខ្ពស់មិនងាយនឹងខូច ឬដាច់ទេ ហើយវាអាចជួយសង្គ្រោះម្ចាស់ដំរីពីការបង់ប្រាក់សំណង នៅពេលសត្វដំរីរបស់គាត់ដាច់រួចទៅស៊ីដំណាំគេ ឬអាចបង្កឲ្យមានការបាត់បង់អាយុជីវិតមនុស្សជាដើម។

កត្តាផ្សេងៗដែលត្រូវយកមកពិចារណានៅពេលត្រូវទិញ ឬសម្រេចចិត្តជ្រើសរើសខ្សែប្រវាក់ណាមួយដែលត្រូវយកមកប្រើ រួមមានទំហំដំរី ថាតើវាតែងប៉ុនប៉ងផ្ដាច់ប្រវាក់ដែលចងវាដែរឬទេ (សូមមើលទំព័រទី ៥៣) និងបរិស្ថានដែលដំរីត្រូវចងដាក់ប្រវាក់ ជា

ពិសេសទាក់ទងនឹងចំណីអាហារ។ ចំពោះសត្វដំរី ដែលគេដាក់ច្រវាក់វានៅកន្លែងណាមួយ ដែលមានចំណីអាហារ និងទឹកគ្រប់គ្រាន់ ភាគច្រើនវាមិនចង់ផ្តាច់ច្រវាក់របស់វាទេ។ ប៉ុន្តែបើដំរីឃ្លាន ឬស្រេកទឹក គឺនៅពេលដែលមានចំណីអាហារ ឬទឹកមិនគ្រប់គ្រាន់នៅកន្លែងដែលគេដាក់ច្រវាក់វា ពេលនោះសត្វដំរីអាចនឹងព្យាយាមផ្តាច់ច្រវាក់វា។ បញ្ហាទាំងអស់នេះ ហ្មដំរីដើងចាស់ គាត់ដឹងសព្វគ្រប់អស់ហើយ លើកលែងតែហ្មដំរីថ្មីៗ ដែលពួកគាត់មិនទាន់ដឹងឲ្យបានគ្រប់ជ្រុងជ្រោយនៅឡើយទេ។

*គុណប្រយោជន៍នៃច្រវាក់* លើមធ្យោបាយដែលត្រូវប្រើប្រាស់ សម្រាប់ចងសត្វដំរីគឺមានច្រើនលើសលប់។ ខ្សែច្រវាក់មិនលូត ឬរួមនៅពេលវាត្រូវកំដៅ ឬសំណើម។ នៅពេលដែលយើងជ្រើសរើសខ្សែច្រវាក់ឲ្យបានត្រឹមត្រូវ គឺវាពិតជាល្អប្រើជាងខ្សែផ្សេងៗទៀតទាំងអស់។ ច្រវាក់មិនដូចខ្សែពួរ ឬខ្សែលួសទេ គឺច្រវាក់មិនងាយធ្វើឲ្យសត្វដំរីមានរបួសស្នាមទេ និងមិនងាយនឹងរមួល ឬមិនងាយវណ្ឌជាប់នឹងដើមឈើ ឬថ្មទៀតផង។ ច្រវាក់ប្រើជាប់បានយូរជាងខ្សែផ្សេងៗទៀតទាំងអស់។

*គុណវិបត្តិនៃច្រវាក់* គឺយើងត្រូវការចំណាយថវិកាច្រើនជាងការប្រើប្រាស់ខ្សែពួរ និងខ្សែផ្សេងៗទៀត ហើយច្រវាក់ធ្ងន់ជាងខ្សែផ្សេងៗទៀតទាំងអស់។ ច្រវាក់អាចចម្លងចរន្តអគ្គិសនីបាន ហើយនៅពេលប៉ះនឹងចរន្តអគ្គិសនី វាអាចធ្វើឲ្យឆក់បាន។ ប្រសិនបើយើងត្រូវការយកខ្សែច្រវាក់មកចងរុំព័ទ្ធលើខ្លួនដំរី វាពិបាកកាត់ជាងខ្សែពួរ។ ទោះបីជាមានគុណវិបត្តិទាំងនេះក៏ដោយ ក៏ច្រវាក់នៅតែជាជម្រើសដ៏ល្អបំផុតមួយ ទាំងសម្រាប់មនុស្ស និងសម្រាប់សត្វដំរី។

*ប្រយ័ត្ន៖* នៅពេលត្រូវដឹកដំរីពីកន្លែងមួយទៅកន្លែងទៀត ជាពិសេសនៅពេលយប់ត្រូវយកដំរីទៅដាក់កន្លែងចងទុក និងពេលថ្ងៃត្រូវយកដំរីទៅកាន់កន្លែងធ្វើការ មិនត្រូវឲ្យដំរីអូសច្រវាក់នៅជាប់នឹងជើងវាទេ។ ទម្ងន់ច្រវាក់ធំ ហើយដែលមានបណ្តោយពី ២០ ទៅ ៣០ ម៉ែត្រ អាចធ្វើឲ្យដំរីគ្រេច ឬថ្លោះកជើងរបស់វាបាន (ប្រសិនបើយើងធ្វើបែបនេះញឹកញាប់ពេក វានឹងបណ្តាលឲ្យច្រវាក់សឹកអស់មុនអាយុផងដែរ)។ ប្រសិនបើជាដីរអិលវិញ ខ្សែច្រវាក់អាចវណ្ឌជើង ដែលអាចបណ្តាលឲ្យសត្វដំរីមានគ្រោះថ្នាក់។ មានករណីលើកលែងតែមួយគត់ ចំពោះការហាមទុកច្រវាក់នៅជាប់នឹងជើងដំរីឲ្យវាដើរអូស

គឺដើម្បីអនុវត្តវិធានការសុវត្ថិភាពជាមួយសត្វដំរីណាមួយ ដែលអាចបង្កគ្រោះថ្នាក់ នៅពេលវាចង់វាយប្រហារហ្មរបស់វា ដែលកំពុងដើរក្បែរនោះ។ ច្រវាក់នឹងជួយកាត់បន្ថយល្បឿនរបស់សត្វដំរីបានយ៉ាងខ្លាំង។

យើងគួរតែយកច្រវាក់ទៅដាក់ពាក់នៅលើកញ្ចឹងក ដោយទុកឲ្យចុងច្រវាក់ធ្លាក់ចុះមកក្រោមក្រោមស្មា ដោយមានប្រវែងស្មើគ្នា។

មានគន្ទឹះពីរ ដែលយើងនឹងត្រូវការវាយកមកប្រើជាមួយច្រវាក់ គឺគន្ទឹះជាប៊ូឡុងដែលមានរាងជាអក្សរ "U" និងគន្ទឹះជាទំពក់វិល។ លើសពីនេះទៀត យើងនៅត្រូវការឧបករណ៍ផ្សេងទៀតដូចជាកន្ត្រៃកាត់ដែក និងរណារអារដែក ដែលត្រូវតែមាននៅគ្រប់កន្លែងទាំងអស់។ ចៀសមិនផុតទេ នៅពេលខ្លះ ប្រាកដជាមានសត្វដំរីណាមួយវណ្ឌនឹងច្រវាក់របស់វា (ដូចគ្នានេះដែរចំពោះខ្សែពួរ) ហើយប្រសិនបើយើងមិនមានសម្ភារៈយកមកប្រើសម្រាប់ដោះ ឬកាត់ច្រវាក់ឲ្យបានទាន់ពេលវេលាទេ ដំរីនោះអាចនឹងមានរបួស ឬអាចរហូតដល់ស្លាប់ទៀតផងក៏អាចមានដែរ។

**ប៊ូឡុងរាងអក្សរ "U"**

ប៊ូឡុងរាងអក្សរ "U" ពីរត្រូវបានគេយកមកប្រើ នៅពេលគេត្រូវការចងដំរី។ ប៊ូឡុងមួយសម្រាប់ខ្ទាស់ច្រវាក់ចងភ្ជាប់ជុំវិញជើងដំរី និងមួយទៀតសម្រាប់ខ្ទាស់ច្រវាក់ចងភ្ជាប់ជុំវិញដើមឈើ ឬសសរគ្រឹះ។ ប៊ូឡុងរាងអក្សរ "U" ត្រូវតែមានទំហំ និងកម្លាំងយ៉ាងហោចណាស់ ក៏ឲ្យបានស្មើនឹងច្រវាក់ដែរ។ ច្រវាក់ល្អ រឹងមាំខ្លាំង ក៏ត្រូវការប៊ូឡុងល្អរឹងមាំដូចគ្នាដែរ (ប៊ូឡុងក៏ដូចជាច្រវាក់ដែរ គឺមានគ្រប់ទំហំគិតជាហ៊ុន ប៉ុន្តែវាប្រែប្រួលទៅតាមគុណភាពលោហៈ ដែលគេយកមកផលិតវា ហ្មដំរីត្រូវមានការប្រុងប្រយ័ត្នខ្ពស់ចំពោះគុណភាពប៊ូឡុងនេះ។)

ប៊ូឡុងរាងអក្សរ "U" មានវីសសម្រាប់មួលចូលភ្ជាប់ក្នុងរន្ធ។ ផ្នែកនេះគឺជាចំណុចខ្សោយរបស់ប៊ូឡុងរាងអក្សរ "U" ហើយនៅពេលដែលខ្សែវីសរលុង ឬសឹកអស់ យើងត្រូវតែដកវាចេញ ហើយដាក់ថ្មីជំនួសវិញជាបន្ទាន់ ព្រោះថាប៊ូឡុងមិនសូវថ្លៃទេ។ ហ្មដំរីដែលល្អតែងតែមានប៊ូឡុងពី ១០ ទៅ ១៥ គ្រាប់ទុកសម្រាប់ផ្លាស់ប្តូរ។

ប្រយ័ត្នៈ សត្វដំរីខ្លះឆ្លាតវៃពូកែណាស់ គឺវាអាចយកប្រមោយរបស់វាដោះពន្ទា គន្លឹះនោះចេញវិញបាន (ទោះបីជាជើងរបស់វាមានដាក់ច្រវាក់ ចាប់ប៊ូឡុងរាងអក្សរ "U" យ៉ាងមាំហើយក៏ដោយ។ ជាមួយនឹងសត្វដំរីប្រភេទនេះ ហ្មដំរីត្រូវតែបត់គន្លឹះសុវត្ថិភាព របស់ប៊ូឡុងរាងអក្សរ "U" នេះឲ្យបានត្រឹមត្រូវជាទីបំផុត។

## គន្លឹះទំពក់វិល



គន្លឹះទំពក់វិល គឺជាឧបករណ៍មួយធ្វើពីលោហៈមានទំពក់ចោះដាក់នៅចំកណ្តាល កងច្រវាក់។ គន្លឹះជាទំពក់វិលត្រូវដាក់ភ្ជាប់ជាមួយច្រវាក់ ដែលខាងចុងរបស់វាអាចវិលចុះ វិលឡើងជុំវិញកងបានដោយស្រួល។ គន្លឹះទំពក់វិលក៏ដូចជាប៊ូឡុងរាងអក្សរ "U" ដែរ គឺ ត្រូវតែរឹងមាំ ឬខ្លាំងជាងខ្សែច្រវាក់ទៅទៀត បើពុំនោះទេ វានឹងធ្វើឲ្យច្រវាក់ខ្សោយ។ គន្លឹះ ទំពក់វិលមិនចាំបាច់ដាក់ឲ្យមាននៅគ្រប់ច្រវាក់ទេ ប៉ុន្តែវាចាំបាច់នៅពេលដែលសត្វដំរី មិនមានសណ្តាប់ធ្នាប់នៅមិនស្ងៀម ហើយជាពិសេសនៅពេលដំរីចុះប្រេង ឬប៉ះចំដំរីកាច ព្រោះថាពេលខ្លះហ្មដំរីមិនអាចទៅក្បែរដំរីបានទេ។ គោលបំណងនៃការប្រើគន្លឹះទំពក់ វិល គឺដើម្បីការពារកុំឲ្យសត្វដំរីផ្តាច់ច្រវាក់បាន ដោយវាអាចធ្វើឲ្យច្រវាក់គាំងរមូរចូលគ្នា ហើយវាអាចទាញដាច់បានដោយងាយ។

ចំណុចខ្សោយបំផុតរបស់ច្រវាក់ គឺនៅត្រង់មុខតំណភ្ជាប់ពីកងមួយទៅកងមួយ ទៀតរបស់ខ្សែច្រវាក់។ ជាធម្មតាភាពរឹងមាំបំផុតរបស់វា គឺរង្វង់មូលរបស់កងក្នុងច្រវាក់ និងមុខតំណរបស់វា ដែលតភ្ជាប់ទៅកងមួយផ្សេងទៀត ប្រសិនបើមានមុខតំណណាមួយ ផ្សារមិនបានល្អ កងមួយនោះនឹងរលា ហើយធ្វើឲ្យច្រវាក់ងាយស្រួលនឹងទាញផ្តាច់។

យើងត្រូវបញ្ជាឲ្យជាងធ្វើគន្លឹះទំពក់វិលសម្រាប់ដំរីរបស់យើង ពីព្រោះគ្មានណា ផលិតវាដាក់លក់នៅលើទីផ្សារជាលក្ខណៈពាណិជ្ជកម្មទេ។ គន្លឹះទំពក់វិលក៏ដូចជារបស់ ផ្សេងៗទៀត ដែលយើងធ្លាប់ប្រើជាមួយនឹងគោ ក្របីដែរ ដូច្នេះយើងអាចខ្ចីគេមួយយក

*មកធ្វើជាគំរូបាន។ គន្ទឹះទំពក់រិលសាមញ្ញ និងមានតម្លៃថោក គេអាចផលិតនៅតាមរោង ជាងដែកបាន។ ឧទាហរណ៍ពីរខាងលើបង្ហាញម៉ូតមួយបែបទំនើប និងមួយទៀតតាម បែបបុរាណ។*

*ប្រយ័ត្នះ គន្ទឹះទំពក់រិលត្រូវតែមានភាពរឹងមាំល្អ និងរលោងល្អ គឺមិនត្រូវឲ្យមានគែម ស្រួចមុតទេ។ គន្ទឹះទំពក់រិលត្រូវតែអាចបង្វិលបានដោយសេរី និងងាយស្រួល ដូច្នេះ ហើយទើបហ្មដំរីត្រូវតែពិនិត្យមើលវាជារៀងរាល់ថ្ងៃ និងដាក់ប្រេងនៅពេលចាំបាច់ ជា ពិសេសនៅមុន និងក្រោយពេលប្រើប្រាស់។*

## ខ្សែ និងខ្សែពួរ

*ខ្សែពួរមានច្រើនប្រភេទ។ ពេលខ្លះគេប្រើខ្សែពួរដើម្បីចងដំរី ឬគ្រប់គ្រងចលនា របស់វា ប៉ុន្តែការប្រើប្រាស់ខ្សែពួរត្រូវបានកំណត់ជាពិសេសចំពោះកូនដំរី។ ខ្សែពួរប្រភេទ ខ្លះមានលក្ខណៈបែបបុរាណ ប៉ុន្តែមានខ្សែពីរប្រភេទទៀត គឺខ្សែលួស និងខ្សែនីឡុង ដែលជាការច្នៃប្រឌិតបែបទំនើប ដែលទាមទារឲ្យមានការប្រុងប្រយ័ត្នក្នុងការប្រើប្រាស់ គឺ ត្រូវប្រើវាសម្រាប់តែរយៈពេលខ្លីបានហើយ ព្រោះវាមានសមត្ថភាពបណ្តាលឲ្យសត្វដំរីរង របួសធ្ងន់ធ្ងរបាន។*

*ខ្សែមានគុណសម្បត្តិ និងគុណវិបត្តិជាច្រើន បើប្រៀបធៀបទៅនឹងច្រវាក់ ប៉ុន្តែ កត្តាទាំងនេះខុសគ្នាទៅតាមប្រភេទរបស់ខ្សែ ដែលយើងយកមកប្រើ។*

***ខ្សែពួរស្រកីដូង**ធ្វើពីសរសៃស្រកីដូង ដូច្នេះនៅពេលថ្មីវារឹងខ្លាំងណាស់។ ទំហំខ្សែ ពួរដូងដែលយើងយកមកប្រើជាមួយដំរីមានចាប់ពី ២ ដល់ ៤ ហុន [១/៤ ដល់ ១/២ អ៊ីញ ឬ .៧ ទៅ ១,៤ ស.ម។] ។ ខ្សែពួរស្រកីដូងភាគច្រើន គេប្រើដើម្បីចងផ្នែករាងកាយដូចជា ជើងកន្ទុយ និងប្រមោយសត្វដំរីនៅក្នុងពេលហ្វឹកហាត់។*

***លក្ខណៈសម្បត្តិល្អះ** បន្ទាប់ពីប្រើបានមួយរយៈ ខ្សែពួរស្រកីដូងប្រែមកជាទន់ ហើយងាយស្រួលប្រើណាស់ គឺយើងអាចជឿទុកចិត្តបាន ដូច្នេះវាមិនបង្កឲ្យមានរបួស ស្នាមច្រើនដល់សត្វដំរី ដូចប្រភេទខ្សែផ្សេងៗទៀតទេ។ នៅពេលវាស្ងួត ខ្សែពួរស្រកីដូង មិនរួញ ឬយឺតទេ។*

លក្ខណៈសម្បត្តិមិនល្អ៖ ខ្សែពួរស្រកីដូងមានតម្លៃថ្លៃ ហើយពិបាករកទិញ។ វាងាយនឹងពុកផុយយ៉ាងឆាប់រហ័ស ដូច្នេះយើងត្រូវតែថែរក្សាវាឲ្យបានត្រឹមត្រូវ។ នៅពេលខ្សែពួរស្រកីដូងសើម វាអាចយឺតវែង ហើយវាអាចរួញខ្លីនៅពេលវាស្ងួត ដែលជាហេតុអាចបង្កឲ្យសត្វដំរីរងរបួសបាន។

ខ្សែនីឡុងធ្វើពីសរសៃសំយោគ ហើយមានទំហំចាប់ពីមួយហុន (១/៨ អ៊ីញ ឬ ៣.៥ ម.ម ឡើងទៅ។ ខ្សែនីឡុងមានប្រយោជន៍ខាងផ្នែកជាប់បានល្អ ប៉ុន្តែមិនគួរយកខ្សែប្រភេទនេះមកចងក្រវ៉ាត់រឹតលើខ្លួនដំរីទេ ព្រោះវាអាចបង្កឲ្យមានមានរបួសធ្ងន់ធ្ងរដល់ដំរី។ ជាអកុសល ហ្មដំរីមិនល្អ និងគ្មានបទពិសោធន៍មួយចំនួន បានយកខ្សែប្រភេទនេះមកប្រើក្នុងការបង្ខឹកបង្ហាត់ដំរី ដែលបណ្តាលឲ្យមានស្នាមរបួសស្នាមដល់ដំរី។ ប្រសិនបើកាលៈទេសៈតម្រូវឲ្យប្រើខ្សែនីឡុងជាបណ្តោះអាសន្នដើម្បីបង្ខាំងដំរី យើងត្រូវតែត្រួតពិនិត្យមើលសត្វដំរីឡើងវិញជាញឹកញាប់ ព្រោះបើទុកយូរពេក វាអាចនឹងបង្កឲ្យមានរបួសស្នាមដល់សត្វដំរី។

លក្ខណៈសម្បត្តិល្អ៖ ខ្សែនីឡុងមានអាយុកាល និងប្រើបានយូរ ហើយងាយស្រួលថែទាំ ព្រមទាំងមានតម្លៃថោក និងងាយស្រួលរក។ នៅពេលសើមខ្សែនីឡុង មិនលាតនិងរួញទេ។

លក្ខណៈសម្បត្តិមិនល្អ៖ ខ្សែនីឡុងមានលក្ខណៈរឹង អាចធ្វើឲ្យមានសំណឹក និងងាយបង្កឲ្យមានស្នាមរបួស។ ម្យ៉ាងទៀតនៅពេលយើងប្រើវាយូរៗទៅ ខ្សែនីឡុងកាន់តែរឹងទៅៗ។ នៅពេលហួសកាលបរិច្ឆេទផុតកំណត់ វានឹងងាយដាច់ណាស់។

ខ្សែកាប គឺជាខ្សែពួរដែលធ្វើពីសរសៃលួស ជាប់ខ្លាំងជាងច្រវាក់។ ខ្សែកាបល្អបំផុតសម្រាប់យកមកប្រើនៅពេលមានអាសន្ន ដូចជានៅពេលដែលសត្វដំរីអាចបង្កគ្រោះថ្នាក់ ហើយយើងត្រូវការឃាត់បង្ខាំងវាទុកមួយរយៈសិន ជាពិសេសនៅពេលដែលច្រវាក់ដាច់ ឬគ្មានច្រវាក់។ យើងមិនត្រូវប្រើប្រាស់ខ្សែកាបលើសពីមួយថ្ងៃទេ ហើយនៅពេលយើងយកខ្សែកាបមកដាក់ជើងដំរី យើងត្រូវតែត្រួតពិនិត្យឡើងវិញឲ្យបានញឹកញាប់ និងដោយប្រុងប្រយ័ត្ន។ ត្រូវឧស្សាហ៍ប្តូរខ្សែកាបនៅជើងខាងមុខ ពីជើងមួយទៅជើងមួយទៀត ដើម្បីកាត់បន្ថយឱកាសនៃការរងរបួសដល់ដំរី។

*ការប្រើប្រាស់ខ្សែកាបត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ នៅពេលដឹកដំរីចូលទៅទីកន្លែងដែលវាមិនចង់ចូល ឬពីកន្លែងដែលវាមិនចង់ចាកចេញ។*

*លក្ខណៈសម្បត្តិល្អ៖ ខ្សែកាបរឹងមាំមិនគួរឲ្យជឿ ហើយវាមានតម្លៃថោកណាស់ យើងអាចរកបានយ៉ាងងាយស្រួល។*

*លក្ខណៈសម្បត្តិមិនល្អ៖ ខ្សែកាបងាយនឹងធ្វើឲ្យដាច់សាច់ណាស់។ នៅពេលយើងប្រើខ្សែកាបដើម្បីក្រវ៉ាត់ ឬចងដំរី ខ្សែកាបអាចរមួល និងធ្វើឲ្យដំរីពិបាកដើរ ហើយពេលខ្លះវាអាចបង្កឲ្យមានគ្រោះថ្នាក់ថែមទៀតផង។ ខ្សែកាបងាយនឹងដាច់ចេញសរសៃលួសមកក្រៅណាស់ ដែលអាចមុតចូលទៅក្នុងស្បែកដំរី។*

***ខ្សែពួរក្រចៅ*** *ធ្វើពីសរសៃអំបោះរុក្ខជាតិមួយប្រភេទហៅថាធ្មៃ ឬក្រចៅ ដែលមានលក្ខណៈស្រដៀងនឹងខ្សែពួរស្រូវគីដូងដែរ។ វាមិនដែលក្រាស់ជាង ៤ ហ៊ុន [១/២ អ៊ីញឬ ១,៤ សង្ទីម៉ែត្រ] និងមិនដែលវែងជាង ៦ ហ្វីតទេ (ស្មើនឹង ១,៨ ម៉ែត្រ)។ គេប្រើខ្សែរពួរប្រភេទនេះសម្រាប់ចងជើង និងចងសម្ភារៈផ្សេងៗដូចជាក្រណាត់ ជាលផ្តៅភ្ជាប់ទៅនឹងខ្លួនរបស់សត្វដំរី។*

***ខ្សែផ្តៅ*** *គឺរលោង និងមិនងាយរមួល ដូច្នេះគេប្រើវាសម្រាប់ចងលើខ្លួនដំរីព្រោះវាមានលក្ខណៈល្អ ដោយអាចពង្រីកបាន។ ផ្តៅដែលមានអង្កត់ផ្ចិតតូចពេក អាចកប់ចូលទៅក្នុងសាច់ដំរី ហើយបណ្តាលឲ្យមានស្នាមរបួសជ្រៅ។ ដូច្នេះនៅពេលយកផ្តៅចងដំរី យើងគួរតែយកវាច្រើនសរសៃមកក្រងដាក់បញ្ចូលគ្នាដើម្បីឲ្យវាក្រាស់។*

## ដំរីដែលផ្តាច់ច្រវាក់របស់វា

*ដំរីភាគច្រើនចូលចិត្តព្យាយាមម្តងហើយម្តងទៀត ដើម្បីផ្តាច់ច្រវាក់របស់វា ក្នុងការប៉ុនប៉ងស្វែងរកសេរីភាព។ សត្វដំរីខ្លះដែលគ្រាន់តែចង់ផ្តាច់ច្រវាក់វា មិនមានគ្រោះថ្នាក់ទេ ប៉ុន្តែភាគច្រើនវាអាចកាច ហើយអាចបង្កឲ្យមានគ្រោះថ្នាក់ដល់មនុស្សទៀតផង។*

*យើងអាចយល់បានថាការប៉ុនប៉ងរបស់សត្វដំរីបែបនេះ គឺគ្រាន់តែជាការព្យាយាមចង់បានសេរីភាព ប៉ុន្តែហ្មដំរីក៏ត្រូវតែព្យាយាមបញ្ឈប់ពួកវា ពីព្រោះដំរីដែលរួចពីចំណងអាចបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិ ដំណាំ និងដល់មនុស្សទៀតផង។*

*ចំពោះសត្វដំរីណាដែលព្យាយាមផ្តាច់ច្រវាក់រត់គេចខ្លួន ក្រៅពីអាចបង្កគ្រោះថ្នាក់ដល់មនុស្ស វាក៏អាចបង្កឲ្យមានរបួសធ្ងន់ធ្ងរដល់ខ្លួនវាផងដែរ។ ដំរីខ្លះយកប្រមោយវាកាន់*

*ច្រវាក់មួយកង់ទៅជាមួយ ហើយវាយកច្រវាក់នោះវាយរ៉ែទៅលើវត្ថុផ្សេងៗ ដែលនៅក្បែរវាថែមទៀតផង។ បច្ចេកទេសទូទៅរបស់សត្វដំរីគឺវាយកច្រវាក់ព័ទ្ធលើខ្លួនវា លើភ្លុក លើប្រមោយ លើក្បាល ហើយបន្ទាប់មកវាចាប់ផ្តើមទាញច្រវាក់។ ពេលខ្លះដំរីថយ ហើយប្រឹងបញ្ចេញកម្លាំងដើម្បីសាកល្បងទាញសសរ ឬគ្រឹះដែលចងច្រវាក់របស់វា។ ពេលនោះភាគច្រើនអាចនឹងមានស្នាមដាំ ស្នាមដាច់រលាត់ គ្រេចកជើង បាក់ភ្លុក ថែមទាំងអាច ស្លាប់ខ្លួនវាទៀតផងក៏ថាបាន។ ដំរីខ្លះទៀតប្រឹងខាំច្រវាក់រហូតទាល់តែបាក់ធ្មេញខ្លួនវាទៀតផងក៏មានដែរ។*

*វិធីល្អបំផុតដើម្បីដោះស្រាយបញ្ហានេះ នឹងកុំឲ្យដំរីរងរបួសដោយច្រវាក់ គឺយើងត្រូវព្យាយាមឲ្យអស់ពីសមត្ថភាព ដើម្បីជានាមិនឲ្យវាកើតឡើងបាន តាំងពីដំបូង៖*

*ត្រូវប្រុងប្រយ័ត្ន ជាពិសេសជាមួយដំរី ដែលធ្លាប់មានប្រវត្តិផ្តាច់ច្រវាក់។ សត្វដំរីអូសឈើហ៊ុបអាចក្លាយជាអ្នកជំនាញពិតៗ ក្នុងការផ្តាច់ច្រវាក់នេះ។*

*កុំប្រើច្រវាក់មិនត្រឹមត្រូវ (ឬប៊ូឡុងរាងអក្សរ "U" និងគន្លឹះទំពក់វិលមិនល្អ) ដូចជាអន់ពេក តូចពេក ឬសឹករេចរឹលពេក។ សត្វដំរីជាច្រើនតែងដឹងពីចំណុចខ្សោយរបស់ច្រវាក់ ហើយចង់សាកល្បងទាញផ្តាច់ច្រវាក់។ ប៉ុន្តែបើច្រវាក់ខ្លាំងជាង វាក៏នៅសម្ងំស្ងៀមទៅវិញ។*

*ប្រសិនបើចំណុចគល់សម្រាប់ចងច្រវាក់នោះមានភាពផុយស្រួយ ដូចជាដើមឈើនោះតូចពេក ឬសសរគ្រឹះផុយពេក សត្វដំរីជាច្រើននឹងដឹងពីភាពទន់ខ្សោយទាំងនោះ ហើយពួកវានឹងព្យាយាមទាញច្រវាក់។*

*កុំចងដំរីឲ្យវាសម្រាកនៅក្បែរកន្លែង ដែលមានការរំខាន ព្រោះអាចធ្វើឲ្យសត្វដំរីខឹង ដូចជានៅជិតកន្លែងដែលមានសម្លេងខ្លាំងៗ មានអ្នកចម្លែក ដែលសត្វដំរីមិនធ្លាប់ស្គាល់ជាដើម។ល។*

គ្រប់ពេលត្រូវតែធានាថា សត្វដំរីនោះទទួលបានចំណីអាហារ និងទឹកគ្រប់គ្រាន់។ ដំរីដែលឃ្លាន ឬស្រេកទឹក គឺងាយនឹងទាញផ្ដាច់ច្រវាក់ជាងដំរីដែលបានស៊ី និងផឹកទឹកគ្រប់គ្រាន់។

## ឧបករណ៍ពិសេសសម្រាប់ស្ថានភាពដែលមានបញ្ហា

ដើម្បីហ្វឹកហាត់សត្វដំរី ឬកុំឲ្យដំរីផ្ដាច់ច្រវាក់ គេបានយកឧបករណ៍ជាច្រើនប្រភេទមកប្រើប្រាស់ជាយូរមកហើយ។ ដោយផ្អែកលើគោលការណ៍ដូចគ្នានេះ គេបានរចនាឧបករណ៍មួយផ្សេងទៀតឡើង ដើម្បីកុំឲ្យដំរីព្យាយាមបោះគ្រវែងអ្នកជិះពីលើវាចោល។ ក្នុងគ្រប់ករណីទាំងអស់ គោលដៅគឺដើម្បីធានាថាសត្វដំរីមិនរត់គេច ដើម្បីទៅបង្កការខូចខាតដល់ដំណាំ ឬទ្រព្យសម្បត្តិ ហើយជាពិសេស គឺកុំឲ្យវាសម្លាប់មនុស្ស។

ឧបករណ៍ខាងក្រោមត្រូវបានគេយកមកប្រើ ប៉ុន្តែអ្នកប្រើត្រូវតែជាអ្នកជំនាញពិតប្រាកដ ហើយមិនដែលឲ្យលើសពីមួយថ្ងៃទេ។ យើងត្រូវតែត្រួតពិនិត្យសត្វដំរីឲ្យបានញឹកញាប់ ដើម្បីរកមើលរបួសធ្ងន់ធ្ងរ ឬស្នាមរបួសតូចៗណាមួយ ដែលគួរតែធ្វើការព្យាបាលភ្លាមៗ។ ឧបករណ៍ទាំងអស់ត្រូវតែសម្អាតវាយ៉ាងប្រុងប្រយ័ត្ន ទាំងនៅមុនពេលនិងក្រោយពេលប្រើប្រាស់រួច។

## កងជើងដែកគោល



រូបខាងលើនេះគឺជាកងជើងដែកគោល ដែលមានកម្រាស់ប្រហែល ៤ ហុន (១/២ អ៊ីញ ឬ ១,៤ ស.ម) ខ្សែច្រវាក់ត្រូវថ្លក់ភ្ជាប់ទៅនឹងកងជើងដែកគោលនេះ។ ប្រសិនបើដំរីឈរនៅស្ងៀម ឬផ្លាស់ទីយឺតៗ និងដោយប្រុងប្រយ័ត្ន នោះវានឹងមិនមានអារម្មណ៍ឈឺ

ចាប់ដោយសារមុតបន្លាដែកគោលនោះទេ។ ប្រសិនបើសត្វដំរីផ្លាស់ទីយ៉ាងលឿន ឬដោយគំហុកខ្លាំងៗ ពេលនោះបន្លាដែកគោលនឹងមុតចូលទៅក្នុងសាច់ ហើយបណ្ដាលឲ្យមានការឈឺចាប់ខ្លាំង។

នៅមានខ្សែក្រវ៉ាត់ច្រវាក់ដាំបន្លាដែកគោល ដែលគេបានច្នៃបង្កើតឡើងតាមគោលការណ៍ដូចគ្នានេះដែរ។ ប្រសិនបើសត្វដំរីធ្វើចលនាដោយថ្នមៗ នោះវានឹងមិនមានការឈឺចាប់ទេ ប៉ុន្តែប្រសិនបើសត្វដំរីធ្វើចលនាដោយកម្រោល ឬប្រើកម្លាំងខ្លាំងៗ ពេលនោះវានឹងទទួលការឈឺចាប់ខ្លាំងដែរ។

**ប្រឡៅកបន្លា**



ប្រឡៅកបន្លា គឺជាខ្សែពួរមួយ ដែលមិនត្រូវតឹងពេក ហើយក៏មិនរលុងពេកដែរ ដោយមានបន្លាធ្វើពីដែក ឬឈើរឹងៗ។ ជាធម្មតាហ្មដំរីថៃតែងបញ្ជាឲ្យសត្វដំរីរបស់ពួកធ្វើការងារ ដូចជាឲ្យវាអូសឈើហុប ឬក៏ឲ្យអ្នកទេសចរជិះអង្គុយលើកញ្ចឹងកសត្វដំរី ដើម្បីដើរលេងកំសាន្ត។ ដំរីខ្លះមានទម្លាប់អាក្រក់ ដោយវាគ្រញែងខ្លួនវាខ្លាំងៗ និងគ្រវីក្បាលវាជួលកាលអាចធ្វើឲ្យហ្មដំរីធ្លាក់ចុះពីលើកវាបានទៀតផង (សត្វដំរីមួយចំនួនតូចអាចមានជំនាញពិសេស ក្នុងការញាក់ស្បែករបស់វាយ៉ាងខ្លាំងៗ ដែលអាចធ្វើឲ្យហ្មដំរីធ្លាក់ចេញពីខ្លួនវាបាន)។

នៅពេលគេពាក់ប្រឡៅកបន្លាឲ្យសត្វដំរី ហើយហ្មដំរីឡើងជិះលើករបស់វា ប្រសិនបើសត្វដំរីនោះឈរ ឬដើរធម្មតា វានឹងមិនមានអារម្មណ៍ឈឺចាប់ទេ។ ប្រសិនបើវាប្រឹងរមួលខ្លួន បត់ខ្លួន វិលខ្លួន ឬញាក់ក វានឹងមានអារម្មណ៍ឈឺចាប់ខ្លាំង។

សូមមើលរូបភាពកងជើងដែកគោល និងប្រឡៅកបន្លា វាហាក់ដូចជាឃោរឃៅបន្តិច ដោយគេបានរចនាឡើងដើម្បីធ្វើឲ្យសត្វដំរីមានការឈឺចាប់។ ប៉ុន្តែវានៅតែប្រសើរជាងភាពសាហាវឃោរឃៅពិតប្រាកដ ព្រោះការធ្វើឲ្យសត្វដំរីមានឈឺចាប់ខ្លះៗនោះ គឺ

ពិតជាតាមបែបមនុស្សធម៌។ ឧបករណ៍ដែលយើងមើលទៅហាក់ដូចជាឃោរឃៅ និងមានលក្ខណៈបុរាណទាំងនេះ តាមពិតទៅវាទំនើបណាស់ ព្រោះសត្វដំរីខ្លួនវាទេ ដែលជាអ្នកកំណត់លើកម្រិតនៃការឈឺចាប់របស់វាដោយផ្ទាល់។ ចំពោះសត្វដំរីណា ដែលកាចនឹងទទួលពិន័យបន្តិចម្តងៗ ហើយនឹងធ្វើឲ្យវាមានការឈឺចាប់កាន់ខ្លាំងឡើងៗ បើវានៅតែព្យាយាមទៀត។ ហ្មដំរីមិនមានតួនាទីធ្វើឲ្យសត្វដំរីមានការឈឺនៅពេលនោះដោយផ្ទាល់ទេ។ កងជើងដែកគោល និងប្រឡោកបន្ទាអាចធ្វើកិច្ចការនេះបានដោយស្វ័យប្រវត្តិ ដោយមិនចាំបាច់មានវត្តមានរបស់ហ្មដំរីនៅក្បែរនោះទេ ជាពិសេសនៅពេលដែលដំរីមានបំណងចង់ផ្តាច់ច្រវាក់របស់វា។

ប្រសិនបើឧបករណ៍ទាំងនេះនៅក្នុងដៃរបស់អ្នកជំនាញវិញ គឺវានឹងល្អប្រសើរសម្រាប់សត្វដំរីជាងវិធីសាស្ត្របច្ចុប្បន្ន ដើម្បីប្រឆាំងនឹង "សត្វដំរីណាដែលប៉ុនប៉ងផ្តាច់ច្រវាក់របស់វា"៖ ហ្មដំរីដាក់ទណ្ឌកម្មទៅលើសត្វដំរីដោយផ្ទាល់ដៃ។ បញ្ហាដែលអាចកើតមានឡើងនោះគឺ ដំរីអាចមានការយល់ច្រលំ ហើយវានឹងមិនយល់ពីមូលហេតុដែលបុរសជាហ្មដំរីនោះធ្វើឲ្យវាមានការឈឺចាប់ដែរ។ "ការដាក់វិន័យ" ដែលគ្មានជំនាញបែបនេះគឺអាចនឹងផ្តល់ផលអាក្រក់ច្រើនជាង ហើយវាទំនងជាអាចបណ្តាលឲ្យមានរបួសធ្ងន់ធ្ងរជាងឧបករណ៍ខាងលើ។ ការរំលោភបំពានដោយហ្មដំរីអាចធ្វើឲ្យដំរីមានការភ័យខ្លាចជាងឧបករណ៍ ដែលបានរៀបរាប់ខាងលើ។

**ទម្ពក់ខៀន**



ឧបករណ៍នេះមានរាងដូចអក្សរ "U" ប៉ោងខាងក្រោម មានជន្ទញពីរនៅខាងចុងភ្ជាប់ទៅនឹងបង្គោលវែង។ គេប្រើឧបករណ៍នេះ ដើម្បីចាប់ដំរីដែលបានរត់គេចខ្លួនដោយ

សារវារបូតច្រវាក់ជើង។ នៅពេលសត្វដំរីធ្វើចលនា ទម្ពក់ជៀងនេះនឹងបុកនឹងថ្ម ដើមឈើ ហើយជៀងរបស់វានឹងមុតចូលទៅក្នុងសាច់ដំរី ធ្វើឲ្យវាមានការឈឺចាប់ ហើយដំរីត្រូវតែបន្ថយល្បឿន។ ដោយសារមានការច្នៃប្រឌិតថ្មី ដោយប្រើថ្នាំសន្ទប់បាញ់ចេញពីកាំភ្លើងពិសេស ដូចនេះយើងលែងមានយុត្តិកម្មសម្រាប់ការប្រើប្រាស់ឧបករណ៍នេះទៀតទេ។

## លំពែង

លំពែងត្រូវបានគេយកប្រើ ដើម្បីគ្រប់គ្រងសត្វដំរីពីចម្ងាយ នៅក្នុងស្ថានភាពគ្រោះដល់ថ្នាក់ហ្នដំរីមិនអាចចូលទៅជិតដំរីបាន។ យើងអាចប្រើប្រាស់លំពែងបាន លុះត្រាតែសត្វដំរីអាចបង្កគ្រោះថ្នាក់យ៉ាងច្បាស់ចំពោះមនុស្ស ឬសត្វដំរីដទៃទៀត (ញឹកញាប់ជាងគេនោះគឺកូនដំរី និងមេរបស់វា)។

ក្រៅពីការសង្គ្រោះបន្ទាន់ តម្រូវការក្នុងការប្រើលំពែងគឺ សម្រាប់ហ្នដំរីណាដែលគ្មានសមត្ថភាព មិនសូវស្រឡាញ់ និងមិនទុកចិត្តដំរីរបស់ខ្លួន។ ជាទូទៅការប្រើប្រាស់លំពែងភាគច្រើនជាងគេបំផុត គឺសម្រាប់បង្ខំ (ដោយចាក់ជើង និងត្រគាករបស់សត្វដំរី) សត្វដំរី ដោយធ្វើឲ្យវាខ្លាច ឬដំរីក្បាលរឹង ដើម្បីឲ្យវាចាកចេញពីកន្លែងណាមួយ ដែលពួកវាមិនចង់ចាកចេញ ឬញឹកញាប់ជាងនេះទៅទៀតនោះគឺ នៅពេលយើងឲ្យសត្វដំរីចូលទៅក្នុងចន្លោះណាមួយ ដែលពួកវាមិនចង់ចូល ដូចជានៅពេលដែលយើងត្រូវឲ្យដំរីឡើងលើរថយន្តដឹកជញ្ជូន។

ក្នុងករណីដ៏កម្រមួយ ដែលមានតម្រូវការចាំបាច់ ក្នុងការប្រើលំពែងលើសត្វដំរីតាមបែបបុរាណនោះគឺ ដោយសារលំពែងវាមានលក្ខណៈល្អប្រសើរជាងការប្រើវត្ថុមុតស្រួចជាបណ្ដោះអាសន្ន ដូចជាកាំបិតចុងស្រួចជាដើម។ លំពែងបែបបុរាណមានក្បាលដែកមួយដែលមានចំណុចចុងមុតស្រួច (ប៉ុន្តែមិនមែនមុតស្រួចរហូតធ្វើឲ្យហូរឈាមនោះទេ) ប្រវែងមិនលើសពីប្រាំមួយហុន [៣/៤ អ៊ិញ ឬ ២ ស.ម។] នៅខាងក្រោយចំណុចចុងស្រួចនោះគឺមានក្រដាស់ក្រាស់ពារាំងលំពែងមិនអោយចូលជ្រៅទៅក្នុងសាច់ដំរី។ លំពែងនេះបណ្ដាលឲ្យមានការឈឺចាប់ ប៉ុន្តែគែមរបស់វាមិនអាចបណ្ដាលឲ្យសត្វដំរីមានរបួសបានឡើយ រីឯលំពែងធម្មតាអាចបណ្ដាលឲ្យមានស្នាមរបួសគួរឲ្យរន្ធត់។

## គោលការណ៍ណែនាំសម្រាប់ចងសត្វដំរី

*កុំចងដំរីនៅកន្លែងដែលចោត និងរអិលព្រោះបើដំរីរអិលដួល ឬធ្លាក់ពីចំណោត វាអាចពិការ ឬស្លាប់បាន។*

*ហ្មដំរីត្រូវតែត្រួតពិនិត្យច្រវាក់ ដើម្បីធានាថាច្រវាក់នោះមិនរមួល ដែលអាចធ្វើឲ្យច្រវាក់នោះងាយនឹងជាប់ដើមឈើ ឬថ្ម បែបនេះទើបអាចធ្វើឲ្យសត្វដំរីកំរើកខ្លួនមិនបាន ហើយងាយនឹងរងគ្រោះ ដោយសារភ្លើង និងដោយសារការវាយប្រហារពីដំរីដទៃទៀត។*

*ប្រសិនបើត្រូវចងសត្វដំរីនៅក្នុងទីប្រជុំជន ឬភូមិ ហ្មដំរីត្រូវត្រួតពិនិត្យកន្លែងនោះដោយប្រុងប្រយ័ត្នចំពោះខ្សែអគ្គិសនីដែលគ្មានស្រោម។ ត្រូវដឹងថាច្រវាក់ក៏អាចចម្លងរន្តអគ្គិសនីបានដែរ ហើយវាអាចឆក់ដំរី។*

*ប្រសិនបើត្រូវយកដំរី ទៅចងនៅកន្លែងដែលមានសំរាម ឬកន្លែងដែលគេយកសំរាមទៅចោលនៅទីនោះ ត្រូវតែត្រួតពិនិត្យមើលថង់ប្លាស្ទិច (ជាពិសេសថង់ដែលមានសំណល់អាហារ) ដែលដំរីអាចលេបទាំងអស់ ព្រោះវាមានជាតិគីមីពុល។ល។*

*ប្រសិនបើត្រូវយកដំរីទៅចងក្នុងតំបន់អគារណាមួយក្នុងទីក្រុង ត្រូវតែត្រួតពិនិត្យឲ្យបានហ្មត់ចត់បំផុតចំពោះកំទេចដែក ដែកគោល បំណែកឈើមុតស្រួច ឬក៏កញ្ចក់។ល។ យើងត្រូវដកយកវត្ថុគ្រោះថ្នាក់ទាំងអស់នេះចេញ។*

*កុំយកដំរីទៅចងនៅកន្លែងដែលធ្លាប់ធ្វើជាផ្ទះ ជាពិសេសនៅជុំវិញតំបន់ដែលធ្លាប់ជាកន្លែងផ្ទះបាយ ឬកន្លែងបរិភោគអាហារ ឬកន្លែងលាងចាន។ វានឹងមានជាតិអំបិលនៅក្នុងដី ហើយដំរីអាចនឹងកាយយកដីនៅទីនោះមកស៊ី ដែលអាចបណ្តាលឲ្យដំរីស្ទះពោះវៀន។*

*មុននឹងចងដំរីនៅទីណាមួយ ហ្មដំរីត្រូវធានាថា នៅតំបន់ជុំវិញទីនោះ មិនមានសត្វដំរីផ្សេងទៀត ដែលអាចឈ្លានពានលើសត្វដំរីដែលយើងបានយកទៅចងនៅទីនោះ ដូចជាមានសត្វដំរីឈ្មោលនៅជិតទីនោះ (ជាពិសេសសត្វដំរីឈ្មោលដែលកំពុងចុះប្រេង)។ កុំចងដំរីនៅជិតគ្នាពេក ព្រោះច្រវាក់របស់ពួកវាអាចជាប់គ្នា ដែលជាគ្រោះថ្នាក់។*

*កុំចងសត្វដំរីដែលមិនធ្លាប់ស្គាល់គ្នាឲ្យនៅជិតគ្នា ព្រោះបើចងវានៅកន្លែងបែបនេះអាចធ្វើឲ្យពួកវាស្ថិតក្នុងភាពតានតឹងយ៉ាងខ្លាំង ដែលអាចរំខានដល់ការស៊ីចំណីអាហារ*

ផឹកទឹក និងការសម្រាករបស់សត្វដំរី ពេលនោះស្ថានភាពរាងកាយរបស់ដំរីកាន់តែយ៉ាប់យ៉ឺន។ (ក្នុងស្ថានភាពបែបនេះ ត្រូវចងដំរីឲ្យឃ្លាតពីគ្នាឲ្យបានចម្ងាយ យ៉ាងហោចណាស់ ១០០ ម៉ែតពីគ្នាដែរ។)

នៅពេលដែលត្រូវការចងដំរីចាំបាច់នៅតែមួយកន្លែង សម្រាប់រយៈពេលយូរ ដូចជាក្នុងករណីដំរីចុះប្រេង ឬនៅពេលដែលហ្មដំរីត្រូវទៅណាឆ្ងាយអស់រយៈពេលយូរ កន្លែងនោះត្រូវតែមានម្លប់ល្អ និងទឹកគ្រប់គ្រាន់។

កុំចងដំរីនៅជិតកន្លែង ដែលមានភ្លើងភ្លឺខ្លាំងនៅពេលយប់ ពីព្រោះដំរីនឹងមិនហ៊ានដេក ហើយវានឹងសម្លឹងមើលពន្លឺរហូតដល់កើតជម្ងឺឈឺភ្នែក និងអាចកើតមានជម្ងឺធ្ងន់ផ្សេងៗទៀត។

## ការហាមឃាត់ដាច់ខាតក្នុងពេលគ្រប់គ្រងដំរី

មិនថាដោយសារមូលហេតុអ្វីក៏ដោយ ដាច់ខាតមិនត្រូវចិញ្ចឹមសត្វដំរីដោយប្រើថ្នាំញៀនផ្សេងៗដូចជា អំហ្វេតាមីន អាភៀន កញ្ឆា ឬក៏ថ្នាំញៀនដទៃទៀតទេ។

ដាច់ខាតកុំចាក់ ឬបាញ់ថ្នាំប្រេងប្រភេទ turpentine លើដងខ្លួនរបស់ដំរី [ដែលជាធម្មតាថ្នាំទាំងនោះ ធ្វើឲ្យសត្វដំរីឈឺនឹងមានបញ្ហាកាន់តែធ្ងន់ធ្ងរនៅជើងរបស់វា] ព្រោះវានឹងមានជម្ងឺធ្ងន់នៅលើស្បែកដំរី ហើយស្បែកនោះនឹងដាច់ចេញមកទាំងផ្ទាំងៗ។ ក្រោយមកយើងនឹងមានលំបាកខ្លាំងក្នុងការព្យាបាលជម្ងឺនោះឲ្យជាសះស្បើយទាំងស្រុង។

ដាច់ខាតកុំប្រើរបស់ក្ដៅ (ទឹកពុះ ឬភ្លើងនៅជិត ឬប៉ះដំរីផ្ទាល់) ដើម្បីបង្ខំដំរីឲ្យវាឡើងលើឡាន ឲ្យវាធ្វើការ ឬធ្វើអ្វីផ្សេងៗទៀត ព្រោះវាអាចរងរបួស ហើយដំរីអាចស្លាប់ ឬក្លាយទៅជាសត្វខូចចិត្ត មានអារម្មណ៍មិនល្អ។

ដាច់ខាតមិនត្រូវប្រើចំពាមកៅស៊ូ ព្រួញ ធ្នូ កាំភ្លើងខ្លី កាំភ្លើងផាវ កាំភ្លើងហ្គាស កាំភ្លើងធុនស្រាល ២២ កាំភ្លើងខ្យល់ ឬអាវុធផ្សេងៗទៀតមកបាញ់ទៅលើសត្វដំរីដើម្បីបំភិតបំភ័យដំរី បង្ខំឲ្យវាធ្វើអ្វីមួយ។ ប្រសិនបើគ្រាប់កាំភ្លើងវាហោះទៅត្រូវលើរាងកាយ ឬសរីរាង្គដ៏សំខាន់របស់សត្វដំរី វានឹងអាចធ្វើឲ្យសត្វដំរីរងរបួស ឬពិការ ហើយពេលខ្លះអាចធ្វើឲ្យសត្វដំរីអាចស្លាប់បានទៀតផង។

កុំយកដំរីមេ និងកូនរបស់វា ដែលមានអាយុតិចជាងបីឆ្នាំ ទៅដាក់ឲ្យនៅក្បែរដំរីដទៃទៀតដែលមិនធ្លាប់ស្គាល់មេនិងកូនដំរីនោះ ព្រោះមេនិងកូនរបស់វា អាចនឹងរងការវាយប្រហារ និងអាចគ្រោះថ្នាក់ដល់ជីវិតរបស់មេនិងកូនដំរីនោះបានទៀតផង។

## ឧបករណ៍សម្រាប់អូស

ឧបករណ៍សម្រាប់អូស គឺជាខ្សែបង្ហៀរដែលគេប្រើដើម្បីអូសឈើហុបកាត់ព្រៃ មើលទៅវាដូចជាសាមញ្ញទេ ប៉ុន្តែតាមការពិតវាស្មុគស្មាញណាស់។ ឧទាហរណ៍ លក្ខណៈសាមញ្ញនោះគឺគ្រាន់តែបន្ទះឈើពីរ ប៉ុន្តែមិនមែនយកតែសំបកឈើពីរដើមឈើដែលគេអាចរកបាននៅក្នុងព្រៃធម្មជាតិប៉ុណ្ណោះទេ គេក៏នៅតែត្រូវការងារជំនាញសិល្បៈហត្ថកម្មដ៏អស្ចារ្យដើម្បីរៀបចំធ្វើខ្សែសម្រាប់អូសឈើហុប។ ខ្សែបង្ហៀរសម្រាប់ចងនៅដើមទ្រូងដំរី ក៏ជាផ្នែកមួយនៃឧបករណ៍សម្រាប់អូសនេះ ដែលត្រូវការជំនាញត្បាញយ៉ាងស្មុគស្មាញ (គឺធ្វើពីរុក្ខជាតិពិសេសផងដែរ)។ នៅជំនាន់មុន ហ្មដំរីនីមួយៗមានភាពប៉ិនប្រសប់ក្នុងការធ្វើឧបករណ៍នេះដោយខ្លួនឯង តែសព្វថ្ងៃនេះ មានហ្មដំរីតែមួយចំនួនតូចទេអាចធ្វើការងារនេះបាន។ ដូច្នេះការព្យាយាមបង្រៀនជំនាញសិប្បកម្មបុរាណមួយនេះគឺពិតជាហួសពីវិសាលភាពនៃសៀវភៅនេះ។ ម្យ៉ាងទៀតមនុស្សតិចតួចទេ ដែលនៅសេសសល់របរកាប់ឈើក៏បានក្លាយជាគ្រូជំនាញខាងសិល្បៈ ហើយការសរសេរសម្រាប់ពួកគេ គឺដូចជា "ការបង្រៀនឧត្តមអយ្យកោពីរបៀបអាន" [ជាភាសាថៃគេថា៖ "បង្រៀនជីដូនរបស់អ្នកឲ្យចេះបឺតពងមាន់ដែរ"]។

ឧបករណ៍សម្រាប់អូសទាញសព្វថ្ងៃនេះ ភាគច្រើនត្រូវបានគេច្នៃយកមកប្រើជាលក្ខណៈសាមញ្ញៗ សម្រាប់បង្ហាញដល់ភ្ញៀវទេសចរ គឺគេឲ្យដំរីអូសតែឈើស្រាលៗ និងនៅលើដីរាបស្មើ។ បើសិនជាមានអ្នកគ្រប់គ្រងមជ្ឈមណ្ឌលណាគិតចង់បន្ថែមការអូសឈើហុប នៅក្នុងកម្មវិធីសម្តែងរបស់ខ្លួន យើងសូមផ្តល់អនុសាសន៍ថាគ្រាន់តែជួលហ្មដំរីដើងចាស់ពីជំនាន់មុនពីរ ឬបីថ្ងៃ ដើម្បីឲ្យគាត់រៀបចំឧបករណ៍សម្រាប់អូសទាញ និងបង្រៀនឲ្យអ្នកជំនាន់ក្រោយចេះប្រើប្រាស់ឧបករណ៍នោះឲ្យបានត្រឹមត្រូវ។ អ្វីដែលត្រូវប្រុងប្រយ័ត្នបំផុតនោះគឺថា ប្រសិនបើឲ្យដំរីអូសឈើធ្ងន់ៗ ត្រូវយកខ្សែពួរធ្វើពីសរសៃរុក្ខ

ជាតិ (ដើមស៊ីហ្សាល់) មកធ្វើជាបង្អៀរចងលើដើមទ្រូងរបស់ដំរី គួរចៀសវាងកុំប្រើខ្សែពួរនីឡុងដែលវាក្តៅខ្លាំង ហើយអាចអាចបណ្តាលឲ្យមានស្នាម ឬរបួសលើស្បែកដំរីនៅលើដើមទ្រូង ជាងខ្សែរពួរធ្វើពីវត្ថុជាតុដើមធម្មជាតិ។

នេះជាដំបូន្មានសម្រាប់អ្នកគ្រប់គ្រងមជ្ឈមណ្ឌល ដែលមានបំណងចង់បង្ហាញសកម្មភាពបែបនេះដល់ភ្ញៀវទេសចរ ព្រោះថាបើយើងប្រើខ្សែពួរមិនបានត្រឹមត្រូវ ឬខុសទំហំវាអាចបណ្តាលឲ្យមានដំបៅ និងស្នាមរបួសលើខ្លួនដំរី។ ប្រសិនបើអ្នកមានហ្មដំរីដ៏ជំនាញ អ្នកនឹងមិនមានបញ្ហាទេ។ ប្រសិនបើអ្នកមិនទាន់មានហ្មដំរីល្អទេ អ្នកគួរជួលហ្មដំរីជំនាញម្នាក់ឲ្យមកធ្វើជាទីប្រឹក្សា ឬជ្រើសរើសគាត់យកមកធ្វើជាបុគ្គលិកអចិន្ត្រៃយ៍នៅក្នុងមជ្ឈមណ្ឌលរបស់អ្នក នោះកាន់តែប្រសើរថែមទៀត។

# ព្រឹត្តិការណ៍ក្នុងជីវិត

## ការកំណត់អាយុ

ការកំណត់អាយុរបស់សត្វដំរីគឺមានប្រយោជន៍ណាស់ ជាពិសេសនៅពេលដែលយើងត្រូវការបញ្ជាក់ថា តើដំរីមួយណាដល់អាយុ ដែលត្រូវចុះបញ្ជីទទួលវិញ្ញាបនប័ត្រ។ ជាធម្មតាការកំណត់អាយុប្រហាក់ប្រហែលរបស់ដំរី គឺអាចធ្វើទៅបានតែជាមួយដំរីក្មេង និងដំរីចាស់ទេ។ ប៉ុន្តែចំពោះដំរីពេញវ័យវិញ ការប៉ាន់ស្មានអាយុអាចមានការភ័ន្តច្រឡំច្រើន។ លក្ខណៈរបស់សត្វដំរីមានដូចខាងក្រោម៖

| | ដំរីក្មេង (ក្រោមអាយុ១២ឆ្នាំ) | ដំរីពេញវ័យ (១២-៤៥ឆ្នាំ) | ដំរីចាស់ (លើសពី ៤៦ឆ្នាំ) |
|---|---|---|---|
| ក្បាល | ស្បែកតឹង និង សៀតផ្កាពបស្មើល្អ | ស្បែកតឹង និងសៀតផ្កាផតបន្តិច | សៀតផ្កាខូងជ្រៅ |
| ត្រចៀក | គ្មានជ្រួញនៅផ្នែកខាងលើនៃត្រចៀក | មានជ្រួញនៅផ្នែកខាងលើនៃត្រចៀក | មានជ្រួញខ្លាំងនៅផ្នែកខាងលើនៃត្រចៀក |

| | | | |
|---|---|---|---|
| | គ្មានស្នាមហែកនៅផ្នែកខាងក្រោមត្រចៀក | នៅផ្នែកខាងក្រោមត្រចៀកមានស្នាមហែកខ្វះៗ | នៅផ្នែកខាងក្រោមត្រចៀកមានស្នាមហែកជាច្រើន |
| ស្បែក | ក្រាស់ តឹង រាបស្មើ គ្មានស្លាកស្នាម និងទន់ល្អ | ក្រាស់ មិនសូវជ្រីវជ្រួញខ្លាំងទេ និងនៅទន់ | មានស្នាមជ្រួញ ស្វិតទ្រោម គ្រើម និងស្ងួត |
| សាច់ដុំ | ដុំៗ និងខ្លាំង | ដុំៗ និងខ្លាំង | ទន់រយាក និងខ្សោយ |
| ជើងនិងក្រចក | រង្វង់ជើង និងកជើងមានទំហំប៉ុនគ្នា ក្រចកជើងរលោងល្អ | រង្វង់ជើង ធំជាងកជើងបន្តិច ក្រចកជើងនៅរលោង បាតជើងមិនទាន់មានស្នាមប្រេះទេ | រង្វង់ជើងធំខ្លាំងជាងកជើង ក្រចកជើងរីករបកៗ និងគ្រើមៗ |
| កន្ទុយ | គ្មានកន្ទួល / រមួលរោមកន្ទុយរលូនល្អ | គ្មានកន្ទួល / រមួលរោមកន្ទុយរលូនល្អ | មានពកៗ រោមកន្ទុយជ្រុះ |
| លាមក | ម៉ត់ល្អ | ម៉ត់ល្អ | គ្រើមៗ នៅសល់ស្លឹករុក្ខជាតិ ឬសូម្បីតែចេកដែលមិនអាចរំលាយ |

## ការកំណត់រដូវបន្តពូជ

សត្វដំរីញីដែលចិញ្ចឹមក្នុងស្រុកភាគច្រើន ចាប់ផ្តើមចូលវ័យអាចបន្តពូជបាននៅពេលវាចាប់ផ្តើមមានអាយុប្រហែល ៩ ឆ្នាំ ឬអាចលើសពីនេះ ហើយឈានដល់រដូវកាលដោយញីដោយឈ្មោលមានរយៈពេលប្រហែល ១៦ សប្តាហ៍ឬ ៤ ខែ។ ដូច្នេះជាមធ្យមក្នុងរយៈពេលមួយឆ្នាំ ដំរីញីអាចនឹងបង្កាត់ពូជ និងមានផ្ទៃពោះបានតែប្រមាណជា ៣ ដង។ សត្វដំរីមិនបង្ហាញសញ្ញាណាមួយ នៅលើរាងកាយខាងក្រៅរបស់វាច្បាស់លាស់ថាពួកវាឈានចូលដល់រដូវដោយញីដោយឈ្មោលទេ គឺវាខុសគ្នាពីសត្វដទៃទៀត ដូចជា

គោ ក្របី ជ្រូក និងឆ្កែដែលតែងមានហើមប្រដាប់បន្តពូជ ឬក៏អាចមានឈាមរដូវ ឬទឹករំអិលនៅពេលវាចង់ដោយឈ្មោល។ ដូច្នេះហ្មដំរីត្រូវចេះសង្កេតមើលដោយយកចិត្តទុកដាក់ និងកត់សម្គាល់នូវភាពប្រែប្រួលនៃអាកប្បកិរិយារបស់ដំរី។

ហ្មដំរីដែលល្អប្រាកដជានឹងដឹង នៅពេលដំរីរបស់គាត់ឈានចូលដល់វ័យបន្តពូជ។ ប្រសិនបើមានដំរីញីណាមួយចូលដល់ពេញវ័យបន្តពូជ ពេលនោះដំរីឈ្មោលតែងតែប្រើប្រមោយរបស់ពួកវាហិតក្លិនសរីរាង្គភេទ ឬទឹកនោមរបស់ដំរីញីមួយនោះជាញឹកញាប់។ ប្រសិនបើអ្នកជាអ្នកសង្កេតការណ៍ដ៏ស្ទាត់ អ្នកនឹងអាចមើលឃើញថាប្រដាប់ភេទរបស់ដំរីញីធ្លាក់ចុះបន្តិច ហើយហៀរទឹកនោមញឹកញាប់។ ដំរីញីភាគច្រើននឹងបក់កន្ទុយជាញឹកញាប់ ត្រដុសនឹងប្រដាប់ភេទរបស់វា ហើយដំរីញីខ្លះទៀតនឹងលើកកន្ទុយឡើងលើអាកាសដូចជាការធ្វើសញ្ញាដើម្បីផ្សាយពាណិជ្ជកម្មដែរ។ ពេលខ្លះទៀតដំរីឈ្មោលដែលពេញវ័យអាចបង្កាត់ពូជបាននឹងបង្ហាញភាពរំជើបរំជួលស្រែកយំ ហើយថែមទាំងបង្កការខូចខាតដល់ដំរីដទៃទៀតដែលនៅក្បែរនោះទៀតផង។ សត្វដំរីញីខ្លះទៀតនឹងបញ្ចេញបរិមាណអង្គជាតុរាវ ដែលមានលក្ខណៈដូចទឹករំអិលថ្លាៗ។ ប្រសិនបើសត្វដំរីញីដែលបង្ហាញឥរិយាបថបែបនេះ ហើយបានបង្កាត់ជាមួយដំរីឈ្មោល នោះវាមានឱកាសមានផ្ទៃពោះខ្ពស់ណាស់។

ដើម្បីកំណត់ឲ្យបានត្រឹមត្រូវថាតើដំរីញីណាមួយចង់ដោយឈ្មោល យើងត្រូវតែត្រួតពិនិត្យតាមដានដំរីញីនោះជារៀងរាល់ថ្ងៃ។ ពេលវេលាល្អបំផុតសម្រាប់ធ្វើការត្រួតពិនិត្យវា គឺនៅពេលព្រឹកមុនពេលដំរីត្រូវបានបញ្ជូនទៅឲ្យធ្វើការ។ ជាពិសេស គឺនៅក្នុងមជ្ឈមណ្ឌលធំៗ ការងារត្រួតពិនិត្យនេះអាចធ្វើទៅបាន ដោយឲ្យដំរីញីដែលមានអាយុបង្កាត់ពូជទាំងអស់តម្រង់ជួរ ហើយឲ្យវាបង្ហាញត្រគាករបស់វា បន្ទាប់មកយកដំរីឈ្មោលមកឲ្យហិតធ្វើតេស្តម្តងមួយៗ។ ប្រសិនបើមានដំរីញីណាមួយចង់ដោយឈ្មោល ពេលនោះដំរីឈ្មោលនឹងបង្ហាញពីចំណាប់អារម្មណ៍យ៉ាងខ្លាំង ហើយវានឹងប្រើប្រមោយរបស់វាហិតក្លិនប្រដាប់ភេទរបស់ដំរីញី។

## ការព្យាករណ៍វដ្តបន្តពូជ

ការកំណត់វដ្តបន្តពូជរបស់ដំរីញីអាចនឹងមានប្រយោជន៍ទៅបាន នៅពេលណាដែលយើងមានដំរីឈ្មោលអាចបង្កាត់ពូជបាននៅក្បែរនោះ។ ក្នុងករណីដែលគ្មានដំរីឈ្មោលសម្រាប់បង្កាត់ពូជនៅក្បែរនោះទេ ការរកឃើញវដ្តបន្តពូជរបស់ដំរីញីនឹងជ្រុលពេល ដើម្បីរៀបការបង្កាត់ពូជ ព្រោះយើងត្រូវរៀបចំធ្វើការដឹកជញ្ជូនដំរី ហើយសំខាន់បំផុតនោះគឺ ត្រូវទុកពេលវេលាឲ្យសត្វទាំងពីរមានអារម្មណ៍សុខស្រួលជាមួយគ្នាសិនមុនពេលធ្វើការបង្កាត់ពូជជាក់ស្តែង។

ដូច្នេះយើងត្រូវធ្វើការព្យាករណ៍ទុកជាមុន ចំពោះវដ្តកាលដែលដំរីញីរបស់យើងអាចនឹងចង់ដោយឈ្មោល ដែលវាពិតជាមានប្រយោជន៍ខ្លាំងណាស់ដល់ម្ចាស់ដំរីញីណាដែលចង់បង្កាត់ពូជដំរីរបស់គាត់។ រយៈពេលដំរីញីចង់ដោយឈ្មោលជាមធ្យមប្រហែល ១៦ សប្តាហ៍ (១១២ ថ្ងៃ) ប៉ុន្តែដំរីញីជាច្រើនអាចនឹងមានវដ្តចង់ដោយឈ្មោលយឺត ឬលឿនជាងនេះ ដែលអាចខុសគ្នាពីរបីថ្ងៃ ឬជាច្រើនសប្តាហ៍។ តែយើងមានវិធីល្អមួយដើម្បីធ្វើការព្យាករណ៍ទុកក្នុងរយៈពេលមួយ ឬពីរសប្តាហ៍ ថាតើពេលណាដំរីញីរបស់យើងអាចនឹងចង់ដោយឈ្មោល។

១. ពេលដែលដំរីញីរបស់អ្នកចង់ដោយឈ្មោលជាលើកដំបូង

នៅក្នុងប្រតិទិនត្រូវកត់ត្រាកាលបរិច្ឆេទៈ ថ្ងៃទី ខែ ឆ្នាំ ។

២. ពេលដែលដំរីញីរបស់អ្នកចង់ដោយឈ្មោលជាលើកដំបូង

នៅក្នុងប្រតិទិនត្រូវកត់ត្រាកាលបរិច្ឆេទៈ ថ្ងៃទី ខែ ឆ្នាំ ។

ប្រើប្រតិទិនរាប់ចំនួនថ្ងៃចន្លោះពីពេលវាចង់ដោយឈ្មោលលើកទីមួយ និងទីពីរ។

សរសេរចំនួនថ្ងៃនៅលើប្រតិទិនៈ ថ្ងៃ។

នៅលើប្រតិទិនចាប់ពីកាលបរិច្ឆេទដែលដំរីញីរបស់អ្នកចង់ដោយឈ្មោលលើកទីពីរ ហើយរាប់ចំនួនថ្ងៃដែលយើងបានកត់ត្រាខាងលើទៅមុខបន្តទៀត។

កត់ត្រាកាលបរិច្ឆេទនោះទុកៈ ថ្ងៃទី ខែ ឆ្នាំ ។

កាលបរិច្ឆេទចុងក្រោយនេះហើយ គឺជាថ្ងៃដែលដំរីញីរបស់អ្នកអាចនឹងចង់ដោយឈ្មោលជាលើកទីបី។

*នៅពេលដឹងពីថ្ងៃដែលដំរីញីរបស់អ្នកចង់ដោយឈ្មោល ប្រហែលជាពីរបីសប្តាហ៍មុនកាលបរិច្ឆេទនេះ អ្នកអាចរៀបចំសម្ភារៈដឹកជញ្ជូនដំរីញីរបស់អ្នកយកទៅដាក់បា (ឬក៏ធ្វើផ្ទុយពីនេះ ដោយទៅដឹកដំរីបាមកវិញក៏បាន) ហើយអ្នកត្រូវទុកពេលឲ្យពួកវាប្រហែលមួយសប្តាហ៍ទៀត ដើម្បីឲ្យដំរីញីឈ្មោលទាំងពីរបានស្គាល់គ្នាមុនពេលដំរីញីចង់ដោយឈ្មោលមែនទែន។*

*វិធីសាស្ត្រនៃការព្យាករណ៍នេះច្រើនតែដំណើរការបានល្អ ប៉ុន្តែវាអាចមានខុសខ្លះដែរ ជាពិសេសប្រសិនបើដំរីញីនោះឈឺធ្ងន់ ធ្វើការហួសកម្លាំង ខ្វះចំណីអាហារ ឬពិបាកខាងផ្លូវចិត្ត ដូចជាផ្លាស់ទៅទីតាំងថ្មីដែលដំរីញីនោះមិនចូលចិត្ត ឬមួយក៏វាមិនចូលចិត្តដំរីបានោះ។*

## ការដាក់បា

*ជាធម្មតាមុនពេលយកដំរីពីរញីឈ្មោលពីរក្បាលទៅដាក់ជាមួយគ្នាឲ្យពួកវាបង្កាត់ពូជ ជាការល្អបំផុតយើងគួរតែផ្តល់ឱកាសឲ្យវាទាំងពីរបានស្គាល់គ្នា និងធ្វើឲ្យពួកវាទាំងពីរមានអារម្មណ៍ជាមួយគ្នាសិន។ ប្រសិនបើពួកវាទាំងពីរមិនចូលចិត្តគ្នាទេ ពួកវាអាចនឹងធ្វើឲ្យខូចខាតដល់គ្នាទៅវិញទៅមក ឬក៏ពេលខ្លះ ដំរីបានោះអាចនឹងព្យាយាម "រំលោភសេពសន្ថវៈ" លើដំរីញី ហើយវាអាចនឹងសម្លាប់ដំរីញីនោះទៀតផង។ ជាធម្មតាដំរីញីចូលចិត្តដំរីឈ្មោលដែលមានមាឌធំជាង និងអាយុច្រើនជាង ហើយដំរីញីខ្លះមិនចូលចិត្តដំរីឈ្មោលដែលមានមានភ្លុកទេ។*

*អ្នកមិនគួរផ្គូផ្គងបង្កាត់ដំរីដែលមានជាប់សាច់ញាតិនឹងគ្នាទេ ព្រោះកូនដំរីដែលបានមកពីការបង្កាត់នោះអាចខ្សោយ ឬខូចទ្រង់ទ្រាយណាមួយ។*

*កន្លែងដែលត្រូវជ្រើសរើស សម្រាប់ដាក់សត្វដំរីញីឈ្មោលទាំងពីរឲ្យវាបង្កាត់ពូជគ្នា ត្រូវតែជាកន្លែងដែលមានភាពស្ងប់ស្ងាត់ មានម្លប់ត្រជាក់ល្អ និងនៅក្បែរទឹក។ រយៈពេលដែលដំរីញីឈ្មោលទាំងពីរមានការចាប់អារម្មណ៍លើគ្នា ដើម្បីធ្វើការបង្កាត់ពូជអាចនៅពេលណាមួយ ចាប់ពីមួយសប្តាហ៍រហូតដល់មួយខែ អាស្រ័យទៅលើចំណង់ផ្លូវភេទរបស់ដំរីបា និងចំណូលចិត្តរបស់ដំរីញី។ ច្រវាក់របស់ដំរីបាត្រូវតែប្រឡាយឲ្យបានវែង។ ចំ*

ណែកដំរីញីវិញ មិនត្រូវចង់វាទេ ដើម្បីការពារនៅពេលដែលដំរីបាមិនសប្បាយចិត្ត វាអាចនឹងធ្វើឲ្យខូចខាតដល់ដំរីញី បើសិនដំរីញីនោះមិនសុខចិត្តបង្កាត់ពូជជាមួយវា។

មុនពេលពាក់គ្នា ដំរីញីឈ្មោលទាំងពីរនឹងមានអាកប្បកិរិយាចូលជិតទាក់ទងគ្នា។ ដំរីបានឹងប្រើប្រមោយ ឬក៏ភ្លុករបស់វា ដើម្បីរុញដំរីញីឲ្យនៅពីមុខវា។ ចំណែកដំរីញីនឹងប្រើប្រមោយរបស់វា ដើម្បីស្រង់ក្លិន ឬស្ទាបលិង្គរបស់ដំរីឈ្មោល ហើយដំរីបានឹងប្រើប្រមោយរបស់វាធ្វើដូចគ្នា គឺស្រង់ក្លិន ឬស្ទាបសរីរាង្គភេទរបស់ដំរីញីវិញដែរ។ នៅពេលដែលលិង្គរបស់ដំរីបាឡើងរឹងខ្លាំង លិង្គរបស់វានឹងកោងមានរាងជាអក្សរ 'S' (មានប្រវែងពី ១,៥ ទៅ ២ ម៉ែត្រ)។ ដំរីបានឹងឡើងពាក់ដំរីញីពីខាងក្រោយ ហើយការឡើងពាក់គ្នាម្តងៗនឹងមានរយៈពេលពីមួយទៅពីរនាទី។ ដំបូងសត្វដំរីញីឈ្មោលទាំងពីរទំនងជាត្រូវគ្នាខ្លាំងណាស់ គឺពួកវាពាក់គ្នារហូតដល់ទៅ ១០ ដងក្នុងមួយថ្ងៃ ប៉ុន្តែមួយរយៈពេលក្រោយមក ពួកវានៅពាក់គ្នាប្រហែលពី ២ ទៅ ៣ ដងក្នុងមួយថ្ងៃ។ ជាធម្មតាពួកវាពាក់គ្នានៅពេលព្រឹក និងពេលព្រលប់ គឺនៅពេលដែលសីតុណ្ហភាពចុះត្រជាក់។ (នៅពេលដែលសត្វដំរីកំពុងពាក់គ្នា ហ្មដំរីនិងអ្នកដទៃទៀតដែលនៅជិតនោះត្រូវតែស្ងាត់ស្ងៀម កុំឲ្យមានសម្លេងរំខាន ឬធ្វើសកម្មភាពណាមួយដែលអាចរំខានដល់ដំរី។)

បន្ទាប់ពីបានពាក់គ្នាគ្នាមួយរយៈហើយ មានដំរីបាខ្លះបានក្លាយទៅជាចុះប្រេងប្រសិនបើរឿងនេះកើតឡើង យើងត្រូវតែយកដំរីបាចេញទៅភ្លាមៗ ប្រសិនបើស្ថានភាពហាក់ដូចជាមានគ្រោះថ្នាក់ ឬប្រសិនបើយើងមិនអាចគ្រប់គ្រងដំរីបានោះបាន។

## ការបង្កាត់ពូជ

### ការជ្រើសរើសដំរីយកមកបង្កាត់ពូជ

### ដំរីបា

- ត្រូវមានអាយុចន្លោះពី ២០-៥០ ឆ្នាំ។
- រាងកាយគួរតែមានមាឌធំល្អ រូបរាងសង្ហា និងរឹងមាំ។ នៅពេលដំរីបាដើរ សាច់ដុំរបស់វាគួរតែផុសឡើង។ ផ្ចត់នៅលើស្បែកមិនគួរធ្លាក់ចុះទេ។
- គ្មានជម្ងឺ។
- គ្មានស្នាមរបួស ឬខូចទ្រង់ទ្រាយកន្លែងណាមួយលើរាងកាយ។

- មិនមានបុគ្គលិកលក្ខណៈទម្លាប់អាក្រក់ណាមួយ ដូចជាចេះតែរគ្រវីក្បាលញឹក។
- មិនកាចឈ្លានពានលើគេ ជាពិសេសដូចជាមិនធ្លាប់មានប្រវត្តិវាយប្រហារលើហ្មដំរី ឬទៅលើដំរីដទៃទៀត។
- មានចំណង់ខាងផ្លូវភេទខ្លាំងក្លា ដែលវាតែងពន្លូតលិង្គចេញពីស្រោមស្បែករបស់វាជាញឹកញាប់ និងបង្ហាញថាវាចង់ឡើងពាក់ នៅពេលដែលមានដំរីញីនៅជិត។
- មានកេរ្តិ៍ឈ្មោះថាជាបាបង្កាត់ពូជដ៏ល្អ និងបានបង្កើតកូនជាច្រើនពិតប្រាកដ។

## ដំរីញី

- ត្រូវមានអាយុចន្លោះពី ១៥ ទៅ ៥០ ឆ្នាំ។ (បើមានអាយុលើសពី ២០ ឆ្នាំ ដំរីញីនោះនោះប្រហែលជាធ្លាប់ផើម ឬធ្លាប់មានកូនរួចទៅហើយ។)
- សមនឹងស្ថានភាពរាងកាយ មិនធាត់ពេក និងមិនស្គមពេក។
- មានសុខភាពល្អ ដោយមិនមានជម្ងឺ ឬស្ថិតក្នុងស្ថានភាពពិការ។
- មាននិស្ស័យល្អ។
- មិនមានបញ្ហានៅពេលកើតកូន ដូចជាធ្លាប់មានរលូតកូន បង្កើតកូនដោយមានការលំបាកខ្លាំង ឬវាយប្រហារកូនខ្លួនឯងជាដើម។

## ពេលផើម

ដំរីញីផើមមានរយៈពេលពី ២០ ទៅ ២៣ ខែ។ ហ្មដំរីភាគច្រើនជឿថាកូនដំរីឈ្មោល ចំណាយពេលនៅក្នុងពោះរបស់មេវាយូរជាងកូនដំរីញី។

ពិតជាពិបាកប្រាប់ថាតើដំរីញីណាមួយចាប់ផ្តើមផើមហើយ ឬនៅ គឺរហូតទល់តែចេញពោះធំផើមពិតប្រាកដទើបដឹង។ ប៉ុន្តែហ្មដំរីដែលជំនាញអាចដឹងថាដំរីញីរបស់ខ្លួនចាប់ផ្តើមផើម នៅពេលគាត់សង្កេតឃើញថាដំរីញីរបស់គាត់លែងចង់ដោយឈ្មោលទៀតហើយ។ បន្ទាប់ពីផើមបានមួយឆ្នាំ ដោះនិងពោះដំរីញីរីកធំ ហើយប្រហែលមួយខែមុនពេលសំរាលកូន ប្រសិនបើអ្នកច្របាច់ដោះនោះ នឹងមានសារធាតុរាវថ្លាៗចេញមក។ ដំរីញីផើមមានសកាពយឺតយ៉ាវ ងងុយដេក គឺហាក់ដូចជាធ្ងន់ខ្លួនដើរលើកជើងមិនចង់រួច។ ដំរីញីផើម មិនត្រូវបង្ខំវាឲ្យធ្វើការហួសកម្លាំងពេកទេ ព្រោះអាចធ្វើឲ្យវារលូតកូនដោយ

ឯកឯង។ ត្រូវតែផ្តល់ចំណីអាហារបន្ថែមដូចជាចេក ស្រូវ និងអំបិលគ្រាប់ (ដោយកិនអំបិលដុំឲ្យទៅជាគ្រាប់តូចៗ ហើយយកទៅត្រាំក្នុងទឹកឲ្យដំរីផឹក ឬដោយលាយជាមួយចំណីអាហាររបស់វា) ប៉ុន្តែអាហារបន្ថែម ឬអាហារបំប៉នមិនគួរផ្តល់ឲ្យវា នៅពេលដំរីញីនោះផើមជិតគ្រប់ខែហើយទេ ព្រោះកូនក្នុងពោះអាចធំពេក ដែលនាំឲ្យលំបាកនៅពេលវាកើតកូន។

## កំណើត

នៅពេលដំរីញីមួយជិតសម្រាលកូន ត្រូវតែយកវាចេញទៅដាក់ឲ្យឆ្ងាយពីដំរីដទៃទៀត។ យើងត្រូវយកវាទៅដាក់កន្លែងស្ងាត់មួយ មានម្លប់ល្អ មិនចោត ផ្ទៃដីរាបស្មើល្អ ជាកន្លែងដែលមានដីទន់ ឬវាលស្មៅ។ ប្រសិនបើមានសត្វដំរីញីចំណាស់ណាមួយ ដែលមេវាធ្លាប់ស្គាល់ ត្រូវតែនាំដំរីចាស់នោះទៅជិដំរីញីដែលជិតកើតកូន ដើម្បីឲ្យដំរីមេចំណាស់នោះធ្វើជា "ម្តាយមីង" ដើម្បីលួងលោមវា និងជួយថែរក្សាកូននៅពេលកើត។

សត្វដំរីញីភាគច្រើនបង្កើតកូននៅពេលយប់។ នៅពេលជិតកើតកូន ដំរីញីនឹងបង្ហាញពីភាពធុញថប់ មិនចង់ស៊ីចំណីអាហារ ឬផឹកទឹក ហើយហាក់ដូចជាអស់កម្លាំង។ ពេលខ្លះសត្វដំរីញីនោះនឹងប្រើប្រមោយរបស់វាផ្លុំស្មៅ ដីខ្សាច់ ធូលី។ល។ ដាក់លើខ្នងរបស់វា ហើងលើកចុងកន្ទុយឡើងលើ។ ដំរីញីនឹងដេកក្រោកៗ ហើយបញ្ចេញសម្លេងបង្ហាញពីការឈឺចាប់។ ទឹករំអិលរាវថ្លាៗ ដែលមានលាយឈាមខ្លះនឹងហូរចេញសរីរាង្គភេទរបស់វា។ នៅពេលខ្លះបាតជើងវានឹងរីកធំដូចជាត្រីកោណដែរ។ ដំរីនឹងលើកកន្ទុយរបស់វាជាប្រចាំ ហើយតំបន់ជុំវិញសរីរាង្គភេទរបស់វានឹងហើម ហើយរីកធំប្រហែល ៣ ឬ ៤ ម៉ោង។ កំណើតពិតប្រាកដនិងចាប់ផ្តើមក្នុងរយៈពេលពីរបីនាទីទៀត។

កូនដំរីដែលទើបនឹងកើតជាធម្មតាមានទម្ងន់ប្រហែលពី ៧០ ទៅ ១០០ គីឡូក្រាម និងមានកំពស់ប្រហែល ៨០ ទៅ ៩០ សង្ទីម៉ែត្រ។

ទាំងជើងខាងមុខ ឬជើងខាងក្រោយលេចចេញមុនគេក្នុងកំណើតធម្មតា។ នៅពេលកូនដំរីដល់ដី វានៅតែគ្របដណ្តប់ដោយថង់សុក។ ម្តាយវានឹងប្រើជើង ឬប្រមោយរបស់វាដើម្បីហែកស្រោមសុក ហើយមេវាអាចនឹងប្រើប្រមោយរបស់វាដើម្បីផ្លុំខ្សាច់លើ

កូនដំរី ឬយកស្មៅជូតកូនដំរី ដើម្បីបោសសម្អាតទឹករំអិល។ មេវានឹងប្រើជើងរបស់វាដើម្បីអង្រួនកូនដំរី ឬគោះកូនដំរីថ្នមៗ ដើម្បីរំញោចឲ្យកូនដំរីចាប់ផ្ដើមដកដង្ហើម។ ពេលខ្លះមេដំរីប្រើប្រមោយរបស់វា ដើម្បីបឺតយកទឹករំអិល និងវត្ថុរាវចេញពីថង់ទឹកភ្លោះ និងចេញពីមាត់របស់កូនដំរី។ កូនដំរីមិនគួរឃ្លាតឆ្ងាយពីមេវានៅពេលនេះទេ ព្រោះអាចធ្វើឲ្យមេវាភ័យ ឬខឹង ហើយអាចជាន់ឈ្លីលើកូនរបស់វាហួតដល់ស្លាប់ទៀតផងក៏មានដែរ។

កូនដំរីនេះនឹងចំណាយពេលប្រហែលកន្លះម៉ោង ដើម្បីប្រឹងងើបឈរ ហើយដើរទៅរកមេវា ដើម្បីទៅរកបៅដោះ។ ទឹកដោះដំបូងរបស់ដំរីមានគុណភាពខ្ពស់បំផុតហើយត្រូវបានគេហៅថា "ទឹកដោះលឿង" ដែលមានអាហារូបត្ថម្ភដ៏អស្ចារ្យ ហើយក៏មានអង្គបដិប្រាណប្រឆាំងនឹងជម្ងឺផ្សេងៗផងដែរ។ ប្រសិនបើកូនដំរីនោះមិនបានទទួលទឹកដោះដំបូង ដែលមានតែក្នុងរយៈពេលពីរថ្ងៃដំបូងនោះទេ វានឹងខ្សោយ ហើយងាយនឹងកើតជម្ងឺ។

ជាធម្មតាសុកនឹងត្រូវធ្លាក់ចេញមកក្រៅតាមសរីរាង្គភេទរបស់មេវា ក្នុងចន្លោះពី ១ ទៅ ៣០ ម៉ោងបន្ទាប់ពីកើតកូនរួច។

នៅពេលដំរីផើម ម្ចាស់គួរតែដឹងពីប្រវត្តិ និងនិស្ស័យរបស់វា ដូចជាវាធ្លាប់មានរលូតកូន ធ្លាប់មានកូនម្ដងរួចហើយតែកូនមុននោះបានស្លាប់ ឬធ្លាប់ធ្វើឲ្យកូនរបស់វាមានបួស។ ប្រសិនបើវាធ្លាប់មានប្រវត្តិដូចខាងលើនេះ ពេទ្យសត្វគួរតែមានវត្តមាននៅទីនោះ ដើម្បីធានាដល់សុវត្ថិភាពរបស់មេដំរី និងកូនរបស់វា។

ចំពោះមេដំរីដែលទើបតែបង្កើតកូនជាលើកដំបូង យើងត្រូវតែមើលថែទាំវាយ៉ាងយកចិត្តទុកដាក់ជាពិសេស ព្រោះវាគ្មានបទពិសោធន៍ ហើយប្រតិកម្មរបស់មេវាចំពោះកូនដំរីក៏មិនអាចទាយទុកជាមុនបានដែរ។ ដំរីស្រុកដែលគ្មានបទពិសោធន៍អាចនឹងច្រឡំដោយការឈឺចាប់នៅពេលវាបង្កើតកូន និងឈាមដែលហូរចេញពីសរីរាង្គភេទរបស់វា។ លទ្ធផលនៃការភ័យខ្លាចអាចបណ្ដាលឲ្យមេវាវាយប្រហារលើកូនដំរី ដែលទើបនឹងកើត ហើយថែមទាំងអាចសម្លាប់កូនរបស់វាទៀតផង។ (ចំពោះដំរីព្រៃវិញ ដំរីញីក្មេងៗតែងធ្លាប់បានឃើញ និងជួយម្ដាយរបស់ពួកវាបង្កើតកូនពី ៣ ទៅ ៤ ក្បាល មុនពេលដល់វេនពួកវាត្រូវបង្កើតកូនផ្ទាល់ខ្លួន)។

## ការជ្រើសរើសទីកន្លែង

កន្លែងដែលមេដំរីត្រូវបង្កើតកូន ត្រូវតែមានម្លប់ល្អ មានសភាពស្ងប់ស្ងាត់ មានអាកាសធាតុត្រជាក់ និងមានខ្យល់ចេញចូលបានល្អ។ មិនត្រូវឲ្យមានមនុស្សសត្វ ឬយានយន្តបង្កការរំខានឡើយ។ ទីតាំងត្រូវតែខ្ពស់ និងគ្មានប្រហោងដី គ្មានសំរាម គ្មានវត្ថុមុតស្រួច និងគ្មានសារធាតុគីមី និងគ្មានគ្រោះថ្នាក់ផ្សេងៗទៀត។ ត្រូវតែមានសសរគ្រឹះ ឬដើមឈើ ដើម្បីចងច្រវាក់មេដំរី។

## រៀបចំក្រុមការងារ

មនុស្សដែលត្រូវមកជួយបង្កើត ឬមើលថែទាំងកូនដំរី ដែលទើបនឹងកើតត្រូវតែមានភាពក្លាហាន រឹងមាំ និងរាងវៃ ព្រោះបើមេដំរីប្រែក្លាយទៅជាសត្វកាចសាហាវ ហើយព្យាយាមបង្ករបួសស្នាម ឬប៉ុនប៉ងសម្លាប់កូនរបស់វា នោះពួកគេត្រូវប្រញាប់ប្រញាល់ញែកយកកូនដំរីនោះចេញភ្លាមៗ។ ពួកគេត្រូវជូតកូនដំរីឲ្យបានស្អាត និងស្ងួត ហើយជួយឲ្យកូនដំរីងើបឈរ។ ក្នុងពេលជាមួយគ្នានោះដែរ ពួកគេត្រូវតែគ្រប់គ្រង និងព្យាយាមលួងលោមមេដំរី និងធ្វើឲ្យវាស្ងប់។ បន្ទាប់មកក្រុមការងារត្រូវនាំកូនដំរីមកជិតមេវា ដើម្បីកំណត់ថាតើវានឹងទទួលយកកូននោះដែរឬទេ។ ប្រសិនបើមេវាទទួលយកកូនវាហើយមិនធ្វើបាបវាទេ បន្ទាប់មកត្រូវសង្កេតមើលកូនដំរី ដើម្បីឲ្យដឹងថាតើវាអាចបៅដោះដោយខ្លួនឯងបានទេ ហើយតើមេវាបង្ហាញពីក្តីស្រឡាញ់ និងយកចិត្តទុកដាក់ថែកូនដែរឬទេ។

ការរៀបចំពិសេសពីរយ៉ាង ចាំបាច់សម្រាប់មេដំរីដែលទើបបង្កើតកូនជាលើកដំបូង និងមេដំរីដែលធ្លាប់មានបញ្ហា៖

១. ត្រូវនៅជិតវា និងសង្កេតមើលវាដោយយកចិត្តទុកដាក់បំផុត ដោយហ្មដំរីត្រូវមាននៅនឹងដៃនូវឧបករណ៍ ដែលគាត់ត្រូវការដើម្បីគ្រប់គ្រងដំរី។ ត្រូវតែមានដំបងឬស្សីមួយដែលមានប្រវែងប្រហែលពីរម៉ែត្រ ហើយមានចុងស្រួច។ បើមេដំរីព្យាយាមធ្វើឲ្យកូនរបស់វាមានរបួស សូមប្រើដំបងឬស្សីនោះដើម្បីបំបែកមេវាចេញពីកូនដំរីភ្លាមៗ។

២. ត្រូវជូនដំណឹងដល់ពេទ្យសត្វរបស់អ្នក និងត្រៀមជួយប្រសិនបើមានបញ្ហា នៅពេលមេវាប្រែក្លាយជាកាច ឬព្យាយាមវាយប្រហារលើកូនរបស់វា។ ពេទ្យសត្វអាចប្រើថ្នាំ

រំខាប់អារម្មណ៍ ដើម្បីធ្វើឲ្យមេដំរីមានសភាពស្ងប់ស្ងៀម ហើយកូនរបស់វាមានសុវត្ថិភាព ទើបយើងព្យាយាមយកកូនទៅដាក់ឲ្យមេវាជាថ្មីម្តងទៀត។

### ទំនាក់ទំនងរវាងកូនដំរី និងមេរបស់វា

ជាធម្មតាកូនដំរីគួរតែត្រូវបានរក្សាទុកជាមួយមេរបស់វាអស់រយៈពេលបីឆ្នាំ មុនពេលទទួលការហ្វឹកហាត់ ជាពេលវេលាដែលកូនដំរីភាគច្រើននឹងផ្តាច់ដោះពីមេរបស់វាដោយខ្លួនឯង។ កូនដំរីនឹងចាប់ផ្តើមស៊ីចំណីអាហារដូចជាចេក និងស្មៅទន់ពី ៣ ទៅ ៦ ខែ។ ចាប់ផ្តើមពី ៦-៨ ខែ កូនដំរីនឹងស៊ីលាមកម្តាយខ្លះៗ (ឬលាមកដំរីពេញវ័យមួយផ្សេងទៀត) ដើម្បីចម្លងដាក់ក្នុងខ្លួនរបស់ពួកវានូវមីក្រូសរីរាង្គមានប្រយោជន៍មួយចំនួនដែលពួកវាត្រូវការប្រើ ដើម្បីជួយសម្រួលដល់ការរំលាយអាហាររបស់ពួកវា។ ក្នុងអំឡុងពេលបីឆ្នាំនេះ មេដំរីនឹងបង្រៀនកូនវាពីរបៀបស្វែងរកចំណី ព្រមទាំងវិធីដើម្បីចៀសវាងគ្រោះថ្នាក់ផ្សេងៗ ដូចជាពស់ជាដើម។ ក្នុងអំឡុងពេលនេះ មិនត្រូវយកមេរបស់វាឲ្យទៅធ្វើការទេ ព្រោះទង្វើនេះអាចបង្កឲ្យមានគ្រោះថ្នាក់ ដោយសារមេដំរីមានអារម្មណ៍រំខាន និងព្រួយបារម្ភអំពីកូនរបស់វា។ លើសពីនេះទៅទៀតកូនដំរីអាច "ធ្វើអ្វីផ្តេសផ្តាស់" [វាអាចលេង និងដើរផ្សងព្រេងចេញឆ្ងាយពីមេរបស់វា] ដែលងាយបង្កឲ្យមានគ្រោះថ្នាក់។

### ការផ្តាច់ដោះ

ចំពោះដំរីស្រុកការផ្តាច់ដោះនៅអាយុ ៣ ឆ្នាំគឺល្អបំផុត។ បើកូនកូនដំរីមានសុខភាពល្អ គេអាចផ្តាច់ដោះវានៅអាយុ ២ ឆ្នាំ គឺអាចធ្វើទៅបានដរាបណាគេត្រូវផ្តល់ចំណីអាហារឲ្យបានល្អព្រោះកូនដំរីក្មេងអាយុ ២ ឆ្នាំអាចចាប់ផ្តើមស៊ីអាហារធម្មជាតិបានហើយវាធំហើយរឹងមាំល្មមអាចហ្វឹកហាត់បាន។ កូនដំរីឈ្មោលមានចរិតលក្ខណៈសមរម្យដែលអាចបំបែកចេញពីមេរបស់វាបានស្រួលជាងកូនដំរីញីៗ។

### ចំណីអាហារសម្រាប់កូនដំរី

តាំងពីកើតដល់អាយុ ៤ ខែ កូនដំរីបៅតែទឹកដោះមេវាប៉ុណ្ណោះ។ ចាប់ពីអាយុប្រាំខែទៅ កូនដំរីព្យាយាមទំពារ និងស៊ីចំណីអាហារដែលមេវាកំពុងស៊ី។

ចាប់ពីអាយុ ៦ ខែ កូនដំរីនឹងស៊ីលាមករបស់មេវា ដើម្បីចម្លងដាក់ក្នុងខ្លួនវានូវមីក្រូសរីរាង្គមួយចំនួនដែលចាំបាច់ក្នុងការរំលាយអាហារជារុក្ខជាតិគ្រើមៗ ដែលជាអាហារបំប៉នៗ ចាប់ពីអាយុ ៨ ខែ កូនដំរីនឹងចាប់ផ្តើមស៊ីចេកទុំ និងអាហារទន់ៗងាយរំលាយៗ

ចាប់ពីអាយុ ១០ ទៅដប់ ១២ ខែ កូនដំរីនឹងចាប់ផ្តើមស៊ីចំណីអាហាររឹងផ្សេងៗរួមមានរុក្ខជាតិ និងបន្លែៗ

សម្រាប់ឆ្នាំដំបូងនៃជីវិតរបស់កូនដំរី អាហារសំខាន់របស់វានៅតែជាទឹកដោះមេវាៗ បន្ទាប់ពីអាយុបានមួយឆ្នាំមក កូនដំរីនឹងស៊ីចំណីអាហារកាន់តែច្រើនឡើង ៗ ដែលមាននៅក្នុងធម្មជាតិ រហូតដល់កូនដំរីមានអាយុ ២ ឬ ៣ ឆ្នាំ។ នៅអាយុប្រហែលជា ៣ ឆ្នាំមេវានឹងផ្តាច់ដោះកូនរបស់វាដោយខ្លួនឯង ដើម្បីរៀបចំខ្លួនបង្កាត់ពូជបន្តទៀត។ ជិតពីរឆ្នាំក្រោយមក មេដំរីនោះនឹងបង្កើតកូនទីពីរ នោះមានន័យថាមេដំរីមានសុខភាពល្អអាចបង្កាត់ពូជបានគ្រប់រដូវ នឹងបង្កើតកូនដំរីប្រហែលរៀងរាល់ ៥ ឆ្នាំម្តងៗ ទាំងដំរីព្រៃ និងដំរីស្រុកសុទ្ធតែមានវដ្តជីវិតបែបនេះដូចគ្នាៗ

នៅក្នុងប្រទេសថៃបច្ចុប្បន្ន កូនដំរីរស់នៅក្នុងស្ថានភាពមួយក្នុងចំណោមពីរដូចខាងក្រោមៗ ក្នុងករណីទីមួយ តាមរបៀបពីបុរាណ កូនដំរីនៅជនបទឆ្ងាយ ហើយវាចំណាយពេលច្រើននៅជាមួយមេរបស់វានៅក្នុងព្រៃៗ ក្នុងករណីបែបនេះ កូនដំរីស្រុករស់នៅស្រដៀងនឹងកូនដំរីដំរីព្រៃ ដោយមេរបស់វាជួយរកចំណីអាហារក្នុងធម្មជាតិ ដូចនេះកូនដំរីត្រូវការការចំណីអាហារបន្ថែមតិចតួច ឬមិនបាច់សោះក៏បានដែរៗ នៅពេលដែលកូនដំរីរឹងមាំ និងមានសុខភាពល្អធម្មតាហើយ ហ្មដំរី ឬម្ចាស់ដំរីមិនចាំបាច់ផ្គត់ផ្គង់ចំណីអាហារបន្ថែមទេៗ

ក្នុងករណីទីពីរមេនិងកូនដំរីត្រូវបានរក្សាទុកនៅក្នុងជំរុំទេសចរណ៍ ឬកន្លែងផ្សេងទៀតដែលចំណីអាហារភាគច្រើនត្រូវបានផ្គត់ផ្គង់ដោយមនុស្សៗ បែបនេះអាហាររបស់កូនដំរីក្នុងរយៈពេល ៣ ឆ្នាំដំបូង ឬរហូតដល់ផ្តាច់ដោះ គួរតែជាអាហារទន់ៗ ដែលងាយទំពារ និងរំលាយ (ចេកទុំ សំបកអំពៅៗលៗ) និងត្រូវផ្តល់ឲ្យវាក្នុងបរិមាណតិចតួចរហូតដល់កូនដំរីអាចស៊ីចំណីបានដោយខ្លួនវាផ្ទាល់ៗ ស្មៅដែលផ្តល់ឲ្យវាត្រូវតែស្អាត និងត្រូវឲ្យវាក្នុងបរិមាណតិចតួចៗ កូនដំរីដំរីដែលចិញ្ចឹមនៅក្នុងបរិស្ថានសិប្បនិម្មិតបែបនេះអាច

នឹងមានបញ្ហាជាមួយនឹងអាហាររូបត្ថម្ភ និងការរំលាយអាហារជាងកូនដំរី ដែលបានចិញ្ចឹមនៅក្នុងស្ថានភាពធម្មជាតិទាំងស្រុង។

ចាប់ពីអាយុបីឆ្នាំទៅកូនដំរីអាចស៊ីចំណីអាហារដូចគ្នានឹងដំរីពេញវ័យដែរ ប៉ុន្តែយើងត្រូវតែកាត់ចំណីទាំងនោះជាចំណែកតូចៗ ដើម្បីឲ្យកូនដំរីងាយស្រួលស៊ី។

## ចំណីអាហារសម្រាប់កូនដំរីកំព្រាក្នុងអំឡុងពេលបីខែដំបូង

ប្រសិនបើមេដំរីព្យាយាមវាយប្រហារលើកូនរបស់វាដែលទើបនឹងកើត ឬប្រសិនបើមេវាមិនចង់ ឬមិនអាចបំបៅដោះកូនរបស់វាបានទេ នោះហ្មដំរីត្រូវប្រញាប់យកទឹកដោះដំបូងពីមេរបស់វា ដើម្បីយកទៅបំបៅកូនដំរីនោះ។ (ការងារនេះត្រូវធ្វើក្នុងរយៈពេលដប់ពីរម៉ោងក្រោយពេលកើត។) គួរតែព្យាយាមស្វែងរកមេដំរី ដែលនៅក្បែរនោះ ដើម្បីធ្វើជាមេដោះជួយបំបៅកូនដំរីនោះ ប៉ុន្តែប្រសិនបើមិនអាចធ្វើទៅបានទេ នោះចាំបាច់ត្រូវផ្គត់ផ្គង់ទឹកដោះពីប្រភពផ្សេងទៀត ជាធម្មតាគឺទឹកដោះគោម្សៅ ដែលយើងអាចរកបានយ៉ាងងាយស្រួលនៅលើទីផ្សារ។ ប៉ុន្តែប្រភេទទឹកដោះគោម្សៅដែលងាយរកបានជាធម្មតាពិបាករំលាយ ហើយអាចបណ្តាលឲ្យការលូតលាស់ចុះខ្សោយ មិនរឹងមាំ មានការទល់លាមក រាករូស និងរហូតដល់ស្លាប់ក៏មានដែរ។

១. *ម្សៅទឹកដោះគោសម្រាប់កូនសត្វ* ដូចជាកូនគោ ក្របី ជ្រូក ឬឆ្កែដែរ មានលក់នៅតាមហាងផ្គត់ផ្គង់ចំណីសត្វគ្រប់ទីកន្លែង វាជាទឹកដោះគោដែលមានតម្លៃថោកបំផុត។ ប៉ុន្តែទឹកដោះគោម្សៅថោកអាចបណ្តាលឲ្យរាក និងទល់លាមក។ មុនពេលប្រើវា ជាការល្អបំផុត ត្រូវពិគ្រោះជាមួយពេទ្យសត្វ ឬប្រសិនបើអ្នកប្រើវា ហើយកូនដំរីមានបញ្ហារំលាយអាហារ សូមអ្នកបញ្ឈប់វាជាបន្ទាន់ និងត្រូវពិគ្រោះជាមួយពេទ្យសត្វ។

២. *ទឹកដោះគោម្សៅសម្រាប់ទារកមនុស្ស* គឺមានដាក់លក់នៅតាមហាងគ្រប់ទីកន្លែង តែវាមានតម្លៃថ្លៃ ហើយអាចបណ្តាលឲ្យរាក ពិបាករំលាយ យើងអាចកត់សម្គាល់តាមរយៈពណ៌ស លាមករាវ។ ប្រសិនបើមានរឿងនេះកើតឡើង សូមទៅពិគ្រោះជាមួយពេទ្យសត្វភ្លាមៗ។

៣. *រូបមន្តម្សៅទឹកដោះគោសម្រាប់ទារកមនុស្ស ដែលមានការលំបាកក្នុងការរំលាយអាហារ* (lactose) ភាគច្រើនធ្វើពីសណ្តែកសៀង។ វាថ្លៃជាងទឹកដោះគោម្សៅធម្ម

*តារបស់ទារក ប៉ុន្តែពេលខ្វះវាក៏បណ្ដាលឲ្យរាក ឬទល់លាមកផងដែរ។ បើដូច្នេះសូមបញ្ឈប់ជាបន្ទាន់ ហើយត្រូវទៅពិគ្រោះជាមួយពេទ្យសត្វ។*

*៤. **រូបមន្តពិសេសសម្រាប់កូនដំរី** គឺល្អបំផុត ប៉ុន្តែត្រូវបញ្ជាទិញវាពីបរទេស។*

*កូនដំរីជាច្រើនបានស្លាប់នៅក្នុងប្រទេសថៃជារៀងរាល់ឆ្នាំ ដោយសារពួកគេបានផ្ដល់ទឹកដោះមិនត្រឹមត្រូវ ដែលកូនដំរីមិនអាចរំលាយបាន។ ក្នុងការជ្រើសរើសទឹកដោះគោម្សៅ ឬរូបមន្តល្អបំផុតសម្រាប់កូនដំរី អ្នកគួរតែពិគ្រោះជាមួយពេទ្យសត្វជាមុនសិន។*

**ទឹកដោះគោម្សៅលាយ**

*ក្នុងការលាយ អ្នកត្រូវស្ងោររីលជាមួយទឹកពុះរាល់វត្ថុប្រើប្រាស់ទាំងអស់ មុនពេលរៀបចំទឹកដោះ ឬផ្ដល់ទឹកដោះឲ្យកូនដំរី។ ការផ្ដល់ចំណីដល់កូនដំរី ទាមទារការយកចិត្តទុកដាក់ខ្ពស់បំផុតចំពោះអនាម័យ ពីព្រោះកូនដំរីងាយឆ្លងជម្ងឺរាក និងអាចស្លាប់បាន។ (មើលមេរោគជម្ងឺរាកនៅទំព័រទី ១៦៩) ក្នុងការលាយទឹកដោះ អ្នកគួរសិក្សាដោយយកចិត្តទុកដាក់នូវការណែនាំដែលបានបោះពុម្ពនៅផ្នែកម្ខាងនៃកំប៉ុងទឹកដោះ។*

*យើងមិនត្រូវបន្ថែមស្ករពីលើទៀតទេ ព្រោះជាតិស្ករវាអាចបណ្ដាលឲ្យកូនដំរីមានជម្ងឺរាក។ យើងក៏ត្រូវតែផ្ដល់ថ្នាំគ្រាប់វីតាមីន និងកាល់ស្យូមច្រើនមុខបន្ថែមទៀត ជារៀងរាល់ថ្ងៃដល់កូនដំរី។*

*យើងត្រូវឲ្យកូនដំរីបៅទឹកដោះគោតែក្នុងបរិមាណតិចតួចបានហើយ រៀងរាល់ពេលយើងឲ្យវាបៅម្ដងៗ ប៉ុន្តែត្រូវឲ្យវាបៅឲ្យបានញឹកញាប់។ អ្នកថែរក្សា ឬហ្មដំរីត្រូវតែនៅជាមួយកូនដំរីទាំងយប់ទាំងថ្ងៃ មិនត្រូវទុកវាចោលលើសពីមួយម៉ោងទេ ទោះជាស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ។ យើងត្រូវឲ្យកូនដំរីបៅគ្រប់ពេលដែលវាឃ្លាន គឺនៅពេលដែលយើងឃើញវាស្រែកហៅ ឬនៅពេលកូនដំរីនោះដើរទៅរកអ្នកថែវា។*

***អ្នកគ្រប់គ្រងមជ្ឈមណ្ឌលត្រូវប្រយ័ត្ន៖** ការមើលថែទាំកូនដំរី មិនមែនជាការងារដែលអ្នកអាចចាត់តាំងឲ្យហ្មដំរីមួយណាធ្វើក៏បាននោះទេ ព្រោះការងារនេះក៏ដូចជាការងាររបស់គិលានុបដ្ឋាយិកា ដែលត្រូវមើលថែទាំដំរីឈឺដែរ។ ជារឿយៗមនុស្សដែលពូកែជាងគេ គឺហ្មដំរីដើងចាស់ ឬក៏ភរិយារបស់ហ្មដំរី ព្រោះការងារនេះតម្រូវឲ្យមានការលះបង់ច្រើន ដូចគ្នាទៅនឹងការថែទាំកូនរបស់មនុស្សយើងដែរ។*

## **វិធីផ្តល់ទឹកដោះគោ**

*មានវិធីសាស្ត្រជាច្រើនក្នុងការផ្តល់ទឹកដោះគោ ដូចជាដាក់ក្បាលដោះកៅស៊ូ ដាក់ក្នុងដបទឹកដោះគោ ឬប្រើទុយោចេញពីដបទឹកដោះគោ ទុយោត្រូវមានប្រវែងវែងល្មមដល់អណ្តាត និងដើមបំពង់ក ទើបកូនដំរីអាចបឺតទឹកដោះគោបាន។ បើកូនដំរីនៅតូចទើបនឹងកើត យើងត្រូវផ្តល់ទឹកដោះគោឲ្យវារៀងរាល់ពីរ ឬបីម៉ោងម្តង។ នៅពេលកូនដំរីចំរើនវ័យធំបន្តិចហើយ ការបំបៅពេលយប់អាចខានបាន។ បន្ទាប់ពីកូនដំរីមានអាយុប្រាំបួនខែហើយ មួយថ្ងៃឲ្យវាបៅបួនដង គឺគ្រប់គ្រាន់ហើយ។ ត្រូវផ្តល់ចំណីទៅតាមពេលវេលាទៀងទាត់ជារៀងរាល់ថ្ងៃ បើមានការផ្លាស់ប្តូរពេលវេលាត្រូវតែតិចតួចបំផុត ហើយម្យ៉ាងទៀតការផ្តល់ចំណីគួរតែធ្វើឡើងដោយមនុស្សតែម្នាក់ដដែល ព្រោះកូនដំរីនឹងតាមតែអ្នកដែលថែទាំវាខ្លាំងណាស់។ ត្រូវផ្តល់ទឹកដោះគោដល់កូនដំរីរហូតដល់អាយុពី ១៥ ទៅ ១៨ ខែ បន្ទាប់ពីនោះពួកវានឹងអាចស៊ីតែស្មៅ និងរុក្ខជាតិដទៃទៀត។*

*ប្រសិនបើកូនដំរីនោះមានជម្ងឺរាក យើងត្រូវតែបញ្ឈប់ការផ្តល់ទឹកដោះនោះភ្លាមៗ ហើយត្រូវផ្តល់អេឡិចត្រូលីតជំនួសវិញ (វាមានតម្លៃថោក និងមាននៅតាមគ្រប់ឱសថស្ថានទាំងអស់) គឺជាផលិតផលពីម្សៅ ហើយយើងត្រូវបន្ថែមទឹក។ បន្ទាប់មកយើងត្រូវទៅពិគ្រោះជាមួយពេទ្យសត្វភ្លាមៗ។*

## **ចំណីអាហារសម្រាប់កូនដំរីកំព្រាដែលមានអាយុពី ៣ ទៅ ៦ ខែ**

*បន្ទាប់ពីអាយុបានបីខែហើយ កូនដំរីអាចចាប់ផ្តើមស៊ីចំណីអាហាររឹងខ្លះៗបាន ដូចជាបបរ ដែលមានគ្រឿងផ្សំដូចខាងក្រោម៖*

| | |
|---|---|
| *អង្ករ* | *មួយកំប៉ុង* |
| *ចេកណាំវ៉ាទុំ* | *៥ផ្លែ* |
| *ទឹកស្អាត* | *៣លីត្រ* |
| *អំបិល* | *មួយចឹប* |

*ទឹកគួរតែដាំឲ្យពុះរួចទុកចោលរហូតដល់ត្រជាក់។*

***វិធីសាស្ត្រនៃការរៀបចំ៖*** *ដាំទឹកឲ្យពុះរហូតទាល់តែវាឆ្អិន បន្ទាប់មកច្របាច់ចេកទុំចូលក្នុងខ្ទះមួយដោយដៃរបស់អ្នក ហើយដាក់អង្ករចូល និងដាក់ភ្លើងឲ្យវាពុះទៀត រហូត*

ដល់វាក្លាយទៅជាបបរពាវ រួចហើយបន្ថែមអំបិលមួយចឹប និងទុកបបរឲ្យត្រជាក់។ ឲ្យកូនដំរីផឹកប្រហែល ១,៥ លីត្រក្នុងមួយដង ហើយពីពីរ ទៅបីដងក្នុងមួយថ្ងៃ បង្កើនបរិមាណបបរបន្តិចម្តងៗ។ សូមប្រយ័ត្ន កុំឲ្យកូនដំរីស៊ីឆ្អែតៗពេក ព្រោះវាអាចនឹងក្លាយជាទល់លាមក។

ត្រូវផ្តល់ចេកទុំឲ្យបានច្រើន គឺពីបីទៅបួនដងក្នុងមួយថ្ងៃ ដោយច្របាច់វាឲ្យម៉ត់។ បន្ទាប់ពីបំបៅរួច (មិនថាចេកទុំឬបបរចេក ឬទឹកដោះគោ) អ្នកត្រូវប្រើក្រណាត់ស្អាតដែលត្រាំក្នុងទឹកដើម្បីសម្អាតជុំវិញមាត់របស់កូនដំរី។ ត្រូវប្រើការសម្អាតមាត់វានេះជាឱកាសមួយដើម្បីពិនិត្យមើលផ្នែកខាងក្នុងមាត់របស់វាដោយប្រុងប្រយ័ត្ន ពីព្រោះប្រសិនបើមាត់ឬអណ្តាតរបស់កូនដំរីមានដំបៅវានឹងមិនអាចបរិភោគបានទេ ទោះជាវាឃ្លានយ៉ាងណាក៏ដោយ។ នៅពេលបំបៅកូនដំរីម្តងៗ សមាមាត្រទឹកដោះគោ ចេកណាំវ៉ាទុំ និងបបរត្រូវតែពិចារណាដូចតទៅ៖

ប្រសិនបើកូនដំរីមានលាមកពាវ ឬរាក ត្រូវបន្ថយ ឬដកទឹកដោះគោចេញ តែបើកូនដំរីមានការទល់លាមក ឬមានជម្ងឺមិនរំលាយអាហារ ត្រូវកាត់បន្ថយបបរ តែត្រូវបង្កើនទឹកដោះគោវិញ។ ដូច្នេះនៅពេលចិញ្ចឹមកូនដំរីកំព្រា ហ្មដំរីត្រូវសង្កេតមើលលាមករបស់វារាល់ពេលដែលកូនដំរីបន្ទោរបង់។ ប្រសិនបើលាមកពាវ ឬមានឈាមរអិល ឬប្រសិនបើកូនដំរីមានការទល់លាមក ហ្មដំរីត្រូវហៅពេទ្យសត្វ ដើម្បីព្យាបាលឲ្យបានឆាប់បំផុត។

## អាហារសម្រាប់កូនដំរីកំព្រាដែលមានអាយុពី ៦ ទៅ ១៨ ខែ

នៅពេលកូនដំរីឈានដល់អាយុ ៦ ខែ អ្នកត្រូវទៅរកលាមករបស់ដំរីពេញវ័យ (ជាទូទៅលាមករបស់មេវា) ហើយលាមកនោះត្រូវតែស្រស់ និងពីដំរីដែលមានសុខភាពល្អ។ ឲ្យកូនដំរីស៊ីមួយដុំ ដែលមានទំហំប៉ុនកណ្តាប់ដៃជារៀងរាល់ថ្ងៃ រយៈពេលមួយខែឬពីរខែក្រោយមកទុកឲ្យកូនដំរីវាស៊ី ឬអត់តាមចិត្តវា។ ក្នុងពេលជាមួយគ្នានេះ ត្រូវទៅរកស្មៅប៉ារ៉ាខ្វះៗ (Brachiaria mutica Forsk] ) ឬស្មៅយ៉ាយ៉ា (tawngkong) មកឲ្យកូនដំរី ដូច្នេះកូនដំរីអាចហាត់ស៊ីបាន។ ត្រូវបង្កើនបរិមាណស្មៅបន្តិចម្តងៗ។

សម្រាប់កូនដំរីនៅក្នុងវ័យនេះ ក្រៅពីទឹកដោះគោប្រចាំថ្ងៃ បបរ និងចេក អាហារបំប៉នផ្សេងទៀត គឺមានសំបកអំពៅ ស្មៅ កាល់ស្យូម វីតាមីន និងអ្វីៗផ្សេងៗទៀតដែលពេទ្យសត្វបានចែង។

## អាហារសម្រាប់កូនដំរីកំព្រាដែលមានអាយុពី ១៨ ទៅ ៣៦ ខែ

កូនដំរីនៅអាយុនេះ អាចផ្តាច់ទឹកដោះគោ និងបបរបាន ប៉ុន្តែយើងត្រូវតែផ្តល់បាយដំណើប ជាមួយអំបិលបន្តិចឲ្យវាជាបន្តទៀត។ ពេលខ្លះយើងអាចឲ្យវាផឹកទឹកអំពៅ និងសាច់ដូងខ្ចី។ អាហារសំខាន់ៗ ដែលផ្តល់ឲ្យកូនដំរី គួរតែមកពីក្រុមខាងក្រោម៖

១. ស្មៅផ្សេងៗ រួមមានស្លឹកឫស្សី និងទំពាំង។

២. ខ្ទិះដូង។

៣. ដើមចេកកាត់ជាកង់ៗប្រវែងខ្លីៗបំផុត។

៤. ចេកណាំវ៉ាទុំ និងអំពៅ។

៥. ស្នូលពោតទុំ។

៦. ចំណីសត្វសេះប្រហែល ១,៥ គីឡូក្រាមក្នុងមួយថ្ងៃ មួយដងឲ្យកូនដំរីស៊ីពី ២ ទៅ ៣ ក្តាប់ដៃ។

៧- អំបិលរ៉ែផ្សេងៗ វីតាមីន អាហារបំប៉នជាដើម ដែលមានការណែនាំពីលោកគ្រូពេទ្យសត្វ។

## ការណែនាំដើម្បីអនុវត្តនៅពេលបំបៅដោះ

១. នៅពេលផ្តល់អាហារឲ្យកូនដំរីជាលើកដំបូង ត្រូវផ្តល់ឲ្យវាតែបន្តិចបន្តួចបានហើយ និងបន្ទាប់មកទៀតដឹងថា តើវាងាយរំលាយឬអត់ តាមរយៈការពិនិត្យមើលលាមករបស់វា។ ប្រសិនបើអាហារមិនត្រូវបានរំលាយល្អនោះទេ អាហារដែលត្រូវផ្តល់ឲ្យវា ត្រូវតែយកមកប្របាច់ ឬហាន់ឲ្យម៉ត់ ឬដាំឲ្យពុះរហូតដល់ឆ្អិនល្អ (ដូចជាពោត)។ ប្រសិនបើកូនដំរីមានការទល់លាមក ឬរាកក្រោយពេលស៊ីអាហារនោះ យើងត្រូវតែកាត់បន្ថយ ឬបញ្ឈប់ទាំងស្រុងជាបន្ទាន់។

២. រាល់អាហារដែលផ្តល់ទៅឲ្យកូនដំរី ត្រូវតែកាត់ជាដាបំណែកតូចៗ។

៣. អ្នកត្រូវប្រាកដថារាល់អាហារដែលផ្តល់ទៅឲ្យកូនដំរីគឺស្រស់ល្អ និងមិនមានសារធាតុគីមីពុល។

បន្ទាប់ពីអាយុបានបីឆ្នាំហើយ កូនដំរីអាចស៊ីចំណីអាហារធម្មតារបស់សត្វដំរីពេញវ័យដែរ។

## វ័យចុះប្រេង

វ័យចុះប្រេង គឺជាបាតុភូតធម្មជាតិរបស់សត្វ ស្ទើរតែគ្រប់ដំរីឈ្មោល ដែលមានសុខភាពល្អអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ។ ចំពោះដំរីខ្លះ អាកប្បកិរិយា និងបុគ្គលិកលក្ខណៈរបស់វាមិនផ្លាស់ប្តូរច្រើនទេ នោះគឺពួកវាមិនក្លាយទៅជាសត្វដំរីកាចសាហាវ ឈ្លានពានគេនោះទេ ប៉ុន្តែដំរីភាគច្រើនមានការផ្លាស់ប្តូរអាកប្បកិរិយាខ្លាំង ហើយក្លាយជារឹងរូសមានគ្រោះថ្នាក់ និងឈ្លានពានគេឯង ក្នុងរយៈពេលពីមួយទៅបួនខែ ទើបវាត្រឡប់មកមានសភាពជាធម្មតាដូចដើមវិញ។ នៅពេលវាចុះប្រេងមានអង្គធាតុរាវហូរចេញមក មានក្លិនមិនល្អ ហើយមានពណ៌ប្រផេះថ្លា ឬពណ៌ប្រផេះចាស់។

នៅពេលកំពុងចុះប្រេង សត្វដំរីបាអាចនឹងវាយប្រហារទៅលើហ្មរបស់វា ទៅលើមនុស្សផ្សេងៗទៀតទាំងអស់ ឬនៅដំរីដទៃទៀតសូម្បីតែដំរីញីក៏ដោយ។ ដំរីខ្លះអាចនឹងអត់ធ្មត់ ហើយវាលើកលែងឲ្យមនុស្ស គឺវាឈ្លានពានតែទៅលើដំរីដទៃទៀតទេ។

សត្វដំរីឈ្មោលខ្លះ ចាប់ពីអាយុប្រហែល ១២ ឆ្នាំឡើងទៅ វាចាប់ផ្តើមបង្ហាញសញ្ញាចុះប្រេងបណ្តើរៗហើយ។ ប្រសិនបើសត្វដំរីមានសុខភាពល្អ ហើយបានទទួលអាហារ និងទឹកច្រើន ហើយមានកន្លែងសម្រាកគ្រប់គ្រាន់នោះ ការចុះប្រេងដាដំបូងគេហៅថា "ស្មោចុះប្រេង"។ "ទឹកឃ្មុំចុះប្រេង" ត្រូវបានបង្ហាញដោយការបញ្ចេញទឹករំអិលចេញពីក្រពេញរបស់វា ហើយដំរីបានោះមានឥរិយាបទក្នុងសភាពវង្វេងស្មារតី និងរឹងចចេស។។ ពេលខ្លះដំរីបែបនេះនឹងបង្កឲ្យមានរបួសដល់ដំរីផ្សេងៗទៀត ឬអ្នកថែរក្សាវា ប៉ុន្តែវាមិនសូវខ្លាំងក្លាដូចការចុះប្រេងពិតប្រាកដទេ។ ជាទូទៅសត្វដំរីនឹងចុះប្រេងពិតប្រាកដ នៅប្រហែល ៤ ឬ ៥ ឆ្នាំបន្ទាប់ពី "ស្មោចុះប្រេង" ។

ពេលខ្លះសត្វដំរីញីដែលធាត់ និងមានសុខភាពល្អក៏មាន "ស្មោចុះប្រេង" ដែលភាគច្រើននៅពេលមានឥទ្ធិពលពីខាងក្រៅ ដែលធ្វើឲ្យពួកវាភ័យ ឬមុនពេលបង្កើតកូន។

*ពេលនោះមានចេញទឹករំអិល ដែលមានពណ៌ប្រផេះ និងមានពណ៌ទឹកដោះគោ ដោយគ្មានក្លិនមិនល្អ។ ក្រៅពីមានភាពច្របូកច្របល់ ក៏នៅមានបញ្ហាអាកប្បកិរិយាតិចតួចដែលកើតឡើងចំពោះដំរីបា ដែលស្ថិតក្នុងភាពចុះប្រេងពិត។*

**ចូលដល់ពេលចុះប្រេង** (**១** - **៥ ថ្ងៃ**)

- *ករបស់ដំរីបានឹងឡើងក្រាស់ (វាមានអារម្មណ៍ថាដូចជាមានហ្វូងដំរីអង្គុយនៅលើកញ្ចឹងករបស់វា) ហើយដំរីបានេះហាក់ដូចជាធាត់ជាងមុន។*
- *ក្រពេញសាច់នៅលើថ្ពាសឡើងប៉ោង ហើយយើងចាប់ផ្តើមមើលឃើញច្បាស់។*
- *ដំរីបាចាប់ផ្តើមលែងស្តាប់បញ្ជា ហើយក្លាយជារឹងរូស មិនទទួលបញ្ជា។*
- *ភ្នែករបស់ដំរីបានឹងផ្លាស់ប្តូរទៅជាមានការប្រុងប្រយ័ត្នខ្ពស់ ដោយសំលឹងមើលទៅហ្វូងរបស់វា ដំរីដទៃទៀត ឬអ្វីផ្សេងៗទៀតយ៉ាងយូរ។*
- *លិង្គរបស់វាឡើងរឹងជាញឹកញាប់ ហើយដំរីនឹងបោកលិង្គទៅលើពោះរបស់វា នៅពេលវានោមម្តងៗ ហើងធ្វើហាក់ដូចជាស្រឹមៗ។*
- *ទីបំផុតដំរីបានោះបានក្លាយជាលែងដឹងខ្លួន ហើយចាប់ផ្តើមស៊ីចំណីអាហារតិច។*

**ពេលពេញចុះប្រេង** (**១** - **៥ ខែ**)

- *ក្រពេញឡើងហើមធំ ហើយមានក្លិនស្អុយ និងចេះតែកើនឡើង។ ពេលខ្លះមានទឹករំអិលហូរចូលក្នុងមាត់។*
- *លិង្គរបស់ដំរីបានៅតែបន្តឡើងរឹង ហើយមានទឹករំអិលដែលមានក្លិនស្អុយ ដែលហូរធ្លាក់លើជើងរបស់វា ដែលធ្វើឲ្យមានសំណើម ក្នុងស្ថានភាពមួយហៅថាអាការៈលិង្គបៃតង។*
- *ដំរីនឹងក្លាយទៅជាកាចចង់ឈ្នានពានលើគេឯងគ្រប់គ្នា និងលែងស្គាល់ហ្វូងរបស់វារួមទាំងដំរីផ្សេងៗទៀត ដែលវាធ្លាប់ស្គាល់ពីមុនៗ។ ហ្មដំរី និងអ្នកផ្សេងទៀតដែលនៅជិតដំរីបានោះ ត្រូវតែប្រុងប្រយ័ត្នគ្រប់ពេលវេលា។*

**ចុងបញ្ចប់នៃការចុះប្រេង** (**២ សប្តាហ៍** - **២ ខែ**)

- *ក្រពេញនឹងស្រកថយចុះមកធម្មតាវិញ ហើយបរិមាណទឹករំអិលក៏ថយចុះជាមួយគ្នាដែរ។*

- *ដំរីបាត្រឡប់ជាមានសភាពស្ងប់ស្ងាត់វិញ ហើយចាប់ផ្តើមស្តាប់បញ្ជាហ្មរបស់វាដូចដើមវិញ។*
- *ដំរីបាត្រឡប់មករកសភាពធម្មតាវិញ។*

## ការចំរៀបទុកមុនពេលដំរីចុះប្រេង

*នៅពេលដំរីបាបង្ហាញពីសញ្ញាដំបូងបង្អស់នៃការចុះប្រេងរបស់វា ហ្មដំរីនោះត្រូវតែជ្រើសរើសកន្លែងមួយ ហើយរៀបចំដូចខាងក្រោមៈ*

- *ជ្រើសរើសកន្លែងចងដំរី ដែលមានភាពស្ងប់ស្ងាត់ ហើយដាក់វានៅឲ្យឆ្ងាយពីដំរីផ្សេងទៀត។ សំខាន់គឺត្រូវឲ្យមនុស្សដែលគ្មានកាតព្វកិច្ចជាមួយដំរីឲ្យនៅឆ្ងាយ។*
- *កន្លែងចងដំរីត្រូវតែត្រជាក់ ហើយស្ថិតនៅក្នុងម្លប់ពេញមួយថ្ងៃ។*
- *កន្លែងចងដំរីត្រូវតែមានទឹកស្អាតដែលហូរចេញចូលរហូត។ ប្រសិនបើមិនអាចធ្វើបានទេ ត្រូវតែមានទឹកស្អាតគ្រប់គ្រាន់ ដើម្បីឲ្យដំរីអាចងូតទឹក និងផឹកទឹកបានដោយសុវត្ថិភាព និងដោយងាយស្រួលជារៀងរាល់ថ្ងៃ។*
- *កន្លែងចងដំរីត្រូវតែរាបស្មើល្អ គ្មានគ្រលុក ឬគ្មានធ្លីដែលនាំឲ្យសៅហ្មង ដូចជាសំរាម និងគ្មានវត្ថុមុតស្រួច ដែលអាចបង្កគ្រោះថ្នាក់ដល់ដំរី។*
- *ការជ្រើសរើសទីតាំងចងដំរីឲ្យខ្ពស់ជាងគេបន្តិច គឺមានសារៈសំខាន់ខ្លាំងណាស់ ព្រោះវានឹងជួយសម្រួលដល់ការបង្ហូរចេញក្រៅនូវទឹកភ្លៀង ទឹកដំរីងូត ជាពិសេសទឹកនោមរបស់ដំរី។ ការបង្ហូរទឹកចេញក្រៅឲ្យបានល្អ ក៏នឹងជួយកាត់បន្ថយផលប៉ះពាល់មិនល្អខ្លះលើបញ្ហាជើង និងក្រចកដែលអាចកើតឡើង នៅពេលដំរីមួយត្រូវបានគេឃុំឃាំងអស់រយៈពេលជាច្រើនខែ នៅក្នុងកន្លែងសើម ឬភក់។ ដូចគ្នានេះដែរ គួរជ្រើសរើសកន្លែងណាដែលមានដីអាចស្រូបយកទឹកបានល្អ នោះវាពិតជាមានប្រយោជន៍ណាស់ចំពោះបញ្ហាប្រអប់ជើង និងក្រចក។*
- *ដើម្បីសុវត្ថិភាពគួរតែមានដើមឈើ ឬសសរគ្រឹះសម្រាប់ចងច្រវាក់ដំរី ដែលរឹងមាំល្មមអាចទប់ដំរីកំពុងចុះប្រេងបាន។*
- *រាល់ឧបករណ៍ដែលប្រើសម្រាប់ដំរីកំពុងចុះប្រេង ត្រូវតែមានកម្លាំងខ្លាំងគ្រប់គ្រាន់ដើម្បីទប់ទល់នឹងដំរីបាន ហើយត្រូវត្រៀមឲ្យមាននៅនឹងដៃជានិច្ច។ រាល់មុខតំណ*

តភ្ជាប់ទៅខ្សែព្រវាក់ ត្រូវតែត្រួតពិនិត្យយ៉ាងប្រុងប្រយ័ត្ន ទម្ពក់វិលត្រូវតែរឹងមាំ កុំឲ្យមានចំណុចខ្សោយត្រង់កន្លែងណាមួយ និងអាចវិលចុះឡើងបានដោយសេរី។ គន្លឹះរាងដូចអក្សរ "U" ត្រូវតែដាក់ប្រេង ដើម្បីងាយស្រួលចាប់រឹសចូលទៅក្នុងរន្ធខ្សែស្រប្រឡាយប្រកបដោយសុវត្ថិភាព។

- ត្រូវពិចារណាលើចំណីអាហារពិសេសសម្រាប់ដំរី នៅពេលវាកំពុងចុះប្រេង។

## របបចំណីអាហារនៅក្នុងពេលដំរីកំពុងចុះប្រេង

នៅពេលដំរីស្ថិតនៅក្នុងភាពចុះប្រេង ចំណីអាហារដែលសមស្របបំផុតត្រូវមានអាហារូបត្ថម្ភទាប ដូចជាដើមចេក (ត្រូវកាត់វាប្រវែងប្រហែលមួយចំអាមមុនពេលឲ្យស៊ី) ល្ពៅខ្ចី និងស្មៅស្ងួត (យើងអាចប្រោះទឹកអំបិល ដើម្បីថែក្រអូមមាត់របស់ដំរី) ពីព្រោះអាហារបែបនេះមានអាហារូបត្ថម្ភទាប។ នៅពេលដំរីស៊ីចំណីបែបនេះ វានឹងមានអារម្មណ៍ថាវាបានឆ្អែតភ្លាមៗ។

អាហារផ្សេងទៀតអាចឲ្យវាស៊ីបាន ប៉ុន្តែត្រូវតែបន្ថយឲ្យតិចជាងបរិមាណចំណីអាហារ ដែលធ្លាប់ផ្តល់ឲ្យវាកាលពេលដែលដំរីនោះនៅមិនទាន់ចុះប្រេង។ អាហារដែលមានថាមពលខ្ពស់ ដូចជាស្រូវ បាយដំណើបជាដើម គួរតែជៀសវាង។

អាហារដែលមានថាមពលខ្ពស់នឹងមិនបង្កគ្រោះថ្នាក់ដល់សុខភាព រាងកាយរបស់សត្វដំរីនោះទេ ប៉ុន្តែការផ្តល់ចំណីអាហារដែលមានថាមពលខ្ពស់នឹងធ្វើឲ្យការចុះប្រេងរបស់វានឹងមានរយៈយូរជាងអាហារដែលមានកាឡូរីទាប។ ចំណីអាហារដែលមានកាឡូរីទាប ក្នុងបរិមាណត្រឹមត្រូវនឹងជួយឲ្យសត្វមានសុខភាពល្អ ហើយក៏នឹងឲ្យវាស៊ីចំណីអាហារបានពេញពោះផងដែរ។

**ប្រយ័ត្ន៖** នៅពេលដំរីចុះប្រេង ត្រូវផ្តល់ទឹកស្អាតឲ្យវាឲ្យបានគ្រប់គ្រាន់។

## ការទុកដាក់សាកសពដំរី

នៅពេលសត្វដំរីស្លាប់ សាកសពរបស់វាត្រូវតែស្ថិតនៅក្នុងល័ក្ខខ័ណ្ឌណាមួយ ក្នុងចំណោមល័ក្ខខ័ណ្ឌទាំងពីរ ដែលអាចផ្តល់សុវត្ថិភាពដល់មនុស្ស ឬសត្វដំរីដទៃទៀតក្នុងការបោះចោលសាកសព។ ក្នុងករណីទីមួយ សាកសពមាន "សុវត្ថិភាព" ដំរីបានស្លាប់

ដោយសារចាស់ជរា ដួល គាំងបេះដូង ឡានបុកៗលៗ អ្នកអាចដុត ឬបញ្ចុះសពដំរី ឬយកសាច់របស់វាលក់ក៏បាន ដោយគ្មានការព្រួយបារម្ភទេ ទោះបីជាតាមធម្មតា នៅពេលសត្វស្លាប់ដោយខ្លួនឯង គេមិនគួរបរិភោគសាច់វាក៏ដោយៗ (ទោះជាអ្នកអានសៀវភៅនេះគិតថាការបរិភោគសាច់ដំរីគឺជារឿងសមរម្យ ឬមិនសមរម្យក៏ដោយ ក៏អ្នកស្រុកធ្លាប់ធ្វើបែបនេះគ្រប់ពេលជាយូរមកហើយ ដូច្នេះអ្វីដែលសំខាន់គឺធ្វើវាដោយសុវត្ថិភាពៗ)

ប្រយ័ត្នះ ក្នុងករណីណាក៏ដោយដំរីដែលមានសុខភាពល្អឥតខ្ចោះ ស្រាប់តែស្លាប់តែក្នុងរយៈពេលមួយ ឬពីរថ្ងៃ ដោយមានមូលហេតុតិចតួច ឬគ្មានមូលហេតុច្បាស់លាស់ សាកសពរបស់ដំរីត្រូវតែមានការបញ្ជាក់ពីពេទ្យសត្វ (ដើម្បីដឹងប្រាកដថា តើវាបានស្លាប់ដោយសារជម្ងឺធ្ងន់ធ្ងន់គ្រោះថ្នាក់ដែរ ឬទេ) ។

ករណីទី ២ ដែលសាកសពរបស់ដំរីអាចបង្កគ្រោះថ្នាក់ដល់មនុស្ស ឬដំរីផ្សេងទៀត កាលណាដំរីបានស្លាប់ដោយសារជម្ងឺធ្ងន់ (ប្រភេទផ្សេងៗគ្នាត្រូវបានពិភាក្សាខាងក្រោម) ដែលអាចសម្លាប់មនុស្ស ឬសម្លាប់ដំរី ឬអាចសម្លាប់ទាំងមនុស្ស និងទាំងដំរីៗ ក្នុងករណីគ្រោះថ្នាក់បែបនេះមានពីរប្រភេទទៀតគឺះ ១. ករណីដែលដំរីនោះត្រូវបានព្យាបាលដោយពេទ្យសត្វ ហើយអ្នកបានដឹងពីមូលហេតុច្បាស់លាស់ហើយៗ ២. ករណីដែលហ្មដំរី ឬអ្នកគ្រប់គ្រងមជ្ឈមណ្ឌលដឹង ឬសង្ស័យថាដំរីបានស្លាប់ដោយសារជម្ងឺ តែមិនដឹងច្បាស់ថាជម្ងឺនោះជាជម្ងឺអ្វីទេៗ

ប្រសិនបើដំរីបានស្លាប់ដោយសារតែមូលហេតុអ្វីមួយ ដែលអ្នកគិតថាប្រហែលជាជម្ងឺ សូមអ្នកទៅពិគ្រោះជាមួយពេទ្យសត្វភ្លាមៗ ហើយឲ្យគាត់ធ្វើកោសល្យវិច័យលើសត្វៗ ពេលខ្លះពេទ្យសត្វនឹងអាចប្រាប់អ្នកពីជម្ងឺភ្លាមៗបាន ពេលខ្លះទៀតគាត់នឹងត្រូវយកគំរូដើម្បីធ្វើការវិភាគនៅក្នុងមន្ទីរពិសោធន៍ៗ មានតែនៅពេលដែលអ្នកដឹងពីមូលហេតុពិតប្រាកដនៃការស្លាប់របស់ដំរីនោះទេ ទើបអ្នកនិងពេទ្យសត្វអាចសម្រេចចិត្តដោះស្រាយសាកសពដំរីនោះបានៗ

ប្រយ័ត្នះ មិនត្រូវដោះស្រាយជាមួយសាកសពរបស់ដំរីណា ដែលប្រហែលជាបានស្លាប់ដោយសារជម្ងឺធ្ងន់ (ដូចជាជម្ងឺអាសន្នរោគសត្វ anthrax) ដោយគ្មានពេទ្យសត្វពិនិត្យសាកសពសត្វនោះជាមុនសិនបានទេៗ (តាមការពិត អ្វីដែលល្អបំផុតប្រសិនបើដំរីដែល

ស្លាប់ទាំងអស់ត្រូវបានពិនិត្យដោយពេទ្យសត្វ ប៉ុន្តែដោយសារតែបញ្ហាផ្សេងៗ ឬគ្មានពេលវេលាគ្រប់គ្រាន់ ឬក៏ត្រូវចំណាយថវិកាដល់ម្ចាស់ដំរី ទើបបានជាការពិនិត្យសាកសពដំរីមិនត្រូវបានធ្វើជាញឹកញាប់ៗ) ប្រសិនបើអ្នកព្រងើយកន្តើយនឹងបញ្ហាទាំងនេះ អ្នកអាចសម្លាប់ខ្លួនឯង និងអ្នកដែលបានជួយអ្នកយ៉ាងងាយៗ អ្វីដែលពិសេសបំផុតនោះគឺ មិនត្រូវលក់សាច់សត្វបែបនេះឡើយព្រោះ អ្នកអាចធ្វើឲ្យមនុស្សជាច្រើនស្លាប់ៗ

## កន្លែងកប់សាកសព

ការធ្វើរៀបចំទុកដាក់សាកសពដំរីជាការងាររបស់ពេទ្យសត្វ ប៉ុន្តែដោយសារតែការកប់សាកសពដំរីចោលជាធម្មតាត្រូវធ្វើឡើងនៅកន្លែងដែលដំរីស្លាប់ ទើបម្ចាស់ដំរី ឬអ្នកគ្រប់គ្រងមជ្ឈមណ្ឌលជាអ្នកសម្រេចជ្រើសរើសទីតាំងកប់សាកសាពដំរី ដូច្នេះពួកគេគួរតែពិចារណាដោយយកចិត្តទុកដាក់ជាទីបំផុតៗ ទីតាំងកប់សពគួរតែនៅក្បែរកន្លែង ដែលដំរីស្លាប់ បើមិនដូច្នោះយើងនឹងត្រូវជួលឡានដឹកទំនិញ ឡានស្ទូចយកសាកសពដំរីទៅកប់នៅទីឆ្ងាយៗ

កន្លែងទុកដាក់សាកសពដំរីត្រូវតែស្ថិតនៅ (១) ឆ្ងាយពីតំបន់ដែលមានមនុស្សរស់នៅ (២) ឆ្ងាយពីទឹកហូរ ស្រះ និងប្រភពផ្គត់ផ្គង់ទឹកធម្មជាតិនិង (៣) ឆ្ងាយពីកន្លែងចិញ្ចឹមដំរី ឬសត្វដទៃទៀតៗ ល័ក្ខខ័ណ្ឌទាំងបីខាងលើនេះមានសារៈសំខាន់ណាស់ ជាពិសេសនៅពេលដំរីស្លាប់ដោយសារជម្ងឺឆ្លងៗ ដូច្នេះប្រសិនបើសត្វដំរីណាមួយ កំពុងត្រូវបានគេព្យាបាលនៅកន្លែងណា ដែលមិនត្រូវទៅនឹងល័ក្ខខ័ណ្ឌសុវត្ថិភាពទាំងបីខាងលើ ប៉ុន្តែមើលទៅសត្វដំរីនោះប្រហែលជាមិនរស់ទេ យើងគួរតែនាំវាយកទៅទុកនៅក្បែរកន្លែងដែលត្រូវទុកដាក់សាកសពវាឲ្យហើយទៅៗ នេះជាការពិត ជាពិសេសចំពោះដំរីដែលអាចនឹងមានជម្ងឺឆ្លង ប៉ុន្តែយើងត្រូវយកវាទៅទុកនៅកន្លែងណាមួយ ដែលយើងនឹងត្រូវប្រើកន្លែងនោះសម្រាប់ទុកដំរីឈឺធ្ងន់នាពេលអនាគតៗ

## វិធីសាស្ត្រទុកដាក់សាកសព

យោងទៅតាមច្បាប់ជាតិសម្រាប់គ្រប់គ្រងជម្ងឺឆ្លងរបស់សត្វ សាកសពរបស់សត្វដែលមានជម្ងឺឆ្លងត្រូវតែយកទៅទុកដាក់ដូចខាងក្រោមៗ មានវិធីសាស្ត្រពីរដែលអាច

ទទួលយកបានក្នុងការទុកដាក់សាកសព គឺដុតកំទេចចោល និងការកប់។ វិធីនីមួយៗសុទ្ធតែមានគុណសម្បត្តិ និងគុណវិបត្តិដូចៗគ្នា។

១. ការដុតសាកសពកំទេចចោល៖ ប្រសិនបើមានឡដុតសាកសពសមស្រប នោះការដុតសាកសពដំរីកំទេចចោល គឺជាការងាយស្រួលណាស់ ប៉ុន្តែជាអកុសល កម្រមានឡសម្រាប់ដុតសពដំរីណាស់។ បើដូច្នោះ សាកសពដំរីត្រូវដុតដោយគំនរអុស ឬសំបកកង់កៅស៊ូចាស់ៗ ដាក់នៅជុំវិញ និងនៅពីលើសាកសព។ (ប្រសិនបើយកអុសទៅគរដាក់លើសពដំរីដោយផ្ទាល់ នោះចំហាយទឹក និងឧស្ម័នដែលកាយចេញមក នឹងរំខានដល់ការដុតកំទេចសព គឺវាមិនសូវមានប្រសិទ្ធិភាព ហើយភ្លើងក៏មិនសូវក្តៅខ្លាំងដែរ។) គេអាចប្រើប្រេងឥន្ទនៈដើម្បីជួយបង្កាត់ភ្លើងឲ្យឆេះ។ បុគ្គលិកទាំងអស់គួរមានការប្រុងប្រយ័ត្នខ្ពស់ដើម្បីធានាថាសាកសពដំរីនោះត្រូវបានដុតកំទេចទាំងស្រុង ហើយត្រូវប្រយ័ត្នប្រយែងកុំអោយឆេះរាលដាលដល់តំបន់ផ្សេងទៀត។ បន្ទាប់ពីដុតរួច ត្រូវតែកប់ផេះ ក្នុងករណីមានជម្ងឺធ្ងន់។

គុណសម្បត្តិ៖

- ការដុតមានប្រសិទ្ធភាពណាស់ក្នុងការបំផ្លាញសារពាង្គកាយរបស់មេរោគ ប៉ុន្តែត្រូវមានការយកចិត្តទុកដាក់ខ្ពស់។
- ការដុតមិនត្រូវការទីន្លែងធំទេ។

គុណវិបត្តិ៖

- មានការងារច្រើនណាស់ ដែលត្រូវធ្វើ ត្រូវប្រមូលសំភារៈដែលអាចឆេះបាន ដូចជាឈើ សំបកកង់ ប្រេងឥន្ទនៈជាដើម។
- អាចមានគ្រោះថ្នាក់បង្កើតជាអគ្គីភ័យ អាចធ្វើឲ្យភ្លើងរាលដាលឆេះដល់កន្លែងដទៃទៀត។
- សាកសពអាចដុតមិនបានឆេះសុសល្អ។
- ការដុតត្រូវចំណាយពេលច្រើន ព្រោះភ្លើងត្រូវតែស្មើល្អសម្រាប់រយៈពេលចាប់ពី ៤៨ រហូតទៅដល់ ៧២ ម៉ោង។
- ការដុតមិនអាចដំណើការបានល្អទេ នៅក្នុងរដូវវស្សា។

- *ប្រសិនបើគេប្រើសំបកកង់កៅស៊ូដើម្បីដុតកំទេចសាកសពដំរី ពេលនោះវានឹងមានក្លិនមិនល្អទេ។*

*២. **ការបញ្ចុះសពដំរី៖** សាកសពដំរីត្រូវតែកប់ឲ្យបានជ្រៅល្មម យ៉ាងហោចណាស់ក៏ឲ្យបានជម្រៅមួយម៉ែត្រដែរ ដើម្បីគ្របដណ្តប់ពីលើសាកសពឲ្យបានល្អ។ ក្នុងករណីមានជម្ងឺអាសន្នរោគសត្វ ត្រូវបាចកំបោរពីលើសាកសព និងក្នុងរណ្តៅមុននឹងកប់សាកសពដំរីនោះ។ លាមកដំរី សម្ភារៈដែលបានប្រើជាមួយដំរីនោះ និងសូម្បីតែដីស្រទាប់លើ ក៏ត្រូវតែ កប់ទៅក្នុងរណ្តៅជាមួយគ្នាដែរ។ ក្នុងករណីរជម្ងឺអាសន្នរោគសត្វ ត្រូវតែធ្វើរបងជុំវិញកន្លែងកប់សព មេរោគនៃជម្ងឺនេះអាចរស់បានរាប់សិបឆ្នាំ។*

*គុណសម្បត្តិ៖*

- *ងាយស្រួលដោះស្រាយបានដោយរហ័ស មិនពិបាក។*
- *ការបញ្ចុះសព គឺល្អក្នុងការបញ្ឈប់ការរីកពលដាលនៃជម្ងឺ។*

*គុណវិបត្តិ៖*

- *ការបញ្ចុះសពត្រូវប្រើកន្លែងធំទូលំទូលាយ។*
- *ប្រសិនបើគ្មានគ្រឿងចក្រសម្រាប់ជីករណ្តៅទេ នោះការជីករណ្តៅគឺពិតជាពិបាកណាស់ ហើយត្រូវចំណាយពេលច្រើន។*
- *តែប្រសិនបើប្រើគ្រឿងចក្រសម្រាប់ជីករណ្តៅវិញ វិធីសាស្ត្រនេះថ្លៃណាស់។*

## ជម្ងឺដែលទាមទារឲ្យមានការប្រុងប្រយ័ត្ននៅពេលទុកដាក់សាកសពដំរី

*ជម្ងឺដែលមានគ្រោះថ្នាក់ដល់ទាំងមនុស្ស និងសត្វដំរី គឺអាសន្នរោគ ជម្ងឺក្តៅធ្លួត និងជម្ងឺរបេង។ មុនពេលចូលទៅប៉ះពាល់សាកសពដំរីដោយផ្ទាល់ យើងត្រូវតែរៀបចំខ្លួនដូចតទៅ៖ (១) ពាក់ស្រោមដៃកៅស៊ូ ឬបើមិនអាចរកស្រោមដៃបានទេ ត្រូវជូតដៃជាមួយនឹងម៉េមរមៀត មុននិងក្រោយពេលប៉ះពាល់ផ្នែកដែលអាចមានមេរោគ (២) ពិនិត្យលើខ្លួនយើងឲ្យបានហ្មត់ចត់ នៅកន្លែងដែលមានមុត និងមានរបួស ត្រូវរុំរបួសឬស្នាមមុតទាំងនោះឲ្យបានជិតល្អ ព្រោះមេរោគអាចចូលទៅក្នុងខ្លួនយើងតាមមុខរបួស (៣) កម្មករណាដែលឈឺ ឬមិនស្រួលខ្លួនមិនត្រូវមកចូលរួមក្នុងការងារនោះទេ ព្រោះប្រព័ន្ធការពាររាង*

កាយរបស់ពួកគេនឹងត្រូវចុះខ្សោយ ដែលអាចធ្វើឲ្យពួកគេងាយឆ្លងជម្ងឺទាំងនោះ។ ប្រើម៉ាស ឬក្រណាត់ដើម្បីបិទច្រមុះ និងមាត់ឲ្យបានល្អ។

## ជម្ងឺដែលអាចឆ្លងទៅមនុស្ស

ជម្ងឺ Anthrax ជម្ងឺខាន់ស្លាក់ ជាជម្ងឺនៅលើសត្វ ប៉ុន្តែវាក៏អាចឆ្លងទៅដល់មនុស្សបានផងដែរ ហើយវាច្រើនតែមានគ្រោះថ្នាក់ដល់ជីវិត។ ជម្ងឺអាសន្នរោគសត្វអាចឆ្លងទៅមនុស្ស ឬសត្វមួយទៀត ដោយលម្អងរបស់មេរោគនោះអាចជ្រៀតចូលតាមស្នាមមុត ឬស្នាមរបួសបានយ៉ាងងាយស្រួល នៅពេលយើងចូលរួមក្នុងការងាររៀបចំទុកដាក់សាកសពរបស់ដំរី ដែលមានជម្ងឺនោះ។ ហេតុដូច្នេះហើយបន្ទាប់ពីការដុត ឬបញ្ចុះសាកសពដំរីណាមួយរួចហើយ ហ្មដំរីត្រូវតែងូតទឹកដុសលាងខ្លួនឲ្យហ្មត់ចត់ជាទីបំផុត ហើយត្រូវផ្លាស់ប្តូរសម្លៀកបំពាក់ថ្មីស្អាត មុនពេលចូលទៅជិតដំរីផ្សេងៗទៀត។ ត្រូវស្លៀកសម្លៀកបំពាក់ណាដែលចាស់ជាងគេ ព្រោះសម្លៀកបំពាក់នោះនឹងត្រូវដុតចោលបន្ទាប់ពីចប់ការងារ។

**រោគសញ្ញា៖** រោគសញ្ញារបស់អ្នកដែលឆ្លងជម្ងឺនេះរួចហើយ គឺអ្នកជម្ងឺនោះមានកម្តៅឡើងខ្លាំង មានក្អួត និងមានបញ្ហានៅផ្លូវដង្ហើម។ ករណីខ្លះមានការផ្ទុះចេញដំបៅ និង/ឬមានពងស្បែកនៅលើដៃ ឬកន្លែងណាដែលមេរោគបានចូល។ ជម្ងឺនេះអាចធ្វើឲ្យបាត់បង់ជីវិតមនុស្សពី ១០ទៅ ១៥ ថ្ងៃក្រោយ។ សូមមើលទំព័រទី ១៧៤។

ជម្ងឺរបេងអាចចម្លងពីមនុស្សទៅដំរី ឬពីដំរីទៅមនុស្ស។ ដូច្នេះអ្នកត្រូវចូលរួមរៀបចំទុកដាក់សាកសពដំរី ដែលសង្ស័យថាបានស្លាប់ដោយមានជម្ងឺរបេង ត្រូវតែចាត់វិធានការបង្ការដោយប្រុងប្រយ័ត្ន ដើម្បីជៀសវាងការស្រូបយកមេរោគរបេងចូលខ្លួន ត្រូវមានពាក់ម៉ាសឲ្យបានត្រឹមត្រូវ។ សូមមើលទំព័រទី ១៨២។

ជម្ងឺឆ្កែឆ្កួតជាជម្ងឺកាចសាហាវណាស់ វាអាចវាយប្រហារលើមនុស្ស សត្វដំរី និងថនិកសត្វទាំងអស់។ ជម្ងឺនេះអាចឆ្លងតាមរយៈការខាំរបស់សត្វសាហាវ ឬដោយការចម្លងរោគដែលមាននៅក្នុងឈាម ទឹករំអិល ឬទឹកមាត់របស់សត្វដែលមានជម្ងឺឆ្កែឆ្កួតនេះ។ ហ្មដំរី ឬកម្មករណាដែលមានមុត ឬដំបៅចំហរ គួរជៀសវាងធ្វើការជាមួយសាកសពដំរីដែលបានស្លាប់ដោយសារជម្ងឺឆ្កែឆ្កួត។ ជម្ងឺឆ្កែឆ្កួតបើមានលើខ្លួនមនុស្សណាហើយ អ្នកនោះតែងតែស្លាប់។ សូមមើលទំព័រទី ១៨៩។

*ប៉ារ៉ាស៊ីតខាងក្នុង* ក៏ត្រូវតែគិតគូរឲ្យបានហ្មត់ចត់ដែរ។ ទោះបីជាមិនមានភស្តុតាងដែលបង្ហាញថាមានប៉ារ៉ាស៊ីតនៅខាងក្នុងសាកសពដំរី ដែលអាចឆ្លងទៅមនុស្សក៏ដោយ ក៏អ្នកទាំងអស់គ្នានៅធ្វើការពាក់ព័ន្ធនឹងសាកសពរបស់សត្វដំរី ដែលមានដង្កូវត្រូវតែមានការប្រុងប្រយ័ត្ន។ ជាពិសេសការបរិភោគសាច់ដំរីដែលមានដង្កូវ គួរតែជៀសវាង។

**ជម្ងឺឆ្លងទៅសត្វដំរី**

*ជម្ងឺធ្លាក់ឈាម* (Haemorrhagic septicaemia) គឺជាជម្ងឺឆ្លងរាតត្បាតខ្លាំង ដែលមានសមត្ថភាពឆ្លងពីដំរីមួយ ទៅដំរីដទៃទៀតក្នុងរយៈពេលដ៏ខ្លី។ ដូច្នេះអ្នកណាម្នាក់ ដែលបានចូលរួមក្នុងការទុកដាក់សាកសពដំរី ដែលបានស្លាប់ដោយសារជម្ងឺនេះ ត្រូវជៀសវាងកុំទៅប៉ះពាល់សត្វដំរីផ្សេងៗទៀត ឬជាមួយហ្មដំរីដទៃទៀត គឺត្រូវសម្អាតខ្លួនប្រាណដោយប្រុងប្រយ័ត្ន និងផ្លាស់ប្តូរសម្លៀកបំពាក់ជាមុនសិន។ សូមមើលទំព័រទី ១៧៧។

*ជម្ងឺរាកកើតចេញពីជម្ងឺឆ្លង* វាអាចឆ្លងតាមរយៈមនុស្ស ដូច្នេះកម្មករទាំងអស់ត្រូវតែផ្លូតទឹកដោយប្រុងប្រយ័ត្ន និងផ្លាស់ប្តូរសម្លៀកបំពាក់មុនពេលទៅប៉ះពាល់ដំរី ដែលមានសុខភាពល្អ។ មើលជម្ងឺរាកចាប់ពីទំព័រទី ១៦៨។

*រាល់សម្ភារៈ និងឧបករណ៍ដែលបានប្រើប្រាស់រួច តែត្រូវយកវាទៅធ្វើការសម្លាប់មេរោគឲ្យបានល្អ។ (សូមមើលក្បួនអនាម័យនៅទំព័រទី ៩៧)។*

# ការថែទាំសុខភាពបឋម

*ការថែទាំសុខភាពបឋមគឺសំខាន់ណាស់ ហើយហ្មដំរីទាំងអស់ត្រូវតែសិក្សា ហើយយកទៅអនុវត្តរហូតដល់ស្ទាត់ជំនាញ។ ត្រូវចងចាំជានិច្ចថាដំរីឈឺមួយក្បាលនឹងមិនអាចវិលមករកភាពធម្មតាវិញបានទេ ប្រសិនបើវាមិនបានទទួលការព្យាបាលត្រឹមត្រូវ ទោះបីជាថ្នាំនៅទីនោះច្រើនក៏ដោយ។*

*ការថែទាំសុខភាពបឋមពិតជាមានអត្ថប្រយោជន៍ណាស់ ពីព្រោះហ្មដំរីទាំងអស់ក៏អាចផ្តល់នូវការថែរក្សាដំរីអោយបានត្រឹមត្រូវ មុនពេលពេទ្យសត្វមកព្យាបាលវា ព្រោះហ្មដំរីទាំងអស់អាចតាមដានសុខភាពសត្វបន្ត បន្ទាប់ពីអ្នកពេទ្យសត្វបានមកពិនិត្យរួច*

ហើយហ្មដំរី ឬអ្នកគ្រប់គ្រងមជ្ឈមណ្ឌលក៏អាចព្យាបាលរបួសតិចតួច និងដោះស្រាយបញ្ហាសុខភាពតូចតាចដោយខ្លួនឯងបានដែរ។

## ថ្នាំពេទ្យដែលត្រូវមាននៅក្នុងដៃ

មានថ្នាំពេទ្យមួយចំនួន ដែលហ្មដំរីអាចរក្សាទុកនៅក្បែរខ្លួនបានគ្រប់ពេលវេលាយ៉ាងងាយស្រួល ដើម្បីព្យាបាលបញ្ហាសុខភាពតូចតាច ឬបន្ទាន់។ ថ្នាំពេទ្យភាគច្រើនដែលត្រូវរក្សាទុកនៅក្នុងដៃ គឺសម្រាប់ប្រើប្រាស់លើផ្នែកខាងក្រៅ (ថ្នាំបន្តក់ភ្នែក ថ្នាំបំបាត់ការឈឺចាប់ ថ្នាំបំបាត់ការឈឺមាត់ជាដើម) និងមានប្រយោជន៍ក្នុងស្ថានភាពអាសន្ននៅពេលដែលមិនមានពេទ្យសត្វនៅក្បែរខ្លួន ឬកន្លែងដែលពេទ្យសត្វមិនអាចទាក់ទងបានហើយហ្មដំរី ឬអ្នកគ្រប់គ្រងមជ្ឈមណ្ឌលត្រូវផ្តល់ការព្យាបាលបឋម។

### ១. ថ្នាំដែលត្រូវប្រើលើមុខរបួស

*ថ្នាំលាប អ៊ីយ៉ូត* Tincture៖ *ថ្នាំនេះពណ៌ត្នោតក្រម៉ៅ គេអាចទិញបាននៅតាមឱសថស្ថាន ឬហាងផ្គត់ផ្គង់សម្ភារៈបសុពេទ្យ។*

***វិធីប្រើ៖*** *សម្រាប់លាបលើដំបៅថ្មីៗ (ប៉ុន្តែមិនមានស្នាមរបួសជ្រៅ) ភ្លាមៗ ដើម្បីការពារកុំឲ្យដំបៅនោះក្លាយ។*

*ថ្នាំលាប* Povidone-iodine *១%៖ ពណ៌ត្នោតខ្មៅងងឹតដូចជា អ៊ីយ៉ូត* tincture *ដែរ ប៉ុន្តែវាភាវជាង ១០ ដង ហើយមិនធ្វើឲ្យឈឺផ្សាលើមុខរបួសទេ។ យើងអាចរកវាបានយ៉ាងងាយ និងមាននៅស្ទើរតែគ្រប់ទីកន្លែង ហើយអាចទិញបាននៅតាមឱសថស្ថាន ឬហាងផ្គត់ផ្គង់សម្ភារៈបសុពេទ្យ។*

***វិធីប្រើ៖*** *សម្រាប់ព្យាបាលមុខរបួសថ្មីៗ ដំបៅចាស់ កន្ទែងរលាកភ្នែងៗល។ ដោយយក* Povidone-iodine *១% មួយភាគ ទៅលាយជាមួយទឹក ១០ ភាគ។ ទឹកលាយថ្នាំនេះចាំបាច់ណាស់ ព្រោះថាបើប្រើវាខ្លាំងជាងនេះ វានឹងបណ្តាលឲ្យមានការឈឺផ្សាខ្លាំង និងអាចមានរលាកនៅលើមុខរបួស។ នៅពេលលាងក្អុកដំរី ដែលមានធ្ងន់មេរោគ ត្រូវប្រើ* Povidone-iodine 1% *មួយភាគ លាយជាមួយទឹក ២០ ភាគ។*

ទឹកថ្នាំ Acriflavin៖ វាជាអង្គធាតុរាវពណ៌លឿង។ តាមពិតហ្មដំរីថៃហៅវាថា "ថ្នាំលឿង"។ ថ្នាំទឹក Acriflavin ត្រូវយកវាទៅលាបនៅលើមុខរបួស បន្ទាប់ពីបានសម្អាតស្នាមរបួសនោះរួចហើយ។ យើងអាចរកទិញវាបាននៅតាមឱសថស្ថាន ឬហាងផ្គត់ផ្គង់សម្ភារៈបសុពេទ្យ។

វិធីប្រើ៖ លាបលើមុខរបួសពុំរ៉ៃ ដែលមានខ្ទុះ និងរលួយ / ដំបៅរលួយ។

ទឹកថ្នាំដើមរាជទ្រព្យ (Gentian)៖ វាជាទឹកថ្នាំរាវ មានពណ៌ស្វាយចាស់។ យើងអាចរកទិញវាបាននៅតាមឱសថស្ថាន ឬហាងផ្គត់ផ្គង់សម្ភារៈបសុពេទ្យ។

វិធីប្រើ៖ យើងប្រើថ្នាំនេះ ដើម្បីលាបលើដំបៅមាត់របស់ដំរី លើប្រមោយដំរី និងនៅលើសាច់ដំរីដែលមានជាលិការទន់ៗ [លើក្នាសរំអិល]។ ថ្នាំទឹកនេះមានប្រសិទ្ធភាពណាស់ ជាពិសេសនៅលើស្នាមរបួស ដែលបណ្តាលមកពីការឆ្លងមេរោគផ្សិត។

ទឹកថ្នាំ Hydrogen peroxide ៖ វាជាទឹកថ្នាំរាវ ថ្លា គ្មានពណ៌។ យើងអាចរកទិញវាបាននៅតាមឱសថស្ថាន ឬហាងផ្គត់ផ្គង់សម្ភារៈបសុពេទ្យ។

វិធីប្រើ៖ យើងប្រើវា ដើម្បីសម្អាតស្នាមរបួស ឬដំបៅ ដែលមានខ្ទុះ និងរលួយ។ បន្ទាប់ពីបានលាបវាលើមុខរបួសរួចហើយ ត្រូវទុកវាចោលប្រហែលជា ៥ នាទី មុនពេលយកទឹកស្អាតមកលាងវាចេញ។ យើងគួរតែប្រើអ៊ីដ្រូសែន peroxide តែម្តង ឬពីរដងក្នុងការព្យាបាលដំបូង សម្រាប់សម្អាតមុខរបួស ជាពិសេសដើម្បីសម្អាតខ្ទុះចេញពីមុខរបួស។

ប្រយ័ត្ន៖ ដាច់ខាត មិនត្រូវប្រើអ៊ីដ្រូសែន peroxide លើមុខរបួសថ្មីៗឡើយ។

អាល់កុល៖ វាជាវត្ថុរាវ ថ្លា គ្មានពណ៌ ឬពណ៌ខៀវ។ យើងអាចរកទិញវាបាននៅតាមឱសថស្ថាន ឬហាងផ្គត់ផ្គង់សម្ភារៈបសុពេទ្យ។

វិធីប្រើ៖ យើងប្រើអាល់កុល ដើម្បីសម្អាតស្បែកមុនពេលចាក់ថ្នាំ ឬក៏មុនពេលវះកាត់។ មិនត្រូវប្រើអាល់កុលលាបលើមុខរបួសឡើយ។

ក្រែមថ្នាំផ្សះ៖ ជាក្រែមមានពណ៌លឿង។ យើងអាចត្រូវទិញវាបាន នៅតាមហាងផ្គត់ផ្គង់សម្ភារៈបសុពេទ្យ ឬនៅតាមទីផ្សារទំនើបធំៗណាមួយ។ យីហោរបស់វារួមមាន Baccarin និង Mytocin ជាដើម។

*វិធីប្រើ៖* *យើងប្រើវាលាបលើដំបៅកុំរ៉ែ ដំបៅរលួយ ពី ២ ទៅ ៣ ដងក្នុងមួយថ្ងៃ។ ការលាបថ្នាំនេះលើមុខរបួសមួយរយៈ វានឹងអាចជួយជំរុញការលូតលាស់របស់ជាលិកា។ គុណវិបត្តិរបស់វា គឺភាពស្អិតជាប់ គឺថាវាងាយទាក់ទាញចាប់យកធូលី និងភាពកខ្វក់នៅលើមុខរបួសណាស់។ បន្ទាប់ពីបានលាបថ្នាំនេះរួចហើយ ត្រូវប្រើបង់រុំមុខរបួស ឬដំបៅនោះឲ្យបានជិតល្អ។*

***ថ្នាំផ្សះបាញ់*** (Antibiotic spray)៖ *ថ្នាំផ្សះបាញ់ភាគច្រើន គេលាយជាមួយទឹកថ្នាំដើមរាជទ្រព្រ* (gentian violet) ។ *ថ្នាំបាញ់ប្រភេទនេះ យើងអាចទិញវាបាន នៅតាមហាងផ្គត់ផ្គង់សម្ភារៈបសុពេទ្យ ឬនៅតាមទីផ្សារទំនើបធំៗណាមួយ។ យីហោរបស់វារួមមាន* Alamycin spray *និង* Tetravet aerosol។*ល*។

***វិធីប្រើៈ*** *បាញ់ថ្នាំលើដំបៅកុំរ៉ែ (ដំបៅរលួយ ឬតំបន់ដែលរលួយ។ល។) បន្ទាប់ពីបានសម្អាតរួច។*

***ម្សៅប្រឆាំងនឹងសត្វល្អិត៖*** *ជាល្បាយម្សៅនៃសមាសធាតុសម្រាប់សត្វល្អិត និងថ្នាំប្រភេទអង់ទីប៊ីយោទិច ដែលជួយឲ្យដំបៅឆាប់ជាសះស្បើយ។ មានដាក់លក់នៅតាមហាងផ្គត់ផ្គង់សម្ភារៈបសុពេទ្យ ហើយយីហោធម្មតារបស់វាគឺ* Negasunt ។

***វិធីប្រើ៖*** *រោយម្សៅលើមុខរបួសបន្ទាប់ពីលាងសម្អាតវាហើយ និងបន្ទាប់ពីបានលាបថ្នាំរួចហើយ។ គោលបំណង គឺដើម្បីការពារការឆ្លងជម្ងឺពីសត្វល្អិត ជាពិសេសសត្វល្អិតដែលប៉ុនប៉ងដាក់ពងដាក់នៅលើដំបៅ។*

## ២. ថ្នាំសម្រាប់ស្បែកនិងសាច់ដុំ

***ថ្នាំកាត់បន្ថយការរលាកស្បែក៖*** *សម្រាប់ប្រើនៅក្នុងល័ក្ខខ័ណ្ឌមួយចំនួន ដូចជាស្បែករងការវាយប្រហារបំផ្លាញពីសារធាតុគីមី ដោយសារសត្វល្អិតខាំជាដើម ភាគច្រើនជាថ្នាំស្តេរ៉ូអ៊ីត* (steroids) *ដែលត្រូវបានគេយកមកប្រើ ហើយលាយជាមួយថ្នាំអង់ទីប៊ីយោទិច (ថ្នាំផ្សះ) មាននៅតាមហាងផ្គត់ផ្គង់សម្ភារៈបសុពេទ្យ។ យីហោរួមមាន* Beta-Cream *និង* Beta-Met [*ក្រែម* Betamethazone]។*ល*។

***វិធីប្រើ៖*** *លាបទឹកថ្នាំនៅលើតំបន់ដែលមានរលាកឲ្យបានញឹកញាប់ ពីព្រោះទឹកថ្នាំនេះអាចស្រូបចូលទៅក្នុងស្បែកយ៉ាងលឿន។*

ថ្នាំស្ពឹកសម្រាប់សាច់ដុំនិងសរសៃពួរ៖ ប្រើសម្រាប់លាបលើកន្លែងដែលមានការឈឺចាប់ កន្លែងគ្រេច និងកន្លែងដែលមានហើមជាដើម មានពីរប្រភេទ គឺជាក្រែម និងជាប្រេង។ ឈ្មោះរួមមាន Voltarene ointment, Muay Oil, St. Luke Oil។ល។

វិធីប្រើ៖ លាបថ្នាំនៅលើសាច់ដុំដែលមានការឈឺចាប់ ហើម ឬរលាក យ៉ាងហោចណាស់ក៏ឲ្យបានពីរដងដែរក្នុងមួយថ្ងៃ។

## ៣. ថ្នាំព្យាបាលភ្នែក

ថ្នាំទឹកបន្តក់ភ្នែក៖ ទឹកថ្នាំអង់ទីប៊ីយោទិច (ថ្នាំផ្សះ) គឺជាថ្នាំដែលសំខាន់បំផុត។ គុណសម្បត្តិនៃថ្នាំទឹកបន្តក់ភ្នែក គឺថាវាជួយថែរក្សាភ្នែកឲ្យបានស្អាត ហើយយើងទទួលបានលទ្ធផលលឿនជាងថ្នាំជាក្រមួន (ប៉ូមាដ) ដែលជាធម្មតា យើងត្រូវរង់ចាំរយៈពេលរហូតដល់ប្រហែលជា ២ ថ្ងៃ ទើបអាចទទួលបានលទ្ធផល។ យើងអាចរកទិញវាបាននៅតាមឱសថស្ថានណាក៏បាន។ ឈ្មោះរួមមាន Vanafen និង Chloramphenicol ជាដើម។ សូមមើលការព្យាបាលភ្នែកនៅ ទំព័រទី ១៤៨។

វិធីប្រើ៖ ប្រើនៅពេលដែលមានហៀរទឹកភ្នែកខ្លាំងជាងធម្មតា ភ្នែកដែលមានខ្ទុះដំបៅនៅលើគ្រាប់ភ្នែក។ លាបរៀងរាល់មួយម៉ោងម្តង រហូតដល់ជាសះស្បើយជាស្ថាពរ។

ថ្នាំភ្នែកជាក្រមួន (ប៉ូមាដ)៖ ថ្នាំប្រភេទនេះវានឹងស្ថិតនៅក្នុងភ្នែកបានយូរជាងថ្នាំទឹកបន្តក់ ប៉ុន្តែវាក៏មានគុណវិបត្តិដែរ ដោយសារតែភាពស្អិតរមួតរបស់វា ដែលអាចទាក់ទាញភាពកខ្វក់ កំទេចស្មៅជាដើម។ យើងអាចរកទិញវាបាននៅតាមទីផ្សារ។ ឈ្មោះរួមមាន Vanafen ointment, Tetracycline ointment និង Kemicitin ជាដើម។

វិធីប្រើ៖ ប្រើលើភ្នែកដែលមានហូរទឹកភ្នែកច្រើនជាងធម្មតា លើភ្នែកដែលមានខ្ទុះ ឬលើភ្នែកដែលមានដំបៅ។ ល។ លាបយ៉ាងហោចណាស់ឲ្យបានពីរដងដែរ ក្នុងមួយថ្ងៃ។

## ៤. ថ្នាំបំបាត់ការឈឺចាប់

ថ្នាំបំបាត់ការឈឺចាប់៖ ថ្នាំប្រភេទនេះ វាមានឥទ្ធិពលអាចបន្ថយការឈឺចាប់របស់សត្វដំរីបាន។ ឈ្មោះរួមមាន Daga, Nutamol, Paraset, Sara និង Bayer aspirin ជាដើម។

វិធីប្រើ៖ កិនគ្រាប់ថ្នាំឲ្យទៅជាម្សៅ ហើយដាក់វាឲ្យរលាយក្នុងទឹក ហើយកទៅឲ្យដំរីផឹក ឬក៏យកថ្នាំនោះទាំងគ្រាប់ដាក់ក្នុងចេកទុំ ឬក៏ដាក់ក្នុងចំណីអាហារណា ដែលសត្វ

*ដំរីវាចូលចិត្តខ្លាំង។ ចំពោះសត្វដំរីពេញវ័យ ត្រូវផ្តល់ថ្នាំឲ្យវាប្រហែលជាពី ៤០ ទៅ ៦០ គ្រាប់ក្នុងមួយដង ហើយឲ្យបានមួយដង ទៅពីរដង ក្នុងមួយថ្ងៃរហូតដល់ពេទ្យសត្វមក។*

*ប្រយ័ត្ន៖ ថ្នាំអាស្ពីរីន និងដាហ្គា* (Aspirin *និង* Daga) *មានឥទ្ធិពលធ្វើឲ្យរលាកក្រពះ ប្រសិនបើយើងប្រើវា នៅពេលសត្វដំរីមិនទាន់មានចំណីអាហារនៅក្នុងពោះជាមុនសិន។ ដូច្នេះកុំអោយថ្នាំប្រភេទអាស្ពីរីននៅពេលពោះទទេ។*

## សម្ភារៈនិងឧបករណ៍

*សម្ភារៈនិងឧបករណ៍ ដែលត្រូវតែមាននៅក្នុងមជ្ឈមណ្ឌលដំរី មានពីរប្រភេទ។ ទីមួយ សម្ភារៈនិងឧបករណ៍សម្រាប់មជ្ឈមណ្ឌលដំរី ដែលមានដំរីលើសពីប្រាំក្បាល និងមួយប្រភេទទៀតទុកសម្រាប់ពេលចេញទៅធ្វើដំណើរជាមួយសត្វដំរីណាមួយ។*

### សម្ភារៈនិងឧបករណ៍ដែលត្រូវមាននៅក្នុងមជ្ឈមណ្ឌលដំរី

*សម្ភារៈនិងឧបករណ៍ទាំងនោះ ហ្មដំរីត្រូវការប្រើប្រាស់ ទាំងសម្រាប់ព្យាបាលជម្ងឺ និងទាំងសម្រាប់តម្រូវការប្រចាំថ្ងៃនៅក្នុងមជ្ឈមណ្ឌល។*

***ធុងប្លាស្ទិច ឬដែក ដែលមានចំណុះ ៥ លីត្រ*** *គឺចាំបាច់ណាស់សម្រាប់ទុកដងទឹកឲ្យដំរីផឹក ផ្លូតទឹកឲ្យដំរី សម្រាប់លាងសម្អាតមុខរបួស សម្រាប់ផ្តល់ចំណីអាហារគ្រាប់ ដូចជាស្រូវ។ល។ យ៉ាងហោចណាស់ត្រូវតែមានធុងបែបនេះចំនួន ២ សម្រាប់ដំរីនីមួយៗ។ ធុងទឹកគួរតែគ្មានក្លិនមិនល្អ និងជាប់សារធាតុគីមី ដែលអាចបង្កជម្ងឺដល់សត្វដំរី។*

***ធុងធំ ដែលមានចំណុះ ១០០ លីត្រ*** *សម្រាប់ដាក់ទឹកឲ្យដំរីផឹក នៅពេលពួកវានៅឆ្ងាយពីកន្លែងទឹក។ ត្រូវលាងសម្អាតធុងធំនេះជាប្រចាំ ដូច្នេះវាស្អាតជានិច្ច ហើយមិនមានក្លិនអាក្រក់ទេ។ គួរតែមានធុងធំបែបនេះចំនួន ៣ ឬ ៤ សម្រាប់មជ្ឈមណ្ឌល ដែលមានដំរី ពី៥ ទៅ ១០ ក្បាល ព្រោះដំរីខ្លះវាមិនសុខចិត្តផឹកក្នុងធុងជាមួយសត្វដំរីឯទៀតទេ ហើយហ្មដំរីក៏គួរតែដឹងរឿងនេះដែរ។*

***ប្រយ័ត្ន៖*** *ប្រសិនបើធុង ឬទឹកមានក្លិនមិនល្អ ដំរីនឹងមិនចង់ផឹកទឹកនោះទេ ដូចជាទឹកម៉ាស៊ីនជាមួយក្លរីនច្រើន ឬធុងទឹកដែលធ្លាប់បានដាក់លិតផលប្រេង។ ត្រូវតែលាង*

សម្អាតធុងទឹកយ៉ាងហ្មត់ចត់ និងដាក់ទឹកពេញត្រាំធុងនោះរហូតដល់វាបាត់ក្លិនចាស់មិនល្អណាមួយ ទើបយកវាមកប្រើដើម្បីដាក់ទឹកឲ្យដំរីផឹក។

**ធុងដែកចំណុះ ២០ លីត្រ ឬធ្វើពីសំណប៉ាហាំង** ដែលគេកាត់ផ្នែកខាងលើចេញ ហើយគេយកទៅប្រើសម្រាប់ដាំទឹកពុះ និងយកចំហាយទៅស្អំដើម្បីកាត់បន្ថយការឈឺចាប់នៅត្រង់កន្លែងដែលមានហើម។

**ធុងសម្រាប់លាយថ្នាំបាញ់សម្លាប់សត្វល្អិត** ធុងនេះទុកប្រើសម្រាប់បាញ់ថ្នាំសម្លាប់សត្វល្អិត និងសម្លាប់ប៉ារ៉ាស៊ីត និងប្រើសម្រាប់លាយថ្នាំបាញ់សម្លាប់មេរោគលើដំបៅរបួស សម្អាតធ្មេញ និងក្អុកដែលមានដំបៅ ឬឆ្លងមេរោគ ជាពិសេសសម្រាប់ធ្វើអនាម័យកន្លែងដំរីនៅ។ ធុងនេះមិនត្រូវប្រើសម្រាប់គោលបំណងអ្វីផ្សេងទៀតទេ។

**ទែម៉ូម៉ែត្រ**សម្រាប់វាស់សីតុណ្ហភាពរបស់ដំរីនៅពេលដែលវាមិនសូវស្រួលខ្លួន។ (សម្រាប់វិធីប្រើសូមមើលទំព័រទី ១០៤)។

**សឺរ៉ាំងប្លាស្ទិចដែលមានចំណុះ ៥០ cc** សម្រាប់លាងរបួស ឬបាញ់ថ្នាំដាក់លើមុខរបួស ក្នុងស្ថានភាព ដែលដំរីមិនព្រមឲ្យយើងលាបថ្នាំនៅលើមុខរបួសនោះដោយផ្ទាល់។ យើងអាចយកសឺរ៉ាំង ដែលប្រើរួចទៅស្ងោរក្នុងទឹកក្តៅដាំឲ្យពុះ ហើយយើងអាចយកវាមកប្រើឡើងវិញបាន ប៉ុន្តែមិនត្រូវលាងសម្អាតវា ឬប្រើថ្នាំសម្លាប់មេរោគដើម្បីលាងវាទេ។ (សូមមើលទំព័រទី ៩៧ សម្រាប់វិធីសម្អាត។ ) សឺរ៉ាំងបែបនេះអាចត្រូវការប្រើសម្រាប់ដំរីទាំងអស់ ដូច្នេះយើងគួរតែមាន៣ ឬ ៤ ទុកសម្រាប់ប្រើប្រាស់នៅក្នុងមជ្ឈមណ្ឌលរបស់យើង។

**សឺរ៉ាំងប្លាស្ទិចដែលមានចំណុះពី ១ ទៅ ៣ cc** ដែលត្រូវប្រើដើម្បីបន្តក់ថ្នាំភ្នែក។ អ្នកដាក់ថ្នាំភ្នែកអាចប្រើឡើងវិញបាន ប៉ុន្តែគួរតែប្រើសម្រាប់សត្វដំរីតែមួយប៉ុណ្ណោះបាន ហើយ និងក្រោយពេលប្រើរួច ត្រូវទុកវានៅកន្លែងស្អាត។

**ក្រណាត់ស្អាតប្រហែល ១ x ២ ហ្វីតការ៉េ** គួរតែមានក្រណាត់ស្អាតប្រភេទនេះ ពី ៣ ទៅ ៤ ផ្ទាំងសម្រាប់ដំរីនីមួយៗ។ ក្រណាត់នេះ ទុកប្រើសម្រាប់លាងសម្អាតស្បែកដំរីជុំវិញស្នាមរបួស សម្អាតឧបករណ៍វេជ្ជសាស្ត្រ សម្អាតស្នាមរបួសដែលមានប្រឡាក់ជាដើម ពេលខ្លះយើងយកក្រណាត់នេះ មកប្រើជំនួសបង់រុំសម្រាប់ជូតទឹកភ្នែកឲ្យដំរី ឬលាង

*សម្អាតមុនពេលដាក់ថ្នាំភ្នែកឲ្យវា។ ប្រើក្រណាត់ស្អាតនេះតែជាមួយដំរីមួយប៉ុណ្ណោះ។ ក្រណាត់ដែលយកមកប្រើគួរតែទន់ និងអាចស្រូបយកទឹកបានច្រើន ដូចជាក្រណាត់ប្រភេទ* Terrycloth *។ ត្រូវយកក្រណាត់ប្រើរួចមកស្ងោរទឹកដាំពុះឲ្យបាន ១៥ នាទី។*

***ថង់ផ្លាស្ទិចថ្លាតូចៗ*** *ដែលមានទំហំខុសៗគ្នា ចាប់ពី ៦ អ៊ីញ ទៅ ៩ អ៊ីញសម្រាប់ទុកសឺរ៉ាំងចាក់ថ្នាំ និងឧបករណ៍ផ្សេងៗទៀត ដើម្បីរក្សាវាឲ្យបានស្អាតជាប្រចាំ និងគ្មានធូលី។*

***ថង់សំរាមប្លាស្ទិចធំៗ*** *ទុកសម្រាប់ត្រាំលាងជើងដំរីពេលមានរបួស។ ថង់ប្លាស្ទិចធំៗទាំងនេះក៏អាចទុកប្រើសម្រាប់រក្សាទុកឧបករណ៍ផ្សេងៗទៀតបានផងដែរ។*

***ថង់ប្លាស្ទិចតូចៗ*** (៦ x ៩ អ៊ីញ) *សម្រាប់ទុកដាក់ និងថែរក្សាឧបករណ៍ផ្សេងៗ ដែលត្រូវយកមកប្រើ ក្នុងការព្យាបាលដំរីឲ្យបានស្អាតជានិច្ច និងគ្មានធូលី។*

***ថង់ប្លាស្ទិច*** *ទុកសម្រាប់ត្រាំជើងដំរី នៅពេលវាមានដំបៅ ឬជម្ងឺឆ្លងនៅប្រអប់ជើងរបស់វា។*

*ដង្កាប់សម្រាប់ចាប់ទាញ និងដកយកដែកគោល អំបែងកែវ ឬវត្ថុផ្សេងទៀត ដែលបានមុតកប់ចូលទៅក្នុងជើងដំរី។*

*សាប៊ូរាវដូចជាសាប៊ូលាងចានសម្រាប់លាងសម្អាតឧបករណ៍ ក្រោយពេលប្រើរួច។*

## ឧបករណ៍សម្រាប់មជ្ឈមណ្ឌលតូចៗ និងពេលធ្វើដំណើរ

*វត្ថុទាំងនេះចាំបាច់ណាស់សម្រាប់ស្ថានភាព ដែលកើតឡើងយ៉ាងឆាប់រហ័ស។ វាពិតជាពិបាកណាស់ ប្រសិនបើអ្នកគ្មានឧបករណ៍ទាំងនេះ ទុកសម្រាប់ផ្តល់ចំណីអាហារ និងទឹកឲ្យដំរី និងសម្រាប់ព្យាបាលដំរីភ្លាមៗ។*

***ធុងទឹកចំណុះ ៥ លីត្រ*** *គឺចាំបាច់ណាស់សម្រាប់ដងទឹកឲ្យដំរីផឹក និងសម្រាប់ផ្ញួតទឹកឲ្យវា ជាពិសេសទុកសម្រាប់ដាក់ចំណីអាហារដូចជាស្រូវជាដើម។*

***ធុងទឹកចំណុះ ១០ លីត្រ*** *មានគំរបសុវត្ថិភាពសម្រាប់ទឹកផឹក ដែលហ្មដំរីត្រូវធានាថាមានវានៅគ្រប់ពេលវេលា។*

*ទែម៉ូម៉ែត្រសម្រាប់វាស់សីតុណ្ហភាពរបស់ដំរី នៅពេលវាមិនសូវស្រួលខ្លួន។*

ច្រវាក់ និងប៊ូឡុងរាងអក្សរ "U" និងឧបករណ៍ផ្សេងៗទៀត ដែលប្រើដើម្បីគ្រប់គ្រងដំរី ដូចជាកង្វេរ កាំបិតជាដើម។

**សឺរ៉ាំងប្លាស្ទិចដែលមានចំណុះពី ១ ទៅ ៣ cc** ដែលត្រូវប្រើដើម្បីបន្តក់ថ្នាំភ្នែក។ យើងអាចប្រើវាឡើងវិញបាន ប៉ុន្តែគួរតែប្រើសម្រាប់ដំរីតែមួយប៉ុណ្ណោះបានហើយ និងក្រោយពេលប្រើរួច ត្រូវទុកវានៅកន្លែងស្អាត។

**សឺរ៉ាំងប្លាស្ទិចដែលមានចំណុះ ៥០ cc** សម្រាប់លាងរបួស ឬបាញ់ថ្នាំដាក់លើមុខរបួស ក្នុងស្ថានភាព ដែលដំរីមិនព្រមយើងលាបថ្នាំលើមុខរបួសនោះដោយផ្ទាល់។ យើងអាចយកសឺរ៉ាំង ដែលប្រើរួចទៅស្ងោរក្នុងទឹកក្តៅដាំឲ្យពុះ ហើយយើងអាចយកវាមកប្រើឡើងវិញបាន ប៉ុន្តែមិនត្រូវលាងសម្អាតវា ឬប្រើថ្នាំសម្លាប់មេរោគដើម្បីលាងវាទេ។

**ថង់ប្លាស្ទិចតូចៗ** (៦ x ៩ អ៊ីញ) សម្រាប់ទុកដាក់ និងថែរក្សាឧបករណ៍ផ្សេងៗ ដែលត្រូវយកមកប្រើ ក្នុងការព្យាបាលដំរីឲ្យបានស្អាតជានិច្ច និងគ្មានធូលី។

**ថង់ប្លាស្ទិច** ទុកសម្រាប់ត្រាំជើងដំរី នៅពេលវាមានដំបៅ ឬជម្ងឺឆ្ងងនៅប្រអប់ជើងរបស់វា។

ដង្កាប់សម្រាប់ចាប់ទាញ និងដកយកដែកគោល អំបែងកែវ ឬវត្ថុផ្សេងទៀត ដែលបានមុតកប់ចូលទៅក្នុងជើងដំរី។

ក្រណាត់ស្អាត ពី ៣ ទៅ ៤ ផ្ទាំងសម្រាប់ដំរីនីមួយៗ។ ក្រណាត់នេះ ទុកប្រើសម្រាប់លាងសម្អាតស្បែកដំរីជុំវិញស្នាមរបួស និងទុកសម្រាប់ឃាត់ឃាមកុំឲ្យហូរឈាម។ ត្រូវយកក្រណាត់ប្រើរួចមកស្ងោរទឹកដាំឲ្យបាន ១៥ នាទី ដើម្បីសម្លាប់មេរោគ។

## ថ្នាំពេទ្យដែលត្រូវតែមាននៅក្នុងដៃនៅពេលធ្វើដំណើរ

- ថាំពេទ្យសម្រាប់ព្យាបាលស្នាមរបួសថ្មីៗដូចជា អ៊ីយ៉ូត tincture ឬ Povidone-iodine ១%។
- ថ្នាំពេទ្យសម្រាប់ព្យាបាលអាប់សែ និងដំបៅរ៉ាំរ៉ៃ ដូចជាថ្នាំប៉ូមាដ Furazone ឬទឹកថ្នាំ Acriflavin solution ។
- ថ្នាំម្សៅសម្លាប់សត្វល្អិតដូចជា Negasunt ។
- ថ្នាំភ្នែកជាប៉ូមាដ ឬថ្នាំទឹក ដូចជា Vanafen ឬ Kimicitin។

- ថ្នាំជាក្រែម ឬជាប៉ូមាដ ដូចជាក្រែម Betamethazone។

## អនាម័យ

យើងទាំងអស់គ្នាដឹងហើយថាមេរោគ គឺជាសរីរាង្គតូចៗ ដែលនាំឲ្យមានជម្ងឺ និងរហូតដល់ស្លាប់។ ប៉ុន្តែនៅពេលយើងក្រឡេកមើលឧបករណ៍ ដែលយើងកំពុងប្រើប្រាស់ នៅកន្លែងដែលយើងកំពុងធ្វើការ ឬសូម្បីតែដៃរបស់យើងផ្ទាល់ គឺវាពិតជាងាយស្រួលយល់ណាស់ "មើលទៅហាក់ដូចជាស្អាត ដូច្នេះត្រូវតែស្អាត"

ប៉ុន្តែតាមការពិតវាមិនមែនដូច្នោះទេ។ ក្រណាត់ ឬកាំបិត ដែលយើងមើលទៅវាឃើញហាក់ដូចជាស្អាតល្អឥតខ្ចោះ គឺគ្មានភាពកខ្វក់អ្វីឡើយ ប៉ុន្តែវាពិតជាមានអតិសុខុមប្រាណជាច្រើនមិនដែលខានឡើយ។ ដូច្នេះរាល់ពេលដែលអ្នកធ្វើការព្យាបាល អ្នកគួរតែសម្អាតយ៉ាងហ្មត់ចត់ និងលាងឧបករណ៍ទាំងអស់របស់អ្នក ហើយតាមដែលអាចធ្វើទៅបាន ត្រូវសម្អាតកន្លែងដែលនឹងត្រូវធ្វើការព្យាបាលនៅទីនោះ។ ពេលខ្លះបើយើងមិនបានចំណាយពេលវេលាពី ៥ ទៅ ១០ នាទី ដើម្បីធ្វើអនាម័យទេ វាអាចបណ្តាលឲ្យសត្វដំរីមួយក្បាលអាចស្លាប់បាន ហើយដល់ពេលនោះយើងនឹងខាតបង់អស់រាប់សែនបាត។

## អនាម័យសម្រាប់អ្នកថែទាំជម្ងឺសត្វ

ទម្លាប់ដែលសំខាន់ជាងគេបំផុត ដែលត្រូវតែរក្សានោះ គឺនៅពេលយើងប្រើប្រាស់ឧបករណ៍វេជ្ជសាស្ត្រ និងប៉ះពាល់ស្នាមរបួសបើកចំហនៅលើដំរី គឺត្រូវប្រយ័ត្នប្រយែងជាទីបំផុត គឺថាដៃរបស់យើងត្រូវតែស្អាតជានិច្ច។ ល្អបំផុតនោះ គឺត្រូវធ្វើការលាងសម្អាតដោយប្រុងប្រយ័ត្នជាមួយសាប៊ូ សម្ងួតដៃ និងឧបករណ៍វេជ្ជសាស្ត្រ ហើយបន្ទាប់មកលាងសម្អាតម្តងទៀត។ ត្រូវប្រាកដថាកាត់ក្រចកដៃឲ្យខ្លី និងស្អាតជានិច្ច។

## ការសម្អាតឧបករណ៍វេជ្ជសាស្ត្រ

ឧបករណ៍ដែលប្រើជាមួយដំរីភាគច្រើន ជារបស់របរប្រើប្រាស់ក្នុងផ្ទះធម្មតា ដូច្នេះវាងាយស្រួលក្នុងការសម្អាត និងមើលថែរក្សា។ យើងអាចលាងសម្អាតវាដោយទឹកស្អាតជាមួយសាប៊ូ (សាប៊ូលាងចានគឺល្អ) ជូតវាឲ្យស្អាត ហើយបន្ទាប់មកត្រូវទុកវានៅក្នុងធុងបិទជិត។ មុនពេលប្រើវាម្តងទៀត យកល្អត្រូវតែធ្វើការលាងសម្អាតវាជាថ្មីម្តងទៀត។

*លើកលែងតែស៊ីរ៉ាំង និងធុង ដែលយើងយកមកប្រើ ដើម្បីលាយថ្នាំសម្រាប់លាងសម្អាតមុខរបួស។ ប្រសិនបើវាមិនមែនថ្មីទេ ដូចជាស៊ីរ៉ាំងគ្មានម្ជុល ដែលត្រូវបានប្រើប្រាស់សម្រាប់បូមថ្នាំព្យាបាលម្តងរួចមកហើយ យើងត្រូវយកវាទៅលាងទឹកសម្អាតវាជាថ្មី។*

*ជាធម្មតាក្រណាត់មិនស្អាតទេ លុះត្រាតែយកវាទៅស្ងោរក្នុងទឹកដាំពុះរយៈពេល ១៥ នាទី ហើយបន្ទាប់មកយកវាទៅហាលសម្ងួត ដោយប្រុងប្រយ័ត្ន នៅក្រោមកម្តៅព្រះអាទិត្យឆ្ងាយពីធូលី និងការចម្លងរោគដែលបង្កដោយខ្យល់។ បន្ទាប់ពីស្ងោរក្នុងទឹកដាំពុះ និងហាលសម្ងួតរួច ត្រូវយកក្រណាត់ស្ងួតនោះទៅទុកក្នុងថង់ប្លាស្ទិក ឬធុងបិទជិត។*

*ធុងដែកមានតម្លៃថ្លៃ ហើយបង្កឲ្យមានសម្លេង នៅពេលប្រើប្រាស់ ប៉ុន្តែវាមានភាពរឹងមាំ ហើយអាចដាក់ទឹករួចដាំឲ្យពុះ ដើម្បីសម្លាប់មេរោគបាន។ ធុងប្លាស្ទិកងាយនឹងបែក ហើយពិបាកក្នុងការថែរក្សាអនាម័យ។*

## ការសម្អាតរោងដំរី

*រោងដំរីភាគច្រើននៅប្រទេសថៃមានកម្រាលបាតជាដីបុកបង្ហាប់ និងមានដំបូលប្រក់ស្មៅ។ គេកម្រប្រក់ដំបូលក្បឿង ឬធ្វើកម្រាលបាតពីបេតុងណាស់។ ប្រភេទទាំងពីរនេះត្រូវការវិធីសម្អាតផ្សេងៗគ្នា។*

## ដំបូលស្មៅនិងកម្រាលបាតជាដីបុកបង្ហាប់

- *យកល្អគួរតែប្រមូលយកលាមកដំរីដែលជុះថ្មីៗ ដោយប្រុងប្រយ័ត្នបំផុត ត្រូវប្រមូលភ្លាមៗ បើអាចធ្វើទៅបាន ហើយក៏ត្រូវប្រមូលចំណីអាហារ ដែលនៅសល់រាយប៉ាយ ប្រហែលមួយម៉ោងបន្ទាប់ពីដាក់ចំណីអាហារឲ្យដំរី។*
- *តំបន់ដែលសត្វដំរីនោមញឹកញាប់អាចនឹងសើម និងមានក្លិនមិនល្អ។ បើអាច ហ្មដំរីត្រូវផ្លាស់ប្តូរកន្លែងចងច្រវាក់ដំរី ឬប្រើដីស្អាត ឬដីខ្សាច់រោយពីលើ ដើម្បីធ្វើឲ្យទីនោះស្ងួត និងបំបាត់ក្លិន។*
- *រោងដំរីដែលមានដំបូលប្រក់ស្មៅ គួរតែផ្លាស់ប្តូរស្មៅរៀងរាល់ពី ២ ទៅ ៣ ឆ្នាំម្តង។ នៅពេលផ្លាស់ប្តូរស្មៅដំបូល យកល្អត្រូវទុកផ្នែកក្នុងរោងឲ្យត្រូវកម្តៅព្រះអាទិត្យ*

*ដោយផ្ទាល់រយៈពេលប្រហែល ៣៥ ថ្ងៃ ដើម្បីសម្ងួតវាឲ្យបានល្អ និងបំផ្លាញអតិសុខុមប្រាណមួយចំនួន។*

**ដំបូលប្រក់ក្បឿង និងកម្រាលបាតពីបេតុង**

- *ត្រូវប្រមូលលាមកឲ្យបានទាប់បំផុត ហើយលាងទឹកនោមភ្លាមៗ។*
- *ប្រមូលចំណីអាហារ ដែលនៅសេសសល់ មួយម៉ោងបន្ទាប់ពីបានផ្តល់ចំណីឲ្យដំរី។*
- *លាងសម្អាតកំពលតដ្ឋឲ្យបានពីរដងក្នុងមួយថ្ងៃ ម្តងនៅពេលព្រឹក និងម្តងទៀតនៅពេលរសៀល។*
- *លាងសម្អាតកម្រាលតដ្ឋដោយប្រុងប្រយ័ត្នជាមួយថ្នាំសម្លាប់មេរោគ (ដូចជាទឹកថ្នាំឌីថុល* Dettol) *យ៉ាងហោចណាស់ម្តងក្នុងមួយខែ ហើយកាន់តែញឹកញាប់ជាងនេះ ប្រសិនបើមានជម្ងឺធ្ងន់។*

**ការចោលសំរាម**

*កាកសំណល់ដែលកើតចេញពីការងារ និងសកម្មភាពផ្សេងៗទៀតនៅក្នុងមជ្ឈមណ្ឌលដំរី ទាមទារឲ្យមានការបោះចោលឲ្យបានត្រឹមត្រូវ ព្រោះកាកសំណល់ទាំងនោះអាចជាឃ្លាំងផ្ទុកមេរោគ និងជាតិពុល ដែលអាចបង្កឲ្យមានផលប៉ះពាល់មិនល្អសុខភាពដំរី និងមនុស្ស។*

*កាកសំណល់មកពីសត្វដំរី និងសកម្មភាពផ្សេងៗទៀត ដែលទាក់ទងនឹងដំរីៈ*

- *ត្រូវប្រមូលលាមកដំរីជារៀងរាល់ថ្ងៃ ទាំងនៅក្នុងរោងដំរី ទាំងនៅក្នុងតំបន់ជុំវិញ ហើយត្រូវកប់ និងគ្របឲ្យបានជិតល្អ។ (បច្ចុប្បន្នមជ្ឈមណ្ឌលអភិរក្សដំរីថៃឡាំផាង* Lampang *ប្រមូលយកលាមកសត្វដំរី ហើយកែច្នៃឲ្យទៅជាជី ទៅជា កដាស និងយកទៅទុកក្នុងឡ ដើម្បីផលិតជីវឧស្ម័នសម្រាប់ចម្អិនអាហារក្នុងផ្ទះ)។*
- *កាកសំណល់ពីសកម្មភាពការងារ មានដូចជាកាកសំរាមជាសំណល់ពីទេសចរ ក៏ត្រូវប្រមូលយកទៅកប់ ឬដុតឲ្យបានត្រឹមត្រូវដែរ។ សំរាមមួយចំនួន ដែលពិបាកនឹងបោះចោល ដូចជាដប កែវ កំប៉ុងកេសជ្ជៈជាដើម គួរតែញែកវាឲ្យបានត្រឹមត្រូវ ហើយដាក់ក្នុងធុងបិទជិតយ៉ាងប្រុងប្រយ័ត្ន ហើយទុកឲ្យអ្នកប្រមូលសំរាមមក*

យក ព្រោះសំរាមបែបនេះវាលួយយឺតណាស់នៅក្នុងបរិស្ថានធម្មជាតិ ត្រូវប្រើពេលយូរ។

ប្រយ័ត្នះ ពេលខ្លះសត្វដំរីអាចនឹងស៊ីសំរាម ដែលភ្ញៀវទេសចរណ៍បោះចោលដោយចៃដន្យ ជាពិសេសថង់ផ្លាស្ទិច និងកញ្ចប់ស្ករគ្រាប់ហើយបន្ទាប់មកបង្កើតការស្ទះពោះវៀន។

- សំរាមដែលមានផ្ទុកទៅដោយមេរោគ ជាកាកសំណល់ពីការព្យាបាលដំរីឈឺ ដូចជាបង់រុំចាស់ៗ សំឡី និងកាកសំណល់ហូរចេញពីរាងកាយ។ សំរាមបែបនេះគួរតែធ្វើការញែកវា និងដុតវាដោយប្រុងប្រយ័ត្ន ឲ្យឆ្ងាយពីសំរាមផ្សេងៗទៀត។ បន្ទាប់ពីឡដុតកាកសំណល់ប្រភេទនេះរួច ត្រូវកប់វាឲ្យជ្រៅ យ៉ាងហោចណាស់ឲ្យបានជម្រៅ ១ ម៉ែត្រដែរ ប៉ុន្តែក៏ត្រូវពោយកំបោរមួយស្រទាប់ពីលើបន្ថែមទៀត ដើម្បីគ្របពីលើមេរោគ។ សឺរ៉ាំង និងម្ជុល ត្រូវប្រមូលទុកមួយដុំ ហើយយកចេញពីទីកន្លែងនោះ ទៅតាមការណែនាំរបស់បសុពេទ្យ។
- ទឹកកាកសំណល់ និងទឹកដែលបានប្រើនៅពេលលាងសម្អាតកម្រាលបាត ត្រូវតែបង្ហូរចូលទៅក្នុងដីវិញ ដោយមានតម្រងសម្រាប់ច្រោះទឹក និងមានទីតាំងយ៉ាងហោចណាស់ឲ្យបានចម្ងាយ ៥០ ម៉ែត្រ ពីអាងទឹក ឬពីប្រភពទឹកផ្សេងៗទៀត។ ចំពោះគ្រឿងបរិក្ខារវិញ បើមានថវិកាគ្រប់គ្រាន់ គួរវិនិយោគលើឧបករណ៍នានាដើម្បីធ្វើការច្រោះទឹកជាកាកសំណល់ មុនពេលបញ្ចេញវាទៅក្នុងអាងទឹក ឬទៅក្នុងប្រភពទឹកផ្សេងៗទៀត។

## **ការប្រមូលគំរូសម្រាប់ការវិភាគ**

ការប្រមូលសំណាកគឺមានសារៈសំខាន់ណាស់ ជាពិសេសនៅពេលដំរីមួយឈឺ ហើយយើងមិនទាន់ដឹងមូលហេតុច្បាស់លាស់។ មានតែពេទ្យសត្វទេ ដែលអាចធ្វើការតាមដាន វិភាគ និងកំណត់មូលហេតុបាន ប៉ុន្តែភាគច្រើនមិនអាចរកមូលហេតុឃើញទេ ព្រោះពេទ្យសត្វមិនបានឃើញដំរី នៅពេលវាបង្ហាញសញ្ញាថាវាកំពុងមានជម្ងឺ។ ដូច្នេះហ្មដំរីដែលនៅជាប់ជាមួយដំរីគ្រប់ពេល គួរតែជាអ្នកដែលអាចជួយប្រមូលសំណាកពីដំរី

*ដើម្បីធ្វើរោគវិនិច្ឆ័យឲ្យបានរហ័ស និងច្បាស់លាស់។ គំរូដែលប្រមូលបានមិនត្រឹមត្រូវ គឺជាការខ្ជះខ្ជាយពេលវេលា។*

## ការប្រមូលសំណាករបស់ប៉ារ៉ាស៊ីត

*ជាទូទៅប៉ារ៉ាស៊ីតមាននៅក្នុងលាមករបស់សត្វដំរី។ ហ្មដំរីគួរប្រមូលប៉ារ៉ាស៊ីតមួយចំនួន បន្ទាប់មកលាងវាក្នុងទឹកស្អាត ហើយដាក់វានៅក្នុងកូនដបមួយ ដែលមានដាក់ទឹកថ្នាំហ្វ័រម៉ុល ១០% (ថ្នាំហ្វ័រម៉ុល ១ ភាគ និងទឹក ៩ ភាគ) ឬក៏ដាក់ចូលក្នុងអាល់កុលក៏បានដែរ។ ប៉ារ៉ាស៊ីតនៅក្នុងទឹកថ្នាំហ្វ័រម៉ុល ឬនៅក្នុងអាល់កុលនឹងរក្សាទុកបានរយៈពេលយូរនៅសីតុណ្ហភាពធម្មតា។ ដាក់ស្លាកលើកូនដបនោះ ដោយមានសរសេរឈ្មោះដំរី កាលបរិច្ឆេទ ទីកន្លែង និងឈ្មោះរបស់ហ្មដំរី ឬឈ្មោះម្ចាស់ដំរី។*

*ចំពោះសត្វល្អិតប៉ារ៉ាស៊ីតខាងក្រៅ (តុកកែ ចៃនិងសត្វជញ្ជក់ឈាមផ្សេងៗទៀត) ហ្មដំរីគួរតែប្រមូលសំណាកខ្លះៗ ហើយដាក់វានៅក្នុងកូនដបធម្មតាមួយ ឬជាមួយនឹងទឹកថ្នាំហ្វ័រម៉ុល ឬក្នុងទឹកអាល់កុលដូចប៉ារ៉ាស៊ីតខាងក្នុងដែរ។ ត្រូវដាក់ស្លាកនៅលើកូនដបប៉ារ៉ាស៊ីតនោះ ដោយមានកត់ត្រាព័ត៌មានលម្អិតខាងលើ ប៉ុន្តែក៏ត្រូវបញ្ជាក់ពីផ្នែកណានៃរាងកាយរបស់ដំរី ដែលបានប្រមូលយកប៉ារ៉ាស៊ីតនោះមក។*

## ការប្រមូលសំណាកលាមក

*លាមកគឺជាសូចនាករដ៏ល្អមួយចំពោះសុខភាពរបស់សត្វដំរី។ ហ្មដំរីត្រូវតែពិនិត្យលាមកសត្វដំរីរបស់ខ្លួនជារៀងរាល់ថ្ងៃ។ ប្រសិនបើគាត់រកឃើញថាជាលាមករាក មានឈាម មានពពួកប៉ារ៉ាស៊ីតជាដើម គាត់ត្រូវតែប្រមូលសំណាកលាមកនោះ និងត្រូវពិគ្រោះជាមួយពេទ្យសត្វ។ ត្រូវធ្វើដូចខាងក្រោម៖*

- *យកសំណាកពីលាមកស្រស់។ (កុំយកសំណាកពីលាមក ដែលមានអាយុលើសពីមួយម៉ោង។) សូមយកសំណាក់លាមក ដែលមានទំហំប៉ុនពងមាន់ ត្រូវយកពីផ្នែកកណ្ដាលនៃលាមក។*
- *ដាក់គំរូលាមកនោះក្នុងថង់ប្លាស្ទិចស្អាត។ មុនពេលបិទភ្ជាប់វាត្រូវសង្កត់ឲ្យខ្យល់ចេញអស់ពីថង់ប្លាស្ទិច តាមដែលអាចធ្វើទៅបាន។ បន្ទាប់មកត្រូវសរសេរឈ្មោះ*

*ដំរី កាលបរិច្ឆេទ ទីកន្លែង និងឈ្មោះផ្ទាល់ខ្លួនរបស់អ្នក។*

- *ដាក់សំណាកនោះក្នុងថង់ប្លាស្ទិចមួយជាន់ទៀតជាមួយដុំទឹកកក (ឬដាក់ក្នុងធុងទឹកកក) ហើយយកវាទៅឲ្យពេទ្យសត្វរបស់អ្នក។*

## ការកំណត់សុខភាព

*ហ្មដំរីភាគច្រើនស្គាល់ដំរីរបស់ខ្លួនច្បាស់ជាងគេ។ ហ្មដំរីតែងដឹងថាអ្វីដែលដំរីរបស់ខ្លួនចូលចិត្តស៊ី និងអ្វីដែលវាមិនចូលចូលចិត្ត អ្វីដែលចូលចិត្តធ្វើ និងអ្វីដែលវាមិនចូលចិត្តធ្វើ។ ហ្មដំរីដែលល្អ តែងដឹងពីខែដែលដំរីរបស់គាត់ដល់ពេលចុះប្រេង និងតែងដឹងពីការប្រែប្រួលឥរិយាបថរបស់វា។ ចំណេះដឹងបែបនេះមានប្រយោជន៍ខ្លាំងណាស់ចំពោះហ្មដំរី និងម្ចាស់ដំរីក្នុងការថែរក្សាសត្វ។ ប៉ុន្តែនៅមានចំណេះដឹងជាច្រើនទៀត ដែលហ្មដំរីថ្មីៗត្រូវរៀន និងសិក្សាស្វែងយល់ ដើម្បីក្លាយខ្លួនទៅជាហ្មដំរីដ៏ល្អមួយរូប។ ឧទាហរណ៍តើមានរឿងអ្វីកើតឡើងនៅក្នុងខ្លួនដំរី? ពេលដំរីស៊ីចំណីអាហារហើយ តើចំណីអាហារទាំងនោះវាទៅណា ហើយតើចំណីអាហារទាំងនោះមានគុណប្រយោជន៍អ្វីខ្លះដល់ដំរី? ឬមួយប្រសិនបើចំណីអាហារមានជាតិពុល តើវានឹងមានឥទ្ធិពលអ្វីខ្លះទៅលើដំរី?*

*ប្រទេសថៃមានសត្វដំរីក្នុងស្រុកជិត ៣ ០០០ ក្បាល ប៉ុន្តែមានពេទ្យសត្វមិនដល់ ២០ នាក់ទេ ដែលជាអ្នកមានជំនាញក្នុងការព្យាបាលជម្ងឺរបស់សត្វដំរី។ ចំណែកហ្មដំរីវិញក៏មានចំនួនតែជាង ៣០០០ នាក់ដែរ ហើយជំនាញហ្មដំរីនេះ មានតម្លៃខ្លាំងណាស់ ក្នុងការអភិរក្សសត្វដំរីនៅប្រទេសថៃ។*

### សូចនាករនៃសុខភាពល្អ

- *ដំរីបង្ហាញចលនាថេរ ដែលយើងអាចសង្កេតឃើញបាន តាមរយៈការបក់ស្លឹកត្រចៀក បក់កន្ទុយ និងប្រើប្រម៉ោយដើម្បីបាចដី។*
- *ដំរីស៊ីចំណីអាហារជាប្រចាំ ហើយតែងចង់ស៊ីចំណីអាហាររហូត។ លាមកបង្ហាញថាដំរីទំពារចំណីអាហារបានម៉ត់ល្អ។ លាមកគ្មានក្លិនមិនល្អទេ។*
- *ភ្នែកភ្លឺថ្លា និងមានសំណើមល្អ។ ផ្នែកខាងក្នុងមាត់ ប្រម៉ោយ អណ្តាត និងជាលិកាទន់ផ្សេងៗទៀត គឺមានពណ៌ផ្កាឈូកភ្លឺល្អ។*

- ស្បែកក្រាស់ ប៉ុន្តែទន់ហើយមានអារម្មណ៍ថាមានសំណើម។ ស្បែកនៅខាងលើក្រចក ម្រាមជើង មានសំណើម។

## សូចនាករនៃសុខភាពមិនល្អ

- ដំរីមានសភាពហាក់ដូចជាល្វើយ។ ត្រចៀក កន្ទុយ និងប្រមោយពិបាកធ្វើចលនាណាស់។
- ដំរីមានការហត់នឿយ យើងអាចសង្កេតឃើញវាមានចលនាតិចតួច ហើយចុងក្រោយវាទុកប្រមោយរបស់វាសម្រាកនៅលើដីអស់រយៈពេលជាយូរ។
- ដំរីឈរនៅស្ងៀមតែមួយកន្លែង ភ្នែកបិទ ហើយហេវហត់ល្វឹងល្វើយជាញឹកញាប់។
- នៅពេលដំរីឈ្មោលនោម លិង្គវាមិនចេញពីស្រោម។
- ដំរីមានភាពជ្រួលច្របល់ ហើយជួនកាលវាប្រាស់ខ្លួនដេកផ្ទាល់ដី។ វាប្រើប្រម៉ោយដើម្បីប្រមូលចាប់ដី ហើយបាចទៅលើកន្លែងដែលវាមានការឈឺចាប់។ ពេលខ្លះទៀតវាប្រើប្រមោយផ្លុំខ្យល់ទៅលើកន្លែង ដែលវាមានការឈឺចាប់។
- ដំរីស៊ីចំណីអាហារ និងផឹកទឹកតិច ឬមិនស៊ីអ្វីទាល់តែសោះ។
- ភ្នែកស្រអាប់ ខូងជ្រៅ និងមានស្រក់ទឹកភ្នែករហាម។ មានការបញ្ចេញទឹករំអិលតាមប្រមោយ។ ស្បែកឡើងស្ងួត ហើយពេលយើងស្ទាបទៅមានសភាពរឹង។
- ផ្នែកខាងក្នុងមាត់ អណ្តាត និងផ្នែកខាងក្នុងប្រមោយមានសភាពស្លេកស្លាំងខ្លាំងណាស់ ឬក៏មានព៌ណស្រអាប់ ឬក្រហមខ្លាំងជាងពណ៌ផ្កាឈូកធម្មតា។ ស្បែកនៅខាងលើក្រចកម្រាមជើងមានសភាពស្ងួត។

## ការពិនិត្យមើលប្រវត្តិថ្មីៗរបស់ដំរីឈឺ

សកម្មភាពដែលសំខាន់ជាងគេបំផុតសម្រាប់ជីវិតរបស់សត្វដំរី គឺការស៊ីចំណីអាហារ បន្ទាប់មកផឹកទឹក ហើយនិងដេក។ ដូច្នេះហ្មដំរីត្រូវធ្វើការពិនិត្យឡើងវិញនៃការស៊ីចំណីអាហារ ការផឹកទឹក និងការដេករបស់សត្វដំរី ដែលទើបនឹងកើតក្នុងពេលថ្មីៗ គឺក្នុងរយៈពេល ៣ ទៅ ៤ ថ្ងៃ មុនពេលដំរីនោះបង្ហាញសញ្ញាថាវា នដឈឺ។

*ការផ្តល់ចំណី៖* ប្រសិនបើដំរីបាន និងកំពុងស៊ីចំណីអាហារ ដែលពិបាករំលាយ ឧទាហរណ៍អាហារដែលមានសរសៃវែងៗ (ដូចជារុក្ខជាតិវល្លិ ដើមចេក ឬធាងត្នោតខ្ចីៗ) ដែលមិនបានកាត់ឲ្យខ្លីៗ ទៅតាមប្រវែងសមស្របសម្រាប់ចំណីរបស់ដំរី វានឹងអាចធ្វើឲ្យមានជម្ងឺទល់លាមកៗ ឬពេលខ្លះប្រសិនបើដំរីបានស៊ីចំណីណា ដែលអាចបណ្តាលឲ្យមានកើតឧស្ម័នដូចជាពោត ឬស្រូវ ឬស្រូវសាលី ឬដំឡូងមី នោះដំរីអាចមានជម្ងឺមិនរំលាយអាហារៗ ជម្ងឺនេះអាចធ្វើឲ្យដំរីមួយក្បាលស្លាប់តែក្នុងរយៈពេល ១ ទៅ ៣ ថ្ងៃៗ

*ការផ្តល់ទឹក៖* ជម្ងឺអាចកើតមានប្រសិនបើដំរីមួយក្បាលបានផឹកទឹកដែលមានជាតិគីមី ព្រោះវាអាចពុលបានៗ ឬក៏សត្វដំរីមួយក្បាលអាចនឹងមិនព្រមផឹកទឹក ពីព្រោះហ្មដំរីបានផ្លាស់ប្តូរកន្លែងដែលវាធ្លាប់ផឹកទឹកៗ

*ដេក៖* បើមានដំរីណាមួយមិនដេក នោះវាអាចមានបញ្ហានៅជើងរបស់វា ឬក៏វាអាចនឹងមានការឈឺចាប់ខ្លាំង ដែលវាមិនហ៊ានដេកលើដី ព្រោះវាខ្លាចមិនអាចក្រោកឈរឡើងវិញបានៗ ប្រសិនបើដំរីដេកនៅពេលថ្ងៃ ដំរីនោះប្រាកដជាមានការហត់នឿយខ្លាំងណាស់ អាចមកពីមានការផ្លាស់ប្តូរ ឬមានការរំខាននៅកន្លែងដេក ឬដោយសារសត្វដំរីនោះឈឺធ្ងន់ ហើយវាដេកមិនបានគ្រប់គ្រាន់ៗ

*ការងារ៖* ប្រវត្តិការងារថ្មីៗរបស់ដំរីក៏សំខាន់ដែរៗ ឧទាហរណ៍ ប្រសិនបើសត្វដំរីបានអូសឈើហុប កាលពីម្សិលមិញ ការអស់កម្លាំងខ្លាំងអាចចាត់ទុកថាជារឿងធម្មតា ឬជួនកាលការងារនោះអាចធ្វើឲ្យដំរីនោះឈឺនៅជើងៗ

## ការប្រើប្រាស់ទែម៉ូម៉ែត្រ

មានហ្មដំរីជាច្រើនគិតថាការប្រើទែម៉ូម៉ែត្រ គឺជាការងារសម្រាប់តែគ្រូពេទ្យសត្វ ប៉ុន្តែនេះមិនមែនដូច្នោះទេៗ ការងារវាស់សីតុណ្ហភាពរបស់ដំរីមានភាពងាយស្រួលដូចការវាស់សម្ពាធខ្យល់នៅក្នុងសំបកកង់រថយន្តដែរៗ ទែម៉ូម៉ែត្រដែលអ្នកអាចរកទិញបាននៅតាមបណ្តាហាងណា ដែលមានលក់ថ្នាំសម្រាប់មនុស្ស គឺមានតម្លៃត្រឹមតែពី៥០ ទៅ ១០០ បាតៗ

ហ្មដំរីដែលមានបទពិសោធន៍ច្រើន មានអារម្មណ៍ថាពួកគេអាចប្រាប់បានប្រសិនបើដំរីនោះមានជម្ងឺគ្រុនឬអត់ ដោយគ្រាប់តែយកដៃប៉ះដង្ហើមរបស់ដំរីៗ នេះអាចជាការ

ណែនាំមួយដែរ ប៉ុន្តែវាមិនល្អដូចលទ្ធផលពីទែម៉ូម៉ែត្រទេ។ ការវាស់សីតុណ្ហភាពរបស់ដំរីអាចជួយសន្សំសំចៃពេលវេលា និងថវិកាបានច្រើន។ ប្រសិនបើសត្វដំរីមើលទៅដូចជាឈឺបន្តិច ប៉ុន្តែវាមានសីតុណ្ហភាពធម្មតា អ្នកអាចរង់ចាំមួយរយៈ ដើម្បីតាមដានមើលថាតើវាបាត់ទៅវិញដែរ ឬទេ មុនពេលដែលអ្នកត្រូវចំណាយពេលវេលា និងថវិកាសម្រាប់ពេទ្យសត្វ។ ប្រសិនបើមានគ្រុនក្តៅ ទែម៉ូម៉ែត្រនឹងប្រាប់អ្នកឲ្យបានដឹងយ៉ាងឆាប់រហ័ស និងពិតប្រាកដថា អ្នកត្រូវតែទៅរកពេទ្យសត្វ ដោយសង្ឃឹមថាអាចជួយសង្គ្រោះជីវិតសត្វដំរីដ៏មានតម្លៃរបស់អ្នកបានទាន់ពេលវេលា។

***វិធីប្រើ៖*** យកទែម៉ូម៉ែត្រមកគ្រវីលោក់វាយ៉ាងរហ័ស ដើម្បីធ្វើឲ្យបារតនៅខាងក្នុងបំពង់ចុះទៅក្រោម។ បន្ទាប់មកដាក់ខាងចុងទែម៉ូម៉ែត្របង្វិលបញ្ចូលឲ្យជ្រៅទៅក្នុងរន្ធគូថដំរី។ ទុកវាពីមួយទៅពីរនាទី និងសង្កត់វារហូតទាល់តែវាបានទទួលកម្តៅពីដំរី។ ប្រសិនបើដំរីចង់តដៃ ឬរមួលខ្លួនមិនព្រមឲ្យយើងដាក់ទែម៉ូម៉ែត្រ ពេលនោះយើងអាចយកទែម៉ូម៉ែត្រទៅដាក់ក្នុងដុំលាមករបស់វា ដែលទើបតែជុះថ្មីៗ។ សីតុណ្ហភាពធម្មតារបស់ដំរីត្រូវស្ថិតនៅចន្លោះពី ៩៧,៥ និង ៩៩ អង្សាហ្វារិនហៃ ឬក្នុងចន្លោះពី ៣៦ ទៅ ៣៧ អង្សា C ។ ប្រសិនបើសីតុណ្ហភាពឡើងដល់ ១០០ អង្សាហ្វារិនហៃ ឬលើសពី ៣៧,៨ អង្សាសេ ឬលើសនេះ សត្វដំរីមានជម្ងឺគ្រុនក្តៅ ហើយអ្នកគួរតែហៅពេទ្យសត្វ។ បន្ទាប់ពីប្រើរួចហើយត្រូវលាងទែម៉ូម៉ែត្រជាមួយទឹកថ្នាំសម្លាប់មេរោគឲ្យបានស្អាត។

ត្រូវយកសីតុណ្ហភាពយ៉ាងហោចណាស់ឲ្យបានពីរដងដែរ ក្នុងមួយថ្ងៃ គឺនៅពេលព្រឹក និងនៅពេលល្ងាច។ ប្រសិនបើដំរីនោះឈឺធ្ងន់ អ្នកគួរយកសីតុណ្ហភាពឲ្យបានញឹកញាប់។ សរសេរពេលវេលា និងសីតុណ្ហភាពគ្រប់ពេល ដូច្នេះអ្នកអាចបង្ហាញវាទៅពេទ្យសត្វ។ គាត់អាចមើលឃើញគំរូដែលជួយគាត់ក្នុងការធ្វើរោគវិនិច្ឆ័យលើជម្ងឺ (ឧទាហរណ៍ ដំរីមានសុខភាពធម្មតានៅពេលព្រឹក ប៉ុន្តែវាចាប់មានជម្ងឺគ្រុនក្តៅនៅពេលរសៀល)។

## ការបញ្ច្រុកថ្នាំតាមមាត់

ការផ្តល់ថ្នាំតាមមាត់ជាធម្មតាសម្រាប់ថ្នាំបំបាត់ការឈឺចាប់ និងថ្នាំកែរោគ។ ដំរីគឺខុសពីសត្វដទៃទៀត ព្រោះវាអាចប្រើប្រមោយរបស់វា ដែលអាចប្រៀបធៀបទៅនឹងដៃ

*របស់មនុស្ស ដើម្បីទាញយករបស់ ដែលយើងបានដាក់ក្នុងមាត់របស់វាចេញវិញ។ ប្រសិនបើដំរីមិនចង់លេបថ្នាំវានឹងទាញ ឬអួសចេញមកក្រៅវិញ។*

*វិធីសាស្ត្រដែលសមស្របបំផុតក្នុងការផ្តល់ថ្នាំដល់សត្វដំរីគឺះ*

- *ដាក់ថ្នាំនៅក្នុងអាហារណា ដែលដំរីចូលចិត្តជាពិសេស ចេកទុំ ឬដំណាប់អម្ពិល។*
- *ជាពិសេសសម្រាប់កូនដំរី ត្រូវកិនគ្រាប់ថ្នាំឲ្យទៅជាម្សៅម៉ត់ល្អ ហើយលាយវាចូលក្នុងទឹកដោះគោផ្អែមខាប់ ឬដំណាប់ផ្លែឈើ ដើម្បីកុំឲ្យអណ្តាតរបស់វាអាចដឹងរសជាតិថ្នាំ។*
- *កិនគ្រាប់ថ្នាំឲ្យទៅជាម្សៅម៉ត់ល្អ ហើយលាយម្សៅជាមួយទឹកស្អាត ប៉ុន្តែអ្នកត្រូវតែរំលាយវាក្នុងទឹកឲ្យបានល្អ ព្រោះដំរីអាចដឹងថាមានថ្នាំ។ ដាក់អង្គធាតុរាវដាក់ក្នុងដប ហើយយកដៃទៅបញ្ច្រកដំរីបន្តិចម្តងៗ រហូតទាល់តែវាផឹកថ្នាំនោះអស់។*

## ការប្រើថ្នាំតាមរន្ធគូថ

*សារធាតុទូទៅដែលត្រូវបានគេប្រើភាគច្រើនតាមរន្ធគូថគឺទឹក ក្នុងករណីមានការខ្សោះជាតិទឹកធ្ងន់ធ្ងរ ជាពិសេសក្នុងករណីមានជម្ងឺតេតាណូស។ មុនពេលបញ្ចូលទឹកអ្នកត្រូវប្រើដៃបារយកលាមកចេញមកក្រៅ តាមដែលអាចធ្វើទៅបាន ហើយបន្ទាប់មកត្រូវបញ្ចូលទុយោទឹកតាមរន្ធគូថដំរី។ ត្រូវធ្វើយ៉ាងណា កុំបង្កឲ្យមានរបួសស្នាមដល់រន្ធគូថរបស់ដំរី។*

- *លាងសម្អាតដៃរបស់អ្នកដោយប្រុងប្រយ័ត្នបំផុត។ ត្រូវប្រាកដថាក្រចកដៃត្រូវតែខ្លីជានិច្ច។*
- *ត្រូវប្រើសារធាតុរំអិល មានដូចជាសាប៊ូដុំ ឬសាប៊ូលាងចានលាបនៅលើដៃអ្នក។*
- *លូកដៃចូលតាមរន្ធគូថរបស់ដំរីថ្នមៗតាមដែលអាចធ្វើទៅបាន ហើយបារយកលាមករបស់វាចេញមកក្រៅឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។*
- *បញ្ចូលទុយោជ័រទៅក្នុងរន្ធគូថរបស់ដំរី ដែលមានចុងរបស់វារលោងខ្លាំង គឺមិនត្រូវឲ្យមានគែមមុតស្រួចទេ។*
- *ទឹកត្រូវតែមានកម្តៅប្រហាក់ប្រហែលនឹងសីតុណ្ហភាពរាងកាយរបស់ដំរី។*

- បើកទឹកនោះឲ្យហូរចូលល្មមៗទៅក្នុងខ្លួនរបស់ដំរី។ អ្នកអាចឃើញថាមានដុំលាមកអណ្តែតចេញមក អ្នកត្រូវបារបញ្ចេញវាមកក្រៅ តាមដែលអាចធ្វើទៅបាន។ ពេលខ្លះនៅពេលដែលទឹកបានចូលទៅ សត្វដំរីនឹងត្រូវបន្ទោរបង់ដោយខ្លួនឯង។
- ផ្តល់ទឹកក្តៅឧណ្ហៗរហូតដល់ដំរីបង្ហាញពីភាពមិនស្រួលស្រួល ទើបបិទទឹក ហើយរង់ចាំរយៈពេល ៣០ នាទី។ ដៃត្រូវតែនៅខាងក្នុងដើម្បីខ្ទប់រន្ធគូថ។

ប្រយ័ត្នៈ ត្រូវប្រាកដថាដាក់ដៃរបស់អ្នកមានលាបសារធាតុរំអិល រាល់ពេលដែលអ្នកលូកដៃរបស់អ្នកបញ្ចូលទៅក្នុងរន្ធគូថរបស់ដំរី។

## ហ្មដំរីចាក់ថ្នាំ

នៅប្រទេសថៃ ប្រសិនបើមាននរណាម្នាក់ក្រៅពីពេទ្យសត្វ ចាក់ថ្នាំឲ្យសត្វណាមួយរួមទាំងដំរីផងដែរ នោះវាជាអំពើខុសច្បាប់។ ប៉ុន្តែក្នុងការព្យាបាលសត្វដំរី ពេទ្យសត្វតែងតែជួបប្រទះនូវកាលៈទេសៈខ្លះ ដែលហ្មដំរីក៏អាចធ្វើការចាក់ថ្នាំឲ្យដំរីបានដែរ។ សត្វដំរីមានច្រើនជាងសត្វមានតម្លៃដទៃទៀត ដែលរស់នៅកណ្តាលព្រៃ ឬរស់នៅតាមភូមិដាច់ស្រយាល។ ហេតុដូច្នេះហើយ ពេទ្យសត្វជួនកាលមានការលំបាកក្នុងការធ្វើដំណើរទៅព្យាបាលសត្វដំរីនៅទីនោះ ប្រសិនបើហ្មដំរីមិនបានចាក់ថ្នាំឲ្យដំរីឈឺនៅទីនោះទេ នោះប្រាកដជាគ្មានណាអាចចាក់ថ្នាំឲ្យដំរីទាំងនោះឡើយ។

ក្នុងករណីធម្មតា ដំរីមួយដែលមានជម្ងឺធ្ងន់ អាចនឹងជាវិញដោយងាយ ដោយគ្រាន់តែចាក់ថ្នាំអង់ទីប៊ីយោទិច (ថ្នាំផ្សះ) ឲ្យវាមួយថ្ងៃពីរដង ក្នុងរយៈចំនួន ១០ ថ្ងៃ។ ប៉ុន្តែបើសត្វដំរីនេះនៅចម្ងាយ ៩០ គីឡូម៉ែត្រ ពីការិយាល័យរបស់ពេទ្យសត្វ ក្នុងនោះមានផ្លូវចម្ងាយ ១៥ គីឡូម៉ែត្រ ជាផ្លូវដីដែលពិបាកបំផុតមិនអាចធ្វើដំណើរបានទេ ជាពិសេសនៅក្នុងរដូវវស្សា។ ពេទ្យសត្វមិនអាចស្នាក់នៅជាមួយដំរី ដើម្បីថែទាំចាក់ថ្នាំឲ្យវាសម្រាប់រយៈពេលដប់ថ្ងៃបានទេ។ សត្វដំរីមានសុខភាពល្អគ្រប់គ្រាន់ ដែលវាមិនត្រូវការចូលមន្ទីរពេទ្យទេ ហើយវាអាចបង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាពរបស់សត្វ ប្រសិនបើយើងបង្ខំយករថយន្តដឹកទំនិញកង់ ១០ ធ្វើការដឹកជញ្ជូនសត្វដំរីឈឺនោះទៅកាន់មន្ទីរពេទ្យសត្វ ក្នុងកា

លៈទេសៈបែបនោះ។ ម្យ៉ាងទៀតម្ចាស់ដំរី ប្រហែលជាមិនមានលទ្ធភាពដួលឡានដឹកដំរីនោះទៅមន្ទីរពេទ្យសត្វទេ។

ក្នុងករណីបែបនេះ អ្នកដែលមានបញ្ហាវាងវៃប្រាកដជានឹងយល់ស្របថា ច្បាប់ត្រូវតែមានការលើកលែង ហើយក្រោមការត្រួតពិនិត្យយ៉ាងតឹងរឹងរបស់ពេទ្យសត្វ ហ្មដំរីត្រូវទទួលបាននូវការអនុញ្ញាតឲ្យចាក់ថ្នាំ។ នេះពិតជាពិសេសណាស់ ពីព្រោះគោលបំណងពិតប្រាកដនៃច្បាប់ មិនមែនដើម្បីហាមឃាត់ប្រជាពលរដ្ឋមិនឲ្យចាក់ថ្នាំឲ្យសត្វនោះទេ តែផ្ទុយទៅវិញ គឺដើម្បីបញ្ឈប់ប្រជាពលរដ្ឋមិនឲ្យផ្តល់ថ្នាំខុស ឬខុសកំរិតដល់សត្វទេ។

ប្រសិនបើពេទ្យសត្វជឿទុកចិត្តលើហ្មដំរី ហើយផ្តល់សឺរ៉ាំង និងថ្នាំឲ្យហ្មដំរី ពេលនោះហ្មដំរីគួរតែតបស្នងទៅការជឿទុកចិត្តនោះវិញ ដោយប្រើថ្នាំនេះឲ្យបានត្រឹមត្រូវតាមការណែនាំរបស់ពេទ្យសត្វ៖ មិនត្រូវឲ្យច្រើនជាង និងមិនត្រូវឲ្យតិចជាងនូវអ្វីដែលពេទ្យសត្វបានកំណត់នោះដែរ។ មិនត្រូវសម្រេចចិត្តដោយខ្លួនឯងថា សត្វដំរីរបស់ខ្លួនមានសុខភាពល្អហើយ ដូច្នេះអ្នកអាចបញ្ឈប់ការព្យាបាលមុនពេល ដែលពេទ្យសត្វបានកំណត់នោះទេ៖ ដប់ថ្ងៃ គឺដប់ថ្ងៃ។ ប្រសិនបើអ្នកបញ្ឈប់ការព្យាបាលមុនពេលកំណត់ធាប់ពេកពេលនោះជម្ងឺរបស់ដំរីអាចនឹងវិលត្រឡប់មកវិញ ហើយស្ថានភាពរបស់ដំរីវានឹងកាន់តែអាក្រក់ទៅៗ ព្រោះមេរោគដែលនៅក្នុងខ្លួនដំរីបានវិវត្តទៅជាមានភាពធន់នឹងថ្នាំ។

ដូចគ្នានេះដែរកុំប្រើថ្នាំចាស់ៗ ដែលមាននៅជិតៗខ្លួន។ ដាច់ខាតមិនត្រូវគិតថា៖ "អ្ហា! ខ្ញុំមានថ្នាំដែលនៅសល់ពីសត្វដំរីមួយឈ្មោះផ្លាយហ្កាវ (Phlai Gaew)។ ខ្ញុំគិតថានឹងប្រើថ្នាំទាំងនោះជាមួយដំរីមួយទៀតឈ្មោះផ្លាយប៊ុនរ៉ាដ (Phlai Bunrawd)"។ ការជ្រើសរើសថ្នាំ និងការកម្រិតបរិមាណថ្នាំដោយខ្លួនឯង មិនត្រឹមតែជាអំពើខុសច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាទង្វើមួយប្រកបដោយភាពវៃឆ្លាតនោះដែរ។ ជាមួយទង្វើបែបនេះ អ្នកនឹងអាចធ្វើឲ្យសត្វដំរីស្លាប់បាន។

មិនត្រូវចាក់ថ្នាំឲ្យដំរី ដោយគ្មានការណែនាំ និងបញ្ជាពីពេទ្យសត្វជាដាច់ខាត។ ត្រូវប្រើបច្ចេកទេស ដែលបានផ្តល់ជូនដូចខាងក្រោម៖

## វិធីសាស្ត្រសម្រាប់ចាក់ថ្នាំតាមសាច់

*ការចាក់ថ្នាំត្រូវបានគេសន្មត់ថាត្រូវតែធ្វើឡើងដោយពេទ្យសត្វតែប៉ុណ្ណោះ ព្រោះវាអាចមានគ្រោះថ្នាក់ប្រសិនបើអ្នកផ្សេងប្រើវិធីសាស្ត្រមិនបានត្រឹមត្រូវ។ ប៉ុន្តែពេលខ្លះសត្វដំរីមួយនោះវាកាចសាហាវណាស់ ដែលមានតែហ្មរបស់វាតែប៉ុណ្ណោះ ដែលអាចចូលទៅជិតវាបាន ដូច្នេះហើយគាត់ត្រូវតែជាអ្នកចាក់ថ្នាំ ដោយមានពេទ្យសត្វនៅក្បែរនោះ។*

*១. យកសឺរ៉ាំងថ្មីមួយដែលមានទំហំសមស្របសម្រាប់កម្រិតថ្នាំ ដែលត្រូវចាក់ឲ្យដំរីតាមធម្មតាគឺសឺរ៉ាំងចំណុះ ៥០ CC។ រៀបចំម្ជុលដែលមិនទាន់ប្រើ ឬម្ជុលដែលបានសម្លាប់មេរោគរួចហើយ ដោយមានប្រវែងពី ១,៥ ទៅ ៣ អ៊ីញ លេខរង្វាស់ពី ១៤ ទៅ ១៦ ។*

*២. ជ្រើសរើសកន្លែងដែលអ្នកនឹងត្រូវចាក់ថ្នាំបញ្ចូល គឺតំបន់ដែលមានសាច់ដុំនៅលើខ្លួនរបស់ដំរី។ ចំពោះសត្វដំរីត្រូវចាក់លើសាច់ដុំស្មា ប្រសិនបើអ្នកឈរលើដីរាបស្មើ។ ត្រូវចាក់លើសាច់ដុំកប្រសិនបើអ្នកឈរលើដីទួលខ្ពស់ជាងដំរី។ (សូមមើលទំព័រទី ២០០)។*

*៣. លាងសម្អាតតំបន់ដែលអ្នកនឹងចាក់ថ្នាំ ជាមួយសំឡីដែលមានជាតិអាល់កុល។*



*៤. បូមថ្នាំពីដបបញ្ចូលក្នុងសឺរ៉ាំង ក្នុងបរិមាណដែលបានកំណត់ដោយពេទ្យសត្វ។ (សូមមើលរូបភាព) បាញ់ខ្យល់ដែលនៅសល់ក្នុងសឺរ៉ាំងឲ្យចេញមកក្រៅឲ្យអស់។*



៥. ប្រើកណ្ដាប់ដៃគក់ថ្នមៗលើតំបន់ដែលនឹងត្រូវចាក់ថ្នាំ ដើម្បីឲ្យដំរីដឹងខ្លួនជាមុន ទើបពេលចាក់ម្ជុលចូលទៅ វានឹងមិនធ្វើឲ្យដំរីផ្អើល។

៦. ដោតម្ជុលចូលទៅក្នុងសាច់ដុំដំរី រហូតដល់គល់ម្ជុល។

៧. យកសឺរ៉ាំងដែលបានបូមថ្នាំពេញ ហើយដោតចូលទៅក្នុងគល់ម្ជុល ដែលផ្ទៃរបស់វាបានចូលនៅក្នុងសាច់ដំរីរួចហើយ។

៨. មុនពេលចាក់ថ្នាំ ត្រូវទាញដកស្នូលសឺរ៉ាំងបន្តិច ដើម្បីធានាថាម្ជុលយើងបានចាក់ចូលទៅតែក្នុងសាច់ដុំ គឺមិនបានមុតចូលក្នុងសរសៃឈាមទេ។ ប្រសិនបើម្ជុលស្ថិតនៅក្នុងសរសៃឈាមអ្នកនឹងឃើញឈាមចូលក្នុងសឺរ៉ាំង។ ប្រសិនបើអ្នកចាក់ចំលើសរសៃប្រសាទសត្វដំរីនឹងពិបាកទ្រាំជាងនៅលើសាច់ធម្មតា។ ប្រសិនបើអ្នកចាក់ចំសរសៃឈាម ឬសរសៃប្រសាទ អ្នកត្រូវដកយកសឺរ៉ាំង និងម្ជុលចេញវិញ ហើយចាប់ផ្ដើមកន្លែងថ្មីម្ដងទៀត។

៩. បាញ់ថ្នាំឲ្យអស់ពីសឺរ៉ាំងទាំងស្រុង។ ដកយកសឺរ៉ាំង និងម្ជុលចេញ ហើយបន្ទាប់មកយកដៃរឹតលើកន្លែងដែលទើបតែបានចាក់ថ្នាំ ដើម្បីឲ្យថ្នាំឆាប់ជ្រាបចូលទៅក្នុងសាច់ដំរីបានរហ័យ។ សម្អាតតំបន់នោះដោយប្រើសំឡីដែលមានជាតិអាល់កុលម្ដងទៀត។

ប្រយ័ត្នះ ថាំពេទ្យខ្លះអាចបណ្ដាលឲ្យសាច់នៅតំបន់នោះហើម ប៉ុន្តែជាទូទៅវានឹងឆាប់រលាយបាត់ទៅវិញ។ ហ្នដំរីអាចជួយកាត់បន្ថយការហើមនោះ ដោយប្រើបង់រុំទឹកក្ដៅឧណ្ហៗបិទស្អំលើតំបន់នោះ។

## មើលថែដំរីឈឺដេកនៅលើដី

ជាធម្មតាដំរីដេកពី ២ ទៅ ៥ ម៉ោងក្នុងមួយថ្ងៃ ភាគច្រើននៅពេលយប់ ពេលខ្លះវាដេកផ្ទាល់នៅលើដី និងពេលខ្លះឈរ។ សត្វដំរីដែលកំពុងដេកនៅលើដីពិតជាពូកែដឹងណាស់ នៅពេលមានអ្វីប្លែកកើតឡើងនៅក្បែរវា ដូច្នេះក្រៅពីកូនដំរី និងដំរីឈឺ វាប្រាកដជាមិនធម្មតាទេ នៅពេលហ្មដំរី ឬអ្នកថែដំរីឃើញសត្វដំរីមួយក្បាលដេកនៅលើដី។

ប្រសិនបើសត្វដំរីឈឺខ្លាំង ហើយវាមិនអាចងើបដោយខ្លួនវាបាន ពេលនោះ ហ្មដំរីត្រូវទៅពិគ្រោះជាមួយពេទ្យសត្វ អំពីរការរៀបចំស្ថានភាពឲ្យដំរីដេកឲ្យបានស្រួល ធ្វើបែបនេះ ទើបមិនសូវមានគ្រោះថ្នាក់ដល់ដំរី។

ត្រូវឲ្យដំរីដេកផ្អៀងទៅម្ខាង ខាងណាក៏បាន។ នៅក្នុងកាលៈទេសៈណាក៏ដោយ ក៏មិនត្រូវឲ្យដំរីឈឺដេកពបលើដើមទ្រូងវាដែរ ព្រោះវានឹងពិបាកដកដង្ហើមបានស្រួល ហើយថែមទាំងអាចថប់ដង្ហើមបានទៀតផង ដោយសារតែមានសម្ពាធសង្កត់លើសួតរបស់វា។

ចំពោះដំរីឈឺ ដែលដេកផ្អៀងទៅម្ខាងលើខ្លួនវា យើងត្រូវផ្លាស់ប្តូរប្រែខ្លួនវាទៅម្ខាងទៀត យ៉ាងហោចណាស់ឲ្យបានពីរដងក្នុងមួយថ្ងៃដែរ ដើម្បីការពារកុំឲ្យមានសម្ពាធឈាមខ្ពស់នៅតែម្ខាងៗ (hypostatic congestion)។

ប្រសិនបើសត្វដំរីមួយក្បាលដេកនៅតែលើដី អស់រយៈពេលជាងមួយសប្តាហ៍នោះ នឹងកើតមានដំបៅខ្លះៗនៅលើខ្លួនរបស់វា។ (សូមមើលទំព័រទី ១២៧)។ ត្រូវប្រើស្មៅស្ងួត ឬចំបើងធ្វើជាពូកឲ្យដំរីដេក ដើម្បីជួយការពារកុំឲ្យកើតដំបៅ។

## ស្ថានភាពសុខភាពដំរីបណ្តាលមកពីមនុស្ស

ស្ថានភាពសុខភាពរបស់ដំរីធំៗចំនួន ៤ ដែលបង្កឡើងដោយមនុស្ស ក្នុងករណីធ្ងន់ធ្ងរ ត្រូវមានជំនួយបន្ទាន់ពីផ្នែកវេជ្ជសាស្ត្រ ដូចគ្នានឹងជម្ងឺមែនទែនដែរ គឺនៅពេលសត្វដំរីធ្វើការហួសកម្លាំង កង្វះអាហារូបត្ថម្ភ ភាពតានតឹង និងជម្ងឺដាច់សរសៃឈាមក្នុងខួរក្បាល។ (មនុស្សក៏អាចជាអ្នកចូលរួមចំណែកដល់បញ្ហាសុខភាពទី ៥ ដែលមិនមែនជាជម្ងឺទូទៅរបស់សត្វដំរី នោះគឺជម្ងឺផ្តាសាយ) ល័ក្ខខ័ណ្ឌទាំងអស់នេះអាចកើតមានឡើងចំពោះ

ដំរីព្រៃ ប៉ុន្តែវាកម្រមានណាស់ ព្រោះដំរីព្រៃមានសេរីភាព ហើយវានៅឆ្ងាយពីមនុស្ស។ មនុស្សអាចចង និងបង្ខាំងដំរី ហើយអាចបញ្ជូនពួកវាទៅកន្លែង ដែលមិនសមរម្យ អាចបង្កជាលក្ខខ័ណ្ឌមិនសមស្របជាញឹកញាប់ជាងដំរីព្រៃ។

លក្ខខ័ណ្ឌសុខភាពទាំងបួនដំបូងនៃជម្ងឺរបស់សត្វដំរីទាំងនេះ គឺជាការឈឺចុកចាប់ជាទូទៅ នៅក្នុងចំណោមសត្វដំរីដែលកំពុងចិញ្ចឹមនៅក្នុងប្រទេសថៃ ហើយវាបង្កឲ្យការខូចខាតយ៉ាងខ្លាំង ប្រហែលជាខូចខាតច្រើនជាងជម្ងឺពិតប្រាកដទៅទៀត។ ជាការពិតណាស់ ករណីជាច្រើននៃជម្ងឺពិតប្រាកដកើតឡើង តែដោយសារស្ថានភាពសុខភាពបង្កឡើងដោយមនុស្ស ដែលបានធ្វើឲ្យដំរីចុះខ្សោយ ងាយនឹងរងគ្រោះដោយសារជម្ងឺ។អ្វីដែលគួរឲ្យសោកស្តាយនោះ គឺថាជាមួយនឹងការគ្រប់គ្រងប្រកបដោយវិជ្ជាជីវៈ និងតាមគោលការណ៍នៃការយកចិត្តទុកដាក់របស់មនុស្ស រាល់បញ្ហានៃលក្ខខ័ណ្ឌទាំងអស់នេះអាចជៀសវាងបានយ៉ាងងាយស្រួល។

## ការងារលើសកម្លាំង (ការហត់នឿយខ្លាំង)

ការធ្វើការងារហួសកម្លាំង គឺនៅពេលយើងប្រើឲ្យសត្វដំរីធ្វើការច្រើនជ្រុលពេករហូតដល់វាហត់នឿយខ្លាំង ហើយសុខភាពរាងកាយរបស់វាចុះខ្សោយដល់កម្រិត ដែលត្រូវការព្យាបាលឲ្យបានឆាប់ យ៉ាងហោចណាស់ក៏ត្រូវឲ្យវាបានសម្រាកពេញលេញ និងផ្តល់ចំណីឲ្យដំរីឲ្យបានគ្រប់គ្រាន់ និងល្អៗជាងមុន។ ការហត់នឿយខ្លាំងពេកអាចធ្វើឲ្យដំរីចុះខ្សោយយ៉ាងខ្លាំង រហូតដល់ប្រព័ន្ធភាពស៊ាំរបស់រាងកាយវាចុះខ្សោយខ្លាំង ហើយសត្វដំរីងាយនឹងកើតជម្ងឺផ្សេងៗ។ ការធ្វើការលើសកម្លាំង គឺលើសពីថាមពលដែលដំរីមានច្រើនជ្រុលពេក ពេលនោះការប្រើប្រាស់ពេលវេលារបស់ដំរីក៏ច្រើនជ្រុលដែរ ហើយដំរីនឹងមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់ស៊ីចំណីអាហារដើម្បីចិញ្ចឹមខ្លួនវាទេ។ ដូច្នេះបើឲ្យដំរីធ្វើការច្រើនជ្រុលពេក ករណីភាគច្រើនវាអាចបណ្តាលឲ្យដំរីមានបញ្ហាខ្វះអាហារូបត្ថម្ភ ដោយសារតែវាស៊ីចំណីអាហារបានតិចតួចពេក។

## កង្វះអាហារូបត្ថម្ភ

បញ្ហាខ្វះអាហារូបត្ថម្ភច្រើនតែកើតមានចំពោះសត្វដំរី ដែលធ្វើការងារច្រើនម៉ោងដើម្បីរកលុយ ដូចជាដំរីសម្រាប់ជិះកំសាន្តនៅតាមមជ្ឈមណ្ឌលទេសចរណ៍ ដំរីសម្រាប់

ដើរលេងកំសាន្តនៅតាមទីក្រុងជាដើម។ នៅពេលដំរីខំប្រឹងធ្វើការកាន់តែច្រើម៉ោង ពេលនោះ ប្រាក់ចំណូលរបស់ម្ចាស់វាក៏កាន់តែកើនឡើងច្រើនដែរ។ ជាលទ្ធផល គឺដំរីកំពុងតែទទួលបានចំណីអាហារមិនបាបគ្រប់មុខ ឬចំណីអាហារដែលដំរីកំពុងស៊ីនោះ មិនមានលក្ខណៈដូចគ្នាទៅនឹងចំណីអាហារ ដែលពួកវាអាចស៊ីបន្ថែម នៅក្នុងស្ថានភាពធម្មជាតិទេ។ ពេលខ្លះសត្វដំរីធុញទ្រាន់នឹងចំណីអាហារដែលគេបានដាក់ឲ្យវា ហើយមានពេលខ្លះទៀត ពួកវាមិនព្រមស៊ីចំណីអាហារទាំងនោះទេ។ កូនដំរីកំព្រាភាគច្រើនតែងជួបបញ្ហាខ្វះអាហារូបត្ថម្ភជាញឹកញាប់ (សូមមើលទំព័រទី ៧២)។

បញ្ហាកង្វះអាហារូបត្ថម្ភមានទម្រង់ជាមូលដ្ឋានពីរ ទោះបីជាវាអាចកើតឡើងក្នុងពេលតែមួយក៏ដោយ។ ទីមួយនិងសាមញ្ញបំផុតនោះ គឺដំរីគ្រាន់តែមិនទទួលបានចំណីអាហារគ្រប់គ្រាន់។ ទី ២ គឺនៅពេលដែលសត្វដំរីអាចស៊ីចំណីអាហារត្រឹមតែមួយប្រភេទ ឬមានតែចំណីអាហារពីរបីប្រភេទតែប៉ុណ្ណោះ ពេលនោះសត្វដំរីនឹងត្រូវខ្វះសារជាតុចិញ្ចឹមសំខាន់ៗមួយចំនួនដូចជា ប្រូតេអ៊ីន ជាតិរ៉ែ ឬសារជាតុចិញ្ចឹមផ្សេងៗទៀត។

កង្វះអាហារូបត្ថម្ភ ដែលបណ្តាលមកពីមនុស្សគឺកម្រកើតមានឡើងណាស់នៅក្នុងប្រទេសថៃ លើកលែងតែសត្វដំរីចាស់ និងដំរីពិការខ្លះ ដែលមិនសូវមានតម្លៃ ប៉ុន្តែសត្វដំរីដែលធ្វើការច្រើនហួសពេក ហើយស្ថិតនៅក្នុងស្ថានភាពក្រីក្រក៏អាចទទួលរងគ្រោះខ្វះអាហារូបត្ថម្ភដែរ ជាពិសេសនៅតាមតំបន់ព្រំដែន។

សត្វដំរីដែលមានទម្ងន់ស្រាល ជាធម្មតា គឺជាសត្វដំរីដែលកំពុងធ្វើការ ហើយទទួលបានចំណីអាហារមិនគ្រប់គ្រាន់ ទោះបីជាបញ្ហានេះក៏តែងកើតមានឡោះងចំពោះសត្វដំរីចាស់ ដែលមានធ្មេញរេចរឹលអស់មិនអាចទំពារចំណីអាហារបាន និងប្រព័ន្ធរំលាយអាហារចុះខ្សោយ។

សម្រាប់ហ្មដំរី និងម្ចាស់ដំរី អ្វីដែលសំខាន់បំផុតនោះ គឺការផ្តល់ឲ្យដំរីរបស់ខ្លួននូវចំណីអាហារល្អៗបំផុត ដែលអាចរកបាន និងទុកឲ្យសត្វដំរីមានពេលវេលាគ្រប់គ្រាន់ដើម្បីស៊ីចំណីអាហាររបស់វា។ ការផ្តល់ចំណីល្អៗឲ្យដំរី អាចមើលទៅឃើញថាវាពិតជាថ្លៃណាស់ ប៉ុន្តែក្នុងរយៈពេលយូរៗទៅ សុខភាពរបស់សត្វដំរីនឹងចុះខ្សោយ នោះគឺពិតជាបណ្តាលមកពីចំណីអាហារមិនគ្រប់គ្រាន់ ហើយយើងប្រាកដជានឹងត្រូវខាតបង់ថវិកាយ៉ាង

ច្រើន ដោយសារតែការខាតបង់ពេលវេលាមិនបានធ្វើការ និងពេលវេលាសម្រាប់ធ្វើការព្យាបាលដំរី ជាពិសេសត្រូវបង់ថ្លៃឲ្យបសុពេទ្យ ហើយជួនកាលអាចធ្វើឲ្យសត្វដំរីស្លាប់ថែមទៀត។

រោគសញ្ញា៖ សត្វដំរីធ្លាក់ខ្លួនស្គម ហើមខ្លួន ហើយមានវត្ថុរាវនៅក្រោមថ្គាម មានភាពសោះអង្គើយ មានកម្លាំងតិចតួច ហើយស្បែកឡើងរីងនិងជ្រីវជ្រួញ។

ការព្យាបាល៖

- យកដំរីចេញ ឈប់ឲ្យវាធ្វើការទៀត ហើយឲ្យវាសម្រាកឲ្យបានគ្រប់គ្រាន់។
- បំពេញបន្ថែមរបបអាហាររបស់ដំរី ជាមួយនឹងចំណីអាហារ ដែលមានជីវជាតិដូចជាចេកទុំ ស្រូវ អំពៅ ម្នាស់ និងបាយដំណើបចំហុយ។
- ផ្តល់ឱសថរុក្ខជាតិសម្រាប់សត្វ ដូចជា Tinsospora tuberculata Begum, Dillenia aurea Smith, ដំណាប់អំពិលទុំ (Tammarindus indica Linn) ឬ Cissus quadrangularis Linn។
- ប្រសិនបើមានហើម ត្រូវយកបង់រុំក្តៅឧណ្ហៗ ឬចំហាយកម្តៅឧណ្ហៗស្អំពីលើតំបន់ដែលមានហើម។
- ប្រសិនបើស្ថានភាពដំរីនៅតែមិនទាន់បានល្អប្រសើរទេ ត្រូវតែទៅពិគ្រោះជាមួយលោកគ្រូពេទ្យសត្វ ដើម្បីធ្វើរោគវិនិច្ឆ័យឲ្យបានត្រឹមត្រូវ។

ជម្ងឺកន្ទ្រាក់សាច់ដុំបណ្តាលមកពីខ្វះជាតិកាល់ស្យូម ភាគច្រើនតែងកើតមានឡើងចំពោះសត្វដំរី ដែលធ្វើការនៅក្នុងមជ្ឈមណ្ឌលទេសចរណ៍ ដែលសត្វដំរីមិនមានឱកាសទទួលបានអំបិលរ៉ែធម្មជាតិ។

ដំរីដែលត្រូវបានបង្ខំឲ្យធ្វើការយ៉ាងលំបាក ហើយមិនបានឲ្យវាសម្រាកបានគ្រប់គ្រាន់វាអាចនឹងរងនូវផលប៉ះពាល់ទាំងនេះ ដូចជាឲ្យដំរីធ្វើដំណើរឆ្ងាយ។

រោគសញ្ញា៖ ដំរីចាប់ផ្តើមគ្រប់គ្រងសាច់ដុំរបស់វាលែងបាន ហើយសាច់ដុំរបស់វាក៏ចាប់ផ្តើមកន្ទ្រាក់។

ការព្យាបាល៖

- ឲ្យដំរីឈប់សម្រាកពីការងារភ្លាមៗ។

- បំពេញបន្ថែមអាហារជាមួយអំបិលរ៉ែ ដូចជាដុំអំបិលរ៉ែ ដូចដែលបានផ្តល់ឲ្យគោ និងក្របីដែរ ឬអ្នកអាចផ្តល់ថ្នាំគ្រាប់កាល់ស្យូមតែម្តងក៏បាន ប៉ុន្តែអ្នកគួរតែពិគ្រោះជាមួយពេទ្យសត្វ អំពីបរិមាណថ្នាំដែលត្រូវផ្តល់ឲ្យវាប្រចាំថ្ងៃ។
- ប្រសិនបើស្ថានភាពរបស់ដំរីនៅតែមិនបានល្អប្រសើរឡើងទេ សូមទៅពិគ្រោះជាមួយពេទ្យសត្វជាបន្ទាន់។

ជម្ងឺសាច់ដុំស មិនសូវជួបប្រទះញឹកញាប់ទេ ហើយអាចកើតមានឡើងចំពោះកូនដំរីដែលទើបនឹងកើត នៅក្នុងតំបន់ដែលដី និងបន្លែខ្វះជាតិសេលេញ៉ូម (selenium)។ ជម្ងឺសាច់ដុំសគឺជាជម្ងឺមួយ ដែលពិបាកក្នុងការព្យាបាល ដូច្នេះត្រូវការការពារវា ទើបប្រសើរជាងព្យាបាល។ ប្រសិនបើអ្នកមានមេដំរីផើម ហើយមានរូបកាយស្គមស្គាំង ឬមានសុខភាពទន់ខ្សោយជាពិសេសនៅក្នុងរយៈពេលពី ៣ ទៅ ៦ ខែចុងក្រោយនៃការមានផ្ទៃពោះរបស់វា សូមអ្នកទៅពិគ្រោះជាមួយពេទ្យសត្វ ដែលអាចចេញវេជ្ជបញ្ជាឲ្យផ្តល់អាហារបំប៉នបន្ថែមឲ្យបានសមស្រប។ គេត្រូវការសារជាតុសេលេនីញ៉ូមជាញឹកញាប់ ប៉ុន្តែការប្រើប្រាស់វាលើអ្នកជម្ងឺមានភាពស្មុគស្មាញ យកល្អបំផុតត្រូវប្រើប្រាស់វាក្រោមការត្រួតពិនិត្យរបស់ពេទ្យសត្វ។

រោគសញ្ញា៖ កូនដំរីមិនអាចប្រើជើងរបស់វា ដើម្បីដើបឈរបាន បន្ទាប់ពីកើតរួច។ កូនដំរីដែលស្ថិតក្នុងស្ថានភាពបែបនេះ ភាគច្រើនត្រូវស្លាប់ទៅវិញ តែក្នុងរយៈពេលប្រហែលពីរសប្តាហ៍ក្រោយពេលកើត។

ការព្យាបាល៖

- ក្នុងរយៈពេលពី ៣ ទៅ ៦ ខែចុងក្រោយនៃការមានផ្ទៃពោះរបស់មេដំរី ត្រូវទៅពិគ្រោះជាមួយពេទ្យសត្វ។
- ត្រូវទៅពិគ្រោះជាមួយពេទ្យសត្វភ្លាមៗ។

ជម្ងឺកង្វះទឹកដោះម្តាយ ចំពោះកូនដំរីកំព្រា មានន័យថាកូនដំរីកំព្រាជារឿយៗស្លាប់ដោយសារតែវាកើតជម្ងឺរាក បណ្តាលមកពីសារជាតុមួយចំនួន ដែលគេបានដាក់បញ្ចូលក្នុងទឹកដោះគោម្សៅ។ មូលហេតុមួយទៀតនៃជម្ងឺរាករូស និងបណ្តាលឲ្យកូនដំរីស្លាប់ជាញឹកញាប់ គឺដោយសារតែឲ្យទឹកដោះខុស ដូចជាទឹកដោះគោម្សៅ ដែលកូនដំរី

ជាច្រើនមិនអាចរំលាយបានត្រឹមត្រូវ។ ដំណោះស្រាយដែលល្អបំផុត គឺត្រូវទិញរូបមន្ត ពិសេសសម្រាប់ទារក ដូចជា Prosobee ជាឧទាហរណ៍ ដែលមិនមែនធ្វើពីទឹកដោះគោធម្មតា។

*រោគសញ្ញា៖* កូនដំរីមិនមានការវិវត្តធំធាត់ដូចធម្មតាទេ បង្ហាញពីភាពក្រិន វាតែងមានជម្ងឺរាករូសជាញឹកញាប់ មានស្បែកគ្រើម និងជ្រីវជ្រួញ និងមានធ្មេញទន់។

*ការព្យាបាល៖* ត្រូវចិញ្ចឹមថែវាឲ្យដូចជាកូនដំរីកំព្រាដទៃទៀត (មើលទំព័រទី ៧២)។

**សម្ពាធការខារ** (ស្ត្រេស)

ជាញឹកញាប់ស្ត្រេស គឺជាភាពតានតឹងដែលច្រើនតែបណ្តាលឲ្យកើតមានជម្ងឺ និងបញ្ហាផ្សេងៗទៀត។ ចំពោះសត្វដំរី ភាពតានតឹងតែងតែកើតមានឡើង នៅពេលដែលសត្វដំរីធ្វើការហួសកម្លាំង នៅពេលគេបង្ខំឲ្យសត្វដំរីធ្វើអ្វីមួយខុសពីធម្មតា ឬឲ្យវាធ្វើការងារមិនធម្មតាណាមួយ នៅពេលដែលដំរីស៊ីចំណីអាហារមិនគ្រប់គ្រាន់ វាស្ថិតនៅកន្លែងក្តៅពេក ក្នុងបរិយាកាសដែលមានសម្លេងរំខានខ្លាំង ឬចង្អៀតណែនខ្លាំងពេក គឺមនុស្សបានផ្លាស់ប្តូររបៀបរស់នៅរបស់វា។ល។ ការមកដល់របស់ហ្មដំរីថ្មី ជារឿយៗ វាក៏អាចបណ្តាលឲ្យសត្វដំរីមានភាពតានតឹងដែរ។

*រោគសញ្ញា៖* ជាទូទៅដំរីមិនបង្ហាញសញ្ញាថាវាកំពុងមានភាពតានតឹង ឲ្យយើងអាចមើលឃើញបានដោយច្បាស់លាស់ទេ ប៉ុន្តែជាធម្មតាមានសូចនាករមួយចំនួន ដែលអាចឲ្យយើងដឹងបាន ដូចជានៅពេលគេដាក់ច្រវាក់វា សត្វដំរីគ្រវីក្បាល និងគ្រវែងដងខ្លួនជារឿយៗ ហើយវាប្រឹងបង្កើនល្បឿន។ ដំរីខ្លះនឹងយកប្រមោយរបស់ចាប់យកខ្សែក្រវាត់ដែលគេចងវា ទៅវាយវ៉ៃនឹងដើមឈើដែលគេបានដាក់ច្រវាក់ចងវាទុកនៅទីនោះ។ ក្នុងស្ថានភាពខ្លះ ពេលយើងមើលទៅហាក់ដូចជាគ្មានអ្វីខុសធម្មតាទេ ហើយដំរីក៏មានឥរិយាបទល្អជាធម្មតាដែរ ប៉ុន្តែភ្លាមៗនោះ ដំរីក៏ក្លាយជា "ឆ្កួត" និងអាចបង្កគ្រោះថ្នាក់ដល់មនុស្ស។ ដូច្នេះហ្មដំរីនីមួយៗត្រូវតែមានសមត្ថភាពអាចមើលយល់ថា តើដំរីរបស់គាត់រីករាយ ឬមិនសប្បាយចិត្ត។

*វាក៏សំខាន់ផងដែរក្នុងការពិចារណាដល់ដំរីផ្សេងៗទៀតដែលនៅក្បែរនោះ។ ពេលខ្លះសត្វដំរីមួយក្បាលអាចនឹងតូចចិត្ត ដោយសារតែវានៅជិតដំរីណាមួយ ដែលវាមិនចូលចិត្ត ឬក៏វាខ្លាចដំរីនោះ។*

*នៅពេលសត្វដំរីបង្ហាញពីស្ថានភាពបែបនេះ ប្រសិនបើយើងមិនបានយកចិត្តទុកដាក់ឲ្យបានត្រឹមត្រូវទេ ទីបំផុតទៅដំរីនោះអាចនឹងជួបប្រទះនូវបញ្ហាកើតមានជម្ងឺផ្សេងៗ ដូចជាការទល់លាមក វាមិនព្រមស៊ីចំណីអាហារ វាមានការហត់នឿយជាដើម។*

***ការព្យាបាល៖*** *ប្រើដំរីសម្រាប់តែការងារដែលសមស្រប។ ថែរក្សាសត្វដំរី ឲ្យដូចជាមិត្តមើលថែទាំមិត្តម្នាក់ទៀត។ ធ្វើអ្វីក៏ដោយឲ្យតែចាំបាច់ ដើម្បីការពារកុំឲ្យសត្វដំរីមានភាពតានតឹងបាន។ កុំរក្សាទុកដំរី ជាពិសេសដំរីក្មេងៗ និងដំរីញីឲ្យនៅក្នុងភាពឯកោ។*

***ដំបូន្មានដល់ម្ចាស់មជ្ឈមណ្ឌលដំរី៖*** *ប្រសិនបើសត្វដំរីមួយក្បាលណា កំពុងស្ថិតនៅក្នុងស្ថានភាព ដែលយើងពិបាកពន្យល់មូលហេតុ ក្នុងរាងកាយរបស់វាឲ្យបានច្បាស់លាស់ ត្រូវពិចារណាផ្លាស់ប្តូរហ្វូងដំរី ឬចាត់ទាំងហ្វូងដំរីណាដែលមានបទពិសោធន៍ខ្ពស់ឲ្យសង្កេតមើលស្ថានការណ៍របស់ដំរីមួយនោះ។*

## ជម្ងឺចាញ់ក្តៅ

*ជម្ងឺចាញ់ក្តៅ (ភាពតានតឹងហត់នឿយដោយសារក្តៅខ្លាំង) ច្រើនកើតមានឡើងចំពោះសត្វដំរីណា ដែលបានធ្វើការយ៉ាងខ្លាំង ឬដើរឆ្ងាយនៅក្រោមកម្តៅព្រះអាទិត្យដោយផ្ទាល់។ ជម្ងឺចាញ់ក្តៅនេះ ក៏តែងកើតមានចំពោះសត្វដំរី ដែលស៊ីចំណីអាហារ និងសម្រាកមិនបានគ្រប់គ្រាន់។*

*រោគសញ្ញា៖*

- *ដំរីមានអាការៈភាំងៗ និងភ្នែកឡើងពណ៌សល្អក់។*
- *ដំរីដកដង្ហើមធំគ្រហឹមៗ និងដង្ហក់ជាបន្តបន្ទាប់។*
- *ជាធម្មតាសត្វដំរីនឹងដើរដោយដំណើរទ្រេតទ្រោត ហើយពេលខ្លះវានឹងដួលដល់ដល់ដី ដោយមិនដឹងខ្លួន។ ប្រសិនបើមិនបានព្យាបាលឲ្យទាន់ពេលវេលាទេ សត្វដំរីនោះអាចនឹងស្លាប់។*

*ការព្យាបាល៖*

- *ការការពារជាមុន គឺជាវិធីតែមួយដ៏ល្អប្រសើរបំផុត។ ត្រូវតែថែរក្សាសត្វដំរីដោយក្ដីស្រឡាញ់៖ ចិញ្ចឹមវាឲ្យបានល្អ ឲ្យវាសម្រាកបានច្រើន ហើយកុំឲ្យវាធ្វើការលើសកម្លាំង ឬនៅក្រោមកម្ដៅព្រះអាទិត្យ ដែលកំពុងតែក្ដៅខ្លាំង។*
- *ប្រសិនបើអាចធ្វើបាន សូមឲ្យដំរីដើរនៅក្រោមម្លប់ បើមិនអាចធ្វើបានទេ ចូរប្រក់ដំបូល ដើម្បីជាម្លប់ដល់ដំរី។*
- *ស្រោចទឹកលើដងខ្លួនទាំងមូលរបស់ដំរី ប៉ុន្តែជាពិសេសគឺត្រចៀក។*
- *ឲ្យដំរីផឹកទឹកតែក្នុងបរិមាណបន្តិចបន្តួចសិនបានហើយ ពីព្រោះការផឹកទឹកច្រើនពេកភ្លាមៗ វាអាចធ្វើឲ្យដំរីស្ទះដង្ហើម ហើយអាចដល់ស្លាប់ក៏ថាបាន។*
- *ប្រសិនបើស្ថានភាពមិនបានល្អប្រសើរឡើងវិញទេ សូមទៅពិគ្រោះជាមួយពេទ្យសត្វ។ ដំរីណាដែលមានជម្ងឺចាញ់កំដៅថ្ងៃបែបនេះ ត្រូវតែឲ្យវាបានសម្រាកពីរ ឬបីថ្ងៃ បន្ទាប់ពីបានជាសះស្បើយពីជម្ងឺនេះហើយ។*

## ដំរីដួលដោយសារត្រជាក់

*ករណីដំរីដួលដោយសារតែអាកាសធាតុត្រជាក់នេះ ពិតជាធ្លាប់មានញឹកញាប់ណាស់ នៅរដូវត្រជាក់ ជាពិសេសនៅភាគខាងជើង។ ការដួលរលំរបស់សត្វដំរី ច្រើនកើតមានឡើងនៅគ្រប់អាកាសធាតុត្រជាក់ ប៉ុន្តែជាពិសេសនៅពេលវាត្រជាក់ ហើយសើម។ វិធីការពារដ៏ល្អបំផុត គឺត្រូវថែរក្សាសត្វទាំងអស់ឲ្យស្ថិតនៅក្រោមការសង្កេត និងត្រៀមខ្លួនដើម្បីព្យាបាលដំរីដែលរងផលប៉ះពាល់បែបនេះ ដូចខាងក្រោម។*

*ករណីភាគច្រើននោះ គឺដំរីដែលចាស់ ឈឺ ស្គម ឬដំរីដែលមិនសូវមានកម្លាំង។ ជាពិសេស គឺដំរីដែលងាយរងគ្រោះ ជាសត្វដំរីដែលមានភាពតានតឹង ឬដែលទើបតែផ្លាស់មកពីតំបន់ក្ដៅ។ ដំរីដែលស្ថិតក្នុងប្រភេទណាមួយ យើងគួរតែសង្កេតមើលដំរីនោះឲ្យបានច្បាស់លាស់។*

*រោគសញ្ញា៖*

- *ដំរីដួលដោយសារអាកាសធាតុត្រជាក់ ជាធម្មតាគឺនៅពាក់កណ្ដាលយប់ ឬជិតភ្លឺ។*
- *ដំរីនឹងញ័រពេញខ្លួនវា ហើយជាពិសេសស្បែកនឹងរញ្ជួយ ឬញ័រជាបន្តបន្ទាប់។*

- *ចុងប្រមោយ បបូរមាត់ និងជាលិការទន់ៗដទៃទៀតគឺស្វេកណាស់។*
- *ប្រសិនបើយើងមិនបានជួយដំរីឲ្យបានទាន់ពេលវេលាទេ នោះដំរីនឹងអាចមានដម្ប៊ៅកន្ទ្រាក់សាច់ដុំជាប្រចាំ ដែលជាសញ្ញាបង្ហាញថាដំរីនឹងឆាប់ស្លាប់។*

*ការព្យាបាល៖*

- *ត្រូវដោះខ្សែចង និងយកសម្ភារៈចេញពីលើខ្លួនដំរីភ្លាមៗ។*
- *ប្រសិនបើដំរីដេកនៅលើដី ត្រូវព្យាយាមជួយវាឲ្យក្រោកឈរនៅលើជើងរបស់វា ទោះបីជាមិនអាចធ្វើបានភ្លាមៗក៏ដោយ។*
- *ឲ្យដំរីស៊ីចំណីដែលមានជីវជាតិខ្ពស់ដូចជាចេកទុំ និងអំពៅ។ បាយក្តៅៗរុំស្លឹកចេក ឬចំណីផ្សេងទៀត ដែលដំរីអាចស៊ីបាន ទោះជាវាកំពុងដេកនៅលើដីក៏ដោយ។*
- *បំបាត់ភាពត្រជាក់របស់ដំរី ដោយការដុតភ្លើងនៅក្បែរកន្ទែង ដែលវាកំពុងដេក។ (ប្រសិនបើជាកូនដំរីវិញ ត្រូវប្រាកដថាមានអ្នកណាម្នាក់ឃ្លាំមើលវាជាប្រចាំ) ។*
- *ព្យាយាមរកកន្លែងក្បែរនោះ ដែលអាចបាំងការពារពីខ្យល់បាន ដូចជានៅក្បែរអាគារខ្ពស់ៗ ក្បែរឡានដឹកទំនិញកង់ ១០ ផ្ទាំងថ្មខ្ពស់ៗ ឬអ្វីផ្សេងទៀតក៏បានដែរ។ សូម្បីតែខ្យល់អាកាសបក់បន្តិចៗ ក៏អាចទាញយកកម្តៅពីខ្លួនរបស់ដំរីបានដែរ។*
- *ប្រសិនបើសត្វដំរីមិនមានស្ថានភាពល្អប្រសើរឡើងទេ សូមទៅពិគ្រោះជាមួយពេទ្យសត្វជាបន្ទាន់ ដើម្បីធ្វើការព្យាបាល។*

*សត្វដំរីទាំងអស់ដែលបានដួលរលំ ដោយសារតែអាកាសធាតុត្រជាក់ គួរតែឲ្យវាបានសម្រាកពេញលេញ (ប្រហែលពី ១ ទៅ ២ សប្តាហ៍) ។*

## របួសស្នាម

*ស្នាមរបួសវាជារឿងធម្មតាណាស់ជាមួយសត្វដំរី។ ប្រសិនបើអ្នកបានឃើញសត្វដំរីមួយក្បាលគ្មានស្នាមដំដៅ ឬស្នាមរបួសទេ នោះអ្នកនឹងអាចនិយាយបានថា ហ្មដំរីនោះ ជាហ្មដំរីមួយដ៏ល្អ ហើយគាត់ពូកែមើលថែទាំដំរីរបស់គាត់ ដោយយកចិត្តទុកដាក់បំផុត។*

**ការព្យាបាលរបួសស្លាម**

របួស មិនថាជាមុខរបួសបើកចំហរ ឬជាមុខរបួសជិតទេ វានឹងងាយឆ្លងមេរោគចូលណាស់។ ដំបៅក្នុងអាចនាំឲ្យមានគ្រោះថ្នាក់ខ្លាំងដល់ដំរី។ ដូច្នេះនៅពេលតាមដានព្យាបាលរបួសវា យកល្អត្រូវតែថែរក្សាដំរីទុកនៅក្នុងរោងមួយ ដែលមានកម្រាលពីបេតុងដែលងាយស្រួលក្នុងការសម្អាត និងដើម្បីកុំអោយដំរីផ្ទុំសារធាតុមិនស្អាត ដូចជាលាមក ឬធូលីដីចូលទៅក្នុងមុខរបួស។ ប្រសិនបើមិនមានរោងនៅជិតតំបន់នោះទេ ត្រូវសម្អាតកន្លែង ដែលយើងយកដំរីទៅចងទុក ដោយប្រុងប្រយ័ត្ន ដើម្បីកុំឲ្យមានលាមក ឬកាកសំណល់ចេញមកពីសត្វដទៃទៀតនៅក្បែរនោះ។

**ការហូរឈាមតាមសរសៃឈាម**

លទ្ធភាពអាចបញ្ឈប់ការហូរឈាមបាន មានសារៈសំខាន់បំផុត នៅពេលដែលសត្វដំរីមានរបួសបើកចំហរ និងមានហូរឈាម។ ការហូរឈាមអាចត្រូវបានបញ្ឈប់ដោយប្រើបច្ចេកទេសងាយស្រួលជាច្រើន។ អ្នកអាចជ្រើសរើសវិធីសាស្ត្រមួយ ឬក៏ប្រើវិធីទាំងអស់រួមគ្នា ប៉ុន្តែជាទូទៅអ្នកគួរតែសាកល្បងតាមលំដាប់លំដោយ ដូចដែលបានផ្តល់ជូនខាងក្រោម។

បន្ទាប់ពីការហូរឈាមត្រូវបានបញ្ឈប់ដោយជោគជ័យ ឬប្រសិនបើឈាមនៅតែហូរមិនព្រមឈប់ សូមអ្នកហៅពេទ្យសត្វ។

- ប្រើក្រណាត់ស្អាត គឺក្រណាត់ដែលបានស្ងោរក្នុងទឹកដាំពុះ ទៅខ្ទប់លើមុខរបួស ឬដាក់ក្រណាត់នោះចូលទៅក្នុងរបួសជ្រៅ ដោយប្រើកម្លាំងសង្កត់រយៈពេលប្រហែល ៥ នាទី រហូតទាល់តែឈាមឈប់ហូរ។ ប្រសិនបើក្រណាត់ទីមួយដែលអ្នកបានយកមកប្រើមានសើមជោគដោយឈាម អ្នកត្រូវយកក្រណាត់ស្អាតថ្មីមួយដាក់សង្កត់ពីលើបន្ថែមទៀត ដោយមិនបាច់យកក្រណាត់ទីមួយចេញទេ។
- ប្រសិនបើការហូរឈាមនោះកើតឡើងនៅលើជើង ឬកន្ទុយ ហើយអ្នកមិនអាចគ្រប់គ្រងបាន ដោយគ្រាន់តែសង្កត់លើមុខរបួស អ្នកអាចប្រើខ្សែពួរ ឬក៏ខ្សែអ្វីមួយមកធ្វើជាប្រដាប់សម្រាប់ឃាត់ឈាមបាន។ ខ្សែនោះត្រូវយកមកចងផ្នែកនៅខាងលើបរិវេណដែលមានឈាមកំពុងហូរ។ កុំចងខ្សែនោះលើសពីប្រាំនាទី ប្រសិនបើនៅពេលស្រាយខ្សែចេញ ហើយឈាមនៅតែហូរមិនព្រមបាត់ ត្រូវចងខ្សែរឹតបន្តឹង

ម្តងទៀត ឬសង្កត់ឲ្យធ្ងន់ជាងមុនបន្តិចទៀត។ (កុំប្រើខ្សែពួរដែលតូចពេកព្រោះវាអាចកប់មុតចូលទៅក្នុងស្បែករបស់ដំរីបាន។)

- យកកាំបិតសំប៉ែត ឬប៉ែលស្អាតដាក់វាពេលលើភ្លើងរហូតដល់ក្តៅខ្លាំង បន្ទាប់មកយកវាទៅសង្កត់លើមុខរបួស ដែលមានឈាមហូរ រហូតដល់ឈាមឈប់ហូរ។
- បន្ទាប់ពីឈាមឈប់ហូរយ៉ាងឆាប់រហ័សហើយ អ្នកត្រូវប្រើដើម និងត្រួយស្មៅ Eupatorium odoratum Linn ច្របាច់វាលាយជាមួយដែល (ក្រមួនស្អិតៗដូចខ្លាញ់សត្វ) ហើយលាបវាលើមុខរបួសរហូតដល់ឈាមឈប់ហូរ។

**សំភារៈសម្អាតមុខរបួស**

នៅពេលលាងសម្អាតមុខរបួសថ្មីៗ ដំបៅក្វាយ សម្ភារៈសម្អាតដែលត្រូវយកមកប្រើត្រូវតែគ្មានមេរោគ តាមដែលអាចធ្វើទៅបាន។ មានជម្រើសបីយ៉ាង គឺក្រណាត់ស្អាតសំឡី និងបង់រុំ (ដូចជារបស់គេប្រើក្នុងមន្ទីរពេទ្យ) ។ ហ្មដំរីដែលធ្វើការព្យាបាលស្នាមរបួស គួរតែដឹងពីលក្ខណៈរបស់វានីមួយៗ។

នៅពេលសម្អាតមុខរបួសណាមួយ ហ្មដំរីគួរតែពិគ្រោះ និងអនុវត្តតាមការណែនាំរបស់ពេទ្យសត្វ។

១. **ក្រណាត់ស្អាត** គ្មានពណ៌ អាចរកបានដោយងាយ និងមានតម្លៃថោក។ ជាធម្មតាគេប្រើវាសម្រាប់លាងសម្អាតជុំវិញស្នាមរបួស ឬសង្កត់លើមុខរបួស ដើម្បីបញ្ឈប់ការហូរឈាម ក្នុងគ្រាមានអាសន្ន។ ក្រណាត់បែបនេះគួរតែស្ងោរវាក្នុងទឹកដាំឲ្យពុះយ៉ាងហោចណាស់ឲ្យបានរយៈពេល ១៥ នាទីដែរ ហើយព្យួរហាលវាឲ្យស្ងួត ហើយបន្ទាប់មកយកវាទៅទុកក្នុងថង់ប្លាស្ទិចបិទឲ្យបានជិតល្អ។ ប្រសិនបើថែរក្សាទុកក្រណាត់នោះយូរពួក យើងគួរតែយកវាទៅស្ងោរក្នុងទឹកដាំពុះម្តងទៀតមុនពេលប្រើ។

២. **សំឡី**មានតំលៃថោកណាស់ហើយក៏ងាយស្រួលរកផងដែរ។ នៅពេលប្រើវាដើម្បីសម្អាតស្នាមរបួស គួរតែប្រើវាជាមួយទឹកដែលមានថ្នាំសម្លាប់មេរោគ ហើយប្រើតែទៅតាមការណែនាំរបស់ពេទ្យសត្វតែប៉ុណ្ណោះ។

៣. **បង់រុំ**គេប្រើជាធម្មតានៅតាមមន្ទីរពេទ្យដំរី ឬក្រោមការណែនាំរបស់ពេទ្យសត្វ។

## ការលាងសម្អាតមុខរបួសថ្មីៗ និងដំបៅក្លាយ

*១. ប្រើទឹកស្អាតលាងសម្អាតភាពកខ្វក់ ធូលី និងកំទេចកំទីរបស់ផ្សេងៗទៀតចេញពីមុខរបួស។ ប្រសិនបើមុខរបួសជ្រៅ ត្រូវប្រើសម្ពាធទឹក ដូចជាទឹកពីទុយោ។ ត្រូវពិនិត្យរកមើល និងកំទេចកំទីផ្សេងៗចេញឲ្យអស់ពីមុខរបួសនោះ។ លាងសម្អាតមុខរបួសជាមួយ* Povidone-iodine *១%។*

*២. សម្ងួតបរិវេណ និងខាងក្នុងមុខរបួសដោយក្រណាត់ស្អាត ឬបង់រុំ។ ប្រសិនបើមុខរបួសជ្រៅសូមប្រើដើដុំសំឡី។*

*៣. ប្រើអាល់កុលជូតតំបន់ដែលមានរបួស ជាមួយសំលី ឬបង់រុំ។*

*៤. ជូតមុខរបួសជាមួយសំឡី ឬបង់រុំដែលបានជ្រលក់ក្នុងទឹកថ្នាំ* Povidone-iodine *១%ឬទឹកថ្នាំ* tincture of iodine*។ ប្រសិនបើមុខរបួសមានរន្ធជ្រៅ ត្រូវប្រើដុំសំឡី។*

*៥. ពោយម្សៅប្រឆាំងនឹងសត្វល្អិតនៅលើស្បែកជុំវិញមុខរបួស។*

## លាងសម្អាតដំបៅចាស់ ឬដំបៅក្លាយ

*១. ប្រើទឹកស្អាតលាងសម្អាតភាពកខ្វក់ ធូលី និងកំទេចកំទីរបស់ផ្សេងៗទៀត ចេញពីមុខរបួស និងតំបន់ជុំវិញ។ បន្ទាប់មកលាងសម្អាតមុខរបួសជាមួយទឹកថ្នាំអ៊ីដ្រូសែន* peroxide *មួយថ្ងៃម្តង សម្រាប់រយៈពេលពី ២ ទៅ ៣ ថ្ងៃ រហូតបាត់ខ្ទុះទាំងអស់។*

*២. ទុកទឹកថ្នាំអ៊ីដ្រូសែន* peroxide *ចោល រយៈពេលប្រហែលកន្លះនាទី។ បន្ទាប់មកលាងជម្រះស្នាមប្រឡាក់ដោយទឹកស្អាត រហូតទាល់តែបាត់ស្នាមអ៊ីដ្រូសែន* peroxide *ទាំងអស់។ បន្ទាប់មកជូតផ្នែកខាងក្នុងនៃមុខរបួសដោយក្រណាត់ស្អាត។*

*៣. លាងសម្អាតតំបន់ជុំវិញមុខរបួស ដោយជូតជាមួយសំឡី ឬបង់រុំ ដែលបានត្រាំក្នុងអាល់កុល។*

*៤. ប្រើសំឡី ឬបង់រុំដែលត្រាំក្នុងទឹក "ថ្នាំលឿង" ដើម្បីជូតមុខរបួស។ ប្រសិនបើមុខរបួសជ្រៅសូមប្រើដុំសំឡី។ ចំពោះដំបៅធំៗ ត្រូវប្រើក្រមួនថ្នាំផ្សះ* (អង់ទីប៊ីយ៉ូទិក) *ដូចជាបាក់តាស៊ីន* (Bactacin)*។ ថ្នាំក្រមួននេះនឹងជួយជម្រុញការលូតលាស់របស់ជាលិកា និងកម្ចាត់ជម្ងឺឆ្លងផ្សេងៗបាន។*

*៥. ពោយថ្នាំម្សៅប្រឆាំងនឹងសត្វល្អិត ពាសពេញលើតំបន់ដែលមានមុខរបួស។*

## វិធីក្តៅ និងត្រជាក់

វិធីក្តៅ និងត្រជាក់ត្រូវបានគេយកមកប្រើ ដើម្បីកាត់បន្ថយការហើមសាច់ និងជួយកាត់បន្ថយការឈឺចាប់។ ក្តៅ និងត្រជាក់គឺជាភ្នាក់ងារធ្វើប្រតិបត្តិការ។

ក្រណាត់ត្រជាក់៖ យកទឹកកកហើយរុំវាក្នុងក្រណាត់ស្អាត ហើយបន្ទាប់មកសង្កត់ទៅលើតំបន់ ដែលបានរងរបួស។ ត្រូវប្រើបង់រុំត្រជាក់នោះ សម្រាប់រយៈពេល ២៤ ម៉ោងដំបូងបន្ទាប់ពីបានរងរបួស។ ការប្រើបង់រុំ ឬក្រណាត់ត្រជាក់ គឺល្អណាស់សម្រាប់របួសគ្រេចខ្លាំង ដែលធ្វើឲ្យមានការឈឺចាប់ខ្លាំង ឡើងកម្តៅ និងហើម។

ម៉ាស្សាជាមួយប្រេងមៃ (Muay) ឬប្រេងប្រទាលកន្ទុយក្រពើដទៃទៀត។ ឈ្វីលើតំបន់ដែលហើម ឬឈឺចាប់ដោយប្រើបាតដៃរបស់អ្នក។ យកល្អកុំប្រើម្រាមដៃចុច ឬម៉ាស្សា។ ព្យាបាលពីរ ឬបីដងក្នុងមួយថ្ងៃ។

ក្រណាត់ក្តៅ៖ យកដុំឥដ្ឋ ថ្មមួយដុំ ដើមចេក ឬបាច់ផ្កាលីលី (Crinum asiaticum Linn) មកដាក់ពេលលើភ្លើងរហូតទាល់តែក្តៅ ហើយបន្ទាប់មក យកវាមករុំដោយក្រណាត់ស្អាត។ វិធីសាស្ត្រមួយទៀតគឺដាក់ទឹកក្តៅក្នុងដបទឹកក្តៅ រួចយកវាទៅដាក់នៅលើតំបន់ដែលមានរបួស។ ក្រណាត់ក្តៅសម្រាប់ស្អំ គួរតែយកវាមកប្រើរយៈពេល ២៤ ម៉ោងឬច្រើនជាងនេះ បន្ទាប់ពីមានគ្រោះថ្នាក់រួច។

ត្តុង៖ ការប្រើប្រាស់ឧបករណ៍ស្រដៀងនឹងផ្ទាំងដាំទឹកក្តៅ តាមធម្មតាគេលាយជាមួយឱសថបុរាណ គឺជាបច្ចេកទេស ដែលប្រជាពលរដ្ឋនិយមប្រើ នៅភាគខាងជើងប្រទេសថៃ។ វិធីល្អបំផុតដើម្បីរៀនបច្ចេកទេសនេះ គឺត្រូវទៅពិគ្រោះយោបល់ជាមួយហ្មដំរីជើងចាស់ និងស្ទាត់ជំនាញ។

## ប្រភេទដំបៅ

ដំបៅអាចបែងចែកជាច្រើនប្រភេទដូចខាងក្រោមៈ

### ១. ដំបៅដោយសារស្នាមប្រេះ

កើតឡើងនៅពេលសត្វដំរីត្រដុសនឹងដើមឈើ និងផ្ទាំងថ្ម រហូតដល់មានស្នាមរបួសលេចឡើង។ ស្នាមប្រេះគឺជារឿងធម្មតាបំផុតនៅលើចំហៀង ក្បាល ជើង និងនៅលើ

ត្រគាក។ ស្នាមប្រេះនេះជាញឹកញាប់ចាប់ផ្តើមកើតមាន នៅពេលដំរីអេះរមាស់ ដែលបណ្តាលមកពីសត្វល្អិតខាំ ឬដោយដំបៅលើស្បែកតូចៗ។

*ការព្យាបាលៈ*

- *ទុកឲ្យសត្វដំរីលេងដី និងភក់ ដែលអាចជួយការពារមិនឲ្យដំរីទៅត្រដុសនឹងដើមឈើ និងផ្ទាំងថ្ម។*
- *លាបថ្នាំអង់ទីប៊ីយ៉ូទិក (ថ្នាំផ្សះ) ដូចជាបាក់តាស៊ីន (Bactacin) ជាមួយថ្នាំសម្លាប់សត្វល្អិតដូចជា Negasunt នៅលើកន្លែងដែលមានស្នាមប្រេះ ដើម្បីកុំអោយវារាលដាលធំ។*

*ប្រយ័ត្នៈ នៅពេលអោយសត្វដំរីលេងដី និងភក់ ត្រូវប្រាកដថាគ្មានភាពកខ្វក់មកពីទឹកនោម ឬលាមកទេ។*

**២. ដំបៅដោយសារខ្នងអារុជ**

*(ស្នាមជាំ) ដូចជាការវាយនឹងខ្នងកាំបិត ខ្នងកង្វេរ ឬភាគច្រើនដោយដំបងឈើ។ ស្នាមរបួសទាំងនោះច្រើនតែកើតឡើងនៅជុំវិញក្បាល ខ្នងនិងសន្ទាក់កជើង។ តំបន់ដែលរងរបួសតែងមានស្នាមជាំ ហើយជួនកាលហើមខ្លាំង។ ប្រសិនបើអ្នកយកដៃរបស់អ្នកទៅច្របាច់លើរបួសបែបនេះ អ្នកនឹងឃើញថាសាច់នៅត្រង់តំបន់មានសភាពទន់។ ប្រសិនបើមិនបានព្យាបាលរបួសស្នាមនោះទេ ជាញឹកញាប់វានឹងក្លាយទៅជារឹងហើយវិវត្តទៅជាអាប់សែ (បូស) នៅផ្នែកខាងក្នុង។*

*ការព្យាបាលៈ*

- *ឈប់វាយទៅលើបរិវេណ ដែលមានស្នាមរបួស។*
- *ប្រើក្រណាត់ក្តៅដើម្បីស្អំ ឬត្អុងស្នាមរបួសជារៀងរាល់ថ្ងៃ។*
- *ប្រសិនបើមុខរបួសមិនមានភាពល្អប្រសើរឡើងទេ សូមពិគ្រោះជាមួយពេទ្យសត្វ។*

**៣. ដំបៅដោយសារមុខអារុជ**

*ជាស្នាមរបួសបណ្តាលមកពីផ្លែកាំបិត ឬលំពែង ដែលគេតែងជួបប្រទះជាញឹកញាប់នៅលើក្បាល ប្រមោយ ឬកជើង។ ស្នាមរបួសមុតជាធម្មតាវែង ឬធំប៉ុន្តែ មិនជ្រៅទេ។ ជាធម្មតាមិនមានការហូរឈាមច្រើនទេ។*

ការព្យាបាល៖

- យកដំរីទៅកន្លែងដែលមានម្លប់ ស្ងួត និងស្ងាត់។
- បញ្ឈប់ការហូរឈាមដោយប្រើក្រណាត់ស្អាត ឬសំឡី។
- លាងសម្អាតកន្លែងដែលនៅជុំវិញមុខរបួសដោយទឹកស្អាត ឬ Povidone-iodine ១% ហើយជូតវាឲ្យស្ងួត ដោយប្រើក្រណាត់ស្អាត ឬសំឡី។
- លាងសម្អាតផ្នែកខាងក្នុងនៃមុខរបួសដោយក្រណាត់ ដែលត្រាំក្នុងទឹកថ្នាំ Betadine ឬ Povidone-iodine ១% ។ រោយម្សៅថ្នាំកំចាត់សត្វល្អិតលើមុខរបួស។

៤. ដំបៅដោយសារស្នាមមុត

ជាស្នាមរបួសដែលបង្កឡើងដោយវត្ថុមុតស្រួចអ្វីមួយ ដូចជាដែកគោលលួស អំបែងកែវ ឬថ្ម ភាគច្រើនមាននៅលើបាតជើង។ ជាញឹកញាប់សត្វដំរីនឹងដើរខ្ចើតៗខុសធម្មតា ហើយមុខរបួសអាចរាក់ ឬជ្រៅ។ វាអាចមានការហូរឈាមដែរ ប៉ុន្តែជាទូទៅមិនច្រើនទេ។ ស្នាមរបួសអាចងាយឆ្លងជម្ងឺតេតាណូស។ ប្រសិនបើវត្ថុដែលមុតនោះមានទំហំធំ ពេលនោះមុខរបួសនឹងធំ ហើយជ្រៅ និងមានហូរឈាមយ៉ាងខ្លាំង។

ការព្យាបាល៖

- យកដំរីទៅកន្លែងដែលមានម្លប់ ស្ងួត និងស្ងាត់។
- លាងជើងដំរី (ឬលាងមុខរបួស) ដោយទឹកស្អាត ក្នុងគោលបំណង ដើម្បីអាចត្រួតពិនិត្យមើលបាតជើងឲ្យបានច្បាស់។
- ប្រសិនបើវត្ថុដែលបានមុតជាប់នៅទីនោះ ត្រូវដកយកវាចេញ។
- លាងសម្អាតតំបន់ជុំវិញមុខរបួស ដោយប្រើទឹកថ្នាំ Povidone-iodine ១%។
- លាបថ្នាំលើមុខរបួសដោយប្រើក្រែមអង់ទីប៊ីយ៉ូទិក (ថ្នាំផ្សះ) ឬថ្នាំផ្សះក្រមួន ព្រោះវានឹងនៅជាប់បានយូរជាងប្រភេទថ្នាំដទៃទៀត។
- ប្រសិនបើឈាមនៅតែមិនឈប់ហូរទេ ចូរទៅរកពេទ្យសត្វ។

### ៥. ដំបៅដោយសារគ្រាប់កាំភ្លើង

គេជួបប្រទះជាញឹកញាប់ នៅលើប្រមោយ និងជើងជាពិសេសប្រអប់ជើង។ អ្នកអាចឃើញស្នាមគ្រាប់កាំភ្លើង រឺប្រហោង ដែលជាញឹកញាប់តែងមានឈាមហូរ ហើយជាធម្មតាមុខរបួសឡើងហើម។

ការព្យាបាល៖

- ប្រសិនបើមុខរបួសស្ថិតនៅកន្លែងសំខាន់ៗដូចជាថ្ពាស ទ្រូង ពោះទឹក ឬសរសៃឈាមសំខាន់ៗ ត្រូវទៅតាមពេទ្យសត្វឲ្យមកជាបន្ទាន់។
- ប្រសិនបើមុខរបួសស្ថិតនៅកន្លែងដែលមិនសូវសំខាន់ ដូចជាជើង ហើយមុខរបួសតូច ឬត្រូវកំទេចគ្រាប់កាំភ្លើងតូចៗ ត្រូវយកដំរីនោះ ទៅកន្លែងណា ដែលមានម្លប់ល្អ និងស្ងប់ស្ងាត់។
- ប្រើក្រណាត់ស្អាត ឬសំឡី ដើម្បីទប់ឃាត់ឈាមឲ្យឈប់ហូរ។
- លាងសម្អាត ឬជូតមុខរបួស ដោយប្រើទឹកស្អាត ឬទឹកដែលបានដាំពុះ។
- លាងសម្អាត ឬជូតមុខរបួស ដោយប្រើទឹកថ្នាំ Povidone-iodine ១%។
- អញ្ជើញពេទ្យសត្វឲ្យទៅថតកាំរស្មី X ដើម្បីកំណត់ទីតាំងរបស់ក្បាលគ្រាប់ ឬអំបែងគ្រាប់ និងធ្វើការព្យាបាលបន្ថែមទៀត។

### ៦. ដំបៅដោយសារស្នាមខាំ

ដោយសារមានការវាយប្រហារពីសត្វមួយផ្សេងទៀត ដូចជាដំរី (នៅកន្ទុយ) ឬឆ្កែជាទូទៅច្រើនកើតមានឡើងនៅលើកន្ទុយ ឬជើង។ (របួសដោយពស់ចឹក មានបកស្រាយ នៅទំព័រទី ១៣៦។

ការព្យាបាល៖

- យកដំរីទៅកន្លែងស្ងាត់ដើម្បីបំបាត់ការភ័យខ្លាច។
- បើមានហូរឈាមច្រើន ត្រូវរុំមុខរបួស ដោយប្រើសំឡី ឬក្រណាត់ស្អាតសង្កត់លើមុខរបួស។
- លាងសម្អាតជុំវិញមុខរបួសដោយទឹកស្អាត ហើយប្រើសំឡី ឬក្រណាត់ស្អាតជូតសម្ងួតមុខរបួសនោះ។

- លាងសម្អាតជាមួយទឹកថ្នាំ អ៊ីយ៉ូត tincture, Betadine ឬ Providone-iodine ១%។
- ប្រសិនបើខាំនៅលើកន្ទុយ ត្រូវរុំមុខរបួសឲ្យបានជាប់ល្អ ដោយប្រើក្រណាត់ស្អាត ហើយត្រូវសង្កត់កន្ទុយរហូតដល់ឈាមឈប់ហូរ។
- ទៅពិគ្រោះយោបល់ជាមួយពេទ្យសត្វ។

ប្រយ័ត្ន៖ ប្រសិនបើសត្វដំរីត្រូវសត្វមួយផ្សេងទៀតខាំ ជាពិសេសសត្វឆ្កែ ត្រូវទាក់ទងអ្នកជំនាញខាងជម្ងឺឆ្កែឆ្កួត។ (សូមមើលទំព័រទី ១៨៩)។

### ៧. ដំបៅដោយសារការសង្កត់

ជាស្នាមរបួសដែលបណ្តាលមកពីមានវត្ថុរឹងអ្វីមួយ ដូចជាខ្សែពួររុំព័ទ្ធដើមទ្រូងរបស់ដំរី ដោយខ្សែពួរនោះរុំរឹតតឹងពេក ឬដោយសារដំរីដេកសង្កត់នៅលើដីយូរពេក ដូចជាក្នុងករណីដំរីឈឺជាដើម។ របួសដោយសារសម្ពាធកើតឡើងជាញឹកញាប់នៅសន្ទាក់លើឆ្អឹងដែលលៀនចេញក្រៅ ឆ្អឹងថ្ពាល់ និងផ្នែកខាងក្រោយ ដោយសារការអូសឈើហុប ឬខ្សែពួរដែលចងលើខ្លួនដំរី។ មុខរបួសគឺជាដំបៅដែលមានគែមក្រាស់ ហើយអាចមានខ្ទុះ។ ប្រសិនបើមិនបានព្យាបាលទេ វាអាចក្លាយទៅជា "ប្រហោងខ្ទុះ"។

ការព្យាបាល៖

- ត្រូវដោះស្រាយបញ្ហា ដែលបានបង្កឲ្យមានរបួសស្នាមភ្លាមៗ។
- យកដំរីទៅកន្លែង ដែលមានម្លប់ ស្ងួត និងស្ងាត់ល្អ។
- ប្រើទឹកស្អាតដើម្បីលាងសម្អាតភាពកខ្វក់ ឬកំទេចកំទីផ្សេងៗទៀត។
- យកថ្នាំពណ៌លឿង ឬថ្នាំផ្សះក្រមួន (អង់ទីប៊ីយ៉ូទិក) លាបលើមុខរបួស ហើយរោយម្សៅថ្នាំកម្ចាត់សត្វល្អិត។
- ប្រសិនបើមុខរបួសធំ ត្រូវយកដំរីចេញពីកន្លែងការងារ។
- ប្រសិនបើស្ថានភាពធ្ងន់ធ្ងរឬមិនអាចព្យាបាលបាន ត្រូវពិគ្រោះជាមួយពេទ្យសត្វ។

### ៨. ដំបៅដោយសាររលាក

ភាគច្រើនតែងកើតមាននៅចុងប្រមោយ ផ្នែកខាងក្រោយ និងជើង។ ការរលាកភ្លើងចែកចេញជា ៤ ប្រភេទធំ ៗ គឺ៖ មែកឈើដែលឆេះ រលាកកម្តៅថ្ងៃ រលាកភ្លើងឬទឹកពុះ និងការរលាកដោយសារជាតុគីមី។

*ប្រយ័ត្នះ ស្ទើរតែគ្រប់មុខរបួសរលាកសុទ្ធតែបើកចំហរ ឬក្លាយទៅជាបើកចំហរ ដូច្នេះវាងាយនឹងឆ្លងជម្ងឺផ្សេងៗទៀត។ ហេតុដូច្នេះដើម្បីឲ្យសត្វដំរីធាប់ជាសះស្បើយ ត្រូវព្យាយាមរកជម្រកមួយ ដែលមានដីជាកម្រាលបេតុង ដូច្នេះដំរីមិនអាចយកដីទៅបាចនៅលើមុខរបួសនោះបានទេ។ ប្រសិនបើអ្នកមិនអាចរកដីមានកម្រាលជាបេតុងបានទេ ចូរជ្រើសរើសកន្លែងណា ដែលគ្មានសំណល់ពីលាមកសត្វដំរី ឬសត្វដទៃទៀត។*

***របួសរលាក ដែលបណ្តាលមកពីឈើរលួយ*** *មានច្រើនប្រភេទដូចជាដើមល្ហុង ឬដើមរ៉ានីខ្មៅ ភាគច្រើនវាបណ្តាលឲ្យស្បែកឡើងជាំ ហើយរមាស់ ប៉ុន្តែប្រសិនបើយើងមិនបានព្យាបាលវាឲ្យទាន់ពេលវេលាទេ វាអាចក្លាយទៅជាដំបៅ ដែលមានមេរោគ។*

***ការព្យាបាលះ***

- *កំណត់ប្រភេទរុក្ខជាតិ ដែលបានបង្កឲ្យមានរលាក ហើយត្រូវយកដំរីទៅទុកនៅកន្លែងមួយផ្សេងទៀត ដែលគ្មានរុក្ខជាតិនោះ។*
- *លាងសម្អាតតំបន់ដែលមានរលាក ដោយទឹកស្អាត ហើយបន្ទាប់មកប្រើក្រណាត់ស្អាត ឬប្រើសំបកដូងមួយដុំយកទៅដុសកោសយកកំទេចឈើរលួយនោះចេញ ហើយជូតកន្លែងដែលមានរលាកនោះឲ្យបានស្ងួតល្អ។*
- *លាបក្រែមសម្លាប់មេរោគដូចជា* Travogen *ឬ* Caladryl។
- *ប្រសិនបើស្ថានភាពមិនបានល្អប្រសើរឡើងទេ សូមទៅពិគ្រោះជាមួយពេទ្យសត្វ។*

***ការរលាកស្បែកដោយសារពន្លឺព្រះអាទិត្យ*** *របួសនេះនឹងកើតមានឡើង នៅពេលសត្វដំរីត្រូវកម្តៅព្រះអាទិត្យខ្លាំងពេក ដែលភាគច្រើនតែងកើតមានឡើងចំពោះដំរីឡើងកកំពុងចុះប្រេង ដែលគេច្រើនយកវាទៅចងដាក់ច្រវាក់ទុកកណ្តាលវាលគ្មានដំបូល។ ដំបៅឡើងហើម ហើយមានពណ៌ក្រហមរលោង និងទៅជាដំបៅក្លាយ។ ស្បែកអាចរហែកដាច់ចេញពីគ្នា ដោយសារមានសម្ពាធពីខាងក្នុង និងអាចរបកស្បែក។ សាច់ឈាមអាចរលួយ ហើយមានខ្ទុះ នៅខាងក្រោមស្បែក។ ដំរីនឹងព្យាយាមប្រើប្រមោយរបស់វាដើម្បីបាញ់ទឹក ឬបាចដីទៅលើដំបៅនោះជាញឹកញាប់។ ប្រសិនបើមិនបានព្យាបាលទេ សត្វដំរីនោះនឹងឈប់ផឹក និងឈប់ស៊ីចំណីអាហារ ហើយវានឹងស្លាប់។ (មើលជម្ងឺចាញ់ក្តៅ ទំព័រទី ១១៧។*

ការព្យាបាល៖

- យកដំរីទៅកន្លែងត្រជាក់ ដោយមានខ្យល់ចេញចូលល្អ។
- ប្រសិនបើសត្វដំរីនោះកំពុងតែចុះប្រេង ឬយើងមិនអាចទៅជិតវា ឬក៏ប្តូរទីតាំងរបស់វាបាន ត្រូវយកទឹកដាក់សម្រាប់ឲ្យដំរីផឹក និងបាញ់លើខ្លួនវា។
- លាងសម្អាតមុខរបួសដោយទឹកស្អាត ហើយត្រូវលាងសម្អាតវាដោយថ្នមៗ។
- ព្យាបាលដំរីដោយប្រើថ្នាំបំបាត់រលាក យកមកលាបលើមុខរបួសនោះ។
- ត្រូវទៅពិគ្រោះជាមួយពេទ្យសត្វភ្លាមៗ។

*ការរលាកដោយសារជាតុគីមី* ភាគច្រើនមានដូចជាប្រេងឥន្ធនៈ និងទឹកអាស៊ីដ។ បន្ទាប់ពីបានប៉ះពាល់សារជាតុគីមីទាំងនោះហើយ ស្បែកនឹងឡើងហើម ហើយឡើងពណ៌ក្រហម ហើយជារឿយៗនៅចុងបញ្ចប់វាក្លាយទៅជារលួយ។ ជាញឹកញាប់ការរលាកដោយសារជាតុគីមី បណ្តាលមកពីវត្ថុរាវទាំងនោះបានលេចធ្លាយចេញពីកុងតឺន័រ ដែលមានទុកនៅក្នុងរោងដំរី។

ការព្យាបាល៖

- ប្រសិនបើដំរីកំពុងពាក់គ្រែលើខ្នង ហើយមានរលាកដោយសារជាតុគីមីនៅខាងក្រោមនោះ ត្រូវដោះយកគ្រែលើខ្នងដំរីចេញជាបន្ទាន់។
- យកទឹកស្អាតជូតមុខរបួសដោយថ្នមៗ។
- យកដំរីទៅកន្លែងដែលមានម្លប់ ស្ងួត មានខ្យល់ចេញចូលល្អ និងស្ងប់ស្ងាត់។
- យកទឹកលាងសម្អាតតំបន់ដែលរងរបួស ដោយប្រើសំឡី ឬក្រណាត់ស្អាត ហើយបន្ទាប់មកជូតវាឲ្យស្ងួត។
- លាបថ្នាំបំបាត់ការរលាកលើតំបន់ដែលមានរបួស ឬលាបក្រែមប្រឆាំងនឹងមេរោគដូចជា Cibis ឬ Fennistil។
- ទៅពិគ្រោះជាមួយពេទ្យសត្វ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

*របួសរលាកភ្លើង និងទឹកក្តៅ* ជាធម្មតាច្រើនកើតឡើងចំពោះកូនដំរីតូចៗ ពីព្រោះអ្នកមើលថែរក្សាដំរី ច្រើនបង្កាត់ភ្នក់ភ្លើងនៅក្បែរពួកវានៅពេលយប់ ជាពិសេសចំពោះកូនដំរីកំព្រា។ ត្រូវតែមានការប្រុងប្រយ័ត្នជាពិសេសចំពោះភ្នក់ភ្លើង និងទឹកក្តៅ ដែលមាន

នៅក្បែរកូនដំរីតូចៗ ពីព្រោះហ្វូងដំរីភាគច្រើន តែងលែងកូនដំរីទុកឲ្យពួកវាមានសេរីភាព ដោយគ្មានដាក់ច្រវាក់ ឬមិនបានត្រៀមបង្ការទុកខ្លាចមានគ្រោះថ្នាក់ឡើយ។ ប្រសិនបើការរលាក ឬរបួសលើស្បែកនោះមានទំហំធំ ដំរីនោះអាចនឹងស្លាប់បាន។ ស្នាមរបួសបែបនេះច្រើនតែហើម ហើយងាយនឹងរលួយណាស់។

ការព្យាបាល៖

- ព្យាយាមធ្វើឲ្យសត្វស្ងប់ស្ងៀម អត់ធ្មត់ និងនៅថែរក្សាវា។
- យកដំរីទៅកន្លែងត្រជាក់ មានម្លប់ល្អ និងកន្លែងស្ងួត។
- ពិគ្រោះយោបល់ជាមួយពេទ្យសត្វជាបន្ទាន់ ប៉ុន្តែប្រសិនបើអ្នកត្រូវរង់ចាំគាត់យូរ ដំបូងត្រូវប្រើម្សៅប្រឆាំងនឹងការឆ្លងមេរោគ ឬលាបថ្នាំបំបាត់រលាក។

ខណៈពេលកំពុងរង់ចាំពេទ្យសត្វ ត្រូវឲ្យដំរីលេបថ្នាំបំបាត់ការឈឺចាប់រៀងរាល់ ៤ ម៉ោងម្តង។ រក្សាស្លាក ឬសំបកថ្នាំបំបាត់ការឈឺចាប់នោះទុក ដើម្បីបង្ហាញវាដល់លោកគ្រូពេទ្យសត្វ។ (សម្រាប់វិធីផ្តល់ថ្នាំបំបាត់ការឈឺចាប់សូមមើលទំព័រទី ១០៦។

## ៩. ដំបៅដោយសារប៉ះ

ជារបួសស្នាមដែលកើតឡើងពីការប៉ះដោយវត្ថុអ្វីមួយខ្លាំង ទៅលើសត្វដំរី ដូចជាប៉ះយានយន្ត ដំរីដួល ប៉ះដើមឈើ ដោយគ្រោះថ្នាក់ក្នុងអំឡុងពេលសម្តែង ឬបំពេញការងារអ្វីមួយ។ល។ ស្នាមរបួសបែបនេះច្រើនតែកើតមាននៅលើជើង សន្លាក់ស្មា ឬសន្លាក់ផ្សេងៗទៀត ឬនៅលើខ្នង។ របួសនេះចាប់ផ្តើមពីស្នាមជាំ និងហើមរហូតដល់មានហូរឈាមខាងក្នុង ហូរឈាមខាងក្រៅ និងឆ្អឹងដែលបាក់ និងបែក។

ការព្យាបាល៖ ពិគ្រោះជាមួយពេទ្យសត្វអោយបានលឿនបំផុត។

## ១០. ដំបៅដោយសារការផ្ទុះ

ជាធម្មតាមាននៅលើជើងខាងមុខ និងប្រអប់ជើង។ វានឹងមានស្បែកនិងជាលិកាហែក។ ជាធម្មតាជាលិកាខ្លះនឹងងាប់។ នៅមានកាកសំណល់ អំបែង ឬកំទេចកំទីនៃជាតិផ្ទុះលើមុខរបួសទាំងមូល។

ការព្យាបាល៖ ពិគ្រោះជាមួយពេទ្យសត្វអោយបានលឿនបំផុត។

**ជម្ងឺបូស** ( Abscesses )

*បូសមានច្រើនប្រភេទ ដូច្នេះវិធីងាយបំផុតក្នុងការគិតពីជម្ងឺបូស វាគឺជាជម្ងឺធ្ងន់មួយដែលសរីរាង្គខាងក្នុងមិនអាចគ្រប់គ្រងបាន។ ជម្ងឺបូសខ្លះអាចក្លាយទៅជាអាក្រក់ដែលនាំឲ្យមានការឆ្លងមេរោគទៅក្នុងឈាមជាប្រព័ន្ធ។*

*ជម្ងឺបូសកើតឡើងយ៉ាងឆាប់រហ័សនៅក្រោមស្បែក សាច់ដុំ និងសរីរាង្គខាងក្នុង។ ចំពោះជម្ងឺបូសលើខ្លួនរបស់សត្វដំរីច្រើនតែកើតឡើងនៅក្រោមស្បែក។ ជម្ងឺភាគច្រើនតែងបណ្តាលមកពីស្នាមរបួស និងដំបៅ។ បូសខ្លះចាប់ផ្តើមដោយស្នាមរបួសតូចៗ ដែលបន្ទាប់មកវាកាន់តែរីកធំឡើងៗ ជាពិសេសនៅពេលដំរីអេះស្នាមរបួសទល់នឹងដើមឈើ ឬផ្ទាំងថ្ម។ ជួនកាលអាការៈនេះចាប់ផ្តើមដោយសារតែបូសតូចមួយតែប៉ុន្តែ នៅពេលដែលបូសនោះបានផ្ទុះឡើង វាក៏ក្លាយទៅជាដំបៅដែលមានមេរោគ។ ពេលខ្លះពិបាកនិយាយណាស់ថាតើមួយណាកើតមុន ជាមុខរបួស ឬមួយជាបូស ព្រោះវាមានទំនាក់ទំនងជិតស្និទ្ធគ្នាល្អណាស់។*

*បូសចាប់ផ្តើមពីបុព្វហេតុជាច្រើន។ បុព្វហេតុទូទៅមួយ គឺដំរីនោះបានរងការវាយប្រហារជាញឹកញាប់ពីហ្មរបស់វា។ បុព្វហេតុមួយទៀតគឺស្នាមរបួស ដែលបណ្តាលមកពី*

*ការចងរឹតខ្សែពួរលើដើមទ្រូងរបស់ដំរីខ្លាំងពេក ដោយខ្សែនោះបានកប់ចូលជ្រៅទៅក្នុងស្បែកអស់រយៈពេលជាយូរមកហើយ។ បូសខ្លះចាប់ផ្តើមនៅកន្លែង ដែលមានសត្វល្អិតពងដាក់ និងកន្លែងដែលបានចាក់ថ្នាំ។*

*បូសដែលគេតែងជួបប្រទះនៅលើខ្លួនដំរីអាចបែងចែកជាពីរប្រភេទធំៗ គឺជម្ងឺបូសកាច និងបូសរ៉ាំរ៉ៃ។*

**បូសកាច**

*បូសកាចអាចចាប់ផ្តើមឡើងយ៉ាងលឿន ក្នុងរយៈពេលពីរសប្តាហ៍ចាប់ពីពេលដែលមានរបស់អ្វីមួយមុតចូលទៅក្នុងស្បែក ឬមានមេរោគជាអ្នកបង្កបានជ្រាបចូលទៅ។ ប្រសិនបើអ្នកសង្កត់លើបូសរបស់ដំរី វាមានអារម្មណ៍ឈឺចាប់យ៉ាងខ្លាំង។ នៅតំបន់ដែលមានដំបូស យើងមានអារម្មណ៍ថាក្តៅខ្លាំង។*

នៅពេលចាប់ផ្តើមនៃជម្ងឺបូសនេះ សត្វដំរីនឹងមានអារម្មណ៍ថាពិបាកណាស់ ប៉ុន្តែនៅពេលដែលបូសចាប់ផ្តើម "ទុំ" វាក៏ប្រែជាទន់ ហើយបន្ទាប់មកវាក៏ធ្លាយ។

បូសអាចចាប់ផ្តើមនៅក្នុងសាច់ដុំជ្រៅ។ នៅពេលដំបូង សត្វដំរីនឹងមានជម្ងឺគ្រុនក្តៅ ប៉ុន្តែបូសនឹងមិនទាន់ហើមទេ។ ដំរីនឹងមិនអាចប្រើសរីរាង្គនោះ ឬធ្វើចលនាដូចធម្មតាទេ។ ប្រហែលជា ២ ទៅ ៤ សប្តាហ៍ ក្រោយពីបានឆ្លងមេរោគចូលហើយ បូសក៏ចាប់ផ្តើមមានខ្ទុះចេញ ឬមានហើមនៅតំបន់ជុំវិញ ហើយពេលខ្លះទៀតវាមានប្រហោងជ្រៅ និងលេចចេញខ្ទុះមកក្រៅ។

ការព្យាបាល៖

- ប្រសិនបើមានបូសនៅលើស្បែក ប៉ុន្តែស្បែកដែលគ្របនៅលើមុខបូសមិនទាន់ចាប់ផ្តើមស្តើង គឺបូសនៅមិនទាន់ "ទុំ" នៅឡើយ។ ប្រើក្រណាត់ក្តៅយកទៅស្អំ ឬឆ្អុងលើមុខបូសពី ២ ទៅ ៣ ដងក្នុងមួយថ្ងៃ។ អ្នកក៏អាចលាប អ៊ីយ៉ូត tincture នៅលើតំបន់ដែលមានបូស ព្រោះវាអាចធ្វើឲ្យបូសឆាប់ទុំ។
- នៅពេលបូសចាប់ផ្តើបទុំហើយ ត្រូវដោះ ឬវះបូសនៅកន្លែងណា ដែលមានស្បែកស្តើងជាងគេបំផុត។
- ច្របាច់ខ្ទុះចេញទាំងអស់។ ប្រើទឹកស្អាតដើម្បីលាងសម្អាតផ្នែកខាងក្នុងនៃស្នាមវះ និងជូតសម្ងួតផ្នែកខាងក្នុងបូស។ ប្រសិនបើបូសបានធ្លាយដោយខ្លួនឯង ត្រូវច្របាច់ខ្ទុះទាំងអស់ចេញ ហើយសម្អាតមុខរបួសដូចខាងលើ។
- ប្រើអ៊ីដ្រូសែន peroxide ដើម្បីលាងស្អាតខ្ទុះ ដែលនៅសេសសល់។ ប្រើទឹកធម្មតាដើម្បីលាងសម្អាតជាតិអ៊ីដ្រូសែន peroxide ដែលនៅសេសសល់។ ជូតសម្ងួតមុខរបួសដោយក្រណាត់ស្អាត ឬជាមួយសំឡី។
- លាងសម្អាតបូសជាមួយ Povidone-iodine ១% រហូតទាល់តែផ្នែកខាងក្នុង។
- លាបក្រែមអង់ទីប៊ីយូទិក ឬម្សៅ (ថ្នាំផ្សះ)។
- ប្រសិនបើបូសមានទំហំធំខ្លាំង ឬប្រសិនបើវាស្ថិតនៅក្រោមស្បែក ឬនៅជ្រៅទៅក្នុងសាច់ ត្រូវទៅតាមពេទ្យសត្វជាបន្ទាន់។

## បូសរុំរ៉ៃ

*បូសរុំរ៉ៃមានការវិវត្តយឺតៗ ជាធម្មតាក្នុងរយៈពេលពីមួយ ឬពីរឆ្នាំ ប៉ុន្តែពេលខ្លះមានរយៈពេលរហូតដល់ដប់ឆ្នាំ។ មុខបូសក្រាស់ណាស់ ហើយដូចជាស្នាមដំបៅក្រិន។ ពេលខ្លះបូសរុំរ៉ៃត្រូវបានគេហៅថា "បូសត្រជាក់" ពេលខ្លះទៀតគេហៅបូសប្រភេទនេះថាជា "បូសងាយ"។*

*ការព្យាបាលៈ*

- *ហៅពេទ្យសត្វឲ្យមកវះបូសប្រភេទនេះ ពីព្រោះមុខវាក្រាស់ណាស់។*
- *ប្រសិនបើបូសបានធ្លាយដោយខ្លួនឯង ក៏ត្រូវវះបើកមុខវាបន្ថែម ដើម្បីបង្ហូរខ្ទុះឲ្យចេញមកក្រៅ។*
- *លាងសម្អាតបូសជាមួយទឹកថ្នាំ* Povidone-iodine *១%។*
- *លាបក្រែមអង់ទីប៊ីយូទិក ឬម្សៅ (ថ្នាំផ្សះ)។*

## ជាតិពុល

*ដំរីអាចពុលដោយសារជាតុគីមីទាំងតាមរយៈការប៉ះលើស្បែក ឬតាមរយៈការស៊ីចំណីអាហារ។ កាលពីសម័យមុនសត្វដំរីច្រើនតែត្រូវពស់ចឹក ប៉ុន្តែសព្វថ្ងៃនេះសត្វដំរីងាយរងផលប៉ះពាល់ដោយសារជាតិគីមីពុល នៅក្នុងថ្នាំសម្លាប់សត្វល្អិត និងថ្នាំសម្លាប់ស្មៅដូចជា* Diquat, Paraquat *ជាដើម។ ហេតុដូច្នេះហ្មដំរីត្រូវប្រយ័ត្នប្រយែងបំផុតត្រង់កន្លែងដែលគាត់យកដំរីរបស់គាត់ទៅចងរក្សាទុក និងស៊ីចំណីអាហារ។*

## សារធាតុពុលក្នុងធម្មជាតិ

*លោហធាតុពុលត្រូវបានគេរកឃើញនៅលើផែនដី នៅលើថ្ម និងនៅក្នុងប្រភពទឹកមួយចំនួន។ នីត្រាតដែលបានបំពុលនៅក្នុងប្រភពទឹកមួយចំនួន អាចធ្វើឲ្យសត្វដំរីស្រវឹង និងអាចធ្វើឲ្យសត្វដំរីស្លាប់បាន ប្រសិនបើវាមានបរិមាណគ្រប់គ្រាន់។ ពេលខ្លះដំរីអាចស្រូបយកជាតិលោហធាតុពុលនៅក្នុងចំណីអាហារ ដូចជាជាតិរ៉ៃ ដែលមាននៅក្នុងដីក្រហម ឧទាហរណ៍ដូចជាសេលេញ៉ូម* (selenium)*។*

***រោគសញ្ញាៈ*** *រោគសញ្ញាច្រើនតែលេចចេញជាយូរមកហើយ បន្ទាប់ពីដំរីបានស៊ី និងស្រូបយកជាតិពុលនោះចូលក្នុងខ្លួន ហើយយើងនឹងមានការលំបាក ក្នុងការបញ្ជាក់ពី*

មូលហេតុរបស់វា។ ប៉ុន្តែវាជាការងាយស្រួលក្នុងការប្រាប់ពីមូលហេតុទៅវិញ នៅពេលដំរីច្រើនជាងមួយក្បាលធ្លាក់ខ្លួនឈឺ ក្នុងពេលដំណាលៗគ្នា បន្ទាប់ពីពួកវាបានស៊ីចំណីឬផឹកទឹកដែលមានជាតិពុលដូចគ្នា ពីព្រោះស្ថានភាពនេះទំនងជាមកពីប្រភពតែមួយ។

*ការព្យាបាល៖* ពិគ្រោះជាមួយពេទ្យសត្វ និងមន្ត្រីបរិស្ថាន ដើម្បីព្យាយាមធ្វើរោគវិនិច្ឆ័យលើស្ថានភាពជម្ងឺនោះ និងវិភាគរកមូលហេតុពិតប្រាកដឲ្យឃើញទាន់ពេល។

*ជាតិពុលនៅក្នុងរុក្ខជាតិ* ទាំងតាមរយៈការប៉ះពាល់ និងទាំងតាមការស៊ីចំណីអាហារ ជាឧទាហរណ៍ដូចជាដំឡូងមី សណ្តែកស្វា (Samanea saman Merr.) ឬសណ្តែកខ្មោច (Mucana pruriens [L.] DC.)។ ជារឿយៗរោគសញ្ញាមិនច្បាស់លាស់ទេ។ ហ្មដំរីត្រូវតែដឹងច្បាស់ពីវត្តមានរបស់រុក្ខជាតិដែលមានជាតិពុល មុនពេលយកដំរីរបស់ខ្លួន ទៅឲ្យវាស៊ីចំណីអាហារនៅកន្លែង

ណាមួយ។ ប្រសិនបើដំរីបង្ហាញសញ្ញាថាវាបានស៊ីដោយជាតិពុល ត្រូវយកវាចេញពីការងារភ្លាមៗ ហើយត្រូវអញ្ជើញពេទ្យសត្វមកជាបន្ទាន់។

## ជាតិពុលដែលផលិតដោយមនុស្ស

(ថ្នាំសម្លាប់សត្វល្អិត ថ្នាំសម្លាប់ស្មៅ និងកាកសំណល់ឧស្សាហកម្ម)

*ថ្នាំសម្លាប់សត្វល្អិត* អាចចូលទៅក្នុងខ្លួនរបស់សត្វដំរីទាំងតាមរយៈប្រព័ន្ធរំលាយអាហារ ឬតាមស្បែក។ អ្វីដែលសំខាន់បំផុតនោះ គឺពួកហ្វូសស្វាត (ដូចជា Malathion, Parathion) និងពួកក្លរីន (ដូចជា DDT, Aldrin, carbamate ថ្នាំសម្លាប់សត្វល្អិត។ល។ ការពុលប្រភេទនេះ តែងកើតមានជាញឹកញាប់ចំពោះដំរីនៅតាមទីក្រុង ដែលពួកវាតែងស៊ីចំណីអាហារដូចជាត្រសក់ ត្របែកជាដើម។

*រោគសញ្ញា៖* ថ្នាំសម្លាប់សត្វល្អិតអាចធ្វើឲ្យប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទ ដែលអាចបង្កឲ្យសត្វដំរីមានការភ័យខ្លាច ច្របូកច្របល់ និងពិបាកដកដង្ហើម។ ជាតិពុលទាំងនោះអាចបណ្តាលឲ្យមានហូរទឹកមាត់ ក្អួតចង្អោរ រាករូស ញាក់ស្បែក ប្រកាច់ដេកនៅលើដី ហើយទីបំផុតដំរីក៏ស្លាប់។ ដំរីនឹងចាប់ផ្តើមបង្ហាញរោគសញ្ញា ក្នុងរយៈពេលប្រហែល ១២ ម៉ោងបន្ទាប់ពីវាបានលេបជាតិពុលចូល។ សញ្ញាលើបញ្ហាសរសៃប្រសាទអាចត្រូវពន្យារពេលរហូតដល់ពីរថ្ងៃ។

*ការព្យាបាល៖*

- *ប្រសិនបើអ្នកដឹងពីមូលហេតុ សូមរក្សាទុកធុង ឬស្លាករបស់ថ្នាំពុល ដើម្បីជួយដល់ពេទ្យសត្វ ក្នុងការចេញវេជ្ជបញ្ជាព្យាបាលដំរី។*
- *ត្រូវអញ្ជើញពេទ្យសត្វឲ្យមកភ្លាមៗ។*

***ថ្នាំសម្លាប់សត្វល្អិត*** *ដូចជា* Diquat *និង* Paraquat *តែងតែជ្រាបចូលទៅក្នុងខ្លួនរបស់សត្វដំរី នៅក្រោយពេលប្រមូលផលរួច ហើយគេលែងដំរីឲ្យវាស៊ីស្មៅដោយសេរីនៅតាមវាលស្រែ និងក្នុងចំការរបស់អ្នកភូមិ។ ជួនកាលសត្វដំរីត្រូវបានបំពុល បន្ទាប់ពីវាបានផឹកទឹកនៅក្នុងធុង ដែលមានជាតិពុល។*

*រោគសញ្ញា៖ ប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទ និងបណ្តាលឲ្យដំរីក្អួត ហូរទឹកមាត់មានជម្ងឺរាក ញ័រខ្លួន និងស្លាប់។*

*ការព្យាបាល៖*

- *ប្រសិនបើអ្នកដឹងពីមូលហេតុ សូមរក្សាទុកធុង ឬស្លាករបស់ថ្នាំពុល ដើម្បីជួយដល់ពេទ្យសត្វ ក្នុងការចេញវេជ្ជបញ្ជាព្យាបាលដំរី។*
- *ត្រូវអញ្ជើញពេទ្យសត្វឲ្យមកភ្លាមៗ។*

***កាកសំណល់ឧស្សាហកម្ម*** *ដែលមាននៅក្នុងស្មៅ និងនៅក្នុងទឹក ភាគច្រើនប៉ះពាល់ដល់សត្វដំរី ដែនៅតាមទីក្រុង។*

*នៅក្នុងបរិស្ថានមានសារធាតុគីមីចំនួនបី ដែលអាចបង្កគ្រោះថ្នាក់ខ្លាំង ជាពិសេសចំពោះសត្វដំរី។ អាសេនិក* (Arsenic) *នឹងបណ្តាលឲ្យដំរីឈឺក្រពះយ៉ាងខ្លាំង ដំរីអាចដេកដួលទៅលើដី ហើយនៅទីបំផុតវានឹងស្លាប់។* Strychnine *ធ្វើឲ្យសត្វដំរីប្រកាច់។ ចំណែកជាតិសំណវិញ តែក្នុងរយៈពេលប្រហែលជា ៣ ថ្ងៃ វាអាចធ្វើឲ្យសត្វដំរីដើរមិនស្រួល ហូរទឹកមាត់ និងមានគ្រាប់ភ្នែករលីងរលោង។ សត្វដំរីនឹងប្របូកប្របល់ ញ័រខ្លួន និងប្រកាច់។*

*ការព្យាបាល៖ ត្រូវអញ្ជើញពេទ្យសត្វឲ្យមកភ្លាមៗ។*

***ពស់ចឹក*** *អ្នករងគ្រោះញឹកញាប់ជាងគេបំផុត គឺកូនដំរី។*

*រោគសញ្ញា៖*

- *រោគសញ្ញាខុសគ្នាអាស្រ័យលើប្រភេទពស់។*

- *ពស់វែក និងពស់វែករនាមនឹងបន្សល់ទុកនូវស្នាមចង្កូមធំៗពីរ និងស្នាមធ្មេញតូចៗពីរជួរ។ សត្វដំរីនោះនឹងបង្ហាញសញ្ញាពីការប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទ ដែលអាចធ្វើឲ្យសត្វដំរីខ្វិន ហើយជាញឹកញាប់វានឹងស្លាប់។ លក្ខខណ្ឌខាងលើកើតឡើងក្នុងរយៈពេលពីមួយ ទៅពីរម៉ោងបន្ទាប់ពីត្រូវពស់ចឹក។*
- *ពស់ស្រកាប្រាស់ និងពស់ក្រាយនឹងបន្សល់ទុកស្នាមចង្កូមពីរ ដែលធំៗជាង និងជ្រៅជាងពស់វែក ឬពស់វែករនាម។ ពិសប៉ះពាល់ដល់ឈាម និងបណ្តាលឲ្យហើម និងខូចជាលិកាសាច់ និងស្បែកនៅក្នុងតំបន់ដែលវាចឹកនោះយ៉ាងធ្ងន់ធ្ងរ ធ្វើឲ្យមានសារជាតុរាវ និងឈាមពណ៌ខ្មៅហូរចេញមកក្រៅ។ សត្វដំរីអាចនឹងស្លាប់ដោយសារខូចតម្រងនោម។*
- *ប្រសិនបើត្រូវឱម៉ាល់ ឬខ្យាដំរីទិច ឬខាំ សត្វដំរីនឹងមិនបង្ហាញពីស្ថានភាពធ្ងន់ធ្ងរទេ ប៉ុន្តែវានឹងមានការហើម និងដំបៅខ្លះៗនៅត្រង់មុខរបួសនោះ។*

*ការព្យាបាល៖*

- *ការដឹងពីប្រភេទពស់អាចនឹងជួយដល់ការកំណត់វិធីព្យាបាលឲ្យមានភាពងាយស្រួល ប៉ុន្តែជាធម្មតាមានតែស្នាមខាំ ចំណែកពស់វិញមិនដែលឃើញទេ។*
- *យកដំរីទៅកន្លែងដែលមានម្លប់។*
- *លាងសម្អាតមុខរបួសដោយទឹកស្អាតឲ្យបានច្រើនដង និងជាមួយទឹកប៉ូតាស្យូមពែរម៉ង់កាណាត* (potassium permanganate solution)*។*
- *បន្ទាប់មក ទៅអញ្ជើញពេទ្យសត្វ ឲ្យបានលឿនតាមដែលអាចធ្វើទៅបាន។*
- *ក្នុងករណីមានសត្វល្អិតទិច ឬខាំចូរលាបក្រែមប្រឆាំង និងការបង្ករោគនៅលើតំបន់ដែលសត្វល្អិតនោះបានទិច ឬខាំ។*

***កំណត់ចំណាំ៖*** *ហ្មដំរីចាស់ៗពីជំនាន់មុនបាននិយាយថា ក្នុងករណីមានពស់ចឹក ក្រៅពីរកមើលស្នាមចង្កូម អ្នកក៏គួរពិនិត្យមើលផងដែរថា តើរោមដំរីអាចដកទាញចេញបានស្រួលជាងធម្មតាដែរឬទេ។*

***ដំបូន្មានដល់អ្នកគ្រប់គ្រងមជ្ឈមណ្ឌល៖*** *ជាញឹកញាប់ណាស់ នៅពេលសត្វដំរីមួយក្បាលបានស្លាប់យ៉ាងលឿន ដោយមិនមានមូលហេតុច្បាស់លាស់ ហ្មដំរីនឹងនិយាយ*

ថាវាមកពីមានពស់វែកចឹក ព្រោះនោះជាចម្លើយងាយស្រួលបំផុត។ ប៉ុន្តែជាញឹកញាប់ មូលហេតុពិតប្រាកដ គឺថាហ្មដំរីមិនបានផ្លាស់ប្តូរដំរី ទៅឲ្យវាស៊ីចំណីនៅកន្លែងថ្មី ឬគាត់បានដាក់ច្រវាក់ដំរីនៅកន្លែងដែលគ្មានទឹក ហើយតាមការពិតទៅ ដំរីនេះបានស្លាប់ដោយសារកង្វះអាហារ ឬទឹក។

# ផ្នែកខាងក្រៅរបស់សត្វដំរី

## ស្បែក

ស្បែករបស់សត្វដំរីអាស៊ីមានកម្រាស់ពី ១ ទៅ ៣,៥ សង់ទីម៉ែត្រ។ ស្បែកនៅផ្នែកខាងក្រោយ និងនៅលើត្រគាកជាកន្លែងដែលក្រាស់ជាងគេបំផុត ហើយស្បែកនៅពីក្រោយត្រចៀកស្តើងជាងគេបំផុត។ ស្បែកមានសារៈសំខាន់ក្នុងការគ្រប់គ្រងសីតុណ្ហភាពជាពិសេសវាជួយកាត់បន្ថយកម្តៅ។ ស្បែកដំរីមានស្នាមជ្រីវជ្រួញជាផ្នែកៗ ដើម្បីបង្កើនកម្រាស់ផ្ទៃលើសម្រាប់ថែរក្សាភាពកក់ក្តៅនៅក្នុងរាងកាយ និងមិនឲ្យកម្តៅជ្រាបចូលនៅក្នុងរាងកាយរបស់វាខ្លាំងពេក។ ផ្ទុយទៅវិញ ស្បែករបស់ដំរីគ្មានក្រពេញញើសទេ លើកលែងតែស្បែក ដែលនៅចំពីខាងលើក្រចកជើងរបស់ដំរី។ ស្បែកមានសុខភាពល្អដើរតួនាទីយ៉ាងសំខាន់ ក្នុងការថែរក្សាភាពរឹងមាំរបស់ដំរី។ សត្វដំរីចូលចិត្តរមៀលនៅក្នុងភក់ និងបាចដីដាក់លើខ្លួនពួកវា គឺដើម្បីទប់កម្តៅពីព្រះអាទិត្យនិងប្រឆាំងនឹងសត្វល្អិត។

ពួកវាក៏ចូលចិត្តងូតទឹកយូរៗផងដែរ ហើយការងូតនេះទឹកគឺជាឱកាសដ៏ល្អមួយសម្រាប់ហ្មដំរី ដើម្បីរកមើលអ្វីដែលមិនធម្មតាកើតមាននៅលើស្បែក ដូចជាមុខរបួស បូស និងប៉ារ៉ាស៊ីតផ្សេងៗ។

**ជម្ងឺឬស** Papilloma



ជម្ងឺប្ញស Papilloma បណ្តាលមកពីវីរុសម៉្យាង ដែលគេមិនសូវឃើញមានជាញឹកញាប់នៅលើសត្វដំរីទេ។ ពពួកជម្ងឺប្ញស Papilloma ច្រើនតែកើតមាននៅលើកូនដំរី ជាពិសេសកូនដំរី ដែលមិនបានបៅដោះមេរបស់វាតាំងពីពេលកើតមក។ កង្វះខាតជីវជាតិនេះបណ្តាលឲ្យកូនដំរីខ្វះអង្គបដិប្រាណប្រឆាំងនឹងវីរុស។ ជម្ងឺប្ញសមានលក្ខណៈជាសាច់ពកមូលដុំៗជាច្រើន ដូចជាជម្ងឺប្ញស នៅលើខ្លួនរបស់មនុស្សដែរ ប៉ុន្តែធំៗជាង។ ជម្ងឺប្ញសជាច្រើនកើតមាននៅលើប្រម៉ោយ គឺពីចុងដល់គល់ប្រមោយ។ ភាគច្រើនអ្នកអាចមើលឃើញជម្ងឺប្ញសនោះតែមួយដុំទេ ប៉ុន្តែពេលខ្លះវាមានច្រើន។

រោគសញ្ញា៖

- ក្នុងករណីខ្លះមានប្ញសជាច្រើននៅលើប្រមោយរបស់ដំរី ហើយដំរីនោះអាចប្រើប្រមោយរបស់វាបានយ៉ាងខ្លាំខ្លង។ ពេលខ្លះដំរីនឹងមានការរលាកគួរឲ្យកត់សម្គាល់ ប៉ុន្តែវានៅតែអាចប្រើប្រមោយរបស់វាបានជាធម្មតា ដើម្បីបោចស្មៅ និងផឹកទឹក។
- ប្ញសដុះលូតលាស់យ៉ាងឆាប់រហ័ស លូតលាស់ទាំងទំហំ និងបរិមាណ ក្នុងរយៈពេលពី ២ ទៅ ៤ សប្តាហ៍ ហើយជារឿយៗវាជ្រុះបាត់ទៅវិញដោយខ្លួនឯង។

ការព្យាបាល៖

- ប្រសិនបើប្រទះឃើញជម្ងឺប្ញស នៅកន្លែណាមួយ ដែលវាមិនរំខានដល់ដំណើរការជីវិត ឬនៅកន្លែងណាដែលមិនធ្វើឲ្យអាក្រក់មើលពេកទេ គួរទុកវាចោលនៅទីនោះចុះ ព្រោះវាអាចនឹងជា ហើយជ្រុះបាត់ទៅវិញដោយខ្លួនឯង។
- ប្រសិនបើសត្វដំរីបង្ហាញការឈឺចាប់ ឬប្ញសនោះរំខានដល់ការស៊ីចំណីអាហាររបស់វា សូមពិគ្រោះជាមួយពេទ្យសត្វ ដើម្បីឲ្យគាត់យកប្ញសទាំងនោះចេញ។ កុំប្រើកាំបិត ឬកន្ត្រៃដើម្បីកាត់ប្ញសទាំងនោះឲ្យសោះ ពីព្រោះវាអាចនឹងបណ្តាលឲ្យហូរឈាម។ ប្រសិនបើកាត់វាចោល វានឹងមានដុសប្ញសថ្មីក្នុងរយៈពេលប្រហែលមួយថ្ងៃ (ដូចស្មៅដែរ ប្ញសទាំងនេះមានប្ញសវាកប់ជ្រៅនៅក្នុងស្បែក)។
- ប្រសិនបើមានប្ញសជ្រុះដោយខ្លួនឯង ត្រូវលាងគល់ប្ញសជាមួយ Povidone-iodine ១% (សូលុយស្យុង ១:២០) ឬប្រើថ្នាំបាញ់អង់ទីប៊ីយោទិច ឬលាបថ្នាំ Furazone ointment ឬ Acriflavin។ បន្ទាប់មកហៅពេទ្យសត្វ។

**ជម្ងឺផ្សិតលើស្បែក**

*នៅសម័យចាស់មិនមានការឆ្លងមេរោគផ្សិតនៅលើស្បែកទេ ពីព្រោះសត្វដំរីត្រូវបានរក្សាទុកក្នុងលក្ខណៈសមស្របតាមល័ក្ខខ័ណ្ឌធម្មជាតិ និងមិនធ្វើការហួសកម្រិតដែលវាខុសគ្នាឆ្ងាយពីសព្វថ្ងៃនេះ។*

*ការឆ្លងមេរោគផ្សិតជារឿយៗ ត្រូវបានរកឃើញនៅលើសត្វដំរីដែលចិញ្ចឹមដោយចំណីមិនគ្រប់គ្រាន់ ឬចំណីអាហារខ្វះជីវជាតិ ឬនៅលើដំរីដែលបានធ្វើការរហូតដល់បាក់កម្លាំង។ ផ្សិតឃើញមាននៅគ្រប់ទីកន្លែងលើខ្លួនដំរី។ ការបង្កពេគកើតឡើងជាញឹកញាប់នៅពេលដំរីត្រូវបានរក្សាទុកនៅក្នុងកន្លែងតូចចង្អៀត។*

*របៀបឆ្លង៖*

- *តាមរយៈដំរីដែលមានជម្ងឺនេះរួចហើយ។*
- *តាមរយៈគ្រាប់ពូជផ្សិត ដែលមាននៅក្នុងចំណីអាហារ និងដី។*

*រោគសញ្ញា៖ ដំបូងផ្សិតនោះលេចចេញជាស្នាមប្រេះ ដែលច្រើនតែចាប់ផ្តើមឡើងជាចំណុចពណ៌ប្រផេះតូចៗនៅខាងក្រោយត្រចៀក ឬបំពង់ក។ ប្រសិនបើមិនបានធ្វើការព្យាបាលទេ ចំណុចទាំងនោះនឹងរីកធំធាត់ទៅជាពងបែក ហើយអាចរាលដាលពាសពេញរាងកាយ។ ករណីខ្លះមានដុំពណ៌ផ្កាឈូកភ្លឺច្បាស់ ដែលមានអង្កត់ផ្ចិតរហូតដល់ ១០ សង្ទីម៉ែត្រ។ (ដុំពណ៌ផ្កាឈូកនេះមិនមែនជាពណ៌របស់ផ្សិតទេ ប៉ុន្តែវាជាពណ៌របស់ស្បែក បន្ទាប់ពីផ្សិតបានបំផ្លាញស្រទាប់ស្បែករួចហើយ) រហូតដល់មានរបួស។ ស្ថានភាពនេះអាចជះឥទ្ធិពលដល់ការស៊ីចំណីអាហារ និងការគេងរបស់ដំរី ដែលទីបំផុតអាចធ្វើឲ្យដំរីមានជម្ងឺបន្ទាប់បន្សំ។ សូមមើលរូបថតនៅទំព័រ DDDD។*

*ការព្យាបាល៖*

- *យកដំរីដែលមានជម្ងឺឆ្លងនោះចេញពីដំរីផ្សេងៗទៀត។*
- *ផ្អាកដំរីពីការងារធ្ងន់ៗ ឬឲ្យវាតែធ្វើតែការងារណាស្រាលៗ។*
- *ផ្តល់អាហារមានជីវជាតិខ្ពស់ឲ្យបានគ្រប់គ្រាន់ ដូចជាចេក ស្រូវ និងស្មៅស្រស់ៗ។*
- *ចំពោះសត្វដំរីដែលទើបឆ្លងជម្ងឺនេះថ្មីៗ យើងអាចកាត់បន្ថយស្ថានភាពនេះដោយលាបថ្នាំប្រឆាំងនឹងផ្សិត ដូចជាថ្នាំ* Travogen *ឬ* Ketoconazole *ដែលអាចរកទិញ*

បាននៅតាមឱសថស្ថានណាមួយ។ ថ្នាំប្រឆាំងនឹងផ្សិតមានតម្លៃថ្លៃណាស់ ហើយភាគច្រើនវាថ្លៃពេកសម្រាប់ព្យាបាលករណីដែលមានហើមខ្លាំងៗ ថវិកាគួរតែចំណាយនៅពេលជម្ងឺទើបតែចាប់ផ្តើម ព្រោះការលុបបំបាត់ផ្សិតឆាប់ៗអាចជួយកាត់បន្ថយតម្រូវការចាក់ថ្នាំច្រើន ដែលមានជាតិពុលលើសកម្រិត ហើយអាចមានគ្រោះថ្នាក់ខ្លាំងណាស់។

- ប្រើប្រេងអូលីវលាបលើស្បែកដែលមានមេរោគ វានឹងធ្វើឲ្យស្បែកមានសំណើម និងជួយកាត់បន្ថយមិនឲ្យជម្ងឺនេះរីករាលដាលបាន។
- ប្រសិនបើស្ថានភាពមិនបានល្អប្រសើរឡើងវិញ ក្នុងរយៈពេលមួយខែ សូមទៅពិគ្រោះជាមួយពេទ្យសត្វ ដើម្បីធ្វើរោគវិនិច្ឆ័យ និងព្យាបាលជម្ងឺ។

*ប្រយ័ត្ន៖* មេរោគផ្សិតនេះត្រូវការវិធីព្យាបាល ដែលប្រើពេលវេលាយូរណាស់។ ភាគច្រើន មេរោគនៃជម្ងឺនេះស៊ាំនឹងថ្នាំ ដូច្នេះការព្យាបាលអាចអស់ថវិកាច្រើនណាស់។ ហេតុដូច្នេះប្រសិនបើអ្នកមានដំរីណាមួយ ដែលទើបតែចាប់ផ្តើមបង្ហាញរោគសញ្ញានេះ សូម្បីតែបន្តិចបន្តួចក៏ដោយ អ្នកត្រូវធ្វើការព្យាបាលឲ្យបានលឿន តាមដែលអាចធ្វើទៅបាន ហើយនៅទីបំផុត អ្នកនឹងអាចសល់ប្រាក់ច្រើន។

## ជម្ងឺហើមពោះ

ជម្ងឺហើមពោះបណ្តាលមកពីទឹក (សារធាតុរាវ) ដែលមកប្រមូលផ្តុំគ្នានៅក្នុងជាលិការក្រោមស្បែកដំរី។ ជម្ងឺហើមពោះជាសញ្ញាប្រាប់ថាមានអ្វីមិនស្រួលនៅក្នុងខ្លួនដំរី។ វាកើតមានជាញឹកញាប់ចំពោះដំរី ដែលបានស៊ីចំណីអាហារគ្មានតុល្យភាព ដូចជាស៊ីដើមចេកច្រើនពេក។ ជម្ងឺហើមពោះនេះក៏អាចកើតមានចំពោះដំរី ដែលស្ថិតក្នុងភាពតានតឹង ឬមានកម្រិតប្រូតេអ៊ីនទាបនៅក្នុងឈាម។

*រោគសញ្ញា៖* មានជាតិទឹកហើមនៅក្នុងខ្លួន បំពង់ក ឬពោះ ឬសរីរាង្គភេទ ឬក៏ច្រើនកន្លែងរួមគ្នា។

*ការព្យាបាល៖*

- ការពារ ឬកាត់បន្ថយស្ត្រេស ដែលអាចជាមូលហេតុនៃជម្ងឺហើមពោះនោះ។

- ផ្តល់ ឬស្អំទឹកក្តៅជារៀងរាល់ថ្ងៃទៅតំបន់ ដែលមានហើម។
- ប្រសិនបើស្ថានភាពមិនបានល្អប្រសើរឡើងវិញទេ ត្រូវពិគ្រោះជាមួយពេទ្យសត្វ។

*កំណត់ចំណាំចំពោះអ្នកគ្រប់គ្រងមជ្ឈមណ្ឌលៈ* ជម្ងឺហើមពោះកើតឡើងនៅតែផ្នែកខាងក្រៅ ប៉ុន្តែវាធ្វើឲ្យមានភាពមិនប្រក្រតីខាងក្នុងខ្លួនរបស់សត្វដំរី ដោយមានមូលហេតុជាច្រើនដែលអាចបង្កឲ្យមានកើតជម្ងឺនេះឡើង។ មូលហេតុលើសពីអ្វីដែលបានពិពណ៌នាខាងលើ ជម្ងឺហើមពោះនេះអាចបណ្តាលមកពីថ្លើមខ្សោយ ខូចតម្រងនោម មានជម្ងឺបេះដូងជម្ងឺរបេង ឬដោយសារតែប្រព័ន្ធរំលាយអាហារមានបញ្ហា។ ដូច្នេះមានតែពេទ្យសត្វតែម្នាក់ប៉ុណ្ណោះ ដែលអាចធ្វើរោគវិនិច្ឆ័យរកមូលហេតុពិតប្រាកដឃើញ ដើម្បីកាត់បន្ថយការងារក្នុងការព្យាបាលសត្វដំរី ដែលមានជម្ងឺប្រភេទនេះ។

## ប៉ារ៉ាស៊ីតខាងក្រៅ

ដំរីថៃភាគច្រើននៅតែចំណាយពេលរស់នៅក្នុងធម្មជាតិ ដូច្នេះពួកគេតែងតែជួបប្រទះពពួកប៉ារ៉ាស៊ីតខាងក្រៅ។ ពពួកប៉ារ៉ាស៊ីតដែលភាគច្រើន ដែលគេតែងជួបប្រទះញឹកញាប់ គឺមានសត្វរុយ របោម ដង្កូវ ចៃ និងដង្កែ។ ពពួកប៉ារ៉ាស៊ីតខាងក្រៅអាចធ្វើបាបសត្វដំរី តាមវិធីផ្សេងៗគ្នាៈ

- ធ្វើឲ្យដំរីធំៗខឹងមួម៉ៅមិនចង់ស៊ីចំណី ហើយធ្វើឲ្យកូនដំរីតូចៗលូតលាស់យឺត។
- ប៉ារ៉ាស៊ីតខ្លះបឺតឈាមច្រើន ដែលធ្វើឲ្យដំរីចុះខ្សោយ ហើយវាងាយនឹងកើតជម្ងឺ។
- ពពួកប៉ារ៉ាស៊ីតខ្លះចិញ្ចឹមខ្លួនវាដោយស៊ីសាច់ និងស្បែករបស់ដំរី។
- រុយជាច្រើន និងដង្កែតែងមានផ្ទុកទៅដោយជម្ងឺផ្សេងៗ ដែលពួកវាតែងចម្លងទៅឲ្យសត្វដំរី នៅពេលពួកវាខាំ និងជញ្ជក់ឈាមពីដំរី។

*ប្រយ័ត្នៈ* ប្រសិនបើមានសត្វដំរីណាមួយ ត្រូវបានវាយប្រហារដោយសារសត្វដង្កែ សត្វចៃ អ្នកត្រូវដឹងថាសត្វដំរីផ្សេងៗទៀត ដែលនៅក្បែរនោះទាំងអស់ ក៏មានចៃ និងដង្កែដូចគ្នាដែរ។

វិធីល្អបំផុតក្នុងការការពារ ឬកាត់បន្ថយប៉ារ៉ាស៊ីតខាងក្រៅ គឺត្រូវថែរក្សាអនាម័យតាមរយៈការប្រមូលយកលាមក និងទឹកនោមរបស់ដំរីចេញឲ្យបានស្អាតជានិច្ច។ ចាំបាច់

ត្រូវលាងសម្អាតរាងកាយរបស់ដំរីដោយប្រុងប្រយ័ត្នជារៀងរាល់ថ្ងៃ ដោយប្រើសំបកដូង ដើម្បីកោសស្បែកដំរីជារៀងរាល់ថ្ងៃ។

**របោម**

របោមដាក់ពងរបស់ពួកវានៅលើស្បែករបស់ដំរី ដែលជាកន្លែងដែលពួកវាក្លាយទៅជាដង្កូវ។ នៅពេលធំពេញវ័យពួកវាចាកចេញពីស្បែក ហើយចូលទៅនៅក្នុងដី ដែលជាកន្លែងដែលពួកវាក្លាយទៅជាសត្វរបោមពេញវ័យម្តងទៀត។

រោគសញ្ញា៖ ស្បែករបស់ដំរីមានឡើងកន្ទួលជាំដុំៗ ទំហំប៉ុនគ្រាប់សណ្តែកសៀងជាច្រើនកន្លែង ជាពិសេសនៅចំហៀងត្រគាកនិងពោះ។ ដំរីធាប់ខឹង វាបង្ហាញដោយការត្រដុសនឹងដើមឈើនិងថ្ម។ ដុំពកខ្លះដាច់រលាត់ ហើយក៏ក្លាយទៅជាដំបៅ ស្បែកឡើងកខ្វក់ ដង្កូវក៏ចាប់ផ្តើមលេចចេញមក ជាពិសេសនៅផ្នែកពោះរបស់ដំរី។ ប្រសិនបើយើងគ្រីសស្នាមជាំនោះមើល យើងនឹងឃើញដង្កូវពណ៌សមួយ ដែលមានមាត់ និងចុងកន្ទុយពណ៌ខ្មៅ។

ការព្យាបាល៖

- ប្រើវល្លិ៍សណ្តែកសមុទ្រ (Entada pursaetha DC) យកវាមកកាត់វាជាប្រវែងខ្លីៗល្មម បុកវាឲ្យម៉ត់ ហើយយកវាទៅត្រាំក្នុងទឹក រួចយកទៅជូតលើកន្លែង ដែលមានសត្វប៉ារ៉ាស៊ីតទាំងនោះខាំ រហូតដល់បែកចេញពពុះខ្លាំង បន្ទាប់មកទុកឲ្យវាស្ងួតដោយខ្លួនឯង។ ព្យាបាលតាមរបៀបនេះជារៀងរាល់ថ្ងៃរហូតដល់បាត់ដុំពកៗ។
- បាញ់ថ្នាំការពារដូចជាថ្នាំ Neguvon, Diclovos ឬ Arsuntol ប្រឆាំងនឹងសត្វរុយដែលអាចពងដាក់លើស្បែករបស់ដំរី។ ថ្នាំទាំងអស់នោះត្រូវប្រើដោយប្រុងយ័ត្ន ជាពិសេសកុំឲ្យចូលក្នុងភ្នែក មាត់ ឬមុខរបួសណាមួយ។ បន្ទាប់ពីបាញ់ថ្នាំរួច ត្រូវទុកឲ្យថ្នាំស្ងួតដោយខ្លួនឯង ហើយរង់ចាំប្រហែលកន្លះថ្ងៃមុនពេលឲ្យដំរីផ្ញួតទឹក។
- អនុញ្ញាតឲ្យដំរីដេកននៀលក្នុងភក់ ឬឲ្យវាយកភក់លាបប៉ាតលើខ្លួនវាបាន។
- ឲ្យថ្នាំដែលនៅក្រុម Ivermectin (សូមមើលទំព័រទី ១៦៥)។
- ប្រសិនបើមិនអាចបោសសម្អាតក្នុងរយៈពេលពី ២ ទៅ ៤ សប្តាហ៍ទេ សូមទៅពិគ្រោះជាមួយពេទ្យសត្វ។

*ប្រយ័ត្ន៖ ថ្នាំសម្លាប់សត្វល្អិតអាចមានគ្រោះថ្នាក់ដល់ដំរី និងមនុស្ស ហើយមិនគួរយកវាមកប្រើជាវិធីបង្ការឡើយ គឺមិនត្រូវប្រើថ្នាំទាំងនោះទេ ប្រសិនបើមិនទាន់មានសត្វប៉ារ៉ាស៊ីត។ ការប្រើថ្នាំបាញ់ទាំងនោះលើខ្លួនរបស់ដំរី គឺវាមានប្រសិទ្ធិភាពតែបណ្តោះអាសន្នមួយរយៈពេលខ្លីតែប៉ុណ្ណោះ។*

## ចៃនិងសត្វល្អិតនៅលើកន្ទុយ

*ចៃនិងសត្វល្អិតនៅលើកន្ទុយ គឺជាបុព្វហេតុចំបង ដែលបណ្តាលឲ្យជ្រុះរោម និងមានដំបៅនៅចុងកន្ទុយ។*

*រោគសញ្ញា៖ ដំរីនឹងបោល និងយកកន្ទុយរបស់វាត្រដុសនឹងដើមឈើ ឬ សសរជាដើម និងវៃកន្ទុយបោកទៅលើខ្លួនរបស់វា។ ពេលនោះរោមកន្ទុយនឹងចាប់ផ្តើមរង្គោះជ្រុះចេញ ហើយសកម្មភាពបែបនេះ ច្រើនតែបណ្តាលមានដំបៅរលួយនៅចុងកន្ទុយ។*

*ការព្យាបាល៖*

- *ដើម្បីកំចាត់ចៃ និងដង្កែ ត្រូវប្រើថ្នាំប្រឆាំងនឹងប៉ារ៉ាស៊ីតខាងក្រៅ។ បាញ់ថ្នាំការពារដូចជាថ្នាំ* Neguvon, Diclovos *ឬ* Arsuntol (*ទុកថ្នាំឲ្យនៅយូរលើស្បែករបស់ដំរី ទៅតាមការកំណត់ ដែលមានចែងនៅលើស្លាកថ្នាំ*) *ឬអាចដុសខាត់ជាមួយនឹងទឹកវល្លិ៍សណ្តែកសមុទ្រ* (Entada pursaetha DC)។
- *លាងសមាតមុខរបួស ហើយទុកឲ្យចៃ ឬដង្កែធ្លាក់ចេញ។*
- *ប្រើថ្នាំក្នុងក្រុមប្រទាលពណ៌ស្វាយ ជាមួយថ្នាំអង់ទីប៊ីយោទិច (ថ្នាំផ្សះ) ដូចជាអុកស៊ីតូតេត្រាស៊ីលីន* (Oxytetracyline) *បាញ់រាល់ថ្ងៃ រហូតទាល់តែមុខរបួសបានជាសះស្បើយ ឬលាបម្សៅប្រឆាំងនឹងសត្វល្អិតដូចជា* Negasunt។

## ចៃ

*ចៃ* (Haematomyzus elephantis) *ធ្វើឲ្យដំរីធាប់ខឹង ដែលដំរីភាគច្រើនបានក្លាយទៅជាមានការហត់នឿយអស់កម្លាំងដោយសារតែវា។ ដំរីខ្លះក៏បានក្លាយទៅជាដំរីកាច ហើយក្លាយជាដំរីដែលមានចរិតមិនល្អថែមទៀតផង។*

*រោគសញ្ញា៖ ដំរីនឹងបង្ហាញពីការរមាស់។ ប្រសិនបើអ្នកទៅមើលឲ្យជិតអ្នកនឹងឃើញថាមានចែដូចជាចំណុចក្រហម ឬពណ៌ត្នោតមានទំហំប៉ុនក្បាលម្ជុល។ ចំណុចនេះនឹងមកផ្តុំគ្នាជាក្រុមៗនៅលើស្បែករបស់ដំរី។ ចែភាគច្រើនចូលចិត្តរស់នៅក្នុងជាលិការទន់ៗ នៅខាងក្រោយត្រចៀក នៅខាងចុងនៃសរីរាង្គប្រដាប់បន្តពូជ និងកន្ទុយ។ ដំរីជារឿយៗតែងត្រដុសនឹងដើមឈើ ហើយដំរីភាគច្រើនមានភាពជ្រួលច្របល់ជានិច្ច ដែលពួកវាមិនអាចសម្រាកបាន ហើយអស់កម្លាំងជាខ្លាំង ទីបំផុតវាធ្លងជម្ងឺផ្សេងៗទៀត។*

*ការព្យាបាល៖*

- *អនុញ្ញាតឲ្យដំរីនៅដេកននៀលលេងនៅលើដី និងក្នុងភក់។*
- *លាងដំរីដោយប្រុងប្រយ័ត្ន បន្ទាប់មកដុសខាត់ដងខ្លួនរបស់ដំរីជាមួយវល្លិ៍សណ្តែកសមុទ្រ* (Entada pursaetha DC) *រហូតដល់អង្គជាតុពវប្រែជាល្អក់។ ទុកសារជាតុពវឲ្យស្ងួតតាមធម្មជាតិ និងឲ្យសត្វល្អិតធ្លាក់អស់។*
- *បាញ់ថ្នាំដោយប្រើថ្នាំប្រឆាំងនឹងប៉ារ៉ាស៊ីតខាងក្រៅដូចជា* Neguvon *ឬ* Arsuntol*។*
- *ផ្តល់ថ្នាំដែលនៅក្នុងក្រុម* Ivermectin *ឲ្យដំរី ទៅតាមការណែនាំរបស់ពេទ្យសត្វ។* (*សូមមើលទំព័រទី ១៦៥*)
- *ប្រសិនបើស្ថានភាពរបស់ដំរីមិនមានភាពល្អប្រសើរឡើងវិញ ក្នុងរយៈពេលពី ២ ទៅ ៤ សប្តាហ៍ទេ សូមទៅពិគ្រោះជាមួយពេទ្យសត្វ។*

**រុយ**

*រុយគឺជាអ្នកជញ្ជូនក់ឈាម។ ពួកវាអាចបង្កការលំបាកយ៉ាងធ្ងន់ធ្ងរដល់ដំរី ហើយពួកវាអាចចម្លងជម្ងឺផ្សេងៗឲ្យដំរី ដូចជាជម្ងឺអាសន្នរោគសត្វ និងទ្រីប៉ាណូសូម្យ៉ាស៊ីស* (trypanosomiasis *ឬ* Surra) *។*

*រោគសញ្ញា៖ ដំរីនឹងដើរចុះដើរឡើងមិននៅស្ងៀម ដើម្បីដេញរុយឲ្យទៅឆ្ងាយ។*

*ការព្យាបាល៖*

- *ងូតទឹកឲ្យដំរីដោយប្រុងប្រយ័ត្ន ដុសខាត់ជាមួយសំបកដូងស្ងួតរាល់ថ្ងៃ។*
- *អនុញ្ញាតឲ្យដំរីនៅដេកននៀលលេងនៅលើដី និងក្នុងភក់។*
- *បាញ់ថ្នាំដោយប្រើថ្នាំប្រឆាំងនឹងប៉ារ៉ាស៊ីតខាងក្រៅដូចជា* Neguvon *ឬ* Arsuntol*។*

- ប្រសិនបើស្ថានភាពរបស់ដំរីមិនមានភាពល្អប្រសើរឡើងវិញ ក្នុងរយៈពេលពី ២ ទៅ ៤ សប្តាហ៍ទេ សូមទៅពិគ្រោះជាមួយពេទ្យសត្វ។

## ក្បាល

### ភ្នែក

ភ្នែករបស់ដំរីមានទំហំតូច ប្រហែលជាមានទំហំប៉ុនភ្នែកសេះ ហើយសៀវភៅស្ទើរតែទាំងអស់និយាយថាចក្ខុវិញ្ញាណរបស់វាមានប្រសិទ្ធិភាពតិចជាង បើប្រៀបធៀបទៅនឹងត្រចៀក និងក្លិន។ ទោះយ៉ាងណា ដំរីមានសមត្ថភាពអាចធ្វើដំណើរបានល្អនៅពេលយប់ ក្រោមពន្លឺព្រះច័ន្ទស្រអាប់ នេះបញ្ជាក់ថាភ្នែករបស់ដំរីអាចសម្របខ្លួនបានយ៉ាងល្អទៅតាមពន្លឺដែលមានកម្រិតទាប។ សត្វដំរីមិនចូលចិត្តផងដឹតពេក ឬភ្លឺខ្លាំងពេកទេ វាចូលចិត្តពន្លឺនៅពេលព្រឹក និងពេលព្រលប់ ឬនៅកន្លែងដែលមានម្លប់នៅពេលថ្ងៃ។ ភ្នែកដំរីដែលមានសុខភាពល្អ គឺភ្លឺថ្លាល្អណាស់ ហើយមានជាតិសំណើមដូចប្រេងជានិច្ច។

សុខភាពភ្នែក គឺជាបញ្ហាដ៏ធំមួយសម្រាប់សត្វដំរី មិនថាវារស់នៅក្នុងព្រៃ ឬនៅក្នុងទីក្រុងទេ។ បញ្ហាភ្នែកអាចកើតមានឡើងយ៉ាងឆាប់រហ័ស ហើយយកល្អត្រូវទៅជួបពេទ្យសត្វសម្រាប់គ្រប់បញ្ហាទាំងអស់ ដែលពាក់ព័ន្ធនឹងភ្នែក។

បញ្ហាភ្នែកដំរីដែលគេតែងជួបប្រទះញឹកញាប់ជាងគេបំផុតនោះគឺ៖

**ជម្ងឺរលាកភ្នែក** គឺជាជម្ងឺភ្នែកដែលកើតឡើងពីការរលាកបណ្តាលមកពីធូលី ខ្យល់ (ជាពិសេសនៅពេលដឹកដំរីតាមរថយន្ត) ផ្សែង ឬស្លឹកឈើប៉ះជាដើម។

**រោគសញ្ញា៖** ដំរីនឹងមានទឹកភ្នែកហូររហាម ភ្នែកឡើងពណ៌ក្រហមហើយហើម និងសញ្ញាថាមានជម្ងឺរលាក។ ដំរីព្រិចភ្នែកជាញឹកញាប់ ហើយសត្វដំរីភាគច្រើននឹងប្រើប្រមោយរបស់វាដើម្បីញីនិងជូតភ្នែករបស់វា។ ក្នុងករណីខ្លះភ្នែករបស់ដំរីនឹងមានហូរទឹករំអិលពណ៌លឿង។

ការព្យាបាល៖

- យកដំរីទៅដាក់នៅកន្លែងដែលមានម្លប់។
- លាងភ្នែកដំរីជាមួយទឹកលាងសម្អាត ឬទឹកអាស៊ីត boric។

- ជូតភ្នែកដំរីឲ្យស្ងួត ហើយបន្ទាប់មកលាប ឬបន្តក់ថ្នាំភ្នែក។ (សូមមើលទំព័រ ១៤៨) ប្រសិនបើអ្នកប្រើថ្នាំបន្តក់ជាប្រភេទអង់ទីប៊ីយោទិច (ថ្នាំផ្សះ) អ្នកគួរដាក់ថ្នាំរៀងរាល់មួយម៉ោងម្តង ឲ្យពេញមួយថ្ងៃ។ ប្រសិនបើអ្នកប្រើថ្នាំភ្នែកប្រភេទក្រមួន ត្រូវលាបវាពីរដងក្នុងមួយថ្ងៃ គឺនៅពេលព្រឹក និងពេលល្ងាច។ (យកល្អបំផុតត្រូវប្រើប្រភេទថ្នាំ ដែលពេទ្យសត្វបានជ្រើសរើសឲ្យ។)
- ប្រសិនបើក្នុងស្ថានភាព ដែលអ្នកមិនមានថ្នាំភ្នែកទេ សូមយកដើមប្រេងក្រហម (Ricinus communis Linn) មករោលកម្តៅវាលើភ្លើង។ បន្ទាប់មកផ្តុំផ្សែងនៅខាងក្នុងដើមនោះទៅក្នុងភ្នែក ឬយកសំបកខ្យងគោក ដោយលាយវាជាមួយស្លឹកស្បូវ (Imperata cylindrica Beauv) ហើយដាក់រោលកម្តៅវាលើភ្លើងរហូតដល់វាឆេះ។ បន្ទាប់មកយកទុយោជក់ទឹកមកប្រើ ដើម្បីផ្តុំផ្សែងឲ្យចូលទៅក្នុងភ្នែកដំរី។ វិធីនេះអាចផ្តល់លទ្ធផលល្អ។
- ប្រសិនបើស្ថានភាពមិនបានប្រសើរឡើងវិញទេ សូមទៅជួបពេទ្យសត្វ។

**ជម្ងឺរលាកកែវភ្នែក** (Keratitis) អាចកើតចេញមកពីជម្ងឺ ប៉ុន្តែជាធម្មតាបណ្តាលមកពីមានរបួសនៅលើភ្នែក។ កែវភ្នែកណាដែលបានឆ្លងមេរោគនេះ វាអាចបណ្តាលឲ្យសត្វដំរីទៅជាខ្វាក់ភ្នែក។ ជម្ងឺរលាកកែវភ្នែកអាចបែងចែកជាបួនប្រភេទ។

**ការព្យាបាល៖** ជម្ងឺរលាកកែវភ្នែកទាំង ៤ ប្រភេទត្រូវព្យាបាលទៅតាមវិធីដូចគ្នានឹងជម្ងឺរលាកភ្នែកដែរ។

**១. ជម្ងឺរលាកកែវភ្នែកដែលមានសរសៃឈាមអាចមើលឃើញយ៉ាងច្បាស់** កើតឡើងមកពីជម្ងឺភ្នែក ឬការរលាកភ្នែក ដែលមិនបានព្យាបាល។

**រោគសញ្ញា៖** ភ្នែកមានពណ៌ក្រហម ហើយមានហូរទឹកភ្នែក។ គេអាចមើលឃើញសរសៃឈាមនៅកញ្ចក់ភ្នែក។ ដំរីត្រដុសភ្នែករបស់វាជាមួយនឹងប្រមោយជាញឹកញាប់។

**២. ជម្ងឺដំបៅកែវភ្នែក** កើតចេញមកពីជម្ងឺភ្នែក ដែលត្រូវបានគេវាយដំ ឬមានរបួសដោយបន្លា ឬវត្ថុអ្វីមួយ។ កែវភ្នែកក្លាយទៅជាមានពណ៌ស្រអាប់ ហើយនឹងមានខ្ទុះ។ ភាពពិការភ្នែកតែងតែកើតឡើងចំពោះសត្វដំរី ដែលមានជម្ងឺភ្នែកប្រភេទនេះ។

*រោគសញ្ញា៖* មានដំបៅនៅលើកែវភ្នែក។ ជារឿយៗភ្នែកមានពណ៌ស្រអាប់។ មានទឹកភ្នែកហូរច្រើន។

*៣. ជម្ងឺរលាកកែវភ្នែកដោយសារជម្ងឺរលាកត្របកភ្នែក* គឺជាជម្ងឺភ្នែក ដែលបានកើតឡើងដោយសារតែការរលាក ដែលបណ្តាលមកពីវត្ថុផ្សេងៗ (ជាធម្មតាមានស្ទឹកឈើ ផែត្រូវភ្នែកជាដើម) ផ្សេងៗល។

*រោគសញ្ញា៖* មានទឹកភ្នែកហូរច្រើន។ ភ្នែកឡើងពណ៌ក្រហម និងមានរលាកដោយសារជម្ងឺធ្ងន់ ហើយដំរីតែងបិទបើកភ្នែកភ្លឹបភ្លែតៗ។ ដំរីតែងត្រដុសភ្នែករបស់វាជាមួយនឹងប្រមោយរបស់វាជាញឹកញាប់។ ជួនកាលមានវត្ថុរាវពណ៌លឿងហូរចេញពីភ្នែក។

*៤. ជម្ងឺរលាកកែវភ្នែកដោយសារមានមុត* ជាញឹកញាប់កើតចេញមកពីមានរបួសនៅលើចិញ្ចើមភ្នែក។ វាមានដំបៅនៅលើកញ្ចក់ភ្នែក ហើយមានខ្ទុះចេញមកពីភ្នែក។

*រោគសញ្ញា៖* មានស្នាមរបួសលើគ្រាប់ភ្នែក ដោយមានដាច់សាច់ខ្ទះៗធ្លាក់ចុះមក ហើយពេលខ្លះមានខ្ទុះ និងមានទឹកភ្នែកហូរច្រើន។ ប្រសិនបើមិនបានព្យាបាលទេ ភ្នែកនឹងប្រែពណ៌ជាស្រអាប់ ហើយដំរីអាចនឹងខ្វាក់ភ្នែក។

*ជម្ងឺភ្នែកឡើងបាយ* គឺជាជម្ងឺដែលមានដំបៅនៅលើកែវភ្នែក ដែលប្រែពណ៌ទៅជាស្រអាប់ វាកើតឡើងពីបុព្វហេតុជាច្រើន ដូចជាការរងរបួសលើផ្នែកខ្លះនៃភ្នែក ដែលរាលដាលដល់ភ្នែក។ ជម្ងឺភ្នែកឡើងបាយនេះជះឥទ្ធិពលជាចម្បងទៅលើដំរីចាស់ៗ ប៉ុន្តែបញ្ហាកង្វះអាហារូបត្ថម្ភក៏អាចបណ្តាលឲ្យដំរីកើតជម្ងឺភ្នែកឡើងបាយចំពោះដំរីគ្រប់វ័យ។ ការប៉ះពាល់នឹងពន្លឺព្រះអាទិត្យដោយផ្ទាល់ (ឬពន្លឺខ្លាំងណាមួយផ្សេងទៀត) ក៏អាចបណ្តាលឲ្យមានជម្ងឺភ្នែកឡើងបាយនេះដែរ។ ជម្ងឺភ្នែកឡើងបាយបណ្តាលឲ្យកែវភ្នែកមានភាពស្រអាប់ ហើយដំរីនឹងងងឹតភ្នែកបន្តិចម្តងៗ។

*រោគសញ្ញា៖* កែវភ្នែកមានភាពស្រអាប់ហើយជួនកាលក្លាយទៅជារឹង និងស្ងួត។ ភ្នែកខ្លះនឹងបង្ហាញទឹករំអិលខាប់ៗដូចទឹកដោះគោគួរឲ្យចាប់អារម្មណ៍។ ផ្នែកកណ្តាលនៃគ្រាប់ភ្នែកអាចឡើងប៉ោង។

*ការព្យាបាល៖* សូមទៅពិគ្រោះជាមួយពេទ្យសត្វ។

## ថ្នាំភ្នែក

ភ្នែករបស់ដំរីតូចៗណាស់បើប្រៀបធៀបទៅនឹងទំហំនៃដងខ្លួនរបស់វា។ ភ្នែករបស់ដំរីមានត្របកបីជាន់ដើម្បីការពារភ្នែក។ នៅពេលដែលភ្នែកមានជម្ងឺធ្ងន់ ឬរលាកដោយសារមានកំទេចកំទីវត្ថុផ្សេងៗពីខាងក្រៅ ត្របកភ្នែកទី ៣ កាន់តែប៉ោងឡើង ហើយមានពណ៌ក្រហមខ្លាំង។ ហ្មដំរីគួរតែជាអ្នកជំនាញខាងបច្ចេកទេសដូចខាងក្រោម។

**វិធីបន្តក់ថ្នាំភ្នែកឲ្យដំរី៖**

- យកក្រណាត់ស្អាតសើមជាមួយទឹកស្អាត ឬទឹកសម្លាប់មេរោគ មកលាងសម្អាតកន្ទែងជុំវិញភ្នែកដោយថ្នមៗ។
- លាងដៃរបស់អ្នកដោយប្រុងប្រយ័ត្ន ហើយជូតដៃរបស់អ្នកឲ្យបានស្ងួតល្អ។
- ប្រើសឺរ៉ាំង ដែលអាចបោះចោលបាន ដោយមានចំណុះ ៣ cc ប្រើម្ជុលបឺតយកទឹកថ្នាំមួយចំនួនពីដប។
- ដកយកម្ជុលចេញពីសឺរ៉ាំង។




- ប្របាច់បាញ់ថ្នាំភ្នែកទៅក្នុងភ្នែក ដែលបើកកំពុងបើង។ ធ្វើដូច្នេះរាល់ម៉ោង។
- ថ្នាំភ្នែកប្រភេទក្រមួន គួរតែប្រើទៅតាមការណែនាំរបស់ពេទ្យសត្វ។

## ជម្ងឺត្រចៀក

ត្រចៀកដំរី គឺជាប្រដាប់សម្រាប់ចង្អុលបង្ហាញពីស្ថានភាពសុខភាពរបស់សត្វដំរីមុនគេបង្អស់។ ដំរីដែលមានសុខភាពល្អនឹងបក់ត្រចៀកឥតឈប់ឈរ ប៉ុន្តែដំរីមួយដែលមានសុខភាពខ្សោយនឹងបក់ស្ទើកត្រចៀកបានដែរ ប៉ុន្តែបានតែយឺតៗប៉ុណ្ណោះ។

ជម្ងឺត្រចៀកអាចបែងចែកជាពីរប្រភេទ គឺការដំបៅត្រចៀកខាងក្រៅ និងដំបៅត្រចៀកខាងក្នុង។

**ជម្ងឺត្រចៀកខាងក្រៅ** និងស្លឹកត្រចៀកអាចកើតឡើងមកពីប្រភពពីរ។

- ហ្មដំរីប្រើកង្វេរបស់គាត់ ដើម្បីទាញ និងគាស់ស្លឹកត្រចៀកផ្នែកខាងលើរហូតដល់មានដំបៅ។
- ចៃ ដង្កែ ឬផ្សិតបង្កឲ្យមានដំបៅនៅលើស្លឹកត្រចៀករបស់ដំរី ហើយដំរីប្រើឈើ ឬប្រមោយរបស់វា ដើម្បីត្រដុសអេះត្រង់តំបន់នោះរហូតដល់មានដំបៅ។

**រោគសញ្ញា៖** ស្លឹកត្រចៀកឡើងហើម និងមានពណ៌ក្រហម។ មុខរបួសបញ្ចេញខ្ទុះ និងមានក្លិនមិនល្អ។ ដំរីបង្ហាញពីការឈឺចាប់។ ប្រសិនបើអ្នកវែកមើលមុខរបួសនោះពេលខ្លះអ្នកនឹងឃើញមានដង្កូវ។

ការព្យាបាល៖

- ឲ្យដំរីដេក ឬឈរឲ្យបានស្រួលបួល។
- លាងសម្អាតតំបន់ដែលនៅជុំវិញរង្វង់ត្រចៀកជាមួយនឹងសំឡី ដែលបានត្រាំក្នុងថ្នាំសម្លាប់មេរោគដូចជា Povidone-iodine ១% ។
- ប្រសិនបើមានខ្ទុះសូមសម្អាតតំបន់ជុំវិញរង្វង់ និងស្លឹកត្រចៀកជាមួយនឹងទឹកស្អាត និងអ៊ីដ្រូសែន peroxide (១០:១)។
- ព្យាបាលដោយប្រើ "ថ្នាំពណ៌លឿង" (Acriflavin) ឬប្រសិនបើមានដង្កូវ ត្រូវប្រើថ្នាំសម្លាប់ដង្កូវដូចជា Negasunt។
- ធ្វើដូចខាងលើរាល់ថ្ងៃរហូតទាល់តែបានជាសះស្បើយ។
- ប្រសិនបើស្ថានភាពមិនបានល្អប្រសើរឡើងវិញទេ សូមទៅជួបពេទ្យសត្វ។

**ដំបៅត្រចៀកខាងក្នុង** [Otitis Media] ចាប់ផ្តើមពីដំបៅត្រចៀកនៅខាងក្រៅ ដែលប្រសិនបើមិនបានព្យាបាលវាទេ វានឹងរាលដាលដល់ខាងក្នុង។ ពេលខ្លះមេរោគចូលក្នុងត្រចៀក ហើយក៏បង្កឲ្យមានដំបៅផ្ទុះឡើង។

**រោគសញ្ញា៖** នៅពេលដំរីដេកលើចំហៀងខ្លួន ឬប្រសិនបើអ្នកចុចត្រចៀកដែលឈឺនោះ វានឹងមានខ្ទុះចេញមក។ ប្រសិនបើអ្នកចូលទៅជិតត្រចៀកវានឹងមានក្លិនមិនល្អ។

*ការព្យាបាល៖ ពិគ្រោះជាមួយពេទ្យសត្វ។*

**ប្រមោយ**

*ប្រមោយជាសរីរាង្គដ៏សំខាន់មួយរបស់ដំរី នៅក្នុងដំណើរជីវិតរបស់វា។ ប្រមោយដំរីអាចប្រៀបធៀបទៅនឹងដៃរបស់មនុស្ស។ វាបោចស្មៅនៅលើដី ហើយទាញយកចំណីពីកន្ទែងខ្ពស់ៗ ពី ៤ ទៅ ៥ ម៉ែត្រ។ ដំរីប្រើប្រមោយជាអាវុធ ដើម្បីការពារខ្លួនវា ប្រើជាមធ្យោបាយទាក់ទងជាមួយមិត្តរបស់វា ហិតក្លិន និងដកដង្ហើម។*

*ប្រមោយដំរីផ្សំឡើងពីសាច់ដុំចំនួន ៤០ ម៉ឺនដុំ។ ប្រមោយមានបណ្តាញធំទូលាយទាំងសរសៃឈាម និងសរសៃប្រសាទ។ ដំរីល្អនឹងមានប្រមោយ ដែលមានគល់ធំក្រាស់ ល្អមានសាច់ដុំពាសពេញតាមបណ្តោយប្រមោយ ហើយចុងប្រមោយត្រូវតែអាចបិទបានយ៉ាងជិតល្អ។ ដូច្នេះការរងរបួសធ្ងន់ធ្ងរលើប្រមោយ អាចបណ្តាលឲ្យសត្វដំរីស្លាប់បាន។ ដោយសារតែប្រមោយមានលក្ខណៈទទួលរំញោចខ្លាំងណាស់ ទើបហ្មដំរីដែលមានបទពិសោធន៍ច្រើនតែប្រើចុងកង្វេររបស់គាត់ដើម្បីគ្រប់គ្រងដំរី។*

*ល័ក្ខខ័ណ្ឌតែមួយគត់ដែលធ្វើឲ្យប៉ះពាល់ដល់ប្រមោយគឺ* papilloma (*សូមមើលទំព័រទី ១៣៨*) *និងស្នាមរបួស។ មានសេចក្តីរាយការណ៍ ដែលមិនសូវមានគេរចាប់អារម្មណ៍ពីប្រទេសថៃភាគខាងត្បូងអំពីស្ថានភាពមួយ ដែលស្តាប់ទៅស្រដៀងគ្នាទៅនឹងជម្ងឺទន់ប្រមោយ ស្ថិតក្នុងស្ថានភាពអាថ៌កំបាំងមួយ ដែលជះឥទ្ធិពលដល់ដំរីអាហ្វ្រិក ដោយធ្វើឲ្យប្រមោយដំរីទៅជាខ្វិន និងទៅជាទន់អាចបត់បែនបាន។ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការជូនដំណឹងអំពីករណីបែបនេះ។*

**ភ្លុក**

*អ្វីដែលយើងហៅថាភ្លុក គឺជាធ្មេញមុខ ហើយវាមិនមែនជាចង្កូមទេ។ ប្រសិនបើអ្នកអានសៀវភៅថៃអំពីភ្លុកដំរីអាស៊ី អ្នកនឹងឃើញថាមានតែដំរីឈ្មោលតែប៉ុណ្ណោះដែលមានភ្លុក។ បើអ្នកអានបន្តបន្តិចទៀត អ្នកនឹងឃើញថាដំរីឈ្មោលខ្លះ ហើយដំរីញីទាំងអស់មានភ្លុកតូចៗពេក ដែលគេមិនហៅថាភ្លុកទេ តែគេហៅថាជាចៃដំរីទៅវិញ។*

*តាមទស្សនៈវេជ្ជសាស្ត្រដំរីទាំងអស់សុទ្ធតែមានភ្លុក គ្រាន់តែវាមានទំហំខុសៗគ្នា តែប៉ុណ្ណោះ។ វាជាការពិតដែលយើងហៅថាដំរីភ្លុក ទំនងជាមានបញ្ហាច្រើនជាមួយនឹងភ្លុករបស់វា ទាំងទំហំ និងដោយសារតែពួកវាត្រូវប្រើភ្លុកនោះ ដើម្បីធ្វើការងារលំបាកៗ។ ទោះយ៉ាងណាក៏ដោយ ក៏ដំរីទាំងអស់អាចមានដំបៅនៅភ្លុករបស់វាដែរ។*

*គល់ភ្លុកត្រូវបានបង្កប់យ៉ាងជ្រៅនៅក្នុងលលាដ៍ក្បាលរបស់ដំរី ដែលដុះចេញតាមរន្ធនៅក្រោមភ្នែក។ ភ្លុករបស់ដំរីខ្លាំងណាស់ ចំពោះដំរីឈ្មោលពេញវ័យ ភ្លុករបស់វាអាចលូតលាស់ជាមធ្យមប្រហែល ១៧ សង្ទីម៉ែត្រក្នុងមួយឆ្នាំ។ ប្រហោងនៅខាងភ្លុកមានសរសៃឈាម និងសរសៃប្រសាទ។ ហេតុដូច្នេះមុននឹងកាត់ ឬធ្វើភ្លុកដំរី អ្នកគួរតែដឹងថាត្រូវកាត់ចោលប៉ុន្មានដើម្បីកុំអោយដាច់សរសៃឈាមនិងសរសៃប្រសាទ។ ការបោះភ្លុកអាចបណ្តាលឲ្យដំរីស្លាប់ដោយការបាត់បង់ឈាម ឬកើតដំបៅ ឬឆ្លងជម្ងឺតេតាណូស។*

***ការផ្តល់អនុសាសន៍ដល់អ្នកគ្រប់គ្រងមជ្ឈមណ្ឌលដំរីៈ** នៅពេលធ្វើភ្លុកឲ្យដំរី ត្រូវស្វែងរកដំបូន្មាន និងជំនួយពីហ្មដំរីជំនាញ។ ដោយសារតែភ្លុករបស់សត្វដំរីនីមួយៗមានភាពប្រែប្រួលខុសគ្នាខ្លាំងណាស់ មិនត្រូវអនុវត្តឲ្យកាត់ ឬធ្វើភ្លុកឲ្យដំរីតាមវិធីដែលអ្នកបានអាននៅក្នុងសៀវភៅណាមួយឡើយ។*

***ដំបៅភ្លុកមានច្រើនប្រភេទៈ***

*១. បែកភ្លុក ភាគច្រើនដោយសារតែដំរីលេងជាមួយច្រវាក់ ដើម្បីព្យាយាមផ្តាច់ច្រវាក់នោះ។ ភ្លុករបស់ដំរីអាចរងរបួស ដោយសារតែដំរីវាប្រើកម្លាំងខ្លាំងៗ។*

*២. ភ្លុករង្គើ ដោយសារតែវាសណ្តក ឬបណ្តាលមកពីដំរីយកភ្លុកនោះចាក់ដី ឬដល់ដើមឈើលេងជាល្បែង។ រន្ធភ្លុកអាចនឹងកើតដំបៅ។*

*៣. បាក់ភ្លុក ឬកាត់ភ្លុក តំបន់ក្នុងទីជម្រៅជុំវិញគល់ភ្លុកនឹងកើតដំបៅ។ ស្ថានភាពបែបនេះច្រើនតែកើតឡើងនៅពេល ដែលភ្លុករបស់វាត្រូវបានកាត់ដោយចោរលួចភ្លុក។*

*៤. ជ្រុះភ្លុក គឺភ្លុករបស់ដំរីបានជ្រុះចេញហើយ ប៉ុន្តែរន្ធភ្លុកនៅតែមានដំបៅ។*

## បែកភ្លុក

***រោគសញ្ញាៈ** ស្នាមប្រេះអាចមានតែនៅជិតចុងភ្លុក ឬវាអាចលាតសន្ធឹងរហូតដល់គល់ភ្លុកថែមទៀត។ ក្នុងករណីចុងក្រោយនេះ ជាលិកាដែលគ្របលើគល់ភ្លុកអាចឡើង*

ហើម។ សត្វដំរីនេះមានទឹកភ្នែកហូរចេញពីភ្នែករបស់វា ប្រសិនបើកើតមានដំបៅនៅគល់ភ្លុក។ បើទុកចោលមិនបានព្យាបាលវានឹងមានខ្ទុះហូរចេញពីស្នាមប្រេះ ហើយនឹងមានក្លិនមិនល្អ។

*ការព្យាបាល៖*

- *ប្រសិនបើភ្លុកមានស្នាមប្រេះ ឬបែកនៅជិតចុង ហើយប្រសិនបើវាមិនធ្ងន់ធ្ងរទេ សូមឲ្យសត្វដំរីនោះបានឈប់សម្រាកពីការងារ ហើយស្ថានភាពរបស់ភ្លុកនឹងជាសះស្បើយដោយខ្លួនឯង។ ប្រសិនបើមានស្នាមប្រេះនៅចុងភ្លុក យកល្អត្រូវយកខ្សែលួសទៅចងនៅជុំវិញភ្លុក និងត្រូវពិនិត្យមើលថាតើមានដំបៅ និងហើមដែរឬអត់។ បន្ទាប់ពីនោះសូមទៅពិគ្រោះជាមួយពេទ្យសត្វ។*
- *ប្រសិនបើស្ថានភាពនេះមានលក្ខណៈរ៉ាំរ៉ៃ ហើយបើភ្លុកមានដំបៅធម្មតា ត្រូវតែលាងសម្អាតជាមួយនឹងទឹកស្អាត និង* Povidone-iodine *១% (លាយបញ្ចូលគ្នា ១:២០) ជារៀងរាល់ថ្ងៃ។*
- *បន្ទាប់មកត្រូវទៅពិគ្រោះជាមួយពេទ្យសត្វ។*

## ភ្លុករង្គើ និងភ្លុកជ្រុះបាត់

***រោគសញ្ញា៖*** *មានក្លិនស្អុយ និងខ្ទុះចេញពីគល់ភ្លុក មិនមែនចេញមកពីភ្លុកទេ។ ដំរីនឹងផ្លុំខ្យល់ ឬយកដីដាក់នៅលើតំបន់នោះជាប្រចាំ។ ប្រសិនបើអ្នករង្គើភ្លុកវា ដំរីនឹងបង្ហាញពីការឈឺចាប់។*

*ការព្យាបាល៖ ត្រូវលាងសម្អាតកន្លែងណាដែលមានខ្ទុះជាមួយនឹងទឹកស្អាត និង* Povidone-iodine *១% (លាយបញ្ចូលគ្នា ១:២០) ជារៀងរាល់ថ្ងៃ។ បន្ទាប់មកអ្នកត្រូវទៅពិគ្រោះជាមួយពេទ្យសត្វ។*

## បាក់ភ្លុក ឬកាត់ជិតដល់គល់

***រោគសញ្ញា៖*** *មានខ្ទុះនៅក្នុងប្រហោងស្នូលក្នុងភ្លុក ហើយជាធម្មតាសត្វដំរីនឹងប្រើប្រមោយរបស់វាបាញ់ដីដាក់លើភ្លុក និងប្រើឈើរុកចូលទៅក្នុងប្រហោងភ្លុក។ ប្រសិនបើភ្លុកត្រូវបានបែក ឬកាត់ថ្មីៗ វានឹងមានឈាមហូរចេញពីភ្លុក។*

*ការព្យាបាល៖*

- *ក្នុងករណីមានដំបៅ ដោយសារគេបានកាត់ ឬក្លុកបាក់ថ្មីៗ ប្រសិនបើមានឈាមហូរ សូមយកដុំសំឡីខ្ទប់ឃាត់ឈាម ឬប្រើក្រណាត់ស្អាត។ (អ្នកក៏អាចប្រើចេកខ្ចីដើម្បីស៊កបញ្ចូល ដើម្បីទប់កុំឲ្យឈាមហូរ។ ) បន្ទាប់មកលាងសម្អាតប្រហោងក្លុកជាមួយនឹងទឹកកស្អាត និង* Povidone-iodine *១%* (*លាយបញ្ចូលគ្នា ១*:*២០*) *ជារៀងរាល់ថ្ងៃ ឬបន្ទាប់ពីបានលាងសម្អាតប្រហោងក្លុកដោយទឹកស្អាត យកទៀនពេលលើអណ្ដាតភ្លើងឲ្យទន់ ហើយញាត់បញ្ចូលវាទៅក្នុងប្រហោងក្លុក។*
- *ក្នុងករណីដំបៅក្លុកមានរយៈពេលវែង និងពុំរ៉ៃ សូមលាងសម្អាតរាល់ភាពកខ្វក់និងខ្ទុះចេញ បន្ទាប់មកលាងសម្អាតប្រហោងក្លុកជាមួយនឹងទឹកស្អាត និងទឹកថ្នាំ* Povidone-iodine *១%* (*លាយបញ្ចូលគ្នា ១*:*២០*) *ជារៀងរាល់ថ្ងៃ។ ត្រូវប្រុងប្រយ័ត្នខ្ពស់ក្នុងការការពារកុំឲ្យកើតជម្ងឺតេតាណូស។ ទូរស័ព្ទហៅពេទ្យសត្វ ដើម្បីមកពិនិត្យមើលស្ថានភាព និងផ្ដល់ការណែនាំ។*

## រន្ធក្លុកខទេ

*រោគសញ្ញា៖ ដំរីនឹងប្រើប្រមោយយរបស់វាផ្លុំ ឬបាចដីចូលទៅក្នុងរន្ធក្លុក ប្រហែលជាមានខ្ទុះនៅខាងក្នុង។*

*ការព្យាបាល៖*

- *សម្អាតប្រហោងក្លុក ជាមួយនឹងទឹកស្អាត និងទឹកថ្នាំ* Povidone-iodine *១%* (*លាយបញ្ចូលគ្នា ១*:*២០*) *ជារៀងរាល់ថ្ងៃ។*
- *អញ្ជើញពេទ្យសត្វឲ្យមកពិនិត្យមើលស្ថានភាព។*

## ជើងនិងក្រចក

*ជាធម្មតាដំរីអាស៊ីមានក្រចកជើងចន្លោះពី ១៦ ទៅ ២០។ ដំរីធម្មតាមានម្រាមជើងសរុបចំនួន ១៨ ដែលមាន ៥ នៅខាងមុខ និង ៤ នៅខាងក្រោយ។ ក្រចកជើងមានរាងជារង្វង់ពងក្រពើវែងហើយលេចចេញពីស្បែក ដែលនៅឆ្ងាយៗពីគ្នា។ ជើងខាងមុខមានរាងមូល រីឯប្រអប់ជើងមានរាងពងក្រពើនិងតូចជាង។ ផ្នែកខាងក្រោមនៃជើងដំរីមានប្រអប់*

ជើងក្រាស់ (ពី ១ ទៅ ២ សង្ទីម៉ែត្រ)។ ស្បែកបាតជើងដំរីដែលល្អជាងគេបំផុត គឺត្រូវមាន ចង្អូរ (ស្នាមប្រេះ) ដើម្បីការពារដំរីកុំអោយរអិលដួចកង់ឡាន។

ក្រចកជើងរបស់សត្វដំរីអាចបែក សណ្តាក និងជ្រុះ។ ប្រសិនបើគ្មានការព្យាបាលទេ ល័ក្ខខ័ណ្ឌបែបនេះអាចនឹងបំផ្លាញសុខភាពទូទៅរបស់សត្វដំរី ដោយដំរីមានការលំបាក ក្នុងការធ្វើចលនាផ្លាស់ទី ហើយដំរីអាចនឹងស្លាប់បាន។

មានមូលហេតុទូទៅពីរនៃបញ្ហានៅត្រង់ប្រអប់ជើង និងក្រចកជើង៖

***បុព្វហេតុពីខាងក្នុង៖*** ពេលខ្លះបញ្ហាកើតឡើងដោយសារសត្វដំរីខ្វះអាហារូបត្ថម្ភ ខ្វះជាតិរ៉ែ និងវីតាមីនមួយចំនួន។ ជួនកាលបញ្ហាកើតចេញពីស្ថានភាពខាងសរីរវិទ្យាផ្ទាល់ខ្លួនរបស់សត្វដំរី។ ក្រចកជើងរបស់សត្វដំរីអាចស្តើង ឬផុយ ហើយអាចរបូតចេញឬបែកបានយ៉ាងងាយ។ ដំរីអាចមានជើងមិនធម្មតា ឬពិការពីកំណើតដោយចៃដន្យ។ ដំរីនឹងមានការលំបាកក្នុងការធ្វើចលនា ឧទាហរណ៍ដូចជាជើងរឹង សន្លាក់រឹង ឆ្អឹងខ្នង និងជើងរមួលជាដើម។ ដំរីនោះអាចដើរអូសជើង ឬវាឈរនៅលើឥរិយាបថមិនធម្មតា ដែលបណ្តាលឲ្យក្រចកជើងវែងខុសពីធម្មតា។

***បុព្វហេតុខាងក្រៅ៖*** ប្រសិនបើដំរីដើរធ្វើការនៅលើផ្ទៃដីដែលគ្មានក្រាលថ្មរាបស្មើល្អ មានរន្ធក្រហេងក្រហូង មិនរលោង មានជម្រាលច្រើន មានដុំថ្ម ឬគ្រាប់គ្រួសច្រើន ពេលនោះក្រចកជើងរបស់ដំរីនឹងងាយប្រេះ និងបែក។ ប្រសិនបើដំរីឈររយៈពេលយូរនៅក្នុងទឹកកខ្វក់ ឬទឹកដែលមានលាយដោយទឹកនោម និងលាមករបស់វាផ្ទាល់ ឬដោយសារជាតុគីមី ពេលនោះគុណភាពនៃក្រចកអាចកាន់តែយ៉ាប់យ៉ឺន។

***ការការពារដំរីធម្មតា និងដំរីដែលមានសុខភាពល្អ៖***

- *កុំឃាត់ ឬចងដាក់ច្រវាក់ដំរីរយៈពេលយូរ ទុកលើដីសើម មានភក់ ឬកខ្វក់ដោយទឹកនោមដំរី និងលាមករបស់វា។*
- *ជៀសវាងកុំឲ្យដំរីដើរ និងធ្វើការនៅលើផ្ទៃដីរដិបរដុប នៅតំបន់ដែលមានថ្មមុតស្រួច តំបន់រំអិល និងមានជម្រាលភ្នំ។ ជៀសវាងតំបន់ស្ងួត និងក្តៅខ្លាំង ដែលអាចធ្វើឲ្យក្រចករបស់ដំរីងាយនឹងសណ្តាក បែក ឬជ្រុះចេញ។*
- *ត្រូវប្រាកដថាដំរីទទួលបានចំណីអាហារ ដែលមានជាតិរ៉ែ និងទឹកគ្រប់គ្រាន់។*

- ត្រូវពិនិត្យ និងព្យាបាលក្រចកជើង និងបាតជើង មុននិងក្រោយពេល ដែលដំរីធ្វើដំណើរឆ្ងាយ។

*ស្នាមប្រេះនៅក្នុងប្រអប់ជើង* ត្រូវបានគេជួបប្រទះជាញឹកញាប់ ចំពោះសត្វដំរីដែលដើរនៅក្នុងទីក្រុង ឬដំរីដែលដើរលើផ្លូវចាក់បេតុង។

*រោគសញ្ញា៖* បាតជើងរបស់ដំរីរបកចេញពីជើង។ ដំរីនឹងមិនដាក់ទម្ងន់របស់វាលើជើងទាំងស្រុងទេ។ ក្នុងករណីខ្លះដំរីនឹងប្រើប្រមោយរបស់វាដើម្បីបាញ់ ឬបាចដី ឬកក់ចូលក្នុងស្នាមប្រេះទាំងនោះ។

*ការព្យាបាល៖*

- យកដំរីចេញពីការងារ។
- ត្រាំជើងដំរីក្នុងទឹកប៉ូតាស្យូមពែម៉ង់កាណាតជារៀងរាល់ថ្ងៃ រយៈពេលពី ១៥ ទៅ ២០ នាទី ឬអាចប្រើ Povidone-iodine ១% (លាយបញ្ចូលគ្នា ១:២០)។

*ប្រេះក្រចកជើង* ច្រើនកើតមានឡើងជាញឹកញាប់ ចំពោះដំរីដែលច្រើនដើរនៅតាមតំបន់ដែលមានចំណោត និងឡើងភ្នំ។ ជាទូទៅបញ្ហាក្រចកកើតឡើង ចំពោះដំរីដែលធ្វើការអូសឈើហុបខុសច្បាប់នៅភាគខាងជើងប្រទេសថៃ និងចំពោះដំរីដែលដើរលើបេតុងច្រើន។ កង្វះអាហារូបត្ថម្ភក៏បណ្តាលឲ្យបែក ឬខូចក្រចកដែរ។

*រោគសញ្ញា៖* ដំរីព្យាយាមមិនដាក់ទម្ងន់របស់វាលើជើងក្រោយ និងជើងមុខទាំងស្រុងទេ។

*ការព្យាបាល៖*

- យកដំរីចេញពីការងារ។
- ឆាបក្រចកជើងរបស់ដំរីលើស្នាមប្រេះពីលើទៅក្រោម ឆាបចុងក្រចកដែលប្រេះនៅផ្នែកខាងក្រោមចោល ធ្វើដូច្នេះចុងក្រចកនឹងរលោង ហើយវាមិនបណ្តាលឲ្យដំរីទាក់ជើង និងជំពប់ជើង ដែលអាចបណ្តាលឲ្យស្នាមប្រេះកាន់តែរីកធំឡើង។
- ត្រាំជើងដំរីនៅក្នុងទឹកជាតិស្ពាន់ស៊ុលហ្វាត។



*ក្រចកលូតលាស់ខុសធម្មតា តែងកើតមានឡើងជាញឹកញាប់ ចំពោះដំរីដែលត្រូវដើរលើដី ដែលមានស្ថានភាពចោត និងឡើងភ្នំ។ ក្រចកខុសធម្មតាត្រូវបានគេជួបប្រទះជាញឹកញាប់ ចំពោះសត្វដំរីដែលធ្វើការកាប់អូសឈើខុសច្បាប់ នៅភាគខាងជើងនៃប្រទេសថៃ ហើយក៏មានចំពោះសត្វដំរីដែលចំណាយពេលដើរច្រើនលើបេតុងផងដែរ។*

*រោគសញ្ញា៖ ដំរីនឹងដើរដោយលំបាក។ សត្វដំរីខ្លះនឹងដើរលោតៗ។ ជារឿយៗក្រចកដុះវែងណាស់។*

*ការព្យាបាល៖*

- *ឲ្យដំរីសម្រាកពីការងារ។*
- *កាត់ក្រចកដែលដុះវែងហួសកម្រិត ហើយបន្ទាប់មកខាត់វាឲ្យរលោង។*

*ត្រាំជើងដំរីនៅក្នុងទឹកស្ពាន់ស៊ុលហ្វាត។*

*ការព្យាបាលបញ្ហាជើង និងក្រចកគួរតែត្រូវបានចាប់ផ្តើមយ៉ាងឆាប់រហ័ស និងធ្វើការងារនោះឲ្យបានត្រឹមត្រូវ។ បើមិនដូច្នោះទេ បញ្ហារួមផ្សំច្រើនអាចកើតមានឡើងដោយខ្លួនឯង ហើយដំរីអាចនឹងពិការ ឬអាចស្លាប់បាន។*

# ផ្នែកខាងក្នុងនៃរាងកាយរបស់ដំរី

## សាច់ដុំ

*ដំរីមានសាច់ដុំរឹងមាំណាស់។ ហ្មដំរីទាំងអស់តែងនិយាយថា "សាច់ដុំជាបាច់" របស់ដំរីណែនតឹងជាងសាច់ដុំរបស់សត្វដទៃទៀត ជាពិសេសសាច់ដុំជើងរបស់ដំរី ដែលត្រូវទ្រទ្រង់ទម្ងន់ដ៏អស្ចារ្យបែបនេះ។ ជើងរបស់ដំរីត្រូវតែអាចទ្រទ្រង់ទម្ងន់យ៉ាងហោចណាស់ក៏ប្រហែលពី ២ ០០០ ទៅ ៣ ០០០ គីឡូក្រាមដែរ ក្នុងករណីដំរីពេញវ័យ។ ជើងខាងមុខមានពីរត្រូវទ្រទ្រង់ទម្ងន់ពីរភាគបីនៃទម្ងន់សរុបរបស់ដំរី។*

*ប្រអប់ជើង និងជើងគឺដូចគ្នាទៅនឹងជើងរបស់ដំរីទឹក និងសត្វរមាសដែរ គឺជើងខាងមុខវែងជាងជាងជើងខាងក្រោយ។ ទម្ងន់ត្រូវបានបែងចែកទៅលើបាតជើង។ ដំរីមានដំណើរតែមួយទេ ដូច្នេះដំរីមិនដូចសេះទេ គឺដំរីមិនអាចរត់ត្រឹកៗ ឬផាយដូចសេះបានទេ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ដំរីអាចដើរបានយ៉ាងលឿនដែរ។ ឯកទគ្គកម្មពិភពលោកត្រូវបានកំណត់ដោយដំរីថៃ ដែលមានឧបករណ៍អេឡិចត្រូនិចសម្រាប់វាស់ គឺដំរីជាមធ្យមអាចដើរបាន ២៣,៨៤ គីឡូម៉ែត្រក្នុងមួយម៉ោង។ នៅក្នុងថ្ងៃធ្វើការ ដំរីដែលមានភាពចាស់ទុំអាចដឹកជញ្ជូនទំនិញ ឬមនុស្សនៅលើដីបានចម្ងាយ ២៥ គីឡូម៉ែត្រ។ ឡើងលើ និងចុះកូនភ្នំចម្ងាយ ដែលមិនគួរឲ្យលើសពី ១៥ គីឡូម៉ែត្រទេ។ (ដំរីព្រៃជាមធ្យមផ្លាស់ទីបានតែ ៤ គីឡូម៉ែត្រទេក្នុងមួយថ្ងៃ)។*

*នៅប្រទេសថៃសព្វថ្ងៃនេះ មានហ្មដំរីខ្លះបង្ខំដំរីឲ្យដើរលើជើងពីរ ទង្វើបែបនេះអាចបណ្ដាលឲ្យដំរីរងរបួសនៅតំបន់អាងត្រគាក។*

### សាច់ដុំរមួល

*ជម្ងឺរមួលសាច់ដុំច្រើនកើតមានឡើង ចំពោះដំរីដែលកំពុងធ្វើការយ៉ាងលំបាក ឬដំរីដែលត្រូវបានគេដាក់ឲ្យធ្វើការមិនធម្មតា ឬដំរីដែលត្រូវបានគេផ្ដល់ចំណីអាហារដោយគ្មានតុល្យភាព។ សាច់ដុំរមួលច្រើនកើតមាននៅលើជើងរបស់ដំរី។*

*រោគសញ្ញា៖ ដំរីដើរជើងខ្ញើចៗ ហើយបង្ហាញថាវាមិនចង់ដើរ ឬវាបដិសេធមិនព្រមដើរឡើងភ្នំ។ សាច់ដុំនឹងឡើងក្ដៅ និងហើមនៅតំបន់ដែលមានសាច់ដុំរមួល ជាពិសេសប្រសិនបើវារមួយនៅលើជើង ប៉ុន្តែប្រសិនបើវារមួលនៅកន្លែងផ្សេងទៀត ដូចជាផ្នែកខាង*

ក្រោយ ដំរីនឹងប្រើប្រមោយរបស់វាបឺតទឹក ឬដីដើម្បីបាញ់ទៅលើកន្ទែងនោះ។

ការព្យាបាល៖

- យកដំរីចេញពីការងារទាំងស្រុង រហូតដល់របួសបានជាសះស្បើយ។
- ប្រើក្រណាត់ក្តៅស្អំលើតំបន់ ដែលមានសាច់ដុំរមួល ដោយត្រាំក្រណាត់ស្អាតក្នុងទឹកក្តៅ ឬប្រើដបទឹកក្តៅដែលមានទំហំសមស្រប រុំវាដោយក្រណាត់ស្អាត។ ប្រើវិធីឆ្លុងក៏ល្អដែរ។
- ប្រសិនបើស្ថានភាពមិនបានល្អប្រសើរឡើងវិញទេ សូមទៅជួបពេទ្យសត្វ។

## ឆ្អឹង

ដំរីមានដងខ្លួនធំណាស់ទម្ងន់ជាមធ្យមពី ២០០០ ទៅ ៤០០០ គីឡូក្រាម។ ដូច្នេះសត្វដំរីត្រូវការឆ្អឹងធំណាស់ ហើយត្រូវតែរឹងមាំល្អថែមទៀត ដើម្បីទ្រទ្រង់ទម្ងន់រាងកាយរបស់វា និងដើម្បីទ្រទ្រង់សកម្មភាពប្រចាំថ្ងៃ។ ប៉ុន្តែប្រសិនបើឆ្អឹងដែលទ្រទ្រង់រាងកាយដ៏ធំនេះត្រូវបានខូចខាត ដូចជាមានស្នាមប្រេះ ឬភ្លាត់ខុសសន្លាក់ សត្វដំរីមិនដូចជាសត្វដទៃទៀតទេ គឺជាធម្មតាសត្វដំរីមានឱកាសតិចតួចណាស់ ក្នុងការវិលត្រឡប់ទៅរកការជាសះស្បើយដូចដើមវិញ។

ឆ្អឹងដែលងាយនឹងទទួលរងការបំផ្លាញជាងគេ គឺឆ្អឹងប្រអប់ជើង ឆ្អឹងជំនីរ និងឆ្អឹងខ្នងផ្នែកខាងក្រោម (lumbrosacral vertebrae)។

មូលហេតុចំបងនៃការបែកឆ្អឹង បាក់ឆ្អឹង និងគ្រេចឆ្អឹង គឺបណ្តាលមកពីគ្រោះថ្នាក់ដោយសារយានយន្ត ឬដោយាសារដំរីមួយផ្សេងទៀតបានវាយប្រហារ ឬដោយសារឈើធំៗ ធ្លាក់លើក្អំ ឬការផ្ទុះមីនជាដើម។ ភ្លាមៗបន្ទាប់ពីដំរីណាមួយបានរងរបួសឆ្អឹង ហ្មដំរីត្រូវជួយដំរីយ៉ាងដូច្នេះ៖

- ជួយលួងលោមដំរី ដើម្បីឲ្យវាបាត់ភ័យខ្លាច។
- ប្រសិនបើមានការហូរឈាម ត្រូវប្រញាប់ឃាត់ឈាម ដោយចុចកណាត់ស្អាត ឬដុំសំឡីនៅលើមុខរបួស។

- *កុំផ្លាស់ទីដំរី ហើយព្យាយាមរក្សាវាកុំឲ្យវាកម្រើក គឺកុំឲ្យវាធ្វើចលនារហូតដល់ពេទ្យសត្វមកដល់។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើដំរីស្ថិតនៅក្រោមកំដៅព្រះអាទិត្យ ហើយវានៅតែអាចដើរបាន ត្រូវយកវាទៅកន្លែងមានម្លប់ល្អ ដែលនៅជិតទីនោះបំផុត (មិនលើសពី ១០០ ម៉ែត្រ)។*
- *ព្យាយាមរកកន្លែងបណ្តោះអាសន្នសម្រាប់ឲ្យដំរីផ្អែកដូចជាដើមឈើ ឬផ្ទាំងថ្មធំៗ។*
- *ពិគ្រោះជាមួយពេទ្យសត្វឲ្យបានលឿនបំផុត។ ត្រូវមានហ្មដំរី ឬមនុស្សណាដែលដំរីនោះទុកចិត្តបំផុតឲ្យនៅជាមួយវា។ បញ្ជូនអ្នកណាម្នាក់ផ្សេងទៀតទៅរកពេទ្យសត្វ ឬទូរស័ព្ទទៅគាត់ ដោយផ្តល់ព័ត៌មានលម្អិតទាំងអស់ ដើម្បីឲ្យគាត់ធ្វើពោគវិនិច្ឆ័យលើស្ថានភាពរបួសរបស់ដំរី និងរៀបចំឲ្យមានការដឹកជញ្ជូន ដើម្បីផ្លាស់ទីដំរី ឬបើចាំបាច់ជួយចាត់ចែងរកមធ្យោបាយដើម្បីទ្រទ្រង់ដំរី និងរក្សាវាឲ្យនៅឈរនៅលើជើងរបស់វាបាន។*
- *ត្រូវប្រើក្រណាត់ត្រជាក់ស្អំលើកន្លែងដែលមានហើម។*

*បញ្ហាឆ្អឹងក៏តែងកើតមានជាញឹកញាប់ជាមួយកូនដំរី ដែលបានទទួលអាហារូបត្ថម្ភមិនគ្រប់គ្រាន់ដែរ ជាពិសេសទឹកដោះគោមិនគ្រប់គ្រាន់ ដែលបណ្តាលឲ្យឆ្អឹងរបស់វាខ្សោយ ឬលូតលាស់មិនពេញលេញ ដែលនាំឲ្យការជំជាត់មិនធម្មតា។ ក្នុងករណីខ្លះកូនដំរីបែបនេះងាយនឹងរងរបួសខ្លាំងណាស់ សូម្បីតែមានគ្រោះថ្នាក់តែបន្តិចបន្តួចក៏ដោយ។ ដូច្នេះប្រសិនបើអ្នកមានកូនដំរី ដែលធ្លាប់មានប្រវត្តិសាស្ត្របែបនេះ អ្នកគួរតែចៀសវាងដាក់វាទៅកន្លែងណា ដែលអាចមានគ្រោះថ្នាក់ ហើយត្រូវពិគ្រោះជាមួយពេទ្យសត្វ។*

*ប្រយ័ត្ន៖ ការធ្វើពោគវិនិច្ឆ័យដើម្បីឲ្យដឹងថា តើឆ្អឹងមួយត្រូវបានបាក់ ប្រេះ បែក ឬគ្រេច គឺពិតជាពិបាកណាស់ព្រោះការវិភាគត្រឹមត្រូវទាមទារឲ្យមានកាំរស្មីអ៊ិច។*

## ជម្ងឺរលាកសន្លាក់

*ជម្ងឺរលាកសន្លាក់ឆ្អឹង គឺជាស្ថានភាពឈឺចាប់មួយ ដែលជះឥទ្ធិពលដល់សន្លាក់ឆ្អឹងបណ្តាលមកពីកត្តាខាងក្នុង ដូចជាដំរីមានអាយុចាស់ ឬលើសទម្ងន់ ឬទទួលបានចំណីអាហារមិនគ្រប់គ្រាន់ ឬចំណីអាហារដែលមានគុណភាពអន់ និងមកពីមូលហេតុខាងក្រៅដូចជាដំរីខ្លះត្រូវបានបង្ខំឲ្យធ្វើការហួសកម្លាំង ឬធ្វើការងារមិនសមរម្យ។*

ជម្ងឺរលាកសន្លាក់កើតឡើងទាំងទម្រង់ស្រួចស្រាវ និងរ៉ាំរ៉ៃ។ ជម្ងឺរលាកសន្លាក់បែបរ៉ាំរ៉ៃ គឺពិបាកព្យាបាលខ្លាំងណាស់ ជាពិសេសដោយសារតែស្ថានភាពនេះពិបាកក្នុងការធ្វើរោគវិនិច្ឆ័យឲ្យបានត្រឹមត្រូវ ហើយដោយសារតែការព្យាបាលត្រូវការរយៈពេលយូរ។ ជាទូទៅពេទ្យសត្វធ្វើការព្យាបាលករណីរលាកសន្លាក់រ៉ាំរ៉ៃ ដោយណែនាំឲ្យដកដំរីចេញពីការងារ ហើយបញ្ឈប់រាល់សកម្មភាព ដែលអាចបង្កគ្រោះថ្នាក់ដល់សន្លាក់និងបណ្តាលឲ្យរលាកសន្លាក់កាន់តែធ្ងន់ធ្ងរ។

ជម្ងឺរលាកសន្លាក់ស្រួចស្រាវអាចចាប់ផ្តើមកើតឡើងយ៉ាងឆាប់រហ័ស។ ជម្ងឺរលាកសន្លាក់ស្រួចស្រាវច្រើនតែកើតឡើងដោយការធ្វើការហួសកម្លាំង ឬដោយការងារមិនសមរម្យ ដូចជាការដើរដោយជើងពីរ ឈរលើក្បាល។ល។ ជម្ងឺរលាកសន្លាក់ក៏អាចកើតមានដោយសារការរងរបួសនៅប្រអប់ជើង ឬជើងផងដែរ។

*រោគសញ្ញា៖* ដំរីនឹងមិនប្រើអវយវៈ ដែលមានរលាកសន្លាក់ទេ ឬក៏ប្រើអវយវៈរបស់វាទាំងមានការលំបាកខ្លាំង។ ជារឿយៗតំបន់ដែលមានរលាកសន្លាក់ឡើងហើម។

*ការព្យាបាល៖*

- ប្រសិនបើមានករណីថ្មីក្នុងរយៈពេល ២៤ ម៉ោងដំបូង ត្រូវដកដំរីចេញពីកន្លែងធ្វើការ ដើម្បីឲ្យដំរីបាននៅស្ងៀម។
- ដាក់ស្អំក្រណាត់ស្អាតត្រជាក់ រុំព័ទ្ធជុំវិញដុំទឹកកក ឬប្រើក្រណាត់ដែលជ្រលក់ក្នុងទឹកត្រជាក់ យកទៅស្អំនៅលើតំបន់ហើម ឬលើកន្លែង ដែលដំរីហាក់ដូចជាកំពុងឈឺចាប់។
- ប្រសិនបើអាការៈមិនបានធូរស្រាលបន្ទាប់ពី ២៤ ម៉ោងទេ សូមស្អំក្រណាត់ក្តៅ ឬត្អុងជារៀងរាល់ថ្ងៃ។
- ត្រូវទៅពិគ្រោះជាមួយពេទ្យសត្វយ៉ាងឆាប់រហ័ស។

## ប្រព័ន្ធរំលាយអាហារ

មានចំណុចបួនគួរឲ្យចាប់អារម្មណ៍យ៉ាងខ្លាំង អំពីប្រព័ន្ធរំលាយអាហាររបស់សត្វដំរី ដែលមានលក្ខណៈខុសគ្នាឆ្ងាយពីសត្វដទៃទៀត។ ទីមួយប្រព័ន្ធរំលាយអាហាររបស់ដំរី គឺមានតែក្រពះទោលមួយ មិនដូចគោ និងក្របីទេ ដូច្នេះហើយទើបវាមិនសូវមាន

*ប្រសិទ្ធភាពច្រើនទេ។ ដំរីមួយនៅពេលរំលាយអាហារ វាអាចស្រូបយកតែប្រមាណ ៤៤ ភាគរយនៃចំណីអាហារ ចំណែកសត្វគោ និងក្របី ពួកវាអាចស្រូបយកប្រហែល ៦០ ភាគរយនៃអ្វីៗដែលពួកវាបានស៊ី។ ទីពីរសត្វដំរីស៊ីចំណីអាហារបានច្រើនណាស់ គឺវាអាចស៊ីបរិមាណចំណីអាហារលើសពី ១០០ គីឡូក្រាមក្នុងមួយថ្ងៃ ឬពី ៦ ទៅ ១២ ភាគរយនៃទម្ងន់រាងកាយរបស់ពួកវា។ ទីបីដើម្បីទទួលបានចំណីអាហារច្រើន សត្វដំរីនឹងស៊ីតែរុក្ខជាតិណា ដែលមានកម្រិតអាហាររូបត្ថម្ភទាប គឺជាចំណីអាហារដែលតាមធម្មតាសត្វដទៃទៀតនឹងមិនស៊ីឡើយ។ ទីបួនការរំលាយអាហារភាគច្រើនមិនមែនដោយសារទឹករំលាយក្នុងក្រពះរបស់ដំរីផ្ទាល់ទេ ប៉ុន្តែសត្វដំរីមានមេរោគ (បាក់តេរី) និងសត្វតូចៗផងដែរ។*

*ជាមួយនឹងដំរី អ្នកមានបរិមាណដ៏ច្រើននៃអាហារដែលមានគុណភាពអន់ធ្វងកាត់បំពង់ប្រវែងពី ៤០ ទៅ ៧០ ម៉ែត្រ និងមានទំហំទទឹងបំពង់ធំយ៉ាងខ្លាំង ដោយការរំលាយអាហារភាគច្រើនត្រូវបានធ្វើឡើងដោយសត្វល្អិតដែលរស់នៅក្នុងពោះរបស់ដំរី ដំណើរការរំលាយអាហារទាំងមូល ត្រូវចំណាយពេលពី ២៤ ទៅ ៥០ ម៉ោងមុនពេលត្រូវបញ្ចេញជាលាមកមកក្រៅវិញ។ យោលទៅលើចំណុចពិសេសៗដ៏ចម្លែកទាំងនេះ វាមិនគួរឲ្យភ្ញាក់ផ្អើលទេ ដែលថាប្រព័ន្ធរំលាយអាហាររបស់សត្វដំរី ប្រហែលជាមានចំណុចខ្សោយជាងគេបំផុតរបស់វា។*

## ពពួកប៉ារ៉ាស៊ីតក្នុងប្រព័ន្ធរំលាយអាហារ

*ព្រូនមានពីរប្រភេទសំខាន់ៗនៅក្នុងប្រព័ន្ធរំលាយអាហាររបស់សត្វដំរី គឺពួកព្រូនសំប៉ែត និងព្រូនមូល។ ព្រូនទាំងនេះច្រើនមានក្នុងខ្លួនរបស់សត្វដំរី ដែលរស់នៅក្នុងស្ថានភាពធម្មជាតិ។ ការរីករាលដាលនៃព្រូនអាចគ្រប់គ្រងបាន ដោយសារការសម្អាតប្រចាំថ្ងៃនៃតំបន់រស់នៅ និងកន្លែងធ្វើការរបស់សត្វដំរី ជាពិសេសតាមរយៈការប្រមូល និងការកែច្នៃលាមកសត្វដំរីជាលក្ខណៈប្រព័ន្ធ។ ហ្មដំរីគួរតែពិនិត្យមើលលាមកសត្វដំរីរបស់ខ្លួនជារៀងរាល់ថ្ងៃ។ ប្រសិនបើពួកគេប្រទះឃើញពពួកព្រូន ពួកគេគួរតែទៅពិគ្រោះជាមួយពេទ្យសត្វ។*

***ការផ្តល់អនុសាសន៍ដល់អ្នកគ្រប់គ្រងមជ្ឈមណ្ឌលដំរី៖** ការត្រួតពិនិត្យលាមកសត្វដំរីនីមួយៗ ដើម្បីរកមើលប៉ារ៉ាស៊ីត គួរតែធ្វើឡើងរៀងរាល់បីខែម្តង។*

## ១. ព្រូនថ្លើម

ពពួកព្រូនថ្លើម (Fasciola gigantica, Fasciola hepatica, Fasciola jacksoni) គឺជាប្រភេទពពួកព្រូនសំប៉ែត ដែលត្រូវបានរកឃើញនៅក្នុងថ្លើម និងបំពង់ទឹកប្រមាត់។ ការបង្ករោគកើតចេញពីខ្យងនៅលើចំណីអាហារ ដែលដំរីបានស៊ីដោយចូលទៅក្នុងពោះ។

រោគសញ្ញា៖ ដំរីធ្លាក់ខ្លួនស្គមណាស់ ហើយមានកម្លាំងតិចតួច។ ស្បែកមានឡើងកន្ទួលរដុបៗ ហើយភ្នែក មាត់ និងចុងប្រមោយ (នៅផ្នែកខាងក្នុង) មានសភាពស្លេក ហើយមានពណ៌លឿង។ ការរំលាយអាហារគឺមិនបានល្អឥតខ្ចោះទេ។ ពោះច្រើនតែហើម ពោះមានតែទឹក ហើយពេលខ្លះនាំឲ្យមានជម្ងឺដក់ទឹក (subcutaneous ventral oedema)។ ក្នុងករណីធ្ងន់ធ្ងរដំរីអាចស្លាប់។

ការព្យាបាល៖

- ញែកសត្វដំរីណាដែលមានជម្ងឺនេះ ចេញពីដំរីផ្សេងៗទៀត។
- ដកដំរីចេញពីការងារទាំងស្រុង។
- ពិគ្រោះជាមួយពេទ្យសត្វ ដើម្បីព្យាបាល និងធ្វើរោគវិនិច្ឆ័យ តាមរយៈការពិនិត្យលាមកសត្វ ដើម្បីកំណត់អត្តសញ្ញាណនៃប្រភេទសត្វល្អិត ឬប្រភេទព្រូន។ ការព្យាបាលជាធម្មតាត្រូវចាក់ថ្នាំ Ivermectin-F (សូមមើលទំព័រទី ១៦៥)។

## ២. ព្រូនទំពក់ ( Cestode worms )

ព្រូនទំពក់មានប្រវែងប្រហែលពី ០,៥ ទៅ ១ ស.ម ហើយមានមាត់ដូចជាប្រដាប់ជញ្ជក់បឺតជាប់ទៅនឹងជញ្ជាំងនៃក្រពះ និងទាំងពោះវៀនខ្លីនិងវែង ដែលព្រូននោះស៊ី។



បច្ចុប្បន្ននេះ នៅក្នុងប្រទេសថៃ គេមិនអាចកំណត់បានច្បាស់ថាតើព្រូនទំពក់ប្រភេទណា ឬដោយរបៀបណា ដែលព្រូនទាំងនោះឆ្លងចូលទៅក្នុងខ្លួនរបស់ដំរីនោះទេ។ ប៉ុន្តែហាក់ដូចជាសត្វដំរីភាគច្រើនបានស៊ីចំណីអាហារដោយពងព្រូន ដែលគេបានរកឃើញនៅក្នុងខ្លួនរបស់សត្វល្អិតលើចំណីអាហាររបស់ដំរី។

រោគសញ្ញា៖ ដំរីមានសភាពល្ហិតល្ហៃ ហើយនៅតែស្គមទោះបីជាវាស៊ីចំណីអាហារប៉ុន្មានក៏ដោយ។ ស្បែកឡើងរដុបៗហើយរោមមានសភាពផុយ មកពីសារជាតុចិញ្ចឹមមិនល្អ។ ផ្នែកខាងចុងនៃចុងប្រមោយ មាត់ និងជាលិការទន់ៗរបស់ភ្នែកគឺស្លេកណាស់។ ដំរីមានកម្លាំងតិចតួចដោយសារតែសារជាតុចិញ្ចឹមមិនគ្រប់គ្រាន់។

ការព្យាបាល៖

- ញែកសត្វដំរីដែលគួរឲ្យសង្ស័យចេញពីដំរីដទៃទៀត។
- ដកដំរីចេញពីការងារទាំងស្រុង។
- ពិគ្រោះជាមួយពេទ្យសត្វដើម្បីព្យាបាលដំរី និងរៀបចំផែនការ ដើម្បីការពារសត្វដំរីផ្សេងៗទៀត ដែលនៅក្បែរៗនោះ។

ប្រយ័ត្ន៖ ប្រសិនបើមានដំរីណាមួយមានព្រូនទំពក់នេះ អ្នកអាចសន្មត់បានថាដំរីផ្សេងៗទៀត ដែលនៅក្បែរៗនោះទាំងអស់ក៏ប្រហែលជាអាចឆ្លងដែរ។

### ៣. ព្រូនមូល

ព្រូនមូល (ភាគច្រើនជាប្រភេទសត្វ Strongyle) ប្រហាក់ប្រហែលនឹងឫសខ្ទឹមបារាំង ហើយមានប្រវែងពី ១ ទៅ ២ សង្ទីម៉ែត្រ។ ការឆ្លងគឺតាមរយៈពងព្រូននៅលើចំណីដំរី។



រោគសញ្ញា៖ ជាធម្មតាដំរីមិនមានអាការៈខ្លាំងក្លាទេ ប៉ុន្តែវាអាចបង្ហាញសញ្ញាដូចខាងក្រោម។ សត្វដំរីនេះមានរាងស្គម និងហត់នឿយ។ ចំពោះកូនដំរី ព្រូនទាំងនេះនឹងធ្វើឲ្យការលូតលាស់របស់វាមានសភាពយឺតយ៉ាវខុសធម្មតា ហើយកូនដំរីអាចក្រិន។ លាមករបស់ដំរីនឹងមានព្រូនច្រើន។

*ការព្យាបាល៖* ជាធម្មតាដំរីនឹងបោសសម្អាតពពួកព្រូន ដែលភាគច្រើនជាពពួកព្រូនមូល ដោយខ្លួនវាផ្ទាល់ មួយដងក្នុងមួយឆ្នាំ។ អ្នកអាចឃើញព្រូនទាំងនោះ នៅក្នុងលាមករបស់ដំរី។ ក្នុងនាមជាសត្វចិញ្ចឹម សត្វដំរីស៊ីស្លឹក ឬឫស ឬដើមរបស់ដើមរុក្ខជាតិដែលមានបន្លា (Harrisonia perforate Merr) ឬដីរ៉ែ និងលិចអំបិល ដើម្បីបោសសម្អាតពពួកសត្វល្អិតពីខ្លួនរបស់វា តាមបែបធម្មជាតិ។ ហ្មដំរីក៏អាចជួយបាន ដោយយកដំរីចេញពីការងារ។ រុក្ខជាតិផ្សេងទៀតជាច្រើនអាចត្រូវបានគេយកមកប្រើប្រាស់៖

- វល្លិ៍សណ្តែកសមុទ្រ (Entada pursaetha DC ។ )
- ស្លឹក ឬឫស ឬដើមរបស់រុក្ខជាតិដែលមានបន្លា (Harrisonia perforate Merr)។
- ស្លឹក ឬដើមចេញពីដើមខ្មៅ (Acacia catechu Willd.)។
- ដើមបូរ៉ាផេត (Tinospora tuberculata Beaumee)។
- ផ្លែម៉ាក្លឿ (Diospyros mollis Griff.)។
- សំបកឈើ Albizia procera [Roxb.] Benth។
- សំបក ផ្កា និងផ្លែល្វាមាស (Elaeocarpus grandiforus J.E. Smith)។
- ឫស និងផ្កានៃដើម bael (Aegle marmelos [L. ] Corr. ex Roxb.)
- ឫស គល់នៃដើម Job′s tears (Coix lachrymal-jobi Linn)។
- បើស្ថានភាពមិនបានល្អប្រសើរឡើងវិញទេ សូមពិគ្រោះជាមួយពេទ្យសត្វ។

*ដំបូន្មាន៖* នៅតំបន់ខ្លះដែលគ្មានដុំអំបិលធម្មជាតិធំៗ ហ្មដំរីអាចពិគ្រោះជាមួយពេទ្យសត្វ ដើម្បីធ្វើដុំអំបិលសិប្បនិម្មិត ឬអាចបន្ថែមអំបិលរ៉ែ។

**អនុសាសន៍ស្តីពីការប្រើប្រាស់ថ្នាំ** Ivermectin

មានតែពេទ្យសត្វទេ ទើបអាចផ្តល់ថ្នាំ Vermentinu នេះ ឲ្យយកមកប្រើប្រាស់បាន។ វាមានប្រសិទ្ធភាពណាស់ ក្នុងការប្រឆាំងនឹងពពួកប៉ារ៉ាស៊ីត នៅក្នុងប្រព័ន្ធរំលាយអាហារ និងមានពីរប្រភេទគឺ Ivermectin មានប្រសិទ្ធភាពប្រឆាំងនឹងពួកព្រូន និង Ivermectin-F ដែលមានប្រសិទ្ធភាពប្រឆាំងនឹងព្រូនសំប៉ែត និងព្រូនមូល ហើយវាក៏មានប្រសិទ្ធភាពជាពិសេសចំពោះព្រូនថ្លើមដែរ។ ថ្នាំទាំងពីរនេះដំណើរការតាមរយៈការវាយលុកលើប្រព័ន្ធ

ប្រសាទរបស់ប៉ារ៉ាស៊ីត ដែលធ្វើអោយពួកវាគោងលែងជាប់ និងត្រូវបានសម្អាតចេញពីរាងកាយដំរី។

ថ្នាំ Ivermectin គួរតែផ្តល់ឲ្យសត្វដំរីជាថ្នាំបង្ការ (prophylactic) គឺពីរដងក្នុងមួយឆ្នាំ។ ប្រសិនបើអ្នកធ្វើការអស់រយៈពេលជាយូរមកហើយនៅក្នុងមជ្ឈមណ្ឌល ដែលមានពេទ្យសត្វ ឬប្រសិនបើអ្នកតែងតែធ្វើការយ៉ាងជិតស្និទ្ធជាមួយពេទ្យសត្វនោះ គាត់នឹងជួយមើលតាមកាលវិភាគនេះ។ ប៉ុន្តែចំពោះហ្មដំរី ដែលធ្វើដំណើរច្រើន ឬមានពេទ្យសត្វច្រើននាក់ផ្សេងៗគ្នា អ្នកគួរតែកត់ទុកដោយប្រុងប្រយ័ត្ននូវ (១) ថ្ងៃចាក់ថ្នាំ និង (២) កម្រិតថ្នាំ។ ប្រសិនបើអ្នកមិនបានឲ្យដំរីរបស់អ្នកចាក់ថ្នាំនោះពីរដងក្នុងមួយឆ្នាំទេ វាអាចនឹងមានប៉ារ៉ាស៊ីត។ ប្រសិនបើឲ្យដំរីទទួលថ្នាំមុនពេលកំណត់ នោះជាការខាតបង់ថវិការឥតប្រយោជន៍ ព្រោះកម្រិតថ្នាំដែលចាក់ម្តងៗអាចនឹងរក្សាប៉ារ៉ាស៊ីតនៅក្នុងកម្រិតមួយ ដែលអាចទទួលយកបានក្នុងរយៈពេលប្រាំមួយខែពេញៗ។

ត្រូវរក្សាកំណត់ត្រាឲ្យបានល្អ។ អ្នកអាចសរសេរកាលបរិច្ឆេទ និងកម្រិតថ្នាំដែលបានផ្តល់ឲ្យលើប្រតិទិន រួមទាំងកាលបរិច្ឆេទ ដែលអ្នកត្រូវឲ្យថ្នាំក្នុងរយៈពេល៦ខែលើកក្រោយទៀត។ ទោះយ៉ាងណាល្អបំផុត គឺត្រូវប្រើទម្រង់ព្យាបាល ដែលបានផ្តល់ជូនក្នុងសៀវភៅដៃរបស់ហ្មដំរី។

ដូចថ្នាំជាច្រើនដែរប្រសិនបើប្រើថ្នាំ Ivermectin ច្រើនពេក ថ្នាំអាចមានផលប៉ះពាល់មិនល្អ។ ប្រសិនបើ Ivermectin បណ្តាលឲ្យដំរីរបស់អ្នកហៀរទឹកមាត់ជាប្រចាំ ហើយភ្នែករបស់វាឡើងពណ៌សស្រអាប់ដូចពពក ដែលមើលទៅដំរីដូចជាវាមិនអាចផ្តោតអារម្មណ៍ឲ្យមូលបាន នោះគឺជាសញ្ញានៃការប្រើថ្នាំជ្រុល។ Ivermectin មានឥទ្ធិពលខ្លាំងណាស់ដែលសំណល់នៅក្នុងទឹកនោមក៏អាចបំពុល និងសម្លាប់ពពួកជន្លេនដែលមានប្រយោជន៍ដល់ដី។

**អ្នកគ្រប់គ្រងមជ្ឈមណ្ឌលដំរី៖** ប្រសិនបើអ្នកជាម្ចាស់របស់ដំរីទាំងអស់ នៅក្នុងមជ្ឈមណ្ឌលដំរី យកល្អអ្នកគួរតែមានពេទ្យសត្វដ៏ល្អមួយផ្ទាល់ខ្លួន ប៉ុន្តែទោះជាយ៉ាងណា ក៏អ្នកត្រូវតែរក្សាទុកនូវកំណត់ត្រាសុខភាពដំរីដោយផ្ទាល់ខ្លួនរបស់អ្នកមួយដែរ។

ប្រសិនបើអ្នកជួលដំរីល្អៗជាច្រើន ដែលជាកម្មសិទ្ធិរបស់មនុស្សផ្សេងទៀត អ្នកអាចជួយ

ពន្យល់បញ្ចុះបញ្ចូល និងការទាក់ទាញទឹកចិត្តដល់ម្ចាស់ម្នាក់ៗ ឬអ្នកអាចធ្វើការសម្រុះសម្រួល (និងអាចចូលរួមចំណាយថវិកា) លើការព្យាបាលដំរីទាំងនោះ។ ដោយពិចារណាឃើញថាដំរីទាំងនោះរស់ក្នុងមជ្ឈមណ្ឌលតែមួយជាមួយគ្នា ដូច្នេះវាមានលទ្ធភាពខ្ពស់ក្នុងការចម្លងប៉ារ៉ាស៊ីតទៅដំរីផ្សេងៗទៀត។ ការបង្ការដែលបានគ្រោងទុក គឺអ្នកត្រូវគិតហើយអ្នកគួរតែពិគ្រោះជាមួយពេទ្យសត្វអំពីកម្មវិធីបង្ការ ឬព្យាបាលណាមួយ។

**ជម្ងឺឆ្អល់ពោះ** ( Dyspepsia )

ពេលខ្លះសត្វដំរីមិនអាចបញ្ចេញកាកសំណល់ចេញពីរាងកាយរបស់វា ដោយសារបុព្វហេតុផ្សេងៗមួយចំនួន៖

- ដំរីស៊ីចំណីច្រើនពេក ដូចជានៅដើមរដូវវស្សា នៅពេលមានស្មៅទឹកដមច្រើន។
- ដំរីបានស៊ីចំណីអាហារដែលពិបាករំលាយ ដូចជាធាងដូង ឬផ្តៅ។
- មានការស្ទះពោះវៀន ដែលបណ្តាលចេញមកពីវត្ថុពីខាងក្រៅផ្សេងៗ ចំពោះដំរីនៅក្នុងទីក្រុង ឬនៅក្នុងតំបន់ទេសចរណ៍ ដោយវាបានស៊ីដោយថង់ប្លាស្ទិច។

**រោគសញ្ញា៖** ដំរីគ្មានមានសភាពល្ហិតល្ហៃ មិនចាប់អារម្មណ៍នឹងចំណីអាហារ ហើយពេលខ្លះវាមានអារម្មណ៍ធុញថប់ ឬប្រើប្រមោយរបស់វាគោះលើពោះរបស់វា ឬយកដី ឬភក់បាចលើពោះរបស់វា។ ពោះហើម ឬប៉ោងធំលើសពីធម្មតា ហើយអាចមានការញ័រសាច់ដោយមិនដឹងខ្លួន។ សត្វដំរីខ្លះនឹងក្រោកឈរឡើង ហើយដេកចុះទៅវិញជាច្រើនលើកច្រើនសារ។ សត្វដំរីយកប្រមោយវាផ្លុំបញ្ចេញសម្លេង ឬស្រែកដោយឈឺចាប់ខ្លាំង។ ប្រសិនបើស្ថានភាពបែបនេះមិនត្រូវបានព្យាបាលទាន់ពេលវេលាទេសត្វដំរីអាចស្លាប់។

**ការព្យាបាល៖** ជាធម្មតាជម្ងឺឆ្អល់ពោះ កើតឡើងពីការគ្រប់គ្រងដំរីមិនល្អ ដូចជាហ្មដំរីបានផ្តល់ចំណីអាហារ ដែលដំរីពិបាករំលាយ ឬផ្តល់ម្តងហើយម្តងទៀតច្រើនពេក។ ដូច្នេះជំហានដំបូងនៃការព្យាបាលគឺត្រូវរកមូលហេតុឲ្យឃើញ និងបញ្ឈប់វាជាបន្ទាន់។ ការព្យាបាលត្រូវធ្វើឡើងទៅតាមវិធីមួយចំនួនដូចខាងក្រោម៖

- យកដំរីទៅកន្លែងដែលមានម្លប់ល្អ ស្ងប់ស្អាត់ និងស្អាត។
- បញ្ឈប់ការផ្តល់ចំណីអាហារ។ ដំរីប្រហែលជាមិនចង់ផឹកទេ ប៉ុន្តែបើវាចង់ផឹកទឹកឲ្យវាផឹកទឹកចុះ។

- ស្អំទឹកក្តៅឧណ្ហៗលើផ្នែកក្រពះ។
- ឲ្យដំរីដើរដើម្បីជំរុញចលនាពោះវៀន។
- ប្រសិនបើដំរីមិនមានភាពល្អប្រសើរឡើងវិញទេ សូមទៅពិគ្រោះជាមួយពេទ្យសត្វឲ្យបានលឿនបំផុត។

**ជម្ងឺទល់លាមក**

ដំរីមិនអាចបញ្ចេញកាកសំណល់ចេញពីពោះវៀនរបស់វាបានទេ។

**រោគសញ្ញា៖** ដំរីគឺមានសភាពល្ហិតល្ហៃ ហើយផ្លាស់ទីដោយជ្រួលច្របល់ នៅក្នុងសភាពមិនសូវស្រួល។ ដំរីលែងស៊ីចំណីអាហារ ឬលែងផឹកទឹក។ ពោះវៀនរបស់វាលែងមានចលនា។ សត្វខ្លះនឹងដេកហើយក្រោកឈរម្តងហើយម្តងទៀត។ ការស្ទះពោះវៀនគឺជាកត្តាសំខាន់មួយ ដែលបណ្តាលឲ្យមានជម្ងឺទល់លាមក។

**ការព្យាបាល៖** ចំពោះសត្វដំរីចាស់ៗ ត្រូវធ្វើការវិភាគដោយប្រុងប្រយ័ត្នលើចំណីអាហារ ដែលនឹងត្រូវផ្តល់ឲ្យពួកវា។ គួរតែផ្តល់ឲ្យដំរីចាស់ៗនូវចំណីអាហារណា ដែលងាយរំលាយដូចជាចេកទុំ។ ចំពោះដំរីដែលមានសុខភាព យកល្អក៏ត្រូវគិតគូរពិចារណាពីរបៀប ដែលត្រូវផ្តល់ចំណីអាហារណាមួយ ដូចជាដើមចេក និងចុងដូងជាដើម ត្រូវតែកាត់វាជាបំណែកខ្លីៗ។

- យកដំរីទៅកន្លែងដែលមានម្លប់ល្អ ស្ងប់ស្ងាត់ និងស្អាត។
- បញ្ឈប់ការផ្តល់ចំណីអាហារឲ្យដំរីគ្រប់មុខទាំងអស់។ ដំរីប្រហែលជាមិនចង់ផឹកទេ ប៉ុន្តែប្រសិនបើវាចង់ផឹកទឹក អាចឲ្យវាផឹកទឹកបាន។
- ប្រើទឹកក្តៅ និងសាប៊ូ (សាប៊ូដុសខ្លួនធម្មតា ឬសាប៊ូលាងចានកាន់តែល្អ) លាបប្រេងរំអិលលើដៃ បន្ទាប់មកលូកដៃចូលទៅក្នុងរន្ធគូថរបស់ដំរី ហើយបារយកលាមកសត្វចេញមកក្រៅ តាមដែលអាចធ្វើទៅបាន។
- ឲ្យដំរីស៊ីដំណាប់អម្ពិលទុំ (Tamarindus indica Linn.) ឬដើមឈើខ្មៅ (Acacia catechu Willd.) ដើម្បីជួយជម្រៀសលាមកចេញមកក្រៅ។
- ប្រសិនបើស្ថានភាពមិនបានល្អប្រសើរឡើងវិញ ក្នុងរយៈពេលមួយ ឬពីរថ្ងៃទេ សូមទៅពិគ្រោះជាមួយពេទ្យសត្វភ្លាមៗ ដើម្បីទទួលបានជំនួយ។

## ជម្ងឺរាក

មានការហូរទឹករំអិល និងលាមករាវៗ ដែលអាចបណ្តាលឲ្យខ្វះជាតិទឹកធ្ងន់ធ្ងរដល់សត្វដំរីៗ ជម្ងឺរាកមានពីរប្រភេទធំៗ គឺជម្ងឺរាកមិនធ្ងន់ និងជម្ងឺរាកធ្ងន់ៗ

## ការរាករូសដោយគ្មានមេរោគ

ជម្ងឺរាករូសធំៗ ៣ ប្រភេទ ដែលមិនពាក់ព័ន្ធនឹងការបង្ករោគដោយមេរោគៗ

*ការរាករូសដើម្បី "លាងសម្អាតសត្វល្អិតក្នុងខ្លួន"៖* ជាធម្មតាដំរីនឹងលាងបោសសម្អាតប៉ារ៉ាស៊ីតខាងក្នុងខ្លួនម្តង ឬពីរដងក្នុងមួយឆ្នាំ ក្នុងរយៈពេលពីរ ឬបីថ្ងៃៗ ដំរីនឹងស្វែងរកចំណីធម្មជាតិដូចជាដីរ៉ែ សំបកឈើ ឬឬសឈើ ដើមឈើ ឧទាហរណ៍ដូចជាដើម Harrisonia perforate Merr.ៗ

*រោគសញ្ញា៖* សត្វដំរីមានសភាពល្ហិតល្ហៃ ហើយក៏លែងស៊ីចំណីអាហារដូចធម្មតាៗ លាមកមានសភាពរាវៗ និងមានទឹកច្រើន តែមានស្មៅដែលមិនទាន់បានរំលាយៗ

*ការព្យាបាល៖* ជាទូទៅជម្ងឺរាក ឬការលាងបោសសម្អាតប្រភេទនេះអាចបាត់ទៅវិញដោយខ្លួនឯង បន្ទាប់ពីរាកបានពី ២ ទៅ ៣ ថ្ងៃៗ

- ឲ្យសត្វដំរីបានឈប់សម្រាកពីការងារៗ
- យកដំរីទៅកន្លែងដែលមានម្លប់ល្អ ស្ងប់ស្ងាត់ និងស្អាតៗ
- រក្សាដំរីមួយនោះឲ្យនៅដាច់ដោយឡែកពីដំរីផ្សេងៗទៀត ដើម្បីការពារការរីករាលដាលនៃប៉ារ៉ាស៊ីតៗ
- បន្តការផ្គត់ផ្គង់ទឹកស្អាតឲ្យសត្វដំរីឲ្យបានច្រើនៗ
- ផ្គត់ផ្គង់ចំណីអាហារណា ដែលងាយរំលាយ ដូចជាចេកទុំឲ្យបានច្រើនៗ
- ត្រូវដុតលាមកបន្ទាប់ពីវាស្ងួត ឬបាចកំបោរលើលាមកនោះ និងកប់វាឲ្យជ្រៅៗ

*ប្រយ័ត្ន៖* ពងព្រូនតែងមាននៅក្នុងលាមករបស់សត្វដំរីៗ ពងព្រូនទាំងនេះអាចឆ្លងទៅសត្វដំរីដទៃទៀត ប្រសិនបើអ្នកមិនបំផ្លាញ ឬកប់លាមក និងគ្រប់គ្រងលាមកដែលមានពងព្រូនទាំងនោះមិនបានល្អទេៗ សម្រាប់ព័ត៌មានលម្អិតអំពីប៉ារ៉ាស៊ីតខាងក្នុង សូមមើលទំព័រទី ១៦២ៗ

*ការរាករូសពីអាហារមិនល្អ ឬមិនត្រឹមត្រូវ៖* ស្ថានភាពនេះអាចកើតចេញពីសត្វដំរី ឧទាហរណ៍ការស៊ីចំណីអាហារតែមួយមុខច្រើនពេក ដូចជាដំណាប់អម្ពិលទុំច្រើនពេក គ្រាប់ពោតដែលដាក់លក់ច្រើនពេក ឬស៊ីតែចេកទុំៗ ការរាករូសក៏អាចបណ្ដាលមកពីការស៊ីចំណីអាហារ ដែលពិបាករំលាយ ឬអាហារដែលកខ្វក់ មានដោយដីខ្សាច់ ឬដី ឬថ្នាំអង់ទីប៊ីយោទិច ឬថ្នាំសម្លាប់មេរោគមួយចំនួនផងដែរ ដូចជាថ្នាំ Povidone-iodine ១% ដែលអាចចង្កឲ្យមានការរាករូស។

*រោគសញ្ញា៖* ការរាករូសដូចជាការលាងសម្អាតក្រពះនិងពោះវៀនរបស់សត្វដំរី ជាធម្មតាអ្នកនឹងរកមិនឃើញមានប៉ារ៉ាស៊ីតច្រើនទេ។ ពេលខ្លះអ្នកអាចនឹងប្រទះឃើញមានឈាមតិចៗ ដីខ្សាច់ ឬដី ដែលសត្វដំរីបានស៊ី។

*ការព្យាបាល៖*

- ព្យាយាមកំណត់មូលហេតុនៃការរាករូសនោះឲ្យបានច្បាស់លាស់ ត្រូវបញ្ឈប់ដំរីកុំឲ្យប៉ះពាល់ចំណីអាហារ ឬរបស់ទាំងនោះទៀត។
- ត្រូវយកចិត្តទុកដាក់មើលថែទាំសត្វដំរី ដូចក្នុងករណីដែលវាមានការរាករូសដើម្បីលាងសម្អាតពោះរបស់វាដែរ។

*ប្រយ័ត្ន៖* ប្រសិនបើការរាករូសនេះនៅតែបន្តអូសបន្លាយពេលលើសពីបីថ្ងៃ ឬក្នុងលាមកមានឈាមកាន់តែច្រើន ឬក៏សត្វដំរីកាន់តែបង្ហាញពីសញ្ញានៃកាឈឺចាប់ខ្លាំង កាន់តែចុះខ្សោយជាលំដាប់ ឬកាន់តែល្ហិតល្ហៃខ្លាំង ត្រូវទៅតាមពេទ្យសត្វជាបន្ទាន់។

*ការរាករូសមកពីជម្ងឺស្ត្រេស៖* ដំរីភាគច្រើន ជាពិសេសកូនដំរី និងដំរីញីអាចមានកើតជម្ងឺរាករូសភ្លាមៗ ដោយសារពួកវាមានការភ័យខ្លាច ឬកើតរោគស្ត្រេស (សូមមើលទំព័រទី ១១៧)។ នោះគឺដូចគេតែងនិយាយតៗគ្នាថា "ភ័យលេចអាចម៍"។ ដំរីដែលត្រូវគេបានដឹកជញ្ជូន ឬបំបែកចេញពីគ្រួសារបងប្អូនរបស់វា ឬពីមេរបស់វាអាចកើតជម្ងឺរាកបែបនេះ តែក្នុងរយៈពេលពីរ ឬបីនាទី។ ពេលខ្លះរោគស្ត្រេសអាចកើតឡើងអស់រយៈពេលយូរ ដូចជាក្នុងករណីដែលមានគេដាក់ច្រវាក់ចងដំរីនៅក្បែរនោះ។

**ជម្ងឺរាកដែលបណ្ដាលមកពីមេរោគ**

*មានមេរោគជាច្រើនដែលអាចបង្កឲ្យមានជម្ងឺរាកប្រភេទនេះ រួមមានទាំងពពួកបាក់តេរីផងដែរ (ដូចជា* E. coli, Salmonella, Clostridium, Pseudomonas) ។

*រោគសញ្ញា៖ រោគសញ្ញាមានលក្ខណៈដូចជាជម្ងឺរាកមិនធ្ងន់ដែរ ប៉ុន្តែប្រសិនបើស្ថានភាពបែបនេះនៅតែបន្តរហូតដល់ ៣ ថ្ងៃទៀត នោះវាអាចបណ្ដាលមកពីមេរោគ។*

*ការព្យាបាល៖ ក្រៅពីធ្វើឲ្យដំរីត្រជាក់ខ្លួន ដោយស្រោចទឹក និងឲ្យវាសម្រាក ហ្មដំរីមិនអាចធ្វើបានក្រៅពីហៅពេទ្យសត្វទេ។*

**ជម្ងឺរាក** Enterotoxemia

*ជម្ងឺរាកប្រភេទ* Enterotoxemia *គឺដោយសារតែការឆ្លងមេរោគជាបាក់តេរីម្យ៉ាងហៅថា* Clostridium perfringens *ហើយជម្ងឺនេះមានប្រវត្តិធ្លាប់ធ្វើឲ្យដំរីស្លាប់ជាច្រើន។ ភាគច្រើនជម្ងឺ* Enterotoxemia *នេះឆ្លងទៅសត្វដំរី ដែលបានស៊ីចំណីអាហារ ដែលមានជាតិកខ្វក់។ ជម្ងឺ* Enterotoxemia *គឺជារឿងធម្មតាទៅហើយ នៅក្នុងប្រទេសថៃ។*

*រោគសញ្ញា៖*

- *ដំរីមិនស្រួលខ្លួន និងមិនបានសម្រាក ឬជ្រួលច្របល់។*
- *ដំរីបាត់បង់ចំណង់អាហារ។*
- *ដំរីអាចរាករហូតដល់ស្លាប់ ព្រោះបាត់បង់ជាតិទឹក ជាពិសេសចំពោះកូនដំរី។*

*ការព្យាបាល៖*

- *ញែកដំរីដែលឆ្លងជម្ងឺនេះចេញពីហ្វូងរបស់វា។*
- *យកដំរីចេញពីកន្លែងធ្វើការ។*
- *យកដំរីទៅកន្លែងដែលមានម្លប់ ស្អាត និងស្ងប់ស្ងាត់ល្អ។*
- *រក្សាល័ក្ខខ័ណ្ឌអនាម័យឲ្យបានល្អ ទាក់ទងនឹងលាមក និងកាកសំណល់ដទៃទៀតនិងចំណីអាហារដែលដំរីស៊ីសល់។ ត្រូវកប់ ឬដុតកាកសំណល់ ដើម្បីកុំអោយវាឆ្លងទៅដំរីដទៃទៀត។*
- *ហ្មដំរី និងអ្នកដែលមានទំនាក់ទំនងជាមួយដំរី កម្រាល និងអាហារនៅសេសសល់ពីដំរី គួរតែជៀសវាងការទាក់ទងជាមួយដំរីដែលមានសុខភាពល្អ នៅ*

*ពេលមិនទាន់បានផ្ទួតទឹកសម្អាតខ្លួនដោយប្រុងប្រយ័ត្ន និងផ្លាស់ប្តូរសម្លៀកបំពាក់ស្អាត។*

- *ត្រូវផ្តល់អាហារដែលមានជីវជាតិខ្ពស់ ងាយរំលាយ ដូចជាចេកទុំ។*
- *ទាក់ទងទៅពេទ្យសត្វជាបន្ទាន់។*

**ជម្ងឺរាក** Salmonellosis

Salmonellosis *គឺជាជម្ងឺមួយដែលបណ្តាលឲ្យរាក ហើយអាចធ្វើឲ្យជំរឺស្លាប់បាន ជាពិសេសកូនជំរឺ។ ជម្ងឺនេះបណ្តាលមកពីបាក់តេរីដែលមានឈ្មោះថា* Salmonella *វាត្រូវបានគេរកឃើញភាគច្រើននៅក្នុងកន្លែងបិទជិត ឬកន្លែងដែលមានអនាម័យមិនល្អ។ វាអាចរាលដាលទៅដល់ជំរឺផ្សេងទៀតយ៉ាងឆាប់រហ័ស។*

*របៀបឆ្លង៖ ជម្ងឺ* Salmonellosis *អាចរាលដាលតាមរយៈចំណីអាហារ និងទឹកដែលមានផ្ទុកទៅដោយបាក់តេរី ជាពិសេសចំណីអាហារ ដែលត្រូវបានរក្សាទុកអស់រយៈពេលជាយូរមកហើយ ពីព្រោះវាអាចជួយឲ្យមេរោគអាចបង្កើតចំនួនបានច្រើន។*

*រោគសញ្ញា៖*

- *មានរាកជាប់ៗគ្នា។*
- *មានហៀរទឹករំអិលដែលមានក្លិនមិនល្អ។*
- *ទឹកដែលជ្រាបចេញមកក្រៅមានទឹករំអិល ដែលអាចលាយគ្នាជាមួយឈាម។*
- *ជំរឺគ្មានចំណង់អាហារ ហត់នឿយខ្លាំង។*
- *ជំរឺមានជម្ងឺគ្រុន។*

*ការព្យាបាល៖*

- *ញែកសត្វជំរឺដែលមានជម្ងឺនេះចេញពីជំរឺដទៃទៀត និងផ្តត់ផ្គង់ឲ្យជំរឺនោះនូវទឹកដែលមានប្រភពខុសគ្នាពីទឹកដែលបានផ្តត់ផ្គង់ឲ្យជំរឺដទៃទៀត។*
- *យកជំរឺទៅកន្លែងស្អាត និងស្ងប់ស្ងាត់ល្អ។*
- *លាងសម្អាតកន្លែងដែលជំរឺមានកើតជម្ងឺនោះដោយប្រុងប្រយ័ត្នបំផុត ត្រូវយកចិត្តទុកដាក់ជាពិសេស ក្នុងការធានាថា មេរោគនៅក្នុងលាមករបស់វា មិនឆ្លងទៅសត្វ*

ជំរឺផ្សេងទៀត។ ជម្ងឺ Salmonellosis នេះក៏អាចរីករាលដាលបាន ដោយសារប៉ុយផង ដែរ។

- ផ្តល់ឲ្យជំរឺនូវចំណីអាហារផ្លាយរំលាយតិចៗដូចជាចេកទុំ។
- ត្រូវប្រាកដថាមានការផ្គត់ផ្គង់ទឹកស្អាតគ្រប់គ្រាន់ និងគ្រប់ពេល។
- ពិគ្រោះជាមួយពេទ្យសត្វឲ្យបានលឿនបំផុត។

ប្រយ័ត្ន៖ ហ្វូងជំរឺគួរតែប្រយ័ត្នប្រយែងអនុវត្តអនាម័យឲ្យបានល្អ និងលាងដៃឲ្យបាន ស្អាតជានិច្ច ព្រោះជម្ងឺ salmonellosis អាចចម្លងទៅសត្វជំរឺដទៃទៀត ហើយក៏អាចចម្លង ទៅមនុស្សបានដែរ។

**ជម្ងឺរាក** Colibacillosis

មូលហេតុនៃជម្ងឺរាករូសប្រភេទនេះ គឺបណ្តាលមកពីបាក់តេរីឈ្មោះ Escherichia coli (ដែលគេគ្រប់គ្នាតែងហៅថា "E. coli") ដែលវាបានបំពុលចំណីអាហារ ទឹក ឬប្រភព ផ្សេងៗទៀត។ ជម្ងឺរាក Colibacillosis ត្រូវបានគេជួបប្រទះជាញឹកញាប់ចំពោះកូនជំរឺ ដែលទើបនឹងកើត ព្រោះប្រព័ន្ធនៃភាពស៊ាំរបស់វានៅខ្សោយ ដោយសារវាទទួលបាន ជាតិ colostrum នៅក្នុងទឹកដោះដំបូងមិនគ្រប់គ្រាន់។ ជាពិសេសវាអាចនឹងផ្លាយរង់គ្រោះ ផងដែរ ចំពោះជំរឺតូចៗដែលទទួលបានចំណីអាហារកខ្វក់ ឬដែលរស់នៅក្នុងបរិស្ថានមិន ស្អាត និងមិនត្រឹមត្រូវ។

E. coli អាចឆ្លងទៅថនិកសត្វផ្សេងៗគ្នាជាច្រើន រួមទាំងមនុស្សផងដែរ។ មេរោគ នេះចាប់ផ្តើមវាយប្រហារ ដោយធ្វើឲ្យសត្វជំរឺមានការរមួលពោះវៀន បន្ទាប់ពីមនុស្ស យើងមិនបានលាងដៃរបស់ខ្លួនឲ្យបានត្រឹមត្រូវ មុនពេលកាន់ចំណីអាហារឲ្យសត្វជំរឺស៊ី ហើយបន្ទាប់មករូបធាតុតូចៗក៏បានចូលទៅក្នុងខ្លួនជំរឺតាមរយៈចំណីអាហារទាំងនោះ។

អ្នកគ្រប់គ្រងមជ្ឈមណ្ឌលត្រូវប្រយ័ត្ន៖ សួនសត្វជាច្រើននៅភាគខាងលិចបាន ហាមឃាត់ការផ្តល់ចំណីអាហារដល់សត្វជំរឺចិញ្ចឹម ដោយដៃផ្ទាល់ ដើម្បីបង្ការការរីករាល ដាលមេរោគ E. coli និងបាក់តេរីផ្សេងៗទៀត។ ប៉ុន្តែការបញ្ឈប់ការហុចចំណីអាហារទៅ ឲ្យសត្វចិញ្ចឹមដោយដៃផ្ទាល់ ប្រហែលជាមិនអាចទៅរួចទេនៅក្នុងប្រទេសថៃ ព្រោះវាជា

*កន្លែង ដែលគេអាចរកប្រាក់ចំណូលបានច្រើន អ្នកគ្រប់គ្រងមជ្ឈមណ្ឌលគួរតែដឹងអំពីគ្រោះថ្នាក់នៃការឆ្លងមេរោគតាមរបៀបនេះ។*

*រោគសញ្ញា៖*

- *សត្វដំរីចាប់ផ្តើមមានជម្ងឺគ្រុនក្តៅ។*
- *សត្វដំរីនោះលែងចាប់អារម្មណ៍នឹងចំណីអាហារ។*
- *សត្វដំរីនោះចាប់ផ្តើមរាករូសរហូតដល់ចំណុចខ្វះជាតិទឹកធ្ងន់ធ្ងរ រហូតដល់បង្កឲ្យសត្វដំរីស្លាប់បាន។*

*ការព្យាបាល៖*

- *ញែកដំរីឈឺឲ្យឆ្ងាយពីដំរីដែលមានសុខភាពល្អ។*
- *យកដំរីឈឺទៅកន្លែងដែលមានម្លប់ល្អ ស្អាត និងស្ងប់ស្ងាត់។*
- *ផ្តល់អាហារទន់ៗមួយចំនួនតូចដូចជាចេកទុំ។*
- *ផ្តល់ទឹកផឹកគ្រប់គ្រាន់ដល់ដំរីឈឺ និងឲ្យបានគ្រប់ពេល។*
- *សម្អាតកន្លែងទុកដំរី ដែលមានផ្ទុកមេរោគយ៉ាងប្រយ័ត្នប្រយែង ជាពិសេសត្រូវជានាជាទឹកនោម និងលាមករបស់វាមិនអាចបំពុលដល់តំបន់ក្បែរនោះ ដែលមានដំរីមានសុខភាពល្អនោះទេ។ (ការបង្ហូរទឹកស្អុយ គួរតែហូរទៅតំបន់ដែលគ្មានដំរី ឬគ្មានមនុស្សរស់នៅ។)*
- *អ្នកថែទាំសត្វដំរី និងអ្នកផ្សេងទៀតដែលមានទំនាក់ទំនងជាមួយដំរី ដែលមានជម្ងឺគួរតែផ្ងូតទឹកសម្អាតខ្លួនប្រាណដោយប្រុងប្រយ័ត្នជាទីបំផុត ហើយគួរតែផ្លាស់ប្តូរសម្លៀកបំពាក់មុនពេលទៅប៉ះពាល់សត្វដំរីដែលមិនទាន់ឆ្លងជម្ងឺនេះ*
- *ទៅពិគ្រោះជាមួយពេទ្យសត្វឲ្យបានលឿនបំផុត។*

## ជម្ងឺផ្សេងៗទៀត

### ជម្ងឺរលាកសួត

*ជម្ងឺរលាកសួតគឺជាជម្ងឺមួយនៃប្រព័ន្ធដង្ហើមរបស់ដំរី។ ជម្ងឺរលាកសួតកើតឡើងទាំងតាមទម្រង់វីរុស និងបាក់តេរី ដូច្នេះមូលហេតុពិតប្រាកដជាធម្មតាមិនច្បាស់ទេ យ៉ាងហោចណាស់ ទាល់តែមានការធ្វើតេស្តស្មុគស្មាញនៅមន្ទីរពិសោធន៍ ទើបយើងអាចដឹង*

ច្បាស់បាន។ ជម្ងឺរលាកសួតជារឿយៗវាយប្រហារលើសត្វដំរី បន្ទាប់ពីដំរីមួយនោះត្រូវបានចុះខ្សោយដោយសារជម្ងឺមួយទៀត។

បច្ចុប្បន្នមិនមានវ៉ាក់សាំង ឬមធ្យោបាយវេជ្ជសាស្ត្រផ្សេងទៀតដើម្បីការពារជម្ងឺនេះទេ ប៉ុន្តែវាច្បាស់ណាស់ថាជម្ងឺរលាកសួតជារឿយៗតែងប៉ះពាល់ដល់ដំរីដែលហត់នឿយពីការងារហួសប្រមាណ។ ជាពិសេសងាយរងគ្រោះជាងគេ គឺសត្វដំរីដែលបានស៊ីចំណីអាហារមិនសូវល្អ ឬសត្វដំរីស្ថិតក្នុងស្ថានភាពតានតឹង (កើតរោគស្ត្រេស) អូសបន្លាយពេល។

ជម្ងឺរលាកសួតអាចកើតមាននៅលើដំរីគ្រប់វ័យ។

រោគសញ្ញា៖

- មានដំណក់ទឹករំអិលស្រក់ចេញពីចុងប្រមោយ ហើយសត្វដំរីក៏មានហៀរទឹកមាត់យ៉ាងខ្លាំង។
- មានការបាត់បង់ចំណង់អាហារ។
- សត្វដំរីចាប់ផ្តើមមានជម្ងឺគ្រុនក្តៅ។

ការព្យាបាល៖

- ញែកដំរីដែលមានជម្ងឺចេញពីដំរីដទៃទៀត។
- យកដំរីទៅកន្លែងដែលមានម្លប់ ឬរបងព័ទ្ធជុំវិញដោយមានខ្យល់ចេញចូលល្អ។
- ឲ្យចំណីបំប៉នបន្ថែម ដូចជាចេកទុំស្រូវដែលគ្មានជាតិស្ករ អំពៅនិងស្មៅស្រស់។
- ផ្តល់ទឹកស្អាតឲ្យបានគ្រប់គ្រាន់។
- ទៅពិគ្រោះជាមួយពេទ្យសត្វភ្លាមៗជាពិសេសសម្រាប់កូនដំរី។

**ជម្ងឺខាន់ស្លាក់** ( Anthrax )

Anthrax ជាជម្ងឺឆ្លងខ្លាំង បណ្តាលមកពីបាក់តេរី ដែលអាចវាយប្រហារដំរីគ្រប់វ័យ។ Anthrax ក៏អាចវាយប្រហារលើគោ ក្របី សេះនិងសត្វ ដែលមានឈាមក្តៅ រួមទាំងមនុស្ស

ដែលធ្វើការជាមួយសត្វទាំងនោះផងដែរ។ នៅពេលដែលបាក់តេរីចូលទៅក្នុងចរន្តឈាមពួកវានឹងកើនឡើងយ៉ាងឆាប់រហ័ស បន្ទាប់មកមេរោគនោះតែងតែធ្វើឲ្យប៉ះពាល់ដល់ឈាមថែមទៀត។ ការស្លាប់កើតឡើងយ៉ាងឆាប់រហ័ស ជាធម្មតាក្នុងរយៈពេល

មួយ ឬពីរថ្ងៃ។ ពេលខ្លះសត្វដំរីស្លាប់ភ្លាមៗ បន្ទាប់ពីកើតជម្ងឺនេះ។ សូម្បីតែបន្ទាប់ពីការស្លាប់របស់សត្វដំរីហើយ មេរោគនៃជម្ងឺនេះក៏ឆ្លងរាលដាលតទៅទៀត មិនត្រឹមតែតាមរយៈខ្មោចរបស់ដំរីឈឺតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចឆ្លងតាមស្បែក និងភ្លុករបស់វាបានថែមទៀតផង។

*របៀបឆ្លងមេរោគ៖* មេរោគ anthrax បង្កើតជាស្ព័ ដែលមានភាពរឹងមាំខ្លាំងណាស់ សារពាង្គកាយរបស់វាអាចរស់បានអស់រយៈពេលជាច្រើនទសវត្ស និងមានភាពធន់ទ្រាំខ្ពស់ទៅនឹងកំដៅ និងសារធាតុគីមីសម្លាប់មេរោគ។ សត្វដំរីចិញ្ចឹមសត្វភាគច្រើនតែងឆ្លង

មេរោគចូលក្នុងខ្លួន នៅពេលវាស៊ីស្មៅនៅតាមវាលស្មៅដែលមានជម្ងឺ ឬស៊ីចំណីអាហារដែលមានជាតិកខ្វក់។ ការបង្ករោគកើតឡើងជាញឹកញាប់នៅពេលស្មៅមានកម្ពស់ទាបៗ និងមិនសូវសម្បូរស្មៅ ហើយជារឿយៗវារីករាលដាលនៅពេលមានភ្លៀងធ្លាក់ខ្លាំងនៅរដូវប្រាំង។ ការឆ្លងអាចកើតឡើងតាមរយៈការដកដង្ហើម ការប៉ះពាល់នឹងឈាម ទឹករំអិល និងលាមក។

*រោគសញ្ញា៖*

- ដំរីនឹងមានគ្រុនក្តៅខ្លាំង ដែលគេអាចសង្កេតឃើញតាមរយៈស្នាមក្រហមនៃភ្នែកមាត់ និងផ្នែកខាងក្នុងនៃចុងប្រមោយរបស់ដំរី។
- យកសីតុណ្ហភាពរបស់ដំរីឲ្យបានញឹកញាប់។ សរសេរពេលវេលា និងសីតុណ្ហភាពសម្រាប់ការប្រើប្រាស់របស់ពេទ្យសត្វ។
- ដំរីមានដង្ហើមក្តៅ ហើយអាចពិបាកដកដង្ហើម។
- ដំរីមានសភាពល្ហិតល្ហៃយ៉ាងខ្លាំង។ ប្រមោយ ត្រចៀក និងកន្ទុយលែងកម្រើក។
- ដំរីនេះហាក់ដូចជាកំពុងសម្លឹងមើលអ្វីមួយ ហើយធ្វើភ្នែកស្ងឹៗ។
- ដំរីអាចដួលរលំភ្លាមៗ។
- ដំរីស៊ីចំណីអាហារ និងផឹកទឹកតិចជាងពេលមុនៗ។
- ដំរីអាចមានជម្ងឺរាករូសដែលអាចមានឈាម។
- ជួនកាលមានការហើមនៅក្រោមស្បែក (ជាធម្មតានៅបំពង់កខាងក្រោយត្រចៀក ស្មា ពោះ និងរវាងរន្ធគូថ និងសរីរាង្គផ្លូវភេទ)។ ដំបូងការហើមទាំងនេះក្តៅ និង

ឈឺចាប់ ប៉ុន្តែក្រោយមកត្រជាក់ ហើយមិនឈឺចាប់នៅពេលប៉ះ។

- អាចមានឈាមហូរចេញពីរន្ធច្រមុះ នៅខាងក្នុងមាត់ លិង្គ ឬរន្ធគូថ។

ការព្យាបាល៖

- ស្វែងរកពេទ្យសត្វឲ្យបានលឿនបំផុត។ ការព្យាបាលមានតែមួយគត់ គឺថ្នាំអង់ទីប៊ីយោទិច (ថ្នាំផ្សះ) ដែលបានចេញវេជ្ជបញ្ជាដោយពេទ្យសត្វតែប៉ុណ្ណោះ។ (ការព្យាបាលច្រើនតែឥតប្រយោជន៍ ហើយជាធម្មតាដំរីដែលឆ្លងមេរោគនេះអាចស្លាប់)។
- នៅក្នុងដំណាក់កាលពុំរ៉ៃ ជម្ងឺនេះច្រើនតែស្រដៀងនឹងជម្ងឺដទៃទៀត។ ហេតុដូច្នេះការធ្វើរោគវិនិច្ឆ័យត្រឹមត្រូវ គឺអាចធ្វើទៅបានលុះត្រាតែការធ្វើតេស្ត នៅក្នុងមន្ទីរពិសោធន៍។
- ដំរីត្រូវតែញែកដាច់ពីគ្នាឲ្យបានលឿនបំផុត ហើយដំរីដទៃទៀតក៏គួរតែត្រូវបានផ្លាស់ទីទៅឆ្ងាយបំផុតតាមដែលអាចធ្វើទៅបាន។
- ហ្វូងដំរី និងមនុស្សផ្សេងៗទៀត ដែលប៉ះ ឬថែទាំដំរីឈឺ មិនគួរទៅជិត ឬប៉ះដំរីដទៃទៀតដែលមិនទាន់ឆ្លងជម្ងឺនោះទេ។
- ដំរីឈឺគួរតែរក្សាទុកនៅកន្លែងដែលមានម្លប់ល្អ ស្អាត និងស្ងប់ស្ងាត់។
- ផ្តល់អាហារដែលមានជីវជាតិខ្ពស់ និងចំណីអាហារដែលសត្វដំរីចូលចិត្តខ្លាំង ដូចជាចេកទុំ អំពៅ និងស្មៅបៃតង។
- ប្រសិនបើច្បាស់ថាសត្វដំរីនេះនឹងស្លាប់ ប៉ុន្តែវានៅតែអាចដើរបាន ឬអ្នកអាចផ្លាស់ទីវាទៅកន្លែងដែលត្រូវទុកដាក់សាកសពរបស់វាបាន នោះកាន់តែងាយស្រួល ឬការពារកាន់តែបានល្អជាងមុន ក្នុងការប្រឆាំងនឹងការឆ្លងមេរោគនាពេលអនាគត។
- បើសត្វដំរីនោះនឹងត្រូវស្លាប់ ប្រសិនបើអាចធ្វើទៅបាន គួរតែដុតសាកសពវាចោលព្រមទាំងចំណីអាហារ លាមក គ្រឿងដែលបានប្រើប្រាស់ជាមួយសត្វដំរីដែលបានស្លាប់ដោយសារជម្ងឺនោះជាដើម។ ប្រសិនបើមិនអាចដុតសាកសពវា

បានទេ ត្រូវតែកប់វាក្នុងរណ្តៅជ្រៅមួយ ហើយត្រូវបាចកំបោរលើខ្មោចរបស់ដំរីនោះ មុនពេលចាក់ដីលប់រណ្តៅទៅវិញ។ (សូមមើលទំព័រទី ៨២)។

- ប្រសិនបើសត្វដំរីនោះនឹងត្រូវស្លាប់ អ្នកជំនាញបានផ្តល់អនុសាសន៍ថា មិនត្រូវដកយកក្តុកដំរីឈើនោះចេញទេ ប៉ុន្តែផ្ទុយទៅវិញត្រូវកប់ ឬដុតជាមួយសត្វដំរីស្លាប់។ រាល់ការដកយកក្តុកចេញពីដំរីស្លាប់ ដោយមិនបានសម្លាប់មេរោគនៅលើក្បាលនៅលើក្តុកទេ កម្មករដែលធ្វើការនៅទីនោះ និងឧបករណ៍របស់ពួកគេអាចមានឆ្លងមេរោគ និងអាចធ្វើឲ្យមនុស្សស្លាប់បាន។
- នៅពេលកំពុងវះយកសាច់ (ឬពេលទុកដាក់សពដំរី) របស់ដំរីណា ដែលបានស្លាប់ដោយសារមូលហេតុមិនច្បាស់លាស់ ប្រសិនបើអ្នកឃើញសាច់ និងឈាមរបស់ដំរីនោះមានពណ៌ស្វាយ ឬពណ៌ក្រហមខ្មៅខ្លាំង (មិនមែនពណ៌ក្រហមភ្លឺ) សូមបញ្ឈប់ការងាររបស់អ្នកជាបន្ទាន់ និងទៅពិគ្រោះជាមួយពេទ្យសត្វ។ ឈាមពណ៌ស្វាយ ឬក្រហមខ្មៅ គឺជាសញ្ញាមួយនៃរោគ anthrax នេះហើយ។

**ជម្ងឺរលាកឈាម** ( Haemorrhagic septicaemia: Pasteurellosis )

ជម្ងឺរលាកឈាមប្រភេទនេះ គឺជាជម្ងឺឆ្លងដ៏កាចសាហាវ និងមានអត្រាស្លាប់ខ្ពស់ណាស់។ ជម្ងឺនេះងាយនឹងធ្វើឲ្យច្រឡំគ្នាជាមួយជម្ងឺ anthrax ណាស់ ព្រោះរោគសញ្ញារបស់ជម្ងឺទាំងពីរប្រភេទនេះ មានលក្ខណៈប្រហាក់ប្រហែលគ្នា ហើយដោយសារតែវាដូចគ្នាបែបនេះហើយ ទើបមានករណីរងគ្រោះស្លាប់ច្រើន ដោយមិនបានព្យាបាលត្រឹមត្រូវនិងទាន់ពេលវេលា។ ជម្ងឺនេះអាចឆ្លងចូលទៅក្នុងហ្វូងដំរីយ៉ាងលឿន គឺក្នុងក្នុងរយៈពេលតែប្រហែលពី ១០ ទៅ ១៥ ថ្ងៃ។ ជាទូទៅសត្វដំរីដែលមានជម្ងឺនេះនឹងត្រូវស្លាប់តែក្នុងរយៈពេលពី ៣ ទៅ ៣៦ ម៉ោង ប៉ុន្តែមានសត្វខ្លះអាចទ្រាំបានរហូតដល់រយៈពេល ១៥ ថ្ងៃ។

របៀបឆ្លង៖

- ដំរីច្រើនតែចម្លងជម្ងឺនេះមកពីពួកគោ និងក្របី។
- ជម្ងឺនេះច្រើនកើតមាននៅក្នុងតំបន់ទំនាបលិចទឹក និងនៅពេលផ្លាស់ប្តូររដូវ។
- ការបង្ករោគកើតឡើងតាមរយៈការផឹកទឹកដែលមានជាតិកខ្វក់ ឬនៅពេលសត្វដំរីស៊ីចំណីអាហារណាដែលមិនស្អាត ឬស្រូបយកដំណក់ទឹកដែលមានមេរោគ

ជាទូទៅ កាលណាសត្វដំរីរស់នៅជាមួយគោ និងជាពិសេសក្របី។

- សត្វដំរី ជាពិសេសដំរីពេញវ័យ ជាធម្មតាតែងមានបាក់តេរីខ្លះៗ នៅក្នុងខ្លួនរបស់ពួកវាគ្រប់ពេល ដោយមិនធ្វើឲ្យប៉ះពាល់ដល់សុខភាពវាឡើយ។ ពេលស្ត្រេសច្រើនតែជាកត្តាដែលនាំឲ្យកើតជម្ងឺនេះ។ នៅពេលដំរីចុះខ្សោយ ឬខ្វះអាហារូបត្ថម្ភ ឬធ្វើការហួសកំលាំងពេល អាកាសធាតុ ឬរបបអាហារផ្លាស់ប្តូរ ឬដំរីត្រូវបានដឹកជញ្ជូនតាមរថយន្តជាដើម បាក់តេរីអាចនឹងផ្ទុះឡើងយ៉ាងឆាប់រហ័សដែលបណ្តាលឲ្យមានការឆ្លងរោគ ជាពិសេសកូនដំរីវ័យក្មេង ដែលទើបតែផ្តាច់ដោះ និងមិនទាន់មានប្រព័ន្ធភាពស៊ាំខ្លាំង។

រោគសញ្ញា៖

- គ្រុនក្តៅខ្លាំង។ វាស់សីតុណ្ហភាពដំរីឲ្យបានទៀងទាត់។ (សូមមើលទំព័រទី ១០៤) ប្រសិនបើវាលើសពី ៣៧,៨ អង្សាសេ ឬ ១០០° Fនោះគឺជាសញ្ញាគ្រោះថ្នាក់។
- ខ្យល់ដង្ហើមចេញពីមាត់និងប្រមោយគឺក្តៅណាស់។
- មានពណ៌ក្រហមភ្លឺនៅលើភ្នែក មាត់ ចុងប្រមោយ និងជាលិកាទន់ផ្សេងៗទៀត។
- មានហើមនៅលើផ្នែកមួយចំនួននៃរាងកាយ ដូចជាបំពង់ក គល់កន្ទុយ រន្ធគូថ នៅលើពោះក្រោមជើង។
- សត្វដំរីមានសភាពល្ហិតល្ហៃ ប្រមោយរបស់វាដាក់ផ្ទាល់លើដី ហើយត្រចៀកក៏មិនបក់ដែរ។
- ដំរីក៏លែងស៊ីចំណីអាហារដូចមុនទៀតដែរ។
- ជាញឹកញាប់ដំរីហារមាត់ "ស្វាប"។
- រាងកាយរបស់ដំរីញាប់ញ័រ និងមានចង្វាក់បេះដូងញាប់ ព្រោះដង្ហើមពិបាក។
- ទឹកនោមមានពណ៌សស្រអាប់ និងមានច្រើនពណ៌។

ការព្យាបាល៖

- ពិគ្រោះជាមួយពេទ្យសត្វជាបន្ទាន់ ដើម្បីព្យាបាលសត្វដែលមានផ្ទុកមេរោគ និងរៀបចំផែនការការពារសត្វដំរី ដែលនៅក្បែរនោះផ្សេងៗទៀត។ ញែកដំរីដែលឆ្លងមេរោគនេះជាបន្ទាន់ ហើយរក្សាវាឲ្យនៅឆ្ងាយពីសត្វផ្សេងៗទៀត។

- *យកដំរីធ្ងន់រោគទៅកន្លែងស្អាត ស្ងប់ស្ងាត់ និងមានម្លប់ ដែលងាយសម្អាត ហើយដាក់កន្លែងដែលទឹកនោម និងកាកសំណល់ផ្សេងៗ ដូចជាលាមក និងអាហារសេសសល់មិនស្អាត មិនអាចបំពុលទៅដល់កន្លែងផ្សេងទៀត។*
- *សំខាន់បំផុតត្រូវប្រាកដថាប្រភពទឹកសម្រាប់សត្វឈឺ និងសត្វមានសុខភាពល្អ ត្រូវតែដាច់ដោយឡែកពីគ្នា។ ប្រសិនបើមានប្រភពទឹកផឹកតែមួយ នោះវានឹងអាចធ្វើឲ្យជម្ងឺរីករាលដាលបាន។ បើដូច្នេះសូមព្យាយាមនាំសត្វ ដែលមានសុខភាពល្អទៅរកប្រភពទឹកថ្មី។ អ្នកប្រហែលជាត្រូវដឹកទឹកចូល ប៉ុន្តែអ្នកត្រូវធានាថាសត្វរបស់អ្នកកំពុងផឹកទឹកសុទ្ធដោយគ្មានការឆ្លងមេរោគ។*
- *ត្រូវប្រាកដថាគ្មានហ្វូងដំរី ឬមនុស្សផ្សេងទៀត ដែលបានប៉ះពាល់ដំរីឈឺ មកមានទំនាក់ទំនងជាមួយសត្វដំរីដែលមានសុខភាពល្អ។*
- *ដំរីមានសុខភាពល្អ គួរតែយកពួកវាទៅកន្លែងផ្សេងទៀត ដែលពួកវាមិនអាចប៉ះលាមក ទឹកនោម ឬអាហារដែលនៅសេសសល់ពីសត្វដំរីដែលមានជម្ងឺឆ្លង។*
- *ផ្តល់ចំណីអាហារដល់ដំរីនូវចំណីអាហារណាដែលមានជីវជាតិខ្ពស់ ដូចជាចេក ស្រូវ អំពៅ និងស្មៅស្រស់។*
- *នៅពេលមានសត្វដំរីណាមួយស្លាប់ដោយសារជម្ងឺនេះ ត្រូវតែកប់ ឬដុតសាកសពរបស់វាចោល។ មិនត្រូវយកសាច់ដំរីប្រភេទនេះទៅប្រើ ឬក៏យកភ្លុករបស់វាទេ ព្រោះទង្វើបែបនេះ អាចធ្វើឲ្យជម្ងឺរីករាលដាលដល់សត្វដំរី និងដទៃទៀត។*

*ការបង្ការះ គេអាចបង្ការជម្ងឺនេះបាន ដោយការចាក់វ៉ាក់សាំង ដែលមានមានប្រសិទ្ធិភាពល្អសម្រាប់រយៈពេលមួយឆ្នាំ។ ប៉ុន្តែវ៉ាក់សាំងនេះច្រើនតែបណ្តាលឲ្យតំបន់ជុំវិញចាក់ថ្នាំមានប្រតិកម្ម (អាលែហ្សី) និងហើមអស់រយៈពេលបី ឬបួនថ្ងៃ។ ការហើមនេះអាចព្យាបាលដោយការស្អំទឹកក្តៅ និងទឹកកក។*

## ជម្ងឺតេតាណូស

*ជម្ងឺតេតាណូសបណ្តាលមកពីបាក់តេរី ដែលមានអាយុកាលវែង ហើយដែលត្រូវបានគេរកឃើញនៅក្នុងដី និងក្នុងតំបន់ដែលមានសំណើម។ តេតាណូសច្រើនកើតមានចំពោះសត្វដំរី ដែលបានរងរបួសជ្រៅ ជាទូទៅនៅលើជើង និងជាពិសេសនៅលើប្រអប់*

ដើងដែលបានមុតវត្ថុស្រួចធ្វើពីលោហៈមានច្រែះ ដូចជាដែកគោលចាស់ៗ បន្ទាប់ពីបាក់តេរីបានចូលទៅក្នុងខ្លួនរបស់សត្វដំរីហើយ ពួកវាលូតលាស់ ហើយបន្ទាប់ពីរយៈពេលនៃការក្រាស់ពងរបស់វារយៈពេលពី ១៥ ទៅ ២០ ថ្ងៃ មេរោគនោះចាប់ផ្ដើមផលិតសារជាតុពុល ដែលបំផ្លាញប្រព័ន្ធសរសៃប្រសាទ និងបណ្ដាលអោយសាច់ដុំឡើងរឹង។

នៅចន្លោះឆ្នាំ ១៩៧៧ និង ១៩៩២ ប្រទេសថៃបានឆ្លងកាត់បទពិសោធន៍យ៉ាងច្រើន ចោរបានលបលួចកាត់យកភ្លុកដំរីទៅលក់។ លទ្ធផល គឺដំរីដែលធ្លាប់មានភ្លុកជាច្រើនបានឆ្លងជម្ងឺតេតាណូស ហើយបានស្លាប់។

*របៀបឆ្លង៖* ការឆ្លងជម្ងឺនេះ គឺបណ្ដាលពីដើរជាន់មុតដែក ឬវត្ថុដែលមានជាតិកខ្វក់ផ្សេងៗទៀត ដែលបានបណ្ដាលឲ្យមានស្នាមរបួសជ្រៅ។ ទោះយ៉ាងណា ជាមួយនឹងសត្វដំរី មុខរបួសប្រហែលជាគេមិនបានដឹងច្បាស់នោះទេ ព្រោះដំរីអាចនឹងប្រើតែប្រមោយរបស់វា ដើម្បីប្រមូលយកដី (ដែលអាចមានមេរោគ) ទៅបាចលើស្នាមរបួស ឬទៅលើភ្លុក ដែលគេបានកាត់យកទៅបាត់ហើយនោះផងដែរ។ នៅពេលដែលមេរោគតេតាណូសបានចូលដល់ក្នុងប្រហោងភ្លុករបស់សត្វដំរី វារមែងតែរីកពលដាលយ៉ាងលឿន ព្រោះវាអាចរីកលូតលាស់ធំធាត់នៅក្នុងបរិស្ថានដែលគ្មានអុកស៊ីសែន។

ជាការពិតណាស់ស្នាមរបួសទាំងអស់ត្រូវតែសម្អាតយ៉ាងប្រុងប្រយ័ត្ន ប៉ុន្តែត្រូវប្រុងប្រយ័ត្នជាពិសេសត្រង់កន្លែងដែលបានមុតដែកគោល ឬដែកចាស់ៗមានច្រែះ ជាពិសេសនៅតំបន់មួយ ដែលធ្លាម់មានសត្វជាច្រើនរស់នៅ។ បន្ទាប់ពីឆ្លងមេរោគហើយ ជម្ងឺមិនកើតឡើងយ៉ាងឆាប់រហ័សទេ ហើយដំរីនឹងមានសភាពធម្មតាក្នុងរយៈពេលពី ១៥ ទៅ ២០ ថ្ងៃ (ជួនកាលអាចយូរជាងនេះ) មុនពេលរោគសញ្ញាលេចឡើង។ ទោះបីជាដំរីទទួលបានការព្យាបាលក៏ដោយ ក៏អត្រានៃការរស់រានមានជីវិតនៅទាបណាស់។

*រោគសញ្ញា៖*

- *ដំរីច្រើនតែមានសីតុណ្ហភាពលើសពី ៣៧,៨ អង្សាសេ ឬ ១០០ អង្សាហ្វារិនហៃ បើទោះបីជាវាមិនប្រាកដក៏ដោយ។ ដង្ហើមនឹងក្ដៅគួរឲ្យកត់សម្គាល់។*
- *ភ្នែកនឹងឡើងពណ៌ក្រហមខ្លាំង ហើយជាលិកាទន់ៗនៅខាងក្នុងមាត់ និងប្រមោយនឹងក្លាយជាពណ៌ក្រហមជាំ។*

- ដំរីមានសភាពល្ហិតល្ហៃ ហើយវាមិនព្រមស៊ីចំណីអាហារ ឬផឹកទឹកទេ។
- មានការប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទ ហើយសាច់ដុំជើងឡើងរឹង សាច់ដុំចាប់ផ្តើមកន្ត្រាក់ កន្ទុយឡើងរមួលដូចពស់។
- មានការកន្ត្រាក់សាច់ដុំម្តងៗ ជាពិសេសនៅពេលដំរីភ្ញាក់ ដោយសារមានសម្លេងខ្លាំងៗ ឬនៅពេលឃើញពន្លឺភ្លឺខ្លាំង។
- នៅថ្ងៃបន្ទាប់ដំរីពិបាកដើរ និងឈរ ដោយសារតែការកន្ត្រាក់នៃសាច់ដុំជើង។
- ថ្គាមរបស់ដំរីឡើងរឹងគាំង ធ្វើឲ្យវាមានការលំបាកក្នុងការទំពារអាហារ។ ការស៊ី និងផឹកក្លាយជាការពិបាកណាស់ ហើយដំរីក៏ស្លាប់។

ការព្យាបាល៖

- ត្រូវទៅពិគ្រោះជាមួយពេទ្យសត្វភ្លាមៗ។
- ទោះបីជាតេតាណូសមិនឆ្លងទៅដំរីដទៃទៀតក៏ដោយ ត្រូវញែកដំរីឈឺនោះចេញពីសត្វដទៃទៀត ព្រោះវានឹងកាន់តែមានសុវត្ថិភាព។
- យកដំរីទៅទីជម្រកដែលមានម្លប់ល្អ ស្អាត ដូចជាមានកម្រាលពីបេតុង (មិនត្រូវឲ្យរអិលទេ) ដើម្បីការពារកុំអោយមានដី ឬវត្ថុមិនស្អាតផ្សេងៗចូលក្នុងមុខរបួស ឬប្រហោងក្នុក។
- ទីកន្លែងនោះគួរតែមានខ្យល់ចេញចូលល្អ។
- ក្នុងករណីប្រហោងក្នុកបើកចំហរ យកល្អត្រូវធ្វើការសម្អាតវាជាមួយទឹកស្អាត។ លាងសម្អាតមុខរបួសទាំងអស់ឲ្យបានហ្មត់ចត់ ជាមួយទឹកស្អាត បន្ទាប់មកលាងជាមួយទឹកថ្នាំសម្លាប់មេរោគដូចជា Betadine ឬ Povidine-iodine ១% លាយគ្នាតាមសមាមាត្រ ២០: ១។ ចុងក្រោយបាចម្សៅប្រឆាំងនឹងសត្វល្អិត ដែលមានរួមបញ្ចូលទាំងថ្នាំអង់ទីប៊ីយោទិច (ថ្នាំផ្សះ) ដូចជាថ្នាំ Negasunt។
- បញ្ចុកចំណីដំរីបន្តិចម្តងៗ ដោយរើសយកអាហារណាដែលមានជីវជាតិខ្ពស់ ដូចជាចេកទុំ បាយដំណើប ល្ពៅទុំ។ ល។ (សូមមើលទំព័រទី ៣៩)។
- សម្អាតមុខរបួសរាល់ថ្ងៃ។

*ការបង្ការ៖ ចំពោះដំរីណាដែលមានដំបៅចំហរ ឬប្រហោងក្លុក ត្រូវការពារដំរីកុំឲ្យឆ្លងជម្ងឺតេតាណូស ដោយត្រូវសម្អាតមុខរបួសជារៀងរាល់ថ្ងៃ និងត្រូវរក្សាដំរីទុកនៅកន្លែងស្អាត។ បើមិនដូច្នោះទេ ដំរីអាចនឹងបាចដី ឬរបស់មិនស្អាតផ្សេងទៀតទៅលើដំបៅរបស់វា ដែលអាចធ្វើឲ្យមេរោគតេតាណូសចូលទៅក្នុងមុខរបួសបាន។*

*មិនទាន់មានវ៉ាក់សាំងតេតាណូសសម្រាប់សត្វដំរីនៅឡើយទេ ប៉ុន្តែប្រសិនបើដំរីដែលមានមុខរបួស ដែលអ្នកសង្ស័យថាមានជម្ងឺតេតាណូស ពេទ្យសត្វអាចចាក់ថ្នាំអង់ទីតុស៊ីន* (antitoxin) *ដើម្បីការពារការឆ្លងជម្ងឺពីបាក់តេរី។*

## ជម្ងឺរបេង

*ជម្ងឺរបេងគឺជាជម្ងឺរ៉ាំរ៉ៃនៃប្រព័ន្ធដង្ហើម ដែលជាធម្មតាវាអាចចូលទៅក្នុងខ្លួនរបស់សត្វដំរីតាមរយៈប្រមោយ បំពង់ខ្យល់ និងសួត។ ជម្ងឺរបេង គឺជាជម្ងឺដែលបណ្តាលមកពីបាក់តេរី* (Mycobacterium spp.) *ដែលអាចឆ្លងទាំងដំរី និងមនុស្ស។ ជម្ងឺរបេង គឺជាជម្ងឺដ៏គ្រោះថ្នាក់មួយ ព្រោះវាអាចចម្លងពីមនុស្សទៅសត្វដំរី ពីដំរីទៅមនុស្ស និងពីដំរីទៅដំរី។ ក្រៅពីមនុស្ស និងដំរី ជម្ងឺរបេងក៏អាចកើតមាននៅលើសត្វស្វា គោ ក្របី សេះនិងសត្វដទៃទៀតផងដែរ។*

*ជម្ងឺរបេងនៅក្នុងសត្វដំរីត្រូវបានគេរាយការណ៍មកថា មានកើតនៅក្នុងប្រទេសថៃ ប៉ុន្តែនៅដំណាក់កាលដំបូង ជម្ងឺនេះមានការលំបាកយ៉ាងខ្លាំង ក្នុងការធ្វើរោគវិនិច្ឆ័យ និងដើម្បីធ្វើការផ្ទៀងផ្ទាត់។ អត្រាឆ្លងខ្ពស់របស់មនុស្ស និងភាពស្និទ្ធស្នាលរបស់ហ្មដំរីជាមួយនឹងដំរី បានបង្ហាញយ៉ាងច្បាស់ថាមានដំរីឆ្លងជម្ងឺរបេងជាច្រើននៅក្នុងប្រទេសថៃ។*

*សព្វថ្ងៃនេះនៅប្រទេសថៃជម្ងឺអេដស៍កំពុងតែរាតត្បាតលើមនុស្ស។ មូលហេតុចំបងនៃការស្លាប់ដែលបណ្តាលមកពីជម្ងឺអេដស៍ ដែលបានធ្វើឲ្យប្រព័ន្ធភាពស៊ាំចុះខ្សោយគឺជាជម្ងឺរបេង ពីព្រោះជម្ងឺរបេង គឺជាជម្ងឺឲ្យកាសនិយម ដែលវាយប្រហារនៅពេលប្រព័ន្ធ*

*ការពាររាងកាយចុះខ្សោយ។ ហេតុដូច្នេះជម្ងឺរបេងចំពោះមនុស្សកំពុងរីករាលដាលនៅក្នុងប្រទេសថៃ ហើយដូច្នេះឲ្យកាស ដែលដំរីឆ្លងជម្ងឺរបេងកំពុងតែកើនឡើង។*

*ជម្ងឺរបេងនៅក្នុងខ្លួនដំរីអាចធ្វើឲ្យអស់ថវិកាច្រើន ហើយពិបាកព្យាបាលណាស់។ ជម្ងឺនេះគឺជាបញ្ហាដ៏លំបាកមួយនៅក្នុងសួនសត្វអ៊ឺរ៉ុប និងអាមេរិក។*

*របៀបឆ្លង៖ ជាធម្មតាបាក់តេរីបានចូលទៅក្នុងខ្លួនដោយផ្ទាល់ តាមរយៈខ្យល់ដែលមានផ្ទុកមេរោគរបេង។ ការចម្លងអាចកើតឡើងតាមរយៈអាហារកខ្វក់ ឬទឹក លាមក ទឹកនោម ទឹកដោះគោ ទឹកកាម និងទឹករំអិលផ្សេងៗទៀតនៃរាងកាយ។*

*រោគសញ្ញា៖*

- *រោគសញ្ញាអាចនឹងមិនទាន់មើលឃើញ រហូតដល់ពេលបន្ទាប់ពី ១ ទៅ ២ ឆ្នាំ ហើយជម្ងឺនេះក៏ចាប់ផ្តើមបង្កើនសកម្មភាពយ៉ាងលឿន។*
- *ដំរីចុះខ្សោយ ហើយមិនអាចធ្វើការបានដូចធម្មតាទេ។*
- *ដំរីបាត់បង់ទម្ងន់ ទោះជាវានៅស៊ីចំណីអាហារដូចធម្មតាក៏ដោយ ក្នុងករណីខ្លះទៀតដំរីស្រកទម្ងន់លឿនណាស់។*
- *ដំរីបាត់បង់ចំណង់អាហារ។*
- *ដំរីក្លាយខ្លួនទៅជាស្គម។*
- *មានទឹករំអិលហូរចេញពីប្រមោយ។*
- *ដង្ហើមមានក្លិនមិនល្អ។*
- *ពេលខ្លះមានការក្អកស្ងួត និងពិបាកដកដង្ហើម។*
- *នៅពេលដែលអ្នកឃើញដំរីមួយឆ្លងជម្ងឺរបេង ដែលមានរូបកាយស្គមស្គាំង ហូរទឹកមាត់ជាបន្តបន្ទាប់ ហើយពេលខ្លះវាក្អកដោយមិនដឹងខ្លួន ហាក់ដូចជាមានអ្វីមួយនៅក្នុងបំពង់កវា ស្ថានភាពបែបនេះច្រើនតែកើតឡើង ប្រហែលប្រាំថ្ងៃនៅមុនពេលសត្វដំរីនោះត្រូវស្លាប់។*

*ការព្យាបាល៖*

- *ពិគ្រោះជាមួយពេទ្យសត្វ ព្រោះមានតែពេទ្យសត្វម្នាក់ទេ ដែលគាត់អាចធ្វើរោគវិនិច្ឆ័យ និងព្យាបាលជម្ងឺនេះបាន។*
- *នៅពេលដែលអ្នកសង្ស័យថាសត្វដំរីមួយអាចមានជម្ងឺរបេង អ្នកត្រូវតែញែកដំរីដែលសង្ស័យនោះចេញពីសត្វដំរីដទៃទៀត។*
- *ពិគ្រោះជាមួយពេទ្យសត្វដែលធ្លាប់ស្គាល់ជម្ងឺនេះ។ គាត់នឹងធ្វើការលាងសម្អាតដើម្បីប្រមូលគំរូយកទៅធ្វើរោគវិនិច្ឆ័យឲ្យបានត្រឹមត្រូវ។ ដាក់ដំរីនៅកន្លែងដែល*

*មានម្ប់ល្អ ឬនៅកន្លែងដែលឆាយលាងសម្អាត ដោយមានប្រព័ន្ធបង្ហូរទឹកស្អុយឲ្យបានត្រឹមត្រូវ។*

- *ផ្គត់ផ្គង់ឲ្យសត្វដំរីនូវចំណីអាហារ ដែលមានជីវជាតិខ្ពស់ តាមដែលវាចង់បាន។*
- *ផ្គត់ផ្គង់ទឹកស្អាតអោយបានច្រើន។*

*ការបង្ការ៖ ត្រួតពិនិត្យសុខភាពជារៀងរាល់ឆ្នាំ រួមមានការស្ទីអុិចលើទ្រូងរបស់ហ្មដំរីទាំងអស់ដែលមើលថែទាំដំរី និងអ្នកដែលពាក់ព័ន្ធផ្សេងទៀត។ ប្រសិនបើរកឃើញអ្នកដែលមានជម្ងឺរបេង សូមផ្តល់ការព្យាបាល និងការពារកុំឲ្យមនុស្សទាំងនោះ មានការទាក់ទងប៉ះពាល់សត្វដំរី រហូតដល់ស្ថានភាពជម្ងឺរបស់អ្នកទាំងនោះបានជាសះស្បើយ។ អ្នកគ្រប់គ្រងមជ្ឈមណ្ឌលនៃទីតាំងធំៗ ត្រូវប្រុងប្រយ័ត្នជាពិសេស ក្នុងការអនុវត្តតាមវិធីនេះ ព្រោះថាវាអាចនឹងបង្កនូវការឡំបាកស្មុគ្រស្មាញ និងចំណាយថវិកាច្រើន ប៉ុន្តែបើអ្នកចាត់វិធានការបង្ការជាមុន អ្នកនឹងគ្មានបញ្ហា និងចំណាយថវិកាតិចជាង ប្រសិនបើជម្ងឺរបេងត្រូវផ្ទុះឡើងនៅក្នុងមជ្ឈមណ្ឌលរបស់អ្នក។*

**វីរុស** Herpes

*វីរុស* Herpes *មានប្រវត្តិនៅក្នុងដំរីអាហ្វ្រិក ជាកន្លែងដែលគេបានរកឃើញវានៅក្នុងសួត ក្នុងជាលិការលួយ។ ជម្ងឺនេះត្រូវបានរកឃើញជាទូទៅនៅក្នុងដំរី ដែលត្រូវបានរក្សាទុកនៅក្នុងកន្លែងមិនសូវមានចរន្តខ្យល់ចេញចូល។ នៅឯសួនសត្វនៃបណ្តាប្រទេសលោកខាងលិចវិញ វីរុសនេះត្រូវបានគេរកឃើញ ទាំងនៅលើដំរីអាហ្វ្រិក និងដំរីអាស៊ី។ សត្វដំរីវ័យក្មេងៗងាយនឹងទទួលរងគ្រោះថ្នាក់ជាងគេ។*

*វីរុស* Herpes *មិនទាន់ត្រូវបានគេរាយការណ៍ថាមានវត្តមាននៅក្នុងប្រទេសថៃទេ។ ក្នុងករណីជាច្រើនរោគសញ្ញាមិនច្បាស់ទេ ដូច្នេះការធ្វើរោគវិនិច្ឆ័យគឺមានតែពេទ្យសត្វទេ ដែលត្រូវយកសំណាកទៅធ្វើតេស្តនៅក្នុងមន្ទីរពិសោធន៍ដ៏ធំមួយ ទើបអាចដឹងរោគសញ្ញាច្បាស់លាស់បាន។ នៅក្នុងសត្វដំរីមួយចំនួន ជាពិសេសកូនៗដំរី អណ្តាត មាត់ និងផ្នែកខាងក្នុងនៃចុងប្រមោយនឹងមានពណ៌ខៀវស្វេក។*

*រោគសញ្ញាអាចនឹងលេចចេញឡើង នៅពេលសត្វដំរីស្ថិតក្នុងស្ថានភាពខ្សោយ ឬប្រព័ន្ធភាពស៊ាំរបស់ពួកវាធ្លាក់ចុះទាប ដែលនាំឲ្យមានការឆ្លងមេរោគបន្ទាប់បន្សំផ្សេងៗទៀត ដូចជាជម្ងឺផ្លូវដង្ហើមជាដើម។*

## ជម្ងឺប្រអប់ជើងនិងមាត់

*ជម្ងឺប្រអប់ជើង និងមាត់គឺជាជម្ងឺឆ្លងដ៏សំខាន់មួយចំពោះសត្វចិញ្ចឹម។ ជម្ងឺឆ្លងខ្លាំងនេះច្រើនតែកើតមាននៅលើសត្វគោ ក្របី និងជ្រូក។ នៅក្នុងប្រទេសថៃជម្ងឺប្រអប់ជើងនិងមាត់គឺជាមេរោគ ដែលកើតមាននៅលើសត្វដំរី តាមរយៈការទាក់ទងជាមួយសត្វគោនិងក្របី ដែលមានមេរោគនោះ។ ជម្ងឺនេះមិនសូវកើតមានជាទូទៅនៅលើសត្វដំរីទេ។*

*បសុសត្វដែលឆ្លងជម្ងឺបាតជើង និងមាត់ត្រូវបានគេកំទេចចោល ប៉ុន្តែដោយសារសត្វដំរីត្រូវបានគេចាត់ទុកថាមានសារៈសំខាន់ខ្លាំងណាស់ និងជាពិសេសខាងជំនឿនៅក្នុងវប្បធម៌ថៃ ទើបគេមិនកំទេចសត្វដំរីដែលមានជម្ងឺបែបនេះចោលឡើយ។*

*របៀបឆ្លង៖*

- *ជម្ងឺអាចកើតមកពីការស្រូបយកវីរុស ដែលអាចមាននៅក្នុងខ្យល់។*
- *ការបង្ករោគអាចមកពីការទាក់ទងដោយផ្ទាល់ ជាមួយដំបៅរបស់សត្វដទៃទៀតនិងទឹករំអិលនៃរាងកាយ។*
- *វីរុសជម្ងឺប្រអប់ជើង និងមាត់ក៏ត្រូវបានគេរកឃើញផងដែរ នៅក្នុងទឹកនោម ទឹកដោះ ទឹកមាត់ និងសូម្បីតែនៅក្នុងឈាម ឆ្អឹង សាច់សត្វចិញ្ចឹមដែលឆ្លងជម្ងឺ។*
- *ការឆ្លងជម្ងឺអាចកើតចេញពីអាហារ និងទឹកដែលមានមេរោគឆ្លង។*
- *បន្ទាប់ពីឆ្លងវីរុសចូលទៅក្នុងខ្លួនរួចហើយ វីរុសនោះក៏ចាប់ផ្តើមបង្កជម្ងឺរយៈពេល ២ ទៅ ៥ ថ្ងៃមុនពេលមានរោគសញ្ញា។*

*រោគសញ្ញា៖*

- *មានគ្រុនក្តៅខ្លួនតិចៗ។*
- *ល្ហិតល្ហៃ សោះអង្គើយ។*

- មាត់ដំរីមានពងបែក ដែលដំបូងមានពណ៌ស និងតូចៗ តែក្រោយមកក៏រីកធំ។ ប្រអប់ជើងក៏មានពងបែក ដែលប្រែទៅជាដំបៅ ធ្វើឲ្យដំរីពិបាកស៊ីចំណីអាហារ និងដើរ។
- ពេលខ្លះនៅលើលិង្គ (Limping) បង្ហាញពីសូចនាករដំបូងនៃជម្ងឺនេះ ហើយពេលខ្លះប្រអប់ជើងនឹងមានរបបស្បែក។
- សត្វដំរីបញ្ចេញទឹកមាត់យ៉ាងខ្លាំង ហើយច្រើនតែមើលទៅដូចជាវិលមុខ។
- ដំរីបាត់បង់ចំណង់អាហារ។

*ការព្យាបាល៖*

- ញែកសត្វដែលឆ្លងជម្ងឺចេញពីដំរីផ្សេងទៀតភ្លាមៗ។
- យកដំរីដែលឆ្លងទៅកន្លែងដែលមានម្លប់ល្អ ស្អាត និងស្ងាត់។
- ឲ្យដំរីស៊ីតែចំណីអាហារទន់ៗ មានជីវជាតិខ្ពស់ និងងាយរំលាយ ដូចជាចេកទុំ។
- ត្រូវតាមដានពិនិត្យមើលដោយប្រុងប្រយ័ត្ន ចំពោះសត្វដែលមិនឆ្លងទាំងអស់នៅក្នុងហ្វូង។
- ការពារកុំឲ្យហ្មដំរីទាំងអស់ ដែលមានទំនាក់ទំនងជាមួយសត្វឈឺ ទៅមានការទាក់ទងជាមួយសត្វដំរីផ្សេងទៀត (ឬសត្វចិញ្ចឹមផ្សេងៗទៀត) មុនពេលពួកគាត់បានទៅងូតទឹកសម្អាតខ្លួន និងផ្លាស់សម្លៀកបំពាក់ថ្មី។
- ពិគ្រោះយោបល់ជាបន្ទាន់ជាមួយពេទ្យសត្វ ដើម្បីព្យាបាលសត្វឈឺ និងពិចារណាលើការចាក់វ៉ាក់សាំងសត្វដំរី ដែលមិនទាន់មានឆ្លងនៅក្នុងហ្វូង។
- ហ្មដំរីត្រូវតែប្រយ័ត្នប្រយែងបំផុត ចំពោះដំរីដែលមាន FMD លៃយ៉ាងណាកុំឲ្យពួកវាមានឆ្លងជម្ងឺបន្ទាប់បន្សំបន្ថែម ដែលពួកវាងាយរងគ្រោះបំផុត។
- ការព្យាបាលដំរីដែលរងទុក្ខដោយជម្ងឺបាតជើង និងមាត់ត្រូវការប្រើពេលច្រើនខែទើបចប់ ហើយការជាសះស្បើយជាធម្មតាយឺត ពីព្រោះជាទូទៅនៅក្នុងប្រទេសថៃមិនមានអនាម័យ និងសត្វដែមានជម្ងឺ FMD ងាយនឹងឆ្លងជម្ងឺបន្ទាប់បន្សំផ្សេងៗទៀត។

*ការបង្ការ៖*

- *ជម្ងឺប្រអប់ជើងនិងមាត់អាចត្រូវបានការពារ ដោយការចាក់វ៉ាក់សាំងការពារសត្វគោ ក្របី ពពែ និងជ្រូកដែលចិញ្ចឹមនៅជិតដំរី។ ការចាក់វ៉ាក់សាំងសត្វទាំងនេះមានភាពងាយស្រួល និងងាយស្រួលជាងការចាក់វ៉ាក់សាំងឲ្យសត្វដំរី ពីព្រោះបច្ចុប្បន្ននេះមិនទាន់មានវ៉ាក់សាំងពិសេសសម្រាប់សត្វដំរីទេ។*
- *ប្រសិនបើត្រូវទៅធ្វើការនៅតាមតំបន់ព្រំដែន ដែលដំរី និងបសុសត្វមកពីប្រទេសមីយ៉ាន់ម៉ា (ភូមា) ឡាវ និងកម្ពុជា ត្រូវប្រុងប្រយ័ត្នខ្ពស់ ដោយមិនត្រូវឲ្យសត្វដំរីទាក់ទងជាមួយសត្វចិញ្ចឹម ដែលយើងមិនច្បាស់ថាតើសត្វទាំងនោះបានចាក់វ៉ាក់សាំងប្រឆាំងនឹងជម្ងឺប្រអប់ជើង និងមាត់ដែរ ឬអត់។*
- *ត្រូវទៅពិគ្រោះយោបល់ជាមួយបសុពេទ្យរបស់មន្ទីរបសុព្យាបាលស្រុកអំពីវត្តមាននៃជម្ងឺនេះ មុនពេលទៅធ្វើការនៅតំបន់ព្រំដែនណាមួយ។*

**ជម្ងឺអុតដំរី** (pox)

*អុតដំរីគឺជាជម្ងឺឆ្លងដ៏ធ្ងន់ធ្ងរ ដែលធ្លាប់មានប្រវត្តិឆ្លងរាលដាលយ៉ាងខ្លាំង។ (ដំរី ១៨ ក្បាលនៅក្នុងក្រុមសៀកអឺរ៉ុប មាន ១១ ក្បាលបានឆ្លងជម្ងឺនេះ ហើយដំរីមួយក្បាលបានស្លាប់។) ជម្ងឺអុតដំរីនេះទាក់ទងទៅនឹងជម្ងឺអុតតូចរបស់មនុស្ស ហើយអាចចម្លងបានដោយមនុស្ស។ ដំរីអាស៊ីងាយនឹងឆ្លងវីរុសអុតដំរីនេះច្រើនជាងដំរីអាហ្វ្រិក។*

*ពពួកសត្វព្រៃ សត្វកកេរត្រូវបានគេសង្ស័យថាជាអាងស្តុកនៃវីរុសអុតដំរី។ វាហាក់ដូចជាមិនដែលមានករណីកើតជម្ងឺអុតដំរីនេះ នៅក្នុងប្រទេសថៃទេ ប៉ុន្តែជម្ងឺនេះត្រូវបានគេរាយការណ៍ថាធ្លាប់កើតមាន នៅក្នុងប្រទេសមីយ៉ាន់ម៉ា។*

*របៀបឆ្លង៖ សត្វដំរីអាចឆ្លងជម្ងឺអុតនេះ ទាំងមកពីសត្វដំរីគ្នាវា និងមកពីមនុស្សតាមរយៈការប៉ះពាល់ដោយផ្ទាល់ជាមួយដំបៅ ឬទឹករំអិលរបស់ដំរីដែលមានជម្ងឺនេះ។*

*រោគសញ្ញា៖*

- *រោគសញ្ញាដំបូងរបស់ជម្ងឺអុតដំរីពិបាកនឹងមើលឃើញណាស់។*
- *អាចមានជម្ងឺគ្រុនក្តៅខ្លាំង។*
- *ដំរីអាចនឹងក្លាយទៅជាខ្វិន។*

- *ភ្នាសភ្នែករបស់ដំរីមានរលាក និងឡើងហើម។*
- *ក្រោយមកសត្វដំរីនោះមានចេញពងខ្ទុះនៅលើស្បែក ផ្នែកខាងមុខ ក្បាល និងនៅលើប្រមោយ។ ពងខ្ទុះទាំងនេះអាចរាលដាលពាសពេញរាងកាយ។ ពងខ្ទុះទាំងនោះអាចបែក និងបញ្ចេញអង្គធាតុរាវថ្លា ឬមានឈាម។ ក្រោយមកទៀតវាប្រែទៅជាស្ងួត និងឡើងពណ៌ក្រម៉ៅ ហើយចុងក្រោយមានស្នាមខ្មៅជាប់ជារៀងរហូត។*
- *មានទឹករងៃហូរជ្រាបចេញពីក្រពេញប្រដាប់ភេទ គឺជាអង្គធាតុរាវដែលមានពណ៌ថ្លា ឬពណ៌ទឹកដោះគោ។ សារធាតុរាវនេះមានក្លិនស្អុយរលួយ គឺវាមិនដូចជាក្លិនធម្មតារបស់ដំរីចុះប្រេងនោះទេ។*
- *មាត់របស់ដំរីក៏មានដំបៅ ដែលធ្វើឲ្យវាពិបាកលេបចំណីអាហារ។*
- *ផលវិបាកបន្ទាប់បន្សំដ៏ធ្ងន់ធ្ងរនៃជម្ងឺអុតដំរី គឺវាបានធ្វើឲ្យខូចក្រចក និងបាតជើងដែលអាចបង្កឲ្យមានផលវិបាកខ្លាំងដល់អាយុជីវិតរបស់សត្វដំរី។*

*ការព្យាបាលៈ*

- *ញែកដំរីចេញពីសត្វដទៃទៀត ដែលមាននៅក្នុងហ្វូង។*
- *យកដំរីទៅកន្លែងដែលមានម្លប់ល្អ ស្អាត និងស្ងប់ស្ងាត់។*
- *ផ្តល់ឲ្យដំរីនូវចំណីអាហារណា ដែលមានជីវជាតិខ្ពស់ ងាយលេបចូល ដូចជាចេកទុំ ឬផ្លែឈើស្រស់ផ្សេងៗទៀត។*
- *ហ្មដំរីដែលមានទំនាក់ទំនងជាមួយដំរី ត្រូវតែងូតទឹក និងផ្លាស់ប្តូរសម្លៀកបំពាក់ថ្មីមុនពេលទៅប៉ះពាល់សត្វដំរីដែលគ្មានជម្ងឺ។*
- *ទាក់ទងពេទ្យសត្វភ្លាមៗ។*

**ជម្ងឺឆ្កែឆ្កួត**

*ជម្ងឺឆ្កែឆ្កួត គឺជាជម្ងឺដែលបង្កឡើងដោយវីរុស តាមរយៈការខាំដោយសត្វដែលបានឆ្លងជម្ងឺនេះ នៅក្នុងប្រទេសថៃភាគច្រើនគឺជាសត្វឆ្កែ។ បន្ទាប់មកវីរុសនេះនឹងចូលនៅក្នុងខ្លួនដំរីមួយ ដែលមានរយៈពេលរហូតដល់ ៣០ ថ្ងៃ អាស្រ័យទៅលើភាពធ្ងន់ធ្ងរនៃមុខរបួស ដែលសត្វបានខាំ។ បន្ទាប់ពីការក្មោចមេរោគ នឹងរកឃើញផ្លូវសរសៃប្រសាទខួរឆ្អឹង*

ខ្នងនិងខួរក្បាល។ ពល់សត្វដំរីដែលមានកើតជម្ងឺឆ្កែឆ្កួតស្ទើរតែទាំងអស់ បានក្លាយទៅជាខ្ញិន ហើយបន្ទាប់មកវាក៏ស្លាប់។

គ្រប់ពេលដែលដំរីមួយក្បាល ត្រូវបានសត្វអ្វីមួយខាំ ជាពិសេសប្រសិនបើការខាំនោះនាំឲ្យមានឈាមហូរ ហ្មដំរី និងម្ចាស់ដំរីត្រូវតែធ្វើសកម្មភាព ៤ យ៉ាង។ ដំបូងសរសេរថ្ងៃគ្រោះថ្នាក់នោះនៅលើប្រតិទិន បន្ទាប់មកអ្នកនឹងអាចគិតមើលបានថាពេលណា ដំរីអាចនឹងបង្ហាញរោគសញ្ញា ប្រសិនបើវាបានឆ្លងជម្ងឺនោះមែន។ ទីពីរពិភាក្សាជាមួយមនុស្សដែលស្គាល់ឆ្កែ ហើយសួរអំពីឥរិយាបថរបស់វា នៅប៉ុន្មានថ្ងៃមុនការវាយប្រហារនោះ។ ប្រសិនបើឆ្កែបានធ្វើសកម្មភាពចម្លែកៗ (សម្លឹងមើលទៅមុខស្ញឹមមិនដាក់ភ្នែក បែកពពុះមាត់។ល។) ភាគច្រើនវាគឺជាឆ្កែឆ្កួត។ ទី ៣ ជូនដំណឹងដល់អ្នកពល់គ្នានៅក្នុងសហគមន៍អំពីគ្រោះថ្នាក់ដល់សុខភាព ព្រោះជម្ងឺនេះក៏វាយប្រហារមនុស្សផងដែរ ហើយសុំឲ្យពួកគេជួយតាមដានឆ្កែនេះផង។ ទី ៤ ត្រូវចាប់យកឆ្កែនោះ ដោយប្រុងប្រយ័ត្នបំផុត យកឆ្កែនោះមកឃាំងទុកដោយសុវត្ថិភាព និងសង្កេតមើលស្ថានភាពរបស់វា ប្រសិនបើបន្ទាប់ពីដប់ថ្ងៃវាទៅជារឿងធម្មតាវិញ នោះដំរីមិនមានជម្ងឺឆ្កែឆ្កួតទេ។

រោគសញ្ញា៖

រោគសញ្ញាដំបូងនៃជម្ងឺឆ្កែឆ្កួតនៅលើសត្វដំរី ប្រហែលជាមិនសូវច្បាស់លាស់ទេ ប៉ុន្តែភាគច្រើនដំរី៖

- មានសភាពល្ហិតល្ហៃ។
- ចូលចិត្តនៅកន្លែងងងឹត។
- ស៊ីចំណីអាហារតិចតួចណាស់។

នៅពេលដែលជម្ងឺនេះកាន់តែមានការវិវឌ្ឍដំរី៖

- រមួលខ្លួនដោយការឈឺចាប់។
- លែងស្គាល់ហ្មរបស់វា។
- ដេញនិងវាយប្រហារមនុស្ស និងសត្វដទៃទៀត។
- មានភ្នែកវិលក្រឡាប់ក្រឡើត និងវង្វេង។
- មិនស៊ីចំណីអាហារ។

- ដើរដោយគ្មានលំនឹង ហើយជើងរបស់វាលែងមានកម្លាំង។
- ដេកដួលនៅលើដី ហើយទៅជាខ្វិន។
- ថ្គាមរឹងតាំង ហើយកន្ទុយត្រង់ភ្លឹង។
- មានទឹកមាត់ហូរចេញមកជាបន្តបន្ទាប់។

ការស្លាប់របស់សត្វដំរីអាចនឹងកើតឡើងភ្លាមៗ បន្ទាប់ពីមានលេចចេញនូវរោគសញ្ញាធ្ងន់ធ្ងរទាំងនេះ។ ប្រសិនបើដំរីស្លាប់ ត្រូវពិគ្រោះយោបល់អំពីការរៀបចំទុកដាក់សពរបស់វាឲ្យបានត្រឹមត្រូវ សូមមើលទំព័រទី ៨២។

ការព្យាបាល៖

- ពិគ្រោះយោបល់ជាមួយពេទ្យសត្វភ្លាមៗ។
- មិនមានការព្យាបាលណាមួយ ដែលមានប្រសិទ្ធភាពទេ នៅពេលរោគសញ្ញាបានលេចឡើងរួចហើយ។
- ភ្លាមៗបន្ទាប់ពីសត្វឆ្កែខាំ ត្រូវលាងសម្អាតមុខរបួសឲ្យបានល្អិតល្អន់ជាមួយសាប៊ូ និងទឹក។ បន្ទាប់មកលាបថ្នាំ អ៊ីយ៉ូត tincture ឬ Povidone-iodine ១%។
- ទោះបីជាជម្ងឺនេះមិនឆ្លងទៅដំរីដទៃទៀតក៏ដោយ ក៏ត្រូវតែញែកដំរីឈឺនោះយកទៅកន្លែងដែលមានម្លប់ល្អ ស្អាតនិងស្ងប់ស្ងាត់។
- ត្រូវប្រាកដថាដំរីបានដាក់ច្រវាក់យ៉ាងត្រឹមត្រូវ និងមានសុវត្ថិភាព។

ការបង្ការ៖ ដោយសារជម្ងឺឆ្កែឆ្កួតមិនអាចព្យាបាលបាន ទើបការការពារជាជម្រើសមួយដ៏ល្អបំផុត គឺការលុបបំបាត់សត្វឆ្កែដែលវង្វេងគ្មានម្ចាស់ចេញពីតំបន់នោះ និងត្រូវចាក់វ៉ាក់សាំងឆ្កែ និងឆ្មានៅក្នុងសហគមន៍ជារៀងរាល់ឆ្នាំ។

**ជម្ងឺខ្ទុយដេក** Trypanosomiasis (Surra)

ជម្ងឺនេះកើតមកប៉ារ៉ាស៊ីតដែលមាននៅក្នុងឈាម។ ជម្ងឺនេះអាចឆ្លងទៅសត្វសេះ លា អូដ្ឋ គោ ក្របី ឆ្កែ និងដំរី។ ប៉ុន្តែនៅក្នុងប្រទេសថៃករណីនៃជម្ងឺនេះមិនសូវមានកើតនៅលើសត្វដំរីទេ។

មេរោគនៃជម្ងឺនេះត្រូវបានចម្លងដោយសត្វរុយក្នុងព្រៃ និងរបោម ដែលវាបានទៅជញ្ជក់ឈាមសត្វដែលមានជម្ងឺ ហើយក៏ចម្លងមេរោគទៅឲ្យសត្វដែលមានសុខភាពល្អនៅពេលវាទៅខាំបឺតឈាមសត្វទាំងនោះ។

ជម្ងឺនេះភាគច្រើនកើតនៅលើដំរីណា ដែលបានធ្វើការយ៉ាងខ្លាំង ហើយជាធម្មតានៅរដូវវស្សាគឺនៅពេលដែលមានរុយខាំច្រើន។

រោគសញ្ញា៖

រោគសញ្ញានៃជម្ងឺ Trypanosomiasis នេះពិបាកសង្កេតណាស់។

- មុនពេលដល់ចំណុចដែលរោគសញ្ញាអាចមើលឃើញ រូបរាងរបស់សត្វដំរីនឹងកាន់តែស្គមទៅៗ ហើយបាត់បង់កម្លាំងៗ ផ្នែកខាងក្នុងមាត់ និងផ្នែកខាងក្នុងប្រមោយក្លាយទៅជាស្លេកខ្លាំងណាស់។
- ដំរីនឹងបន្ទឺសម្លេងដែលបង្ហាញពីការឈឺចាប់ បង្ហាញសញ្ញាពីការឈឺក្រពះ និងដកដង្ហើមធំៗ ។ វាមានសភាពស្ពឹកស្រពន់ ល្ហិតល្ហៃ និងងងុយដេក។
- រោមនឹងក្លាយទៅជាក្រញេសក្រញាស និងផុយ។
- ជួនកាលមានការហើមកួនកណ្តុរនៅក្រោមថ្គាម។
- សត្វដែលឆ្លងជម្ងឺនេះហើយ មិនស្លាប់ភ្លាមៗទេ ប៉ុន្តែវាទទួលរងនូវស្ថានភាពពុំរ៉ៃ និងក្លាយទៅជាស្គមស្គាំងកាន់តែខ្លាំងឡើងៗ និងមានសុខភាពខ្សោយ។
- ដំរីអាចនឹងស្លាប់ក្នុងរយៈពេលពី ២ ទៅ ៤ ខែបន្ទាប់ពីបានឆ្លងជម្ងឺនេះហើយ។

ការព្យាបាល៖

- ញែកសត្វដំរីឈឺចេញពីសត្វដទៃទៀតនៅក្នុងហ្វូង យ៉ាងឆាប់រហ័ស។
- យកដំរីទៅកន្លែងដែលមានម្លប់ល្អ ស្ងប់ស្ងាត់ និងស្អាត ឆ្ងាយពីរុយ។
- ពិនិត្យដំរីដទៃទៀតដោយប្រុងប្រយ័ត្ន និងយ៉ាងទៀងទាត់ ។
- ពិគ្រោះជាមួយពេទ្យសត្វ ដើម្បីធ្វើរោគវិនិច្ឆ័យ និងអនុវត្តការព្យាបាល រួមទាំងផែនការដើម្បីថែរក្សាដំរី ដែលមិនមានមេរោគនៅក្បែរនោះឲ្យមានសុខភាពល្អ ឬយ៉ាងហោចណាស់ក៏ត្រូវព្យាបាលពួកវាភ្លាមៗ បន្ទាប់ពីមានលេចចេញរោគសញ្ញា។

***ការបង្ការ៖*** *ការបង្ការដ៏ល្អបំផុតនោះ គឺបង្ការកុំឲ្យសត្វរុយខាំដំរីបាន ដោយបាញ់ថ្នាំជាមួយល្បាយឱសថដូចជា* Arsuntol *និង* Neguvon (*សូមមើលទំព័រទី ៩១*)។

*សត្វរុយខាំអាចត្រូវបានកាត់បន្ថយដោយការចោលលាមក និងដីកខ្វក់ដែលជាជម្រកសម្រាប់សត្វរុយទាំងនោះបង្កាត់ពូជបង្កកំណើត*។

# រូបថត



ដំបៅដោយសារការសង្កត់ (ទំព័រ ១៣០)



ដំបៅដោយសារការសង្កត់ (ទំព័រ ១៣០)



ជម្ងឺរលាកភ្នែក (ទំព័រ ១៤៨)



ជម្ងឺភ្នែកឡើងបាយ (ទំព័រ ១៥០)



ដំបៅផ្កា (ទំព័រ ១២៥)



ជម្ងឺផ្សិតលើស្បែកពោះ (ទំព័រ ១៤២)



ជម្ងឺផ្សិត (ទំព័រ ១៤២)



ជម្ងឺផ្សិត (ទំព័រ ១៤២)

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១៖ ការណែនាំដល់ពេទ្យសត្វ

ចំណេះដឹងអំពីបច្ចេកទេស ដែលពេទ្យសត្វប្រើដើម្បីព្យាបាល និងធ្វើរោគវិនិច្ឆ័យជម្ងឺរបស់សត្វមិនខុសគ្នាច្រើនទេ មិនថាឆ្កែ ជ្រូក សេះ គោ ក្របី ឬដំរី គឺដូចគ្នាច្រើន។ ដូច្នេះសូម្បីតែពេទ្យសត្វ ដែលមិនទាន់មានបទពិសោធន៍មើលថែរក្សា និងព្យាបាលសត្វដំរី ក៏នៅតែអាចជួយដំរីបានដែរ ប៉ុន្តែយ៉ាងហោចណាស់ក៏ត្រូវមានការរៀបចំខ្លះៗជាមុនសិន។ មុនពេលព្យាបាលសត្វដំរី អ្នកគួរតែធ្វើការរៀបចំមួយចំនួនដូចខាងក្រោម៖

ពេទ្យសត្វគួរតែប្រមូលព័ត៌មានលម្អិតអំពីទីតាំង និងប្រវត្តិជាក់លាក់របស់សត្វដំរី ដើម្បីរៀបចំផែនការធ្វើដំណើរទៅព្យាបាល និងត្រៀមរៀបចំថ្នាំ និងឧបករណ៍ឲ្យបានត្រឹមត្រូវ។

ពេទ្យសត្វត្រូវរៀបចំថ្នាំ និងឧបករណ៍ឲ្យបានគ្រប់គ្រាន់ ពីព្រោះជាធម្មតាសត្វដំរីនៅឆ្ងាយពីថ្នល់ជាតិ និងទីប្រជុំជន ហើយដើម្បីទៅដល់ទីនោះ អ្នកនឹងត្រូវការដើរពី ៥ ទៅ ១០ គីឡូម៉ែត្រថែមទៀត។ ប្រសិនបើអ្នកមានភ្លេចអ្វីមួយ ដូចជាថ្នាំ និងឧបករណ៍មិនគ្រប់គ្រាន់ នោះអ្នកនឹងខាតបង់ពេលវេលា ហើយអ្នកនឹងទទួលបានលទ្ធផលតិចជាងអ្វីដែលអ្នកបានរំពឹងទុក។

កន្លែងសម្រាប់ព្យាបាលត្រូវតែមានបង្គោលចង ឬដើមឈើ ដើម្បីបន្ថយកម្លាំងរបស់ដំរី។ ទីកន្លែងនោះត្រូវតែរលូន និងរាបស្មើ រឹងល្អ មិនរអិល និងគ្មានប្រហោង ឬថ្មដែលអាចបណ្តាលឲ្យរអិល ឬដួលពេទ្យសត្វ នៅពេលសត្វដំរីចង់តដៃ ឬប្រែជាមិនអាចគ្រប់គ្រងបាន។

ពេទ្យសត្វគួរតែស្លៀកសម្លៀកបំពាក់សាមញ្ញៗ ដែលមិនធ្វើឲ្យទើសទែង ដើម្បីមានភាពងាយស្រួល និងដើម្បីចៀសវាងគ្រោះថ្នាក់ ប្រសិនបើសត្វដំរីធ្វើការវាយប្រហារដោយមិនដឹងខ្លួន ក្នុងអំឡុងពេលព្យាបាល។

គួរតែមានជំនួយការ ដូចជាហ្មដំរី ឬក៏ជាអ្នកដែលធ្លាប់ស្គាល់ដំរី ឬអ្នកដែលអាចគ្រប់គ្រងវាបាន ព្រោះនៅពេលពេទ្យសត្វកំពុងធ្វើការ ដំរីអាចនឹងជាព្យាយាមរត់គេច ឬក៏វាយប្រហារពេទ្យសត្វ ឬអ្នកនៅក្បែរនោះ។

មុនពេលពេទ្យសត្វចូលពិនិត្យ ឬព្យាបាលដំរី គាត់ត្រូវតែដឹងច្បាស់ថាវាស្ថិតនៅក្រោមការគ្រប់គ្រង និងចងជាប់ល្អហើយឬនៅ។ យ៉ាងហោចណាស់ត្រូវមានហ្មដំរីចំនួនពីរនាក់ ឬមនុស្សផ្សេងទៀត ដើម្បីជួយគ្រប់គ្រងដំរី ដោយមានមនុស្សម្នាក់នៅពីខាងមុខក្នុងករណីដែលសត្វដំរីធំដល់កម្រិតហើយ។ (ត្រូវប្រយ័ត្នប្រមោយ កន្ទុយ និងជើងមុខរបស់ដំរី។) មនុស្សទី ២ នៅពីក្រោយ ដើម្បីមើលកន្ទុយ និងជើងក្រោយរបស់ដំរី។

បន្ទាប់ពីពេទ្យសត្វបានព្យាបាលសត្វដំរីហើយ មុនពេលត្រលប់មកផ្ទះវិញ ប្រសិនបើគាត់មិនអាចវិលត្រឡប់មកព្យាបាល និងពិនិត្យបន្ថែមទៀតទេ គាត់ត្រូវផ្តល់ថ្នាំឲ្យម្ចាស់ ឬហ្មដំរី (និងការណែនាំអំពីរបៀបប្រើប្រាស់ថ្នាំទាំងនោះ) ដែលត្រូវការសម្រាប់ព្យាបាលរហូតដល់ជាសះស្បើយមែនទែន។ ពេទ្យសត្វក៏គួរតែរៀបចំឲ្យហ្មដំរីផ្តល់របាយការណ៍តាមកាលកំណត់។ ក្រៅពីអនុសាសន៍ទូទៅទាំងនេះ ពេទ្យសត្វត្រូវដឹងច្បាស់ពីវិធីចូលទៅជិត និងធ្វើការជាមួយសត្វដំរី។

## វិធីចូលទៅជិតដំរីដោយសុវត្ថិភាព

នៅពេលដំរីឈឺ ពេទ្យសត្វត្រូវពិចារណាថា វាជាសត្វដែលធំ រឹងមាំ ឆ្លាត និងរហ័សរហួន។ សត្វដំរីមួយក្បាលអាចបង្កឲ្យមានគ្រោះថ្នាក់ ហើយវាអាចប្រើប្រាស់ផ្នែកផ្សេងៗនៃរាងកាយរបស់វាបានយ៉ាងងាយស្រួល ដូចជាប្រមោយ ភ្លុក កន្ទុយ ជើង និងសូម្បីតែមាត់របស់វា ក៏វាអាចបង្កឲ្យអ្នកដែលព្យាបាលវា រងរបួស ឬរហូតដល់ស្លាប់បានដែរ។

ប្រសិនបើអាចផ្តេកដំរី ឬឲ្យវាផ្អៀងទៅលើចំហៀងខ្លួនរបស់វា ក្នុងកំឡុងពេលត្រួតពិនិត្យ និងព្យាបាល នោះវានឹងមានសុវត្ថិភាពជាង។

មុនពេលចូលទៅជិតដំរី យកល្អបំផុត អ្នកត្រូវតែបង្ហាញឲ្យវាដឹងខ្លួនថា អ្នកកំពុងតែខិតចូលទៅជិតវា ដូចជាធ្វើឲ្យមានសម្លេងតិចៗ ឬដើរចូលយឺតៗពីចំហៀង ដែលដំរីនោះអាចមើលឃើញអ្នក។

កត់សម្គាល់ឥរិយាបថរបស់ដំរីមុនពេលចូលទៅជិតវា។ ប្រសិនបើវាបត់ត្រចៀកទៅខាងក្បាលរបស់វា ឬប្រសិនបើវាហាក់ដូចជាកំពុងសំលឹងមើលអ្នកមិនដាក់ភ្នែក សូមអ្នកកុំទាន់ទៅជិតវា។

ប្រសិនបើដំរីកំពុងធ្វើចលនាបក់ស្លឹកត្រចៀករបស់វា បក់កន្ទុយរបស់វា ឬប្រសិនបើវាបែរក្បាលទៅរកអ្នក នោះមានន័យថាអារម្មណ៍របស់វាមិនសូវល្អទេ។

កុំចូលទៅជិតដំរីពីខាងមុខ។

សត្វដំរីភាគច្រើនត្រូវបានបង្ហឹក និងឲ្យវាមានទម្លាប់ទទួលហ្មដំរីឡើងជិះនៅផ្នែកខាងស្ដាំ។ ហេតុដូច្នេះហើយប្រសិនបើអ្នកត្រូវចូលទៅជិតដំរីពីខាងឆ្វេង ត្រូវសួរទៅហ្មដំរីជាមុនសិន។

កុំចូលទៅជិតដំរីពីទិស ដែលវាមិនអាចមើលឃើញអ្នកបាន ឧទាហរណ៍នៅចំហៀង ដែលវាមានភ្នែកខ្វាក់ ឬពីខាងក្រោយ។ កន្លែងដែលមានសុវត្ថិភាពបំផុត គឺនៅចំហៀង ក្បែរជើងខាងមុខរបស់ដំរី។ ប្រសិនបើត្រូវធ្វើការពីខាងក្រោយ ត្រូវប្រយ័ត្នកន្ទុយនិងជើងក្រោយ។ បើធ្វើការនៅផ្នែកខាងមុខ ត្រូវប្រយ័ត្នជើងខាងមុខ។

ត្រូវប្រយ័ត្នប្រយែងតាមដែលអាចធ្វើទៅបាន ព្រោះដំរីមានទំហំធំ ហើយអាចផ្លាស់ទីបានយ៉ាងលឿន។ នៅពេលការងាររបស់អ្នករួចរាល់ ត្រូវដកខ្លួនថយចេញឲ្យបានលឿនបំផុត។ នៅពេលចូលទៅជិតដំរី ត្រូវបែរចំហៀងរបស់អ្នកទៅរកដំរី។

## **បច្ចេកទេសផ្ដល់ថ្នាំសម្រាប់ពេទ្យសត្វ**

អ្នកអាចផ្ដល់ថ្នាំឲ្យដំរី តាមប្រើវិធីសាស្ត្រជាច្រើន៖ តាមមាត់ តាមរន្ធគូថ ចាក់សាច់ និងចាក់ក្រោមស្បែក។ ការដាក់ថ្នាំភ្នែក និងការប្រមូលយកសំណាកក៏ត្រូវធ្វើដូចសត្វដទៃទៀតដែរ។

**ការចាក់ថ្នាំបញ្ចូលតាមសាច់ដុំ** អាចចាក់នៅលើសាច់ដុំស្មារ និងផ្នែកខាងលើនៃកញ្ចឹងកដូចក្នុងរូបភាព។



*ប្រើម្ជុលដែលមានប្រវែងពី ១,២៥ ទៅ ២ អ៊ីញ លេខ ១៦ លេខ ១៨ និងលេខ ២០ គឺល្អទាំងអស់។*

*ប្រើថ្នាំសម្លាប់មេរោគលាងសម្អាតតំបន់ដែលត្រូវចាក់ថ្នាំ ដែលបានកំណត់ទុកជាមុនរួចហើយ។*

*ប្រើខ្នងដៃទះលើតំបន់នោះពីបួនទៅប្រាំដង។*

*ចាក់បញ្ចូលម្ជុលទៅក្នុងសាច់ដុំ។*

*បាញ់ថ្នាំចូលទៅក្នុងសាច់ដោយយឺតៗរហូតដល់អស់ថ្នាំពីសឺរ៉ាំង។*

*យកដៃឈ្លីស្រាលៗលើកន្លែងចាក់ថ្នាំ ដើម្បីឲ្យថ្នាំឆាប់ជ្រាបចូលទៅក្នុងសាច់។*

***ការចាក់ថ្នាំក្រោមស្បែក** គឺដើម្បីឲ្យថ្នាំជ្រាបចូលតាមក្រោមស្បែក ដូចជាប្រភេទថ្នាំប្រឆាំងនឹងពពួកប៉ារ៉ាស៊ីត* Ivermectin *សូវលុយស្យុងអំបិល។ល។ ដែលដំរីនឹងស្រូបយកជាតិថ្នាំនោះយ៉ាងសន្សឹមៗ។ ការចាក់ថ្នាំនៅក្រោមស្បែកច្រើនបង្កឲ្យមានសាច់ហើមនៅកន្លែងចាក់ថ្នាំ។ នៅខាងក្រោយជើងខាងមុខ និងនៅលើកញ្ចឹងក គឺជាកន្លែងដែលល្អជាងគេសម្រាប់ចាក់ថ្នាំ ដូចបង្ហាញលើរូបភាព។*

*ប្រើម្ជុលដែលមានប្រវែងពី ១,២៥ ទៅ ២ អ៊ីញ លេខ ១៦ លេខ ១៨ និងលេខ ២០ គឺល្អទាំងអស់។*

*ប្រើថ្នាំសម្លាប់មេរោគលាងសម្អាតតំបន់ដែលត្រូវចាក់ថ្នាំ ដែលបានកំណត់ទុកជាមុនរួចហើយ។*

*ប្រើខ្នងដៃទះលើតំបន់នោះពីបួនទៅប្រាំដង។*

***ការចាក់ថ្នាំតាមសរសៃឈាម** គឺត្រូវចាក់នៅផ្នែកខាងក្រោយនៃត្រចៀករបស់ដំរី ពីព្រោះស្បែកនៅទីនោះស្តើងខ្លាំង ហើយយើងអាចរកសរសៃឈាមឃើញដោយងាយ។*

*ប្រើម្ជុលដែលមានប្រវែងពី ១,២៥ ទៅ ២ អ៊ីញ លេខ ១៦ លេខ ១៨ និងលេខ ២០ គឺល្អទាំងអស់។*



ប្រើថ្នាំសម្លាប់មេរោគលាងសម្អាតតំបន់ដែលត្រូវចាក់ថ្នាំ គឺតំបន់លើសរសៃឈាមនៅខាងក្រោយស្នឹកត្រចៀក។

សង្កត់លើសរសៃឈាមឲ្យខ្លាំង ហើយចាក់ម្ជុលចូល។

ប្រើថ្នាំសម្លាប់មេរោគលាងសម្អាតតំបន់ដែលបានចាក់ថ្នាំហើយជាថ្មីម្តងទៀត។

យកដៃឈ្លីស្រាលៗលើកន្លែងចាក់ថ្នាំ ដើម្បីឲ្យថ្នាំឆាប់ជ្រាបចូលទៅក្នុងសាច់។

ប្រើថ្នាំសម្លាប់មេរោគលាងសម្អាតតំបន់ដែលបានចាក់ថ្នាំហើយជាថ្មីម្តងទៀត។

ការយកគំរូឈាមត្រូវប្រើវិធីសាស្ត្រដូចគ្នានឹងការចាក់ថ្នាំតាមសរសៃដែរ ប៉ុន្តែមុនពេលបូមឈាមចូលក្នុងសឺរ៉ាំង ត្រូវសង្កត់លើសរសៃឈាម ប្រហែលពី ១ ទៅ ២ នាទី ដើម្បីឲ្យឈាមគ្រប់គ្រាន់សម្រាប់សេចក្តីត្រូវការ។

# តារាងទី ១ ៖ ចំណីរបស់ដំរី

| ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះទូទៅ | | ផ្នែកដែលដំរីស៊ី |
|---|---|---|---|
| | English | ខ្មែរ | |
| Ananas comosus Merr. | Pineapple | ម្នាស់ | ផ្លែ និងស្លឹក |
| Arundinaria pusilla & A. Camus | - | ស្មៅបារាំង | ស្លឹក និងដើម |
| Arundo donax Linn. | Spanish reed, Giant reed | ត្រែង | ស្លឹក និងដើម |
| Bambousa spp. | Bamboo | ទំពាំង | ស្លឹក ដើម និងទំពាំង |
| Benincasa hispida Cogn. | Wax gourd, white gourd | ត្រឡាច | ផ្លែ |
| Brachiaria mutica (Forsk.) Stapf. | Para grass, Buffalo grass | ស្មៅទឹក | ស្លឹក និងដើម |
| Brachiaria ruziziensis Germain and Everard | Ruzi grass | ស្មៅ Ruzi | ស្លឹក និងដើម |
| Brassica oleracea var. capitate Linn. | Cabbage | ស្ពៃក្ដោប | ស្លឹក |
| Brassica pekinensis Lour. | Chinese Cabbage | ស្ពៃបូកគោ | ស្លឹក |
| Carica papaya Linn. | Papaya | ល្ហុង | ផ្លែ |
| Centrosema pascuorum Mart. Ex. Benth | Cavalcade | ស្មៅ Cavalcade | ស្លឹក និងដើម |
| Citrullus vulgaris Schrad. | Water melon | ឪឡឹក | ផ្លែ |
| Citrus nobilis Lour. | King orange, King mandarin | ក្រូចឃ្វិច | ផ្លែ |
| Cocos nucifera Linn. | Coconut | ដូង | ស្លឹក |
| Cucumis sativus Linn. | Cucumber | ត្រសក់ | ផ្លែ |
| Daucus carota Linn. | Carrot | ការ៉ុត | ស្លឹក និងដើម |
| Digitaria eriantha Steudel | Pangola grass | ស្មៅ Pangola | ស្លឹក និងដើម |
| Hymenachne pseudointerrupta C. Muell. | Del or bamboo grass (India) | ស្មៅទំពាំងឥណ្ឌា | ស្លឹក និងដើម |
| Lycopersicon esculentum Miller | Tomato | ប៉េងប៉ោះ | ផ្លែ |
| Manihot esculenta Crantz | Cassava | ដំឡូងមី | ដើម |
| Musa sapientum Linn. | Banana | ចេក | ផ្លែ និងដើម |
| Oryza sativa Linn. | Rice | ស្រូវ | គ្រាប់ |
| Panicum plicatum Jacq. | Guinea grass | ស្មៅ Guinea | ស្លឹក និងដើម |
| Panicum plicatum Willd. | - | - | ស្លឹក និងដើម |
| Pennisetum purpureum Schumach | Napier grass, Elephant grass | ស្មៅដំរី | ស្លឹក និងដើម |

| | | | |
|---|---|---|---|
| Pennisetum purpureum x P. americanum (hybrid) | Bana grass | ស្មៅ Bana | ស្លឹក និងដើម |
| Psidium guajaya Linn. | Guava | ត្របែក | ផ្លែ និងស្លឹក |
| Raphanus satibus Linn. | Chinese winter radish | ឆៃថាវ | ស្លឹក និងដើម |
| Saccharum fuscum Roxb. | - | - | ស្លឹក និងដើម |
| Saccharum officinarum Linn. | Sugar cane | អំពៅ | ស្លឹក និងដើម |
| Saccharum spontaeum Linn. | Wild sugar cane, Thatch grass | អំពៅព្រៃ | ស្លឹក និងដើម |
| Solanum tuberpsum Linn. | Potato | ដំឡូងបារាំង | ស្លឹក និងដើម |
| Zea mays Linn. | Maize, corn | ពោត | ស្លឹក ដើម បណ្តូល |
| Calanus spp. Daemonorops spp., etc. | Rattan | ផ្តៅ | ដើម |
| រុក្ខជាតិច្រើនប្រភេទក្នុងងំបូរត្នោត លើកលែងតែផ្តៅ | Palm | ត្នោតព្រៃ | ស្លឹក |

## តារាងទី ២ ៖ រុក្ខជាតិឱសថ

| ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះទូទៅ | | ផ្នែកប្រើបាន | ព្យាបាលរោគ |
|---|---|---|---|---|
| | English | ខ្មែរ | | |
| **ប្រើលើផ្នែកខាងក្នុង** | | | | |
| Acacia Catechu Willd | Black catechu, Cutch | អាកាស្យា | ផ្លែ និងស្លឹក | ថ្នាំបញ្ចុះ |
| Aegle marmelos (L.) Corr. Ex Roxb. | Bael fruit tree, Bengal quince | ក្ទៅ | ផ្លែ | ថ្នាំពក,សម្រួលអារម្មណ៍ |
| Albizia procera (Roxb.) Benth. | Forest siris, White siris | - | សំបក | រំលាយអាហារ |
| Coix lachrymal-jobi Linn. | Job's tears | - | ឫស | ថ្នាំព្រូន |
| Dillenia aurea Smith | - | ក្តុល | សំបក | ថ្នាំប៉ូវកម្លាំង |
| Diospyros mollis Griff. | Ebony tree | ម៉ាក្លឿ | ផ្លែ (ទុំ) | ថ្នាំព្រូន |
| Entada pursaetha DC. | Sea bean | សណ្តែកសមុទ្រ | គ្រាប់ | ថ្នាំប៉ូវកម្លាំង |
| Ficus benjamina Linn. | Golden fig, Weeping fig | ល្វា | ផ្លែ ផ្កា សំបក | ថ្នាំព្រូន |
| Harrisonia perforate Merr. | - | - | ស្លឹក ដើម និងសំបក | ថ្នាំព្រូន |
| Ricinus communis Linn. | Castor-oil plant, Castor bean | ល្ហុងខ្មែរ | គ្រាប់ | ថ្នាំបញ្ចុះ |
| Scindapsus officinalis Schott | - | - | ស្លឹក ដើម | ថ្នាំប៉ូវកម្លាំង |
| Tamarindus indica Linn. | Tamarind | អំពិល | ផ្លែ | ថ្នាំបញ្ចុះ |
| Tinospora tuberculate Beumee | - | - | ដើម | ថ្នាំប៉ូវកម្លាំង រំលាយអាហារ |
| **ប្រើលើផ្នែកខាងក្រៅ** | | | | |
| Bambusa spp. | Bamboo | ឫស្សី | ដើម | ជម្ងឺពងបែក |
| Capsicum frutescens Linn. | Chili | ម្ទេស | ផ្លែ | ការពារដំបៅក្លាយ (ស្បែក ភ្នែក) និងផ្សំថ្នាំឆ្កួត |
| Cocos nucifera Linn. | Coconut | ដូង | ផ្លែ (ប្រេង) | កំចាត់ផ្សិត ដំបៅក្លាយ (ស្បែក ជាពិសេសរលាក) |
| Columella tenuifolia Merr. | - | - | ដើម | ផ្សំថ្នាំឆ្កួត |

| | | | | |
|---|---|---|---|---|
| Crinum asiaticum Linn. | Crinum lily, Asiatic poison lily | - | ស្លឹក | បាត់ហើម |
| Curcuma longa Linn. | Turmeric | រមៀត | មើម | ការពារដំបៅក្លាយនៅភ្នែក |
| Entada pursaetha DC. | Sea bean | សណ្តែកសមុទ្រ | សំបក ដើម | ការពារដំបៅក្លាយ (ស្បែក ភ្នែក) ការពារ/កំចាត់សត្វល្អិត |
| Eupatorium odoratum Linn. | - | ទន្ទ្រានខេត្ត | ស្លឹក | ឃាត់ឈាម |
| Imperata cylindrical Beauv | Thatch grass | ស្បូវ | មើម និងឫស្ស | ការពារដំបៅក្លាយនៅភ្នែក |
| Mimosa pudica Linn. | Sensitive plant | បន្ទាបង្គ្រាប | ដើម ស្លឹក | ការពាររមាស់ ដំបៅក្លាយនៅភ្នែក |
| Musa sapientum Linn. | Banana | ចេក | ផ្លែ (ខ្ចី) | ឃាត់ឈាម (ពេល កាត់ក្លុក) |
| Pterocarpus indicus Willd. | Narra, rosewood | ឈើឯម | សំបក | ការពារដំបៅក្លាយលើស្បែក (បូស ដំបៅលើដើង) |
| Ricinus communis Linn. | Castor-oil plant, Castor bean | ល្ហុងខ្មែរ | មែក | ការពារដំបៅក្លាយនៅភ្នែក |
| Tamarindus indica Linn. | Tamarind | អំពិល | ផ្លែ | ព្យាបាលបូស |
| Thunbergia laurifolia Linn. | Blue trumpet vine | - | ដើម ស្លឹក | ផ្សំថ្នាំផ្តុង |
| Zingiber cassumunar | Cassumunar | រំដេង | មើម | ផ្សំថ្នាំផ្តុង |

# ឯកសារពិគ្រោះ

Aiello, S.E. (ed.) 1998. The Merck Veterinary Manual, 8th edition. John Wiley & Sons. (available at www.merckvetmanual.com/mvm/ index.jsp)

Baker, I. & Kashio, M. (eds.) 2002. Giants on our hands: Proceedings of the international workshop on the domesticated Asian elephant. Bangkok, FAO(RAP). RAP Publication: 2002/30. (available at www.fao.org/DOCREP/005/AD031E/AD031E00.HTM)

Davis, J. & Anderson, R. (eds.) 1971. Parasitic diseases of wild mammals. Iowa State University Press.

Davis, J.; Karstad, L. & Trainer, D. (eds.) 1973. Infectious diseases of wild mammals. Iowa State University Press.

Evans, G.H. 1910. Elephants and their diseases. Rangoon, Government Printer.

FAO. 1994. A manual for the primary animal health care worker. Rome, FAO.

Ferrier, A.J. 1947. The care and management of elephants in Burma. London, Steel Brothers & Co.

Fowler, M.E. (ed.) 1993. Zoo and wild animal medicine, current therapy 3. Philadelphia, W.B. Saunders & Co.

Fowler, M.E. & Miller, E. (eds.) 1999. Zoo and wild animal medicine, current therapy 4. Philadelphia, W.B Saunders & Co.

Lair, R. 1997. Gone astray: The care and management of the Asian elephant in domesticity. Bangkok, FAO (RAP). RAP Publication: 1997/ 16.

McDiarmid, A. 1969. Diseases in free-living wild animals. The Zoological Society of London

Mikota, S.; Sargent, E. & Ranglack, G. 1994. Medical management of the elephant. West Bloomfield, Indira Publishing House.

Milroy, A.J. 1922. A short treatise on the management of elephants. Shillong, Government Printer.

Namboodiri, N. (ed.) 1998. Practical elephant management: A handbook for mahouts. Coimbatore, Elephant Welfare Association.

Pfaff, G. 1940. Reports on the investigation of diseases of elephants. Rangoon, Govmt. Printing and Stationery.

Reibel, J. 1984. Caring for livestock: A veterinary handbook. New York, Arco Publishing.

Roberston, A. (ed.) 1976. The handbook of animal diseases in the tropics. London, British Veterinary Association.

Samuel, W.M.; Pybus, M.J & Kocan, A.A. 2001. Parasitic diseases of wild mammals, 2nd edition. Ames, Blackwell Publishing.

Schmidt, M. J. 1986. Proboscidea (Elephants). In Fowler, M. E., ed. Zoo and wild animal medicine, 2nd edition. Philadelphia, W.B. Saunders.

Schmitt, D. L. 2003. Proboscidea (Elephants). In M.E. Fowler and R.E. Miller, eds. Zoo and wild animal medicine, 5th edition. St. Louis, Elsevier Science.

Sharma, P. & Baldock, C. (eds.) 1999. Understanding animal health in Southeast Asia. Canberra, Australian Centre for International Agricultural Research.

Silas, E.; Nair, M.K.; & Nirmalan, G. (eds.) 1992. The Asian elephant: Ecology, biology, diseases, conservation and management. Trichur, Kerala Agricultural University.

Tesaprateep, Ted. (ed.) 1999. Proceedings of the International Conference on Regional Workshop on Asian Elephant Health Care. Chiang Mai, Faculty of Veterinary Medicine, Chiang Mai.

Van Heerden, J. & Penzhorn, B. (eds.) The African elephant as a game ranch animal. Onderstepoort, South African Veterinary Association.

Williams, E. S. & Barker, I. K. (eds.) 2001. Infectious diseases of wild mammals, 3rd edition. Ames, Iowa, USA, Iowa State University Press.

Wobeser, G.A. 1994. Investigation and management of disease in wild animals. New York & London, Plenum Press.

Woodford, M.H. (ed.) 2000. Post-mortem procedures for wildlife veterinarians and field biologists. Canberra, Australian Centre for International Agricultural Research. (available at www.elephantcare.org/ protodoc_files/afrnecro.pdf)

Thai language references*

Elephant and Wildlife Club. 2001. Project to disseminate knowledge in basic elephant health care. Elephant and Wildlife Clinic, Companion Animal, Faculty of Veterinary Medicine, Chiang Mai University

Laoprasert, Churai. (compiler) 2000. Knowledge about elephants, Volume I. Large Animal Group, Research and Elephant Health Care Institute, Surin Province.

Laoprasert, Churai; Tungsuwan, Malinee & Sarnpechudayan, Prasert. (compilers) 2000. Knowledge about elephants, Volume II. Large Animal Group, Research and Elephant Health Care Institute, Surin Province.

Lunga, Grissada. (ed.) 2002. Manual of elephant health care. Elephant and Wildlife Clinic, Companion Animal, Faculty of Veterinary Medicine, Chiang Mai University.

Phuangkum, Preecha. 2001. Project for training elephant keepers in basic care. Thai Elephant Conservation Organization, Forest Industry Organization.

Teak Division. 1962. Knowing about elephants. (Mimeo) Forest Industry Organization, Lampang Province.

* All titles are given in Thai script in the Thai edition of this book.